ឆ្នាំទី៤ លេខ៣៨-៣៩ ចេញផ្សាយប្រចាំខែមិថុនា-កក្កដា ឆ្នាំ២០១៤

# ព្រឹត្តិបត្រការងារ

# Labour Bulletin

ជាស្ពានរបស់រាជរដ្ឋាភិបាលឆ្ពោះទៅកាន់ ♦ ការងារ ♦ កម្លាំងពលកម្ម ♦ ព័ត៌មានទីផ្សារការងារ ❖ Government gateway to ♦ Job ♦ Workforce ♦ Labour Market Information



រៀបចំ និងបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល


- សកម្មភាពថ្មីៗពាក់ព័ន្ធវិស័យការងារ [ទំព័រ១]
- ការពិនិត្យ និងជ្រើសរើសអាជីព ឬការងារដែលសមស្រប [ទំព័រ៨]
- ព័ត៌មានជ្រើសរើសបុគ្គលិក [ទំព័រ១៤០]
- [ទំព័រ១៤៨] កំសាន្ត និងប្រាជ្ញា

ទីភ្នាក់ងារជាតិមុខរបរ និងការងារ

ព្រឹត្តិបត្រការងារ

# មាតិកា

## ✴ ព័ត៌មាន និងសកម្មភាព


- ❑ សកម្មភាពថ្មីៗពាក់ព័ន្ធនឹងវិស័យការងារ និងការអប់រំបណ្តុះបណ្តាល ........ [ទំព័រ ១]


## ✴ មគ្គុទេសក៍អាជីព


- ❑ ការពិនិត្យ និងជ្រើសរើសអាជីព ឬការងារដែលសមស្រប [ទំព័រ ៤]
  - ❑ បុគ្គលិកផ្នែកសេវាធនាគារ [ទំព័រ ៤]
  - ❑ ប្រធានគ្រប់គ្រងធុរកិច្ច [ទំព័រ ៧]
  - ❑ វិស្វករស៊ីវិល & អ្នកបច្ចេកទេសវិស្វកម្មស៊ីវិល [ទំព័រ ៩]
  - ❑ សិល្បករ [ទំព័រ ១១]
  - ❑ អ្នកសេដ្ឋកិច្ច [ទំព័រ ១៣]
  - ❑ អ្នកភូគព្ភសាស្ត្រ [ទំព័រ ១៥]
  - ❑ អ្នករចនាគំនូក្រាហ្វិក [ទំព័រ ១៦]
  - ❑ វិស្វករមេកានិច [ទំព័រ ១៨]
  - ❑ ចៅក្រម [ទំព័រ ២០]
  - ❑ មេធាវី [ទំព័រ ២២]
  - ❑ អ្នកវិទ្យាសាស្ត្រផ្នែកកសិកម្ម [ទំព័រ ២៤]
  - ❑ អ្នកឯកទេសគីមី [ទំព័រ ២៥]
  - ❑ គិលានុបដ្ឋាក [ទំព័រ ២៧]
  - ❑ បុគ្គលិកផ្នែកយុទ្ធនាការផ្សព្វផ្សាយ [ទំព័រ ២៩]
  - ❑ អ្នកបច្ចេកទេសខាងមូលដ្ឋានទិន្នន័យ [ទំព័រ ៣១]
  - ❑ និពន្ធនាយកសារព័ត៌មាន [ទំព័រ ៣៣]
  - ❑ អ្នកសារព័ត៌មាន [ទំព័រ ៣៤]
  - ❑ ប្រធានគ្រប់គ្រងភោជនីយដ្ឋាន [ទំព័រ ៣៦]
  - ❑ មគ្គុទេសក៍ទេសចរណ៍ [ទំព័រ ៣៨]
  - ❑ ជាងកាត់ដេរ និងអ្នកច្នៃម៉ូត [ទំព័រ ៤០]
  - ❑ អ្នកបង្កើតគំរូម៉ូតសម្រាប់ឧស្សាហកម្ម [ទំព័រ ៤២]
  - ❑ អ្នកបង្កើតកម្មវិធីកុំព្យូទ័រ [ទំព័រ ៤៤]
  - ❑ អ្នកផ្សាយកម្មវិធីវិទ្យុ និទូរទស្សន៍ [ទំព័រ ៤៥]
  - ❑ វេជ្ជបណ្ឌិតផ្នែកការវះកាត់ [ទំព័រ ៤៦]
  - ❑ ឱសថការី [ទំព័រ ៤៨]
  - ❑ មន្ត្រីផ្នែករដ្ឋបាលក្នុងការិយាល័យ [ទំព័រ ៥០]
  - ❑ អាកាសយានិក [ទំព័រ ៥១]
  - ❑ បណ្ណារក្ស [ទំព័រ ៥២]
  - ❑ អ្នកបច្ចេកទេសខាងការវេចខ្ចប់ [ទំព័រ ៥៤]
  - ❑ អ្នកឯកទេសស្ថិតិ [ទំព័រ ៥៥]
  - ❑ អ្នកជំនាញខាងវិទ្យាសាស្ត្រនយោបាយ [ទំព័រ ៥៦]
  - ❑ អ្នកបម្រើសេវាតាមប្រព័ន្ធទូរសព្ទ [ទំព័រ ៥៨]
  - ❑ មន្ត្រីគយ [ទំព័រ ៥៩]
  - ❑ ,,,


## ✴ ព័ត៌មានជ្រើសរើសបុគ្គលិក


- ❑ ព័ត៌មានជ្រើសរើសបុគ្គលិកសម្រាប់ខែសីហា ឆ្នាំ២០១៤ ដែលប្រមូលដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ [ទំព័រ ១៤០]


❀ចំណងជើងក្របមុខ៖ ការចុះឈ្មោះស្វែងរកការងារធ្វើរបស់សិស្ស-និស្សិតនៅក្នុងវេទិកាការងារ របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ
❀ចំណងជើងក្របក្រោយ៖ ពិព័រណ៍ការងារថ្នាក់ជាតិឆ្នាំ២០១៤ លើកទី៤


# ព្រឹត្តិបត្រការងារ

**គណៈគ្រប់គ្រង**

ឯកឧត្តម ពេជ សោភ័ន
ឯកឧត្តម ប៉ុក ប៉ាន់
ឯកឧត្តម ឡៅ ហ៊ីម
ឯកឧត្តម ហេង សួរ

**នាយកគ្រប់គ្រងទូទៅ**

ឯកឧត្តម ហុង ជឿន

**និពន្ធនាយក**

លោក សាម៉េន សុខា

**និពន្ធនាយករង**

លោក ហៃ ហ៊ុនឡេង
លោក សួង សង្វារុទ្ធី
លោក ទូច សុផាត

**ការីនិពន្ធ**

លោក គួច សុមាន
លោកស្រី លី រួចចេង
លោក តាំង ផេងរិទ្ធី
លោក សុជាតិ កញ្ញារិទ្ធ
មន្ត្រីទីភ្នាក់ងារជាតិមុខរបរ និងការងារ

**នាយកគ្រប់គ្រងការផ្សាយ**

លោក ខេង សុគន្ធា

**នាយកគ្រប់គ្រងការបោះពុម្ព**

លោក គឹម កែវស្មី

**នាយកគ្រប់គ្រងផ្នែករូបភាព និងកុំព្យូទ័រ**

លោក ផូរ ឧស្សាហ៍របនា

**អ្នករចនាអត្ថបទ**

កញ្ញា ឈា បញ្ញារី និង លោក ផែន រដ្ឋា

**អ្នកពិនិត្យ និងកែតម្រូវអក្ខរាវិរុទ្ធ**

មន្ត្រីទីភ្នាក់ងារជាតិមុខរបរ និងការងារ


& F *



ព័ត៌មាន និងសកម្មភាព

# សកម្មភាពថ្មីៗ ពាក់ព័ន្ធនឹងវិស័យការងារ និងអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

## វគ្គណែនាំស្តីអំពីការសរសេរ CV និង Cover letter របៀបរបបនៃការសម្ភាសន៍ និងការប្រឹក្សាយោបល់ដល់និស្សិតមកពី សាកលវិទ្យាល័យ វិទ្យាស្ថាន និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ

កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៤ មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញបានធ្វើបទបង្ហាញពីសេវាព័ត៌មានទីផ្សារការងារ របៀបនៃការសរសេរ CV និង Cover Letter និងការត្រៀមខ្លួនមុនសម្ភាសន៍ ដល់និស្សិតនៃគ្រឹះស្ថានសិក្សា ចំនួន ០៧ រួមមាន៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) សាកលវិទ្យាល័យអាស៊ីអឺរ៉ុប (AEU) សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា (PUC) សាកលវិទ្យាល័យជាតិគ្រប់គ្រង (NUM) សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE) វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ (PPI) និងវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ (NIB) ដែលមាននិស្សិតចូលរួម សរុបចំនួន ២១ នាក់ (ស្រី ០៩) ។



ជាលទ្ធផលក្រុមការងារយើងបានចែកជូន ព្រឹត្តបត្រការងារ ចំនួន ២១ ក្បាល និងខិតប័ណ្ណផ្សព្វផ្សាយពីសេវា NEA ចំនួន ២១ សន្លឹក ខិតប័ណ្ណផ្សព្វផ្សាយគម្រោង Sida ចំនួន ២១ សន្លឹក ដល់និស្សិតដែលបានចូលរួម ព្រមជាមួយការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់និស្សិត ដែលនេះជាកម្លាំងមួយជួយអោយមន្ត្រីរបស់មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ ខិតខំបន្តផ្តល់ជូន បម្រើ និងផ្សព្វផ្សាយយ៉ាងសកម្មទៅទៀតដល់អ្នកប្រើប្រាស់សេវាទាំងអស់នូវសេវារបស់ខ្លួនប្រកបដោយប្រសិទ្ធភាព នៅថ្ងៃអនាគត ។

## ការណែនាំពីវិធីសាស្ត្រស្វែងរកការងារធ្វើតាមរយៈការប្រើប្រាស់សេវាអ៊ីនធើណិតការងាររបស់ ជ.ជ.ម.ក

កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៤ មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញបានបង្កើតឱ្យមានជាកម្មវិធីប្រឹក្សាយោបល់លក្ខណៈជាក្រុមមួយដែលមានអ្នកស្វែងរកការងារធ្វើ ចំនួន ០៧ នាក់ បានចូលរួម។ ក្រោមការសាកសួរ និងបំផុសគំនិតពីមន្ត្រីមជ្ឈមណ្ឌលការងារ យើងបានរកឃើញនូវចំណុចខ្សោយមួយចំនួនដែលធ្វើអោយពួកគេពិបាកក្នុងការឈានជើងចូលទីផ្សារការងារ រួមមាន៖

- មិនបានយល់ច្បាស់អំពីធាតុផ្សំនៅក្នុងបរិបទ CV និងគំនិតគាំទ្ររបស់វា
- ពិបាកគាស់កកាយបទពិសោធន៍ការងារដែលមានស្រាប់ សម្រាប់សរសេរក្នុង CV
- មិនហ៊ានដាក់ CV ទៅក្រុមហ៊ុនដែលមានតម្រូវការខ្ពស់ជាងនៅឡើយ


តទៅទំព័របន្ទាប់

- មិនទាន់មានបទពិសោធន៍ក្នុងការជួបសម្ភាសន៍ជាមួយនិយោជក ជាលទ្ធផលមន្ត្រីមជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ បានធ្វើការណែនាំដល់អ្នកស្វែងរកការងារធ្វើ នូវគន្លឹះផ្សេងៗដែលអាចជួយអោយពួកគេ បានស្គាល់អំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន ដើម្បីត្រៀមលក្ខណៈសម្បត្តិចូលទីផ្សារការងារឡើងវិញ។



## កិច្ចប្រជុំបូកសរុបការងាររបស់ ទ.ជ.ម.ក ប្រចាំខែមិថុនា

កាលពីថ្ងៃទី២៧ មិថុនា ឆ្នាំ២០១៤ នៅទីស្នាក់ការកណ្តាលរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) មានកិច្ចប្រជុំបូកសរុបការងារប្រចាំខែកុម្ភៈ ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ហុង ជឿន** ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ដោយមានការចូលរួមពីប្រធានមជ្ឈមណ្ឌលការងារទាំង ០៥ តាមរយៈ Skype និងមន្ត្រីរាជការនៅថ្នាក់កណ្តាលទាំងអស់។

### កិច្ចប្រជុំបូកសរុបការងារសម្រេចបានលទ្ធផលដូចខាងក្រោម៖

- បានចូលរួមកិច្ចប្រជុំលើកទី ១០ នៃគណៈកម្មាធិការចំរុះកម្ពុជា-ជប៉ុន ក្រោមកិច្ចព្រមព្រៀងរវាងជប៉ុន និងព្រះរាជាណាចក្រកម្ពុជា សម្រាប់ធ្វើសេរីភាវូបនីយកម្ម ការជំរុញ និងការការពារវិនិយោគ
- បានចូលរួមរៀបចំកិច្ចប្រជុំគណៈកម្មការប្រឹក្សាការងារ
- បានជួបប្រជុំជាមួយ Ms. Ide Naoko, តំណាងJICA ដើម្បី ពិភាក្សាលើគម្រោងដែលបានស្នើសុំក្នុងឆ្នាំ២០១៣ និង គម្រោងស្នើសុំបន្តសម្រាប់ឆ្នាំ ២០១៤
- បានចូលរួមកិច្ចប្រជុំពាក់ព័ន្ធនឹងសហភាពសហព័ន្ធយុវជនកម្ពុជារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានចូលរួមប្រជុំ "ប្រកចេញ-ចូលតែមួយ" នៃ ក.អ.ក "គ.វ.ក"
- បានចូលរួមប្រជុំសម្ភាសន៍ស្តីពីតម្រូវការកម្លាំងពលកម្ម និងតម្រូវការបណ្តុះបណ្តាលជំនាញ
- បានជួបប្រជុំពិភាក្សាការងារជាមួយ **លោក នួន រិទ្ធី** តំណាង អង្គការ ILO ស្តីពីការបង្ហាញពីលទ្ធផលនៃការអង្កេតសម្រាប់ការរកឃើញនូវចំណុចខ្វះខាតរបស់មជ្ឈមណ្ឌលការងារ
- បានចូលរួមប្រជុំស្តីពីការផ្តល់យោបល់ និងសម្រេចលើសញ្ញា (Logo) របស់ ទ.ជ.ម.ក
- បានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ និងពិភាក្សាលើសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៤-២០១៥
- បានចូលរួមកិច្ចប្រជុំស្តីពីការងារបូកសរុបរបាយការណ៍របស់ក្រសួង
- បានចូលរួមផ្តល់យោបលត្រៀមក្នុងកិច្ចជំនួបជាមួយមន្ត្រី បច្ចេកទេសអគ្គលេខាធិការដ្ឋាន ក.ជ.ក. ក្នុងគោលបំណង ពិភាក្សា និងផ្តល់គំនិតជាទស្សនទាន លើការរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីការពង្រឹងលើការអនុវត្តក្រមសីលធម៌ របស់ក្រុមហ៊ុនជ្រើសរើសពលករ ក្នុងគោលបំណងទប់ស្កាត់ ការជ្រើសរើសពលករជាកុមារ និងជានាការអនុវត្តក្រម សីលធម៌ក្នុងការជ្រើសរើសពលករឱ្យបានត្រឹមត្រូវ
- ការយល់ដឹងស្តីពីគម្រោង និងវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
- បានចូលរួមកិច្ចប្រជុំស្តីពីកិច្ចសហការអន្តរស្ថាប័ន លើការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងការងារ
- វគ្គបណ្តុះបណ្តាលមន្ត្រីថ្មីនៃមជ្ឈមណ្ឌលណែនាំស្តីពីអាជីព និងការងារសម្រាប់យុវជននៅកម្ពុជា
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការធ្វើបច្ចុប្បន្នភាពគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់កម្ពុជា
- បានចូលរួមសិក្ខាសាលាស្តីពីវិទ្យានិពន្ធរបស់សមាគមកម្ពុជា នៃអតីតនិស្សិតពីអូស្ត្រាលី (AAA-C Thematic Workshop)
- បានចូលរួមសិក្ខាសាលាអង្កេតសំណើស្តីពីរបៀបលើក គម្រោងស្នើសុំហិរញ្ញប្បទាន អភិវឌ្ឍន៍ផ្លូវការជប៉ុន សម្រាប់ឆ្នាំ ២០១៤

- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ របស់ក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៤-២០១៥
- បានចូលរួមសិក្ខាសាលាពង្រឹងសមត្ថភាពស្តីពីព័ត៌មានទីផ្សារ ការងារ
- បានចូលរួមសិក្ខាសាលាត្រីភាគីស្តីពីកិច្ចពិគ្រោះយោបល់លើ សេចក្តីព្រាងច្បាប់ស្តីពីសហជីព
- ការពង្រឹងលើការអនុវត្តក្រមសីលធម៌របស់ក្រុមហ៊ុនជ្រើសរើសពលករ ក្នុងគោលបំណងទប់ស្កាត់ការជ្រើសរើសពលករជា កុមារ និងធានាការអនុវត្តក្រមសីលធម៌ក្នុងការជ្រើសរើស ពលករឱ្យបានត្រឹមត្រូវ
- បានចូលរួមអម**ឯកឧត្តមរដ្ឋមន្ត្រី** ជួបសំដែងការគួរសមជាមួយឯកឧត្តម Christoph Burgener ឯកអគ្គរដ្ឋទូតស្វីសប្រចាំព្រះរាជាណាចក្រកម្ពុជា
- បានចូលរួមពិធីផ្សព្វផ្សាយជាផ្លូវការ នៃគម្រោងយន្តការផ្តល់សេវាសង្គម (ការិយាល័យច្រកចេញចូលតែមួយសម្រាប់សេវាសង្គម)
- បានទទួលជួបមន្ត្រីមកពីវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ចំនួន ០២ នាក់ ស្តីពីការ ពិគ្រោះយោបល់ស្រាវជ្រាវ ដើម្បីទទួលព័ត៌មានសម្រាប់គម្រោង "The Interrelation between Public Policy, Migration and Development in Cambodia"
- បានចូលរួមស្តាប់ការផ្សព្វផ្សាយស្តីពីការយល់ដឹងស្តីពីគម្រោង និងវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (គម្រោង RIA) របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

បន្ទាប់ពីការធ្វើរបាយការណ៍របស់មជ្ឈមណ្ឌល-លការងារទាំង០៥ ផ្នែកទាំង០៤ និងក្រុមការងារនីមួយៗរួចមក ឯកឧត្តមប្រធានបានផ្តល់អនុសាសន៍ និងផ្តល់ដំណោះស្រាយទៅលើបញ្ហាប្រឈមដែលកំពុងមានផងដែរ។ ជាចុងក្រោយលោកឯកឧត្តមប្រធានបានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការអនុវត្តការងារដែលសម្រេចបានកន្លងមក និងសំណូមពរឱ្យមន្ត្រីរាជការទាំងអស់បន្តនូវឆន្ទៈពុះពារអនុវត្តការងារឱ្យបានខ្លាំងក្លាបន្ថែមទៀត ដើម្បីចូលរួមចំណែកទាំងអស់គ្នាសម្រេចឱ្យបាននូវផែនការអនុវត្តការងារប្រចាំឆ្នាំ២០១៤នេះ៕




មគ្គុទេសក៍អាជីព

# ការពិនិត្យ និងជ្រើសរើសអាជីព ឬការងារដែលសមស្រប

## បុគ្គលិកផ្នែកសេវាធនាគារ

(Bank Service Workers)

### សង្ខេបអំពីជំនាញ

បុគ្គលិកផ្នែកសេវាធនាគារធ្វើការងារ៖

- ✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ✦ បែងចែកសាច់ប្រាក់ និងធនធាន
- ✦ ជួយកិច្ចការដល់ភ្ញៀវ និងអតិថិជន

G

ជំនាញដែលត្រូវការប្រើ៖

- ✦ និយាយពិគ្រោះ និងស្តាប់នូវយោបល់
- ✦ គណិតវិទ្យា
- ✦ ស្លូតបូត និងស្មោះត្រង់

### តើបុគ្គលិកផ្នែកសេវាធនាគារបំពេញកិច្ចការអ្វីខ្លះ?

G បុគ្គលិកផ្នែកសេវាធនាគារសំដៅដល់បុគ្គលិកច្រើនសណ្ឋានដែលបម្រើការនៅក្នុងធនាគារ និងស្ថាប័នផ្នែកហិរញ្ញវត្ថុដទៃផ្សេងទៀត ហើយដែលទទួលការកិច្ចលើការងារផ្សេងៗជាច្រើនជំពូក។ ឧទាហរណ៍ បេឡាធិការ ឬបេឡាធិការិនី មានតួនាទីទទួល ផ្ទេរ និងបង្វិលសាច់ប្រាក់តាមរយៈគណនេយ្យរបស់អតិថិជន។ ជម្មតាបុគ្គលិកប្រភេទនេះតែងផ្តល់នូវសេវាបម្រើទៅកាន់អតិថិជនដោយផ្ទាល់ រួមមាន ការទទួលបញ្ចូលសាច់ប្រាក់ទៅក្នុងគណនេយ្យ និងផ្តល់វិក្កយបត្រត្រលប់ទៅភ្ញៀវវិញ។ កត់ត្រាបញ្ជី និងដំណើរការរបស់គណនេយ្យ ព្រមទាំងត្រួតពិនិត្យក្រដាសប្រាក់។



*អត្ថបទដកស្រង់ និងប្រែសម្រួលចេញពីឯកសារ* Career Discovery Encyclopedia. Infobase Publishing. Seven Edition, 2009. *ដោយ ហៃ ហ៊ុនឡេង។ ប្រសិនលោកអ្នកចង់ជ្រាបនូវព័ត៌មានបន្ថែមស្តីពីឯកសារនេះសូមអញ្ជើញរកអាននៅ «បណ្ណាល័យការងារ» របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារដោយមេត្រី។*

 តទៅទំព័របន្ទាប់



ដោយឡែក នៅពេលអតិថិជនធ្វើការដកសាច់ប្រាក់ បេឡាធិការត្រូវពិនិត្យលើសមតុល្យរបស់គណនេយ្យ ក្រែងជួនជាមានករណីខ្វះសាច់ប្រាក់ ឬកើតមានប្រការមិនប្រក្រតីកើតឡើងជាយថាហេតុ។

ចំណែកបុគ្គលិកមួយប្រភេទទៀតគឺ ស្មៀនដែលទទួលបន្ទុករៀបចំថែរក្សាបញ្ជី និងឯកសារទាំងឡាយរបស់ធនាគារឱ្យមាន សណ្តាប់ធ្នាប់ដោយបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យរបស់កុំព្យូទ័រ។ ជួនកាល ពួកគេមានភារកិច្ចជួយឆ្លើយនូវសំណួរ និងចម្ងល់របស់អតិថិជនតាមរយៈទូរស័ព្ទ និងជួយក្នុងការបំពេញកិច្ចការផ្សេងៗទៀត។ មានបុគ្គលិកមួយប្រភេទទៀតគឺជាអ្នកជួយអតិថិជនក្នុងការបើកបញ្ជី ឬគណនេយ្យថ្មីនៅក្នុងធនាគារ សម្ភាសន៍អតិថិជន និងត្រួតពិនិត្យគណនេយ្យ ព្រមទាំងពន្យល់ពីសេវាកម្មរបស់ធនាគារទៅដល់អតិថិជន និងគាំទ្រដល់សេវាផ្សេងៗផងដែរ។

ដោយឡែក មន្ត្រី ឬប្រធានគ្រប់គ្រងធនាគារវិញ បំពេញកិច្ចការជាអ្នកត្រួតពិនិត្យ និងផ្តល់ឱវាទទៅដល់បុគ្គលិកដែលស្ថិតក្រោមបង្គាប់ទាំងអស់ ហើយថែមទាំងមានតួនាទី និងសិទ្ធិក្នុងការសម្រេចលើករណីកិច្ចសន្យាកម្ចីសាច់ប្រាក់ដែលបានស្នើឡើងដោយអតិថិជនរបស់ខ្លួន។ ក្រៅពីនេះ ប្រធានគ្រប់គ្រងក៏មានភារៈដឹកនាំ និងដាក់កិច្ចការទៅឱ្យបុគ្គលិក ហើយធ្វើការត្រួតពិនិត្យដំណើរការ និងសកម្មភាពការងារប្រចាំថ្ងៃរបស់ធនាគារទាំងមូល។ ម្យ៉ាងវិញទៀត ប្រធានគ្រប់គ្រងត្រូវត្រួតពិនិត្យ និងបញ្ជាក់ឱ្យបានត្រឹមត្រូវ និងហ្មត់ចត់



នូវរាល់របាយការណ៍ហិរញ្ញវត្ថុទាំងអស់។ ប្រសិនមានពេល ពួកគេក៏ចូលរួមក្នុងកិច្ចការផ្នែកគណនេយ្យ ទំនាក់ទំនងសាធារណៈ ការផ្សព្វផ្សាយ ឬជួយផ្នែកផ្សេងៗទៀតតាមដែលអាចធ្វើបាន។

មុខនាទីដ៏សំខាន់ម្យ៉ាងទៀតរបស់មន្ត្រីធនាគារគឺ ធ្វើការសិក្សាស្រាវជ្រាវទៅលើស្ថានភាពបច្ចុប្បន្នរបស់សេដ្ឋកិច្ច និងសង្កេតទៅលើសកម្មភាពរបស់ធនាគារផ្សេងៗទៀតដែលមាននៅក្នុងតំបន់ជាមួយគ្នា។ ចំណុចនេះគឺដើម្បីពិនិត្យប្រៀបធៀបរកគន្លឹះ និងសេវាកម្មដ៏សមស្របនានាសម្រាប់បម្រើឱ្យអតិថិជនរបស់ខ្លួន។ ជាពិសេស មន្ត្រីធនាគារ ត្រូវរៀបចំរបាយការណ៍ប្រចាំថ្ងៃ ឬប្រចាំអាទិត្យសម្រាប់ដាក់ជូនទៅនាយកគ្រប់គ្រងធនាគារ។



## ការអប់រំ និងការបណ្តុះបណ្តាល

Gតម្រូវការអប់រំសម្រាប់បុគ្គលិកផ្នែកសេវាធនាគារមានកម្រិតខុសៗគ្នា។ សម្រាប់បេឡាធិការ និងស្មៀន យ៉ាងហោចណាស់គួរមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬបរិញ្ញាបត្រកាន់តែប្រសើរ។ បន្ថែមលើនេះ ពួកគេត្រូវរៀននូវជំនាញសំខាន់ៗមួយចំនួនដូចជា របៀបរៀបចំទុកដាក់ឯកសារ វាយអត្ថបទ ធុរកិច្ច (ជំនួញ) និងគណិតវិទ្យា។ ម្យ៉ាងទៀត ពួកគេត្រូវចេះប្រើប្រាស់កុំព្យូទ័រ ចេះភាសាបរទេសសម្រាប់ការទំនាក់ទំនងក្នុងកិច្ចការ។

ចំណែកមន្ត្រីធនាគារ និងអ្នកគ្រប់គ្រងពួកគេត្រូវចេះផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បទបញ្ជា និងច្បាប់ដែលប្រើក្នុងវិស័យធនាគារ។ ដើម្បីទទួលបានតំណែងប្រភេទនេះ ពួកគេ


តទៅទំព័របន្ទាប់

*តម្រូវមានកម្រិតអប់រំទាបបំផុត ត្រឹមបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ឬផ្នែកគ្រប់គ្រងពាណិជកម្ម (Business administration) ឬក៏ខ្ពស់ជាងនេះកាន់តែប្រសើរ ហើយរួមផ្សំជាមួយបទពិសោធន៍ការងារផងដែរ។*



## Kry l dgi

- **មុខវិជ្ជាសិក្សាក្នុងសាលា:**

*ធុរកិច្ច (ជំនួញ) និង*

*វិទ្យាសាស្ត្រកុំព្យូទ័រ*

- **កម្រិតអប់រំទាបបំផុត:**

*បរិញ្ញាបត្រ*

- **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

*អ្នកត្រួតពិនិត្យធនាគារ*

*អ្នកវិភាគក្រេឌីត*

*អ្នកវិភាគហិរញ្ញវត្ថុ*

*អ្នករៀបចំ និង*

*ថែរក្សាឯកសារ ឬសៀវភៅ*

## etIGkdgbeT?

បច្ចុប្បន្ននេះ វិស័យធនាគារនៅក្នុងប្រទេសកម្ពុជា កំពុងមានការរីកចម្រើនជាលំដាប់ដោយគេសង្កេតឃើញថា មានភ្នាក់ងារវិនិយោគទាំងក្នុង និងក្រៅប្រទេសមួយចំនួន បានកំពុងបណ្តាក់ទុនវិនិយោគក្នុងវិស័យនេះ តាមរយៈការពង្រីកសេវា បង្កើនទំនុកចិត្ត និងទាក់ទាញការគាំទ្រពីអតិថិជន ដែលកាលពីមុនពួកគាត់ហាក់មិនសូវនិយមប្រើប្រាស់សេវាធនាគារ ក្នុងការរក្សាទុកសាច់ប្រាក់របស់ខ្លួន។

ចំណែក ការអប់រំបណ្តុះបណ្តាលលើមុខជំនាញនេះវិញក៏មានការពេញនិយម អាស្រ័យដោយឱកាសការងារ និងម្យ៉ាងទៀត សិស្ស និស្សិតបានកំពុងសិក្សាជំនាញនេះនៅតាមគ្រឹះស្ថានសិក្សានានាក្នុងភាគរយមួយដ៏ច្រើន។

# ប្រធានគ្រប់គ្រងធុរកិច្ច

( Business Managers )

**សង្ខេបអំពីជំនាញ**

**ប្រធានគ្រប់គ្រងធុរកិច្ចធ្វើការងារ៖**

- វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- គ្រប់គ្រងបុគ្គលិក និងមនុស្ស
- គ្រប់គ្រងពេលវេលា

G

**ជំនាញដែលត្រូវការប្រើ៖**

- ការសម្រេចចិត្ត
- ការដោះស្រាយបញ្ហា
- ការទទួលខុសត្រូវ

## តើប្រធានគ្រប់គ្រងធុរកិច្ចបំពេញកិច្ចការអ្វីខ្លះ?

G គេកត់សម្គាល់ឃើញថា ស្ទើរគ្រប់ស្ថាប័ន និងក្រុមហ៊ុនទាំងអស់តែងមានកំណត់ពីឋានានុក្រមនៃការគ្រប់គ្រង។ ចំណុចនេះ មានន័យថាស្ថាប័ន ឬក្រុមហ៊ុនមួយមិនមែនគ្រប់គ្រងដោយមនុស្សតែម្នាក់នោះទេ ប៉ុន្តែតម្រូវឱ្យមានការបែងចែកភារកិច្ចទៅតាមផ្នែក និងការទទួលខុសត្រូវខុសៗគ្នា។ ឧទាហរណ៍ នៅក្នុងក្រុមហ៊ុនធំៗមានបែងចែកឋានៈតាមលំដាប់ដូចជា នាយក ឬនាយកប្រតិបត្តិ នាយករង និងមន្ត្រីជំនួយកិច្ចការដល់នាយក។ បន្ទាប់មកមានប្រធានផ្នែកហិរញ្ញវត្ថុ ដែលទទួលគ្រប់គ្រងបញ្ជីស្នាមហិរញ្ញវត្ថុ និងការចំណូលចំណាយ។ ចំណែកប្រធានផ្នែកប្រតិបត្តិការការងារច្រើនតែពិនិត្យ និងគ្រប់គ្រងដំណើរការការងារប្រចាំថ្ងៃរបស់ស្ថាប័ន ឬក្រុមហ៊ុន។ រីឯប្រធានផ្នែកគ្រប់គ្រងព័ត៌មានទទួលបន្ទុកផ្នែកប្រព័ន្ធបច្ចេកទេសព័ត៌មានវិទ្យា ដូចជាផ្នែកតបណ្ដាញកុំព្យូទ័រ និងការតប្រព័ន្ធអិនធើរណិតជាដើម។ ដូច្នេះ អនុប្រធាន និងមន្ត្រីទាំងអស់តាមផ្នែកនានាមានតួនាទីជួយគាំទ្រកិច្ចការរបស់ប្រធានគ្រប់គ្រង។



ជាត្រលប់មកវិញ ប្រធានគ្រប់គ្រងធុរកិច្ច (Business Managers) ធ្វើការគ្រប់គ្រងលើបុគ្គលិក និងមនុស្សជាច្រើននាក់នៅក្នុងស្ថាប័ន។ ធម្មតា ចំនួននៃបុគ្គលិកតិច ឬច្រើន ការមានជំនាញខុសៗគ្នា គឺអាស្រ័យទៅតាមទំហំ និងមុខជំនួញរបស់ក្រុមហ៊ុន។ ម្យ៉ាងទៀតការទទួលខុសត្រូវក៏មានកម្រិតធ្ងន់ ឬស្រាលទៅតាមបែបផែននោះផងដែរ។

Business Managers អាចជាអ្នកទទួលបន្ទុកខាងរៀបចំផែនការសិក្ខាសាលា ត្រួតពិនិត្យលើសេចក្ដីត្រូវការរបស់ផ្នែករដ្ឋបាល។ បន្ថែមលើនេះ Business Managers អាចជាអ្នកដែលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ពិនិត្យលើដំណើរការចំណូលចំណាយ និងពង្រីកប្រព័ន្ធព័ត៌មានដើម្បីវាយតម្លៃពីស្ថិរភាពនៃដំណើរការរបស់ក្រុមហ៊ុន។



## ការអប់រំ និងការបណ្តុះបណ្តាល

G ប្រសិនអ្នកមានបំណងក្លាយខ្លួនជា Business Manager អ្នកគួរគិតសិក្សាលើមុខវិជ្ជាចាំបាច់ខ្វះដូចជា ភាសាបរទេស ជំនួញ វិទ្យាសាស្ត្រកុំព្យូ-ទ័រ គណិតវិទ្យា និងរបៀបនៃការធ្វើបទបង្ហាញ។ ជាការពិតណាស់ថា ក្នុងនាមជា Business Manager អ្នកស្ថិតនៅក្នុង ឋានៈ និងតួនាទីជាអ្នកដឹកនាំ (Management Team) ដូច្នេះ តម្រូវឱ្យអ្នកគឺជាមនុស្សដែលមានជំនាញ និងពូកែក្នុងការទំនាក់ទំនង ព្រមទាំងរីករាយនឹងធ្វើការងារដែលពាក់ព័ន្ធជាមួយតួលេខ ឬបញ្ជីស្នាម។ ជាទូទៅ មុខតំណែងប្រភេទនេះ តម្រូវឱ្យមានសញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្ម (Business administration)។ ម្យ៉ាងវិញទៀត ក្នុងនាមជាអ្នកគ្រប់គ្រង ក៏តម្រូវឱ្យមានបទពិសោធន៍ច្រើនបន្ថែមផងដែរ ក្នុងការដឹកនាំ និងគ្រប់គ្រងបុគ្គលិកនៅក្រោមឱវាទរបស់ខ្លួន។ គេកត់សម្គាល់ឃើញថា អ្នកគ្រប់គ្រង និងនាយករងច្រើនតែមានជំនាញ ឬឯកទេសជាក់លាក់ណាមួយក្នុង វិស័យជំនួញ ឬធុរ-កិច្ច។ ចំណែកអ្នកគ្រប់គ្រងផ្នែកទីផ្សារ និងការលក់វិញ ជាទូទៅមានជំនាញពាក់ព័ន្ធនឹងបទពិសោធន៍ការងាររបស់ពួកគេដែលបម្រើការនៅក្នុងទីផ្សារធំៗ និងមជ្ឈមណ្ឌលពាណិជ្ជកម្ម ហើយច្រើនតែឡើងមុខតំណែងតាមរយៈការងារ និងស្នាដៃ។

### Kry l dgi

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ធុរកិច្ច (ជំនួញ) និងវិទ្យាសាស្ត្រកុំព្យូទ័រ

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកប៉ាន់ស្មានតម្លៃ

មន្ត្រីរដ្ឋបាលការិយាល័យ

ប្រធានគ្រប់គ្រងផ្នែកអចលនវត្ថុ និងទ្រព្យសម្បត្តិ

អ្នកធ្វើការផ្នែកប្រមូលទិញ

### etGkdgbeT?

ទោះបីជា Business managers បានបញ្ចប់ការសិក្សា និងទទួលបានសញ្ញាបត្រពីមហាវិទ្យាល័យហើយក៏ដោយ ប៉ុន្តែប្រការសំខាន់ពួកគេត្រូវតែស្រាវស្រទេញសិក្សាបន្ថែម និងតាមដាននូវរាល់ព័ត៌មានថ្មីៗពាក់ព័ន្ធទៅនឹងស្ថានភាព ឬព្រឹត្តិការណ៍វិវឌ្ឍនៃសេដ្ឋកិច្ច និងជំនួញទាំងក្នុង និងក្រៅប្រទេស។ ការសង្កេតតាមដាននូវរាល់ព័ត៌មានទាំងអស់នោះ និងជួយពួកគេក្នុងការវិភាគ ព្យាករណ៍ ព្រមទាំងគ្រប់គ្រងជំនួញ និងក្រុមហ៊ុនរបស់គេឱ្យស្របទៅនឹងបម្រែបម្រួលនៃបរិដ្ឋានសេដ្ឋកិច្ច សង្គម និងតម្រូវការពីអតិថិជនផងដែរ។

## វិស្វករស៊ីវិល & អ្នកបច្ចេកទេសវិស្វកម្មស៊ីវិល

( Civil Engineers )

**សង្ខេបអំពីជំនាញ**

**វិស្វករស៊ីវិល និងអ្នកបច្ចេកទេសវិស្វកម្មស៊ីវិលធ្វើការងារ៖**

- ✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
- ✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ✦ ធ្វើកិច្ចការជាក្រុម

G

**ជំនាញដែលត្រូវការច្រើន៖**

- ✦ គណិតវិទ្យា
- ✦ ការដោះស្រាយបញ្ហា
- ✦ ការគិត និងអនុវត្តកិច្ចការប្រកបដោយហេតុផល

## តើវិស្វករស៊ីវិល និងអ្នកបច្ចេកទេសវិស្វកម្មស៊ីវិល បំពេញកិច្ចការអ្វីខ្លះ?

G វិស្វករស៊ីវិល (Civil engineers) ធ្វើការសិក្សាអំពីគំរូប្លង់ និងគ្រប់គ្រងផ្តល់យោបល់ចំពោះវិស័យសំណង់ដែលមានជាច្រើនប្រភេទ និងរចនាសម្ព័ន្ធខុសៗគ្នា។ ពួកគេបំពេញការងារនៅតាមការដ្ឋានសំណង់ផ្សេងៗដូចជា ស្ពាន ទំនប់ទឹក ឬវារីអគ្គិសនី អគារ ប្រព័ន្ធផ្លូវលើដី និងក្រោមដី ផ្លូវសម្រាប់ហោះហើរក្នុងអាកាសយានដ្ឋាន ប្រព័ន្ធចែកចាយទឹក និង





ប្រព័ន្ធលូបង្ហូរទឹក ព្រមទាំងសំណង់ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាច្រើនផ្សេងទៀត។

ជាទូទៅ វិស្វករមិនមានជំនាញ ឬឯកទេសដូចៗគ្នានោះទេ។ អ្នកខ្លះមានឯកទេសខាងរចនាសម្ព័ន្ធ និងគ្រោងឆ្អឹងរបស់អគារ ខ្លះទៀតផ្នែកធនធានទឹក ផ្នែកសំណង់ ផ្នែកបរិស្ថាន និងផ្នែកចរាចរ និងប្រព័ន្ធគមនាគមន៍។

ចំណែកអ្នកបច្ចេកទេសផ្នែកវិស្វកម្មស៊ីវិលមានតួនាទីជួយកិច្ចការដល់វិស្វករក្នុងការរៀបចំគម្រោង និងសិក្សាស្រាវជ្រាវកិច្ចការដែលពាក់ព័ន្ធនានា។ អ្នកខ្លះធ្វើការវិភាគ និងប៉ាន់ស្មានតម្លៃនៃការសាងសង់ សម្ភារសំណង់ ហើយខ្លះទៀតរៀបចំគំនូរប្លង់ និងសិក្សាពីស្ថានភាពដីនៅកន្លែងការដ្ឋានដែលត្រូវសាងសង់។

គេកត់សម្គាល់ឃើញថា វិស្វករស៊ីវិលតែងបានប្រើប្រាស់ចំណេះវិជ្ជាផ្នែកបច្ចេកទេសរបស់ពួកគេក្នុងការអនុវត្តការងារ និងដោះស្រាយបញ្ហាប្រចាំថ្ងៃ ដូចគ្នាទៅនឹងវិស្វករនៃជំនាញដទៃទៀតដែរ។ ជម្មតា នៅក្នុងការគូរ និងរៀបចំរចនាសម្ព័ន្ធរបស់សំណង់ តម្រូវឱ្យមានការសិក្សាស្រាវជ្រាវ និងធ្វើតេស្តសាកល្បងជាច្រើន។ មិនតែប៉ុណ្ណោះ វិស្វករតែងតែធ្វើការផ្លាស់ប្តូរគំរូប្លង់របស់គេជាច្រើនលើក ដើម្បីតម្រូវទៅនឹងស្ថានភាព ឬកត្តាចាំបាច់ មុននឹងសម្រេចចិត្តទទួលយកប្លង់នោះ។

នៅពេលដែលការរចនាប្លង់បានបញ្ចប់រួចរាល់ហើយ វិស្វករត្រូវបំពេញតួនាទីរបស់ខ្លួនក្នុងការដឹកនាំសាងសង់រចនាសម្ព័ន្ធ (គ្រោងឆ្អឹង) របស់អគារ។ តាមរយៈកិច្ចការនេះពួកគេត្រូវការជ្រើសរើស និងទិញសម្ភារចាំបាច់នានាសម្រាប់ការសាងសង់ ព្រមទាំងដាក់ផែនការការងារទៅដល់បុគ្គលិក និងកម្មករក្រោមបង្គាប់ទៅតាមតួនាទីរបស់គេម្នាក់ៗ។

កិច្ចការម្យ៉ាងទៀតដែលត្រូវគិត គឺការបែងចែក និងកំណត់ពេលវេលាសម្រាប់ការបញ្ចប់គម្រោង រួមផ្សំនឹងកិច្ច



តទៅទំព័របន្ទាប់



ការដោះស្រាយរាល់បញ្ហាដែលអាចកើតមានជាយថាហេតុនៅក្នុងអំឡុងពេលនៃការសាងសង់។

ជាការគួរកត់សម្គាល់ វិស្វករ និងអ្នកបច្ចេកទេសវិស្វកម្ម តែងបានចំណាយពេលវេលាដ៏ច្រើនលើសលប់របស់ពួកគេនៅក្នុងការដ្ឋានសាងសង់។ ធម្មតា ការដ្ឋានសំណង់អាចស្ថិតនៅជិតទីប្រជុំជន និងទីក្រុង ខណៈពេលដែលការដ្ឋានខ្លះទៀតអាចស្ថិតនៅតាមទីជនបទ ឬទីដាច់ស្រយាល។ វិស្វករខ្លះត្រូវធ្វើដំណើរពីទីកន្លែងមួយទៅទីកន្លែងមួយទៀត ដើម្បីពិនិត្យមើលដំណើរការសាងសង់របស់គម្រោងផ្សេងៗ ដែលគម្រោងនីមួយៗអាចមានរយៈវែងរហូតដល់ពីរ ឬបីឆ្នាំក៏មាន។



## ការអប់រំ និងការបណ្តុះបណ្តាល

G វិស្វករស៊ីវិល តម្រូវឱ្យមានការអប់រំកម្រិតបរិញ្ញាបត្រផ្នែកវិស្វកម្ម។ នៅកម្ពុជា ដើម្បីក្លាយខ្លួនជាវិស្វករ សិស្ស និស្សិតអាចសិក្សាជំនាញនេះនៅតាមគ្រឹះស្ថានអប់រំនានា ប៉ុន្តែ ហាក់មិនសូវមានច្រើននោះទេ មានដូចជាវិទ្យាស្ថានបច្ចេកទេសកម្ពុជា ជាដើម។ ចំណែកអ្នកបច្ចេកទេសខាងវិស្វកម្មវិញ តម្រូវឱ្យមានសញ្ញាបត្រជាអ្នកបច្ចេកទេសជាន់ខ្ពស់ដែរអាចរកសិក្សាបាននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស មួយចំនួនដែលស្ថិតក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សម្រាប់វិស្វករ ដែលមានបំណងក្លាយខ្លួនជាអ្នកស្រាវជ្រាវ និងបង្រៀនមុខវិជ្ជានេះ ត្រូវមានសញ្ញាបត្រខ្ពស់ជាងនេះតាមរយៈការបន្តការសិក្សាបន្ថែមនៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ឬថ្នាក់បណ្ឌិត ជាដើមនៅឯបរទេស។



## Kry l dgj

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

គណិតវិទ្យា និងរូបវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ (សម្រាប់វិស្វករ)

សញ្ញាបត្របច្ចេកទេសជាន់ខ្ពស់ (សម្រាប់អ្នកបច្ចេកទេសជាន់ខ្ពស់)

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកនគរូបនីយកម្ម

អ្នកត្រួតពិនិត្យការសាងសង់

វិស្វករផ្នែកបរិដ្ឋាន

វិស្វករផ្នែកមេកានិច

វិសករផ្នែកចរាចរ និងគមនាគមន៍



## etGkdgbeT?

ប្រសិន ក្រលេកមើលស្នាដៃនៃសំណង់ពីសម័យបុរាណដូចជាពីរ៉ាមីតនៅអេហ្ស៊ីប និងសំណង់របស់ចក្រភពរ៉ូម (បច្ចុប្បន្នប្រទេសអ៊ីតាលី) ព្រមទាំងសំណង់ប្រាសាទបុរាណរបស់ខ្មែរដូចជាអង្គរវត្ត ជាដើម គឺសុទ្ធសឹងជាស្នាដៃនៃវិស្វកម្មស៊ីវិល និងស្ថាបត្យកម្ម។ នៅរាល់ការសាងសង់សំណង់នានាក្នុងសម័យបុរាណ ទំនងជាមិនមានសាលា ឬគ្រឹះស្ថានអប់រំផ្នែកវិស្វកម្មទេ ប៉ុន្តែវិស្វករជំនាន់នោះ អាចជាអ្នកដែលសិក្សាស្វែងយល់ និងអនុវត្តការងារដោយផ្ទាល់ដោយខ្លួនឯង។ យ៉ាងណាមិញ ជំនាញប្រភេទនេះ កំពុងមានតម្រូវការយ៉ាងច្រើនសម្រាប់ទីផ្សារការងារកម្ពុជាបច្ចុប្បន្ន និងអនាគត។

# សិល្បករ

( Artists )

សង្ខេបអំពីជំនាញ

សិល្បករធ្វើការងារ៖

- ✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
- ✦ ជួយក្នុងកិច្ចបម្រើសេវាអតិថិជន ឬភ្ញៀវ
- ✦ ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

G

ជំនាញដែលត្រូវការប្រើ៖

- ✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
- ✦ ការអាន និងការសរសេរ
- ✦ របៀបគ្រប់គ្រងកិច្ចការដោយខ្លួនឯង

## តើសិល្បករបំពេញកិច្ចការអ្វីខ្លះ?

G សិល្បៈត្រូវបានបែងចែកទៅជាប្រភេទ និងទម្រង់ផ្សេងៗគ្នា ហេតុនេះពាក្យថា «សិល្បៈ» គឺមានន័យទូលំទូលាយដរាបណា គេមិនបានពិនិត្យមើលប្រភេទនីមួយៗឱ្យបានជាក់លាក់ទេនោះ។ ឧទា៖ **សិល្បៈរូបទស្សន៍** (Visual arts) **វិចិត្រសិល្បៈ** (Fine arts) **និងសិប្បកម្ម** (Crafts) ជាដើម។

សិល្បៈរូបទស្សន៍ (Visual arts) គឺសំដៅដល់សិល្បៈដែលបង្ហាញ ឬរំលេចចេញតាមរយៈរូបភាព និងរូបរាងផ្សេងៗ ហើយអាចមើលឃើញដោយភ្នែក។ សម្រាប់ប្រភេទនេះត្រូវបានបែងចែកជា ៣ប្រភេទគឺ: **សិល្បៈបែបការផ្សព្វផ្សាយ** (Commercial arts) ដែលប្រើសម្រាប់ផ្សាយពាណិជ្ជកម្ម ការបោះពុម្ព ទំនាក់ទំនងសាធារណៈ និងកិច្ចការជំនួញផ្សេងៗទៀត ដើម្បីទាក់ទាញការចាប់អារម្មណ៍ ការលក់ផលិតផលនិងសេវាកម្ម ការបង្ហាញអំពីគំនិត និងការកត់ត្រាព្រឹត្តិការណ៍ជាដើម។ សិល្បករបែបការផ្សព្វផ្សាយមានរួមបញ្ចូល អ្នកគូរគំនូរ អ្នករចនាគំនូរក្រាហ្វិក និងអ្នកថតរូបជាដើម។ សិល្បៈបែបការផ្សព្វផ្សាយភាគច្រើនគិតបញ្ចូលទាំងប្រភេទរូបភាព និងអត្ថបទជាមួយគ្នា។ បច្ចុប្បន្ននេះ ដោយសារបច្ចេកវិទ្យាខាងវិស័យកុំព្យូទ័រមានការរីកចម្រើន បានអនុញ្ញាតឱ្យសិល្បករមានការងាយស្រួលក្នុងការប្រើប្រាស់កម្មវិធីថ្មីៗដើម្បីរចនា និងធ្វើរូបផ្សាយផ្សេងៗបានច្រើនប្រភេទ។



**វិចិត្រសិល្បៈ** (Fine arts) គឺជាប្រភេទសិល្បៈដែលបង្កើតតាមរយៈការបញ្ចេញគំនិតដោយផ្ទាល់របស់សិល្បករ និងសម្រាប់ការរកប្រាក់ចំណូល។ មានន័យថា កិច្ចការភាគច្រើនត្រូវបានបង្កើតឡើងដោយគំនិតរបស់សិល្បករ មិនមែនជាការបង្គាប់ដោយអតិថិជន ឬភ្ញៀវនោះឡើយ។ វិចិត្រករ ប្រើប្រាស់ពណ៌ផ្សេងដើម្បីគូរគំនូរនៅលើផ្ទាំងក្រដាស ក្រណាត់ ឈើជាដើម។ ចំណែកអ្នកសូនរូប ប្រើប្រាស់ដីឥដ្ឋដើម្បីសូនជារូបចាក់ពុម្ព ឆ្លាក់រូប ជាច្រើនទម្រង់។ រីឯសិល្បករខាងសរសេរស្លាកយីហោ និងផ្ទាំងអក្សរសម្រាប់ផ្សព្វផ្សាយ តែងប្រើប្រាស់ទឹកថ្នាំ ខ្មៅដៃ ក្រដាស សៀវភៅ ឈើ ដើម្បីគូរ ឬឆ្លាក់អក្សរ និងស្លាកសញ្ញាតាមការបញ្ជាគូររបស់អតិថិជន។



ក្រៅពីនេះ អ្នកបោះពុម្ព មានតួនាទីបោះពុម្ពរូបភាពដែលបានបង្កើតរួចជាស្រេចនៅលើពុម្ពធ្វើពីឈើ ឬដែក។ មានសិល្បករមួយពួកទៀតគឺជាអ្នកឯកទេសខាងផលិតវត្ថុធ្វើ

ពីដីឥដ្ឋដែលហៅថា កុលាលភាជន៍ (Ceramics)។ សិល្បករប្រភេទនេះធ្វើវត្ថុដូចជាចាន ថូ ក្អម រូបតាំងលំអរ ដែលមានលាបពណ៌ទៅតាមការចង់បាន។

រីឯអ្នកសិល្បមួយប្រភេទទៀត មានជំនាញខាងផលិតវត្ថុតម្បាញពីផ្តៅ វល្លិ៍ និងឫស្សី ជាដើមដែលយើងនិយមហៅថាសិប្បកម្ម (Handicraft)។ អ្នកផលិតវត្ថុរបៀបនេះតែងធ្វើឡើងក្នុងបំណងលក់ និងរកប្រាក់ចំណេញតាមរយៈការលក់រាយ ឬលក់ដុំនៅតាមទីផ្សារ និងតាមតំបន់ទេសចរណ៍នានា។

មានការកត់សម្គាល់ឃើញថា សិល្បករភាគច្រើនពុំរស់ពឹងអាស្រ័យតែលើចំណូលដែលបានមកពីជំនាញរបស់ខ្លួនតែមួយមុខនោះទេ ផ្ទុយទៅវិញពួកគេត្រូវការរកចំណូលមកពីប្រភពផ្សេងៗ ដោយសារតែមុខជំនាញសិល្បៈជួនកាលគ្រាន់តែធ្វើឡើងដើម្បីបំពេញចំណូលចិត្ត នៅពេលទំនេរតែប៉ុណ្ណោះ ហើយមិនមានទិសដៅស្វែងរកកម្រៃនោះឡើយ។



## ការអប់រំ និងការបណ្តុះបណ្តាល

G ប្រសិនអ្នកចង់ក្លាយខ្លួនជាសិល្ប-ករផ្នែកនេះ អ្នកគួរគិតចាប់ផ្តើមសិក្សាមុខវិជ្ជា ដែលពាក់ព័ន្ធនឹងសិល្បៈ និងទ្រឹស្តីសិល្បៈចាប់ពីការសិក្សានៅវិទ្យាល័យ។ យ៉ាងណាមិញ ការសិក្សាកម្រិតវិទ្យាល័យនៅកម្ពុជាហាក់មិនមានផ្តោតសំខាន់លើមុខវិជ្ជាបែបសិល្បៈប៉ុន្មានទេ ហេតុនេះសិស្សដែលមានបំណងសិក្សា និងចាប់យកជំនាញសិល្បៈច្រើនតែសម្រុករៀនមុខវិជ្ជានេះនៅមហាវិទ្យាល័យតែម្តង។ ឧទាហរណ៍ នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (Royal University of Fine Arts) នាទីក្រុងភ្នំពេញមានមហាវិទ្យាល័យសិល្បៈសូនរូបដែលផ្តោតលើមុខវិជ្ជាឯកទេសខាង វិចិត្រកម្ម (គំនូរ) សូនរូប ចម្លាក់ កុលាលភាជន៍ ជាដើម។ ការសិក្សានៅមហាវិទ្យាល័យនេះសិស្សអាចទទួលបានបរិញ្ញាបត្រតាមឯកទេសរៀងៗខ្លួន។ ក្រៅពីនេះក៏មានមហាវិទ្យាល័យឯកជនខ្លះៗកំពុងបង្រៀនមុខវិជ្ជាសិល្បៈផងដែរ ប៉ុន្តែច្រើនផ្តោតតែសិល្បៈបែបស្ថាបត្យកម្ម ច្រើនជាងសិល្បៈដទៃទៀត។



Kry I dgj



✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

សិល្បៈ និងប្រវត្តិសាស្ត្រ

✦ **កម្រិតអប់រំទាបបំផុត:**

វិទ្យាល័យ ឬបរិញ្ញាបត្រ (ប្រសិនអាច)

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នករចនាគំនូរក្រាហ្វិក អ្នកថតរូប

អ្នកច្នៃម៉ូតខោអាវ និងអ្នកធ្វើគំនូរជីវចល ។ល។

etGkdgbeT?



នៅកម្ពុជា សិល្បៈបែបសិប្បកម្ម និងចម្លាក់ហាក់មានទីផ្សារទូលំទូលាយ អាស្រ័យដោយការរីកចម្រើនខាងវិស័យទេសចរណ៍ ជាពិសេសនៅតាមខេត្តក្រុងមួយចំនួនដែលមានសក្តានុពលទេសចរណ៍។ តាមរយៈការរីកចម្រើននេះបានបង្កលទ្ធភាព និងផ្តល់ឱកាសការងារដល់សិល្បករ និងសិប្បករមួយចំនួនក្នុងការបង្កើនផលិតផល និងស្នាដៃរបស់ខ្លួនសម្រាប់តម្រូវទៅតាមសេចក្តីត្រូវការរបស់ទីផ្សារ និងចំណូលចិត្តរបស់អតិថិជន។ ប្រការនេះបានចូលរួមលើកស្ទួយកម្រិតជីវភាពរបស់ប្រជាពលរដ្ឋបានមួយកម្រិតថែមទៀត។

# អ្នកសេដ្ឋកិច្ច

( Economists )

**សង្ខេបអំពីជំនាញ**

**អ្នកសេដ្ឋកិច្ចធ្វើការងារ៖**

- ✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
- ✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ✦ បង្រៀន

G

**ជំនាញដែលត្រូវការប្រើ៖**

- ✦ គណិតវិទ្យា
- ✦ ការដោះស្រាយបញ្ហាដែលកើតមានចំពោះមុខ
- ✦ ការគិត និងអនុវត្តកិច្ចការប្រកបដោយហេតុផល

## តើអ្នកសេដ្ឋកិច្ចបំពេញកិច្ចការអ្វីខ្លះ?

G នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ មនុស្សគ្រប់ៗគ្នាតែងគិត និងសម្រេចចិត្តតាមវិធីផ្សេងៗក្នុងការចំណាយប្រាក់កាសទៅលើការចាយវាយរបស់ខ្លួន។ យ៉ាងណាមិញ អ្នកសេដ្ឋកិច្ចតែងបានគិត និងអនុវត្តនូវរបៀបបែបគ្នានេះ ប៉ុន្តែប្លែកគ្នាត្រង់ចំណុចដែលថា អ្នកសេដ្ឋកិច្ច នឹងគិតអំពីកិច្ចការបែបនេះក្នុងលក្ខណៈ និងទ្រង់ទ្រាយធំពាក់ព័ន្ធនឹងបរិមាណនៃទឹកប្រាក់។ ពួកគេបំពេញកិច្ចការឱ្យក្រុមហ៊ុន ឬរដ្ឋាភិបាលដើម្បីជួយបង្កើតគម្រោង និងកម្មវិធី ផ្សេងៗ។ ក្រៅពីនេះ អ្នកសេដ្ឋកិច្ចធ្វើការសិក្សាស្រាវជ្រាវអំពីលំហូរ ឬចរាចរនៃសាច់ប្រាក់តាមរយៈការចំណាយរបស់មនុស្សទូទៅនៅក្នុងទីផ្សារ ព្រមទាំងសិក្សាអំពីសង្វាក់ផលិតកម្មនៃការបង្កើតផលិតផល និងកិច្ចបម្រើសេវានានាដែលមាននៅក្នុងសង្គម។

អ្នកសេដ្ឋកិច្ចខ្លះទៀតបម្រើឱ្យតួនាទីដើម្បីជួយកិច្ចការផ្នែកជំនួញក្នុងការរៀបចំផែនការអំពីមុខទំនិញនានាដែលត្រូវផលិត និងសេវាកម្មផ្សេងៗដែលត្រូវផ្តល់ជូនអតិថិជន ហើយត្រូវធ្វើការកំណត់អំពីកម្រៃនៃផលិតផល និងសេវាកម្មទាំងនោះ។ ដើម្បីអាចដឹង និងធ្វើសេចក្តីសន្និដ្ឋានអំពីចំណុចទាំងពីរខាងលើ អ្នកសេដ្ឋកិច្ចត្រូវធ្វើការសិក្សាទៅលើកត្តាសំខាន់ៗដូចជា ចំនួនអតិថិជន ឬអ្នកប្រើប្រាស់សេវាដែលមាននៅក្នុងតំបន់ ឬទីតាំងរបស់ខ្លួន លំហូរនៃសាច់ប្រាក់ ឬបរិមាណនៃការចំណាយជាទូទៅចំពោះសេវាកម្ម និងផលិតផល ព្រមទាំងសិក្សាផងដែរអំពីសេវាកម្ម និងផលិតផលរបស់ក្រុមហ៊ុនដទៃទៀតដែលអាចជាគូប្រជែងនៅក្នុងទីផ្សារ។

អ្នកសេដ្ឋកិច្ច ក៏សិក្សាផងដែរអំពីស្ថិតិដើម្បីបង្ហាញឱ្យដឹងអំពីតម្លៃសម្រាប់ចំណាយក្នុងការផលិតទំនិញ និងសិក្សាកំណត់ទីតាំងណាមួយដែលនិយោជក ឬក្រុមហ៊ុនគួរធ្វើការវិនិយោគនូវទុនរបស់ខ្លួនដើម្បីទទួលបានផលចំណេញ។ គេពិនិត្យឃើញថា អ្នកសេដ្ឋកិច្ចតែងធ្វើការសិក្សានូវរាល់ចំណុចដូចបានពោលមកខាងលើដើម្បីផ្តល់នូវទិន្នន័យ និងព័ត៌មានរួមមួយទៅដល់មន្ត្រី ឬគណៈគ្រប់គ្រងក្នុងការធ្វើសេចក្តីសម្រេចទៅលើផែនការ ឬគម្រោងដែលនឹងត្រូវអនុវត្តក្នុងពេលអនាគត។

បន្ថែមលើនេះ អ្នកសេដ្ឋកិច្ចធ្វើការប្រមូល និងវិភាគនូវទិន្នន័យជាក់លាក់មួយ ដើម្បីពិនិត្យទៅលើទំនាក់ទំនងនានារបស់តួលេខ។ ឧទាហរណ៍៖ ប្រសិនអ្នកសេដ្ឋកិច្ចរកឃើញថាកម្រិតនៃប្រាក់ខែរបស់បុគ្គលិកមានការកើនឡើង នោះពួកគេក៏អាចប្រើប្រាស់ទិន្នន័យ និងតួលេខដដែលនេះ




តទៅទំព័របន្ទាប់

ដើម្បីពន្យល់ក្នុងផ្នែកណាមួយ អំពីហេតុផលដែលធ្វើឱ្យទំនិញក្នុងទីផ្សារមានការតម្លើងថ្លៃ។

ក្រៅពីនេះ ការរៀបចំរបាយការណ៍គឺជាផ្នែកដ៏សំខាន់មួយផ្សេងទៀតក្នុងតួនាទីជាអ្នកសេដ្ឋកិច្ច។ ពួកគេរៀបចំតារាង និងក្រាហ្វិក ដោយពន្យល់បកស្រាយនូវតួលេខទាំងអស់នោះជាលាយលក្ខណ៍អក្សរឱ្យបានច្បាស់ និងដោយមិនបង្វែរអត្ថន័យខ្លឹមសារ។

ជាទូទៅ អ្នកសេដ្ឋកិច្ចតែងមានជំនាញឯកទេសនៅក្នុងផ្នែកណាមួយនៃសាខាធំរបស់សេដ្ឋកិច្ច។ ឧទាហរណ៍ អ្នកសេដ្ឋកិច្ចដែលសិក្សា និងស្រាវជ្រាវអំពីកិច្ចការ ឬគម្រោងធំៗ ឬគោលនយោបាយរបស់រដ្ឋាភិបាលដែលមិនមានលក្ខណៈជាក្រុមហ៊ុនឯកជន (Macroeconomists)។ អ្នកសេដ្ឋកិច្ចមួយបែបផ្សេងទៀតសិក្សា និងអង្កេតអំពីកម្លាំងពលកម្ម និងប្រជាសាស្ត្រ (Labour and demographic economists) មានភារៈក្នុងការសិក្សាទៅលើអត្រានៃប្រាក់បៀវត្សរ៍របស់បុគ្គលិកនៅក្នុងស្ថាប័ននានានៅទូទាំងប្រទេស ដើម្បីពិនិត្យ និងព្យាករណ៍ទៅលើនិន្នាការផ្សេងៗនៅក្នុងវិស័យសេដ្ឋកិច្ច។ ដោយឡែកអ្នកសេដ្ឋកិច្ចក្នុងកម្រិតអន្តរជាតិ (International economists) អាចសិក្សាអំពីចរាចរនៃមុខទំនិញនានាដែល ផលិតនៅក្នុងតំបន់ប៉ុន្តែសម្រាប់បម្រើឱ្យទីផ្សារអន្តរជាតិ។ លើសពីនេះ ពួកគេក៏សិក្សាផងដែរអំពីស្ថិតិដើម្បីអាចកំណត់ដឹងថាតើរដ្ឋាភិបាលរបស់គេទទួលបានផលប្រយោជន៍អ្វីខ្លះអំពីការផ្លាស់ប្តូរទំនិញទៅក្នុងទីផ្សារ និងដៃគូអន្តរជាតិ។ រីឯអ្នកសេដ្ឋកិច្ចផ្នែកហិរញ្ញ-វត្ថុ (Financial economists) សិក្សាអំពីក្រេឌីត សាច់ប្រាក់ ស្ថិតិ និងនិន្នាការនានាដើម្បីជួយទៅដល់ការអភិវឌ្ឍ ឬបង្កើតគោលនយោបាយសាធារណៈ។

អ្នកសេដ្ឋកិច្ចមួយក្រុមទៀត មានឯកទេសខាងការសិក្សាអំពីវិធីនៃការគ្រប់គ្រងជំនួញ និងផ្តល់យោបល់ចំពោះការប្រើប្រាស់ផលចំណេញដើម្បីយកទៅបង្កើនចំណូលឱ្យបានកាន់តែច្រើន (Industrial or organizational economists)។

## ការអប់រំ និងការបណ្តុះបណ្តាល

G អ្នកសេដ្ឋកិច្ចគួរសិក្សាលើមុខវិជ្ជាចាំបាច់មួយចំនួនដូចជា គណិតវិទ្យា ភាសាបរទេស មុខវិជ្ជានានាដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ច ឬវិទ្យាសាស្ត្រសង្គម។ ម្យ៉ាងទៀតគេត្រូវពិចារណាចំពោះការសិក្សាជំនាញកុំព្យូទ័រដែលពាក់ព័ន្ធដល់ការរៀបចំតារាង ក្រាហ្វិក ស្ថិតិ និងមូលដ្ឋានទិន្នន័យផងដែរ។

### Kry I dgi

- **មុខវិជ្ជាសិក្សាក្នុងសាលា:**

ជំនួញ សេដ្ឋកិច្ច និងគណិតវិទ្យា

- **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

- **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

គណនេយ្យករ

អ្នកវិភាគហិរញ្ញវត្ថុ

អ្នកធ្វើគម្រោងហរិញ្ញវត្ថុ ។ល។

# អ្នកភូគព្ភសាស្ត្រ

( Geologists )

**សង្ខេបអំពីជំនាញ**

**អ្នកភូគព្ភសាស្ត្រធ្វើការងារ៖**

- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ជួយការងារដល់ភ្ញៀវ ឬអតិថិជន

G

**ជំនាញដែលត្រូវការប្រើ៖**

- ការគិតប្រកបដោយភាពច្នៃប្រឌិត
- ការដោះស្រាយបញ្ហា
- ការអាន និងសរសេរ

## តើអ្នកភូគព្ភសាស្ត្របំពេញកិច្ចការអ្វីខ្លះ?

G អ្នកភូគព្ភសាស្ត្រ (Geologists) ធ្វើការសិក្សាស្រាវជ្រាវអំពីផែនដី។ ពួកគេមានចំណាប់អារម្មណ៍ទៅលើការកកើតរបស់ផែនដី និងពិភពលោក ព្រមទាំងការវិវត្តន៍ និងប្រែប្រួលរបស់វាទាំងក្នុងអតីតកាល និងទៅក្នុងពេលអនាគតដ៏យូរ។ ក្នុងដំណើរការសិក្សារបស់ពួកគេ អ្នកភូគព្ភសាស្ត្រតែងត្រូវការបង្កើតនូវផែនទីភូមិសាស្ត្ររបស់សណ្ឋានដីនៅតំបន់ណាមួយ ដើម្បីធ្វើការជីក ឬខួងចុះទៅក្នុងជម្រៅដី ហើយស្វែងរកនូវគំរូតាង (samples) របស់សិលាជាច្រើនប្រភេទ សម្រាប់សិក្សា វិភាគ និងធ្វើនូវសេចក្តីសន្និដ្ឋាន។



ក្រៅពីការសិក្សា និងប្រមូលគំរូតាងពីខាងក្រៅ អ្នកភូគព្ភសាស្ត្រត្រូវធ្វើការនៅក្នុងមន្ទីរពិសោធន៍ដើម្បីវិភាគ តាមដានអំពីគំរូតាងដែលបានប្រមូលមានដូចជា សិលា រុក្ខជាតិ និងផូស៊ីលរបស់សត្វផ្សេងៗ ដោយរក្សាទុកវត្ថុទាំងនោះនៅក្នុងសីតុណ្ហភាពមួយសមស្រប។

ជាចុងក្រោយ អ្នកភូគព្ភសាស្ត្រនឹងប្រមូលនូវព័ត៌មានដែលបានពីការសិក្សាវិភាគ ដើម្បីរៀបចំជារបាយការណ៍អំពីលទ្ធផលដែលបានស្រាវជ្រាវឃើញ។ លទ្ធផលនៃរបាយការណ៍អាចប្រើសម្រាប់បញ្ជាក់ពីសមាសធាតុរបស់រ៉ែ ឬធនធានធម្មជាតិដែលមាននៅក្រោមដី ដូចជា ប្រភពទឹកក្រោមដី ប្រេងកាត ប្រភេទរ៉ែនានា និងធនធានជាច្រើនផ្សេងទៀត។



ទោះបីជាអ្នកភូគព្ភសាស្ត្រសំដៅទៅដល់ការសិក្សាអំពីផែនដីក៏ដោយ ប៉ុន្តែពួកគេបានបែងចែកមុខជំនាញឯកទេសដោយឡែកៗពីគ្នា ដូចជា អ្នកភូគព្ភសាស្ត្រខាងមហាសាគរ (marine geologists) អ្នកផ្តោតការស្រាវជ្រាវទៅលើកំណប់រ៉ែប្រេងកាត (petroleum geologists) និងអ្នកភូគព្ភសាស្ត្រដែលធ្វើការសិក្សាពីកំណើត និងការវិត្តរបស់ផែនដីតាមរយៈយុគសម័យនីមួយៗរបស់ថ្ម (paleontologists) ជាដើម។

គេសង្កេតឃើញថា ការងាររបស់អ្នកភូគព្ភសាស្ត្រអាចទាមទារនូវការប្រើប្រាស់កម្លាំងកាយច្រើន ដោយពួកគេត្រូវធ្វើដំណើរទៅកាន់កន្លែងឆ្ងាយៗ ឬដាច់ស្រយាលដើម្បីធ្វើការស្រាវជ្រាវ។ ម្យ៉ាងទៀត ពួកគេត្រូវចំណាយពេលវេលាច្រើនម៉ោងនៅក្នុងមន្ទីរពិសោធន៍ ដើម្បីសង្កេតតាមដានការវិភាគរបស់វត្ថុ និងគំរូតាងមុននឹងរៀបចំរបាយការណ៍។


តទៅទំព័របន្ទាប់

## ការអប់រំ និងការបណ្តុះបណ្តាល

G អ្នកភូគព្ភសាស្ត្រត្រូវមានការអប់រំ និងបណ្តុះបណ្តាលលើជំនាញមួយចំនួនដូចជា វិទ្យាសាស្ត្រកុំព្យូទ័រ ប្រវត្តិសាស្ត្រ ភាសាបរទេស និងមុខវិជ្ជាភូមិវិទ្យា (ផែនដី)។ ក្រៅពីនេះ ពួកគេត្រូវមានជំនាញផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យា ដែលផ្តោតជាពិសេសលើមុខវិជ្ជាវិទ្យាសាស្ត្រផែនដី គីមីវិទ្យា រូបវិទ្យា គណិតវិទ្យា និងស្ថិតិ ជាដើម។

អ្នកបច្ចេកទេសខាងផ្នែកនេះ ភាគច្រើនមានកម្រិតអប់រំទាបបំផុតត្រឹមថ្នាក់បរិញ្ញាបត្រលើឯកទេសរូបវិទ្យា និងវិទ្យាសាស្ត្រផែនដី។ អ្នកភូគព្ភសាស្ត្រខ្លះមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ជាពិសេសសំដៅដល់អ្នកដែលមានអាជីពជាអ្នកស្រាវជ្រាវ និងបង្រៀន។ ក្រៅពីនេះសញ្ញាបត្រថ្នាក់បណ្ឌិតក៏មានដែរ ប៉ុន្តែច្រើនសំដៅដល់អ្នកដែលដឹកនាំ និងគ្រប់គ្រងគ្រឹះស្ថានអប់រំ ឬកិច្ចការជំនួញផ្នែកនេះ។

### Kry l dgi

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

វិទ្យាសាស្ត្រផែនដី និងភូមិវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកគីមីវិទ្យា អ្នកបច្ចេកទេសខាងរ៉ែត្បូងថ្ម

អ្នកជំនាញខាងស្រាវជ្រាវពីលោហធាតុ

អ្នកភូមិសាស្ត្រ វិស្វកររ៉ែ អ្នករូបវិទ្យា និង

អ្នកជំនាញខាងប្រេងកាត ជាដើម។

# អ្នករចនាគំនូរក្រាហ្វិក

( Graphic designers )

**សង្ខេបអំពីជំនាញ**

**អ្នករចនាគំនូរក្រាហ្វិកធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ ជួយការងារដល់ភ្ញៀវ ឬអតិថិជន

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត

✦ ការដោះស្រាយបញ្ហា

✦ ការនិយាយ និងការស្តាប់

## តើអ្នករចនាគំនូរក្រាហ្វិកបំពេញកិច្ចការអ្វីខ្លះ?

G អ្នករចនាគំនូរក្រាហ្វិក (graphic designers) ធ្វើគម្រោងដើម្បីរៀបចំកិច្ចការរចនាតាមបែបសិល្បៈ និងរៀបរចនាអក្សរសម្រាប់បោះពុម្ពក្នុងសៀវភៅ ទស្សនាវដ្តី កម្មវិធីទូរទស្សន៍ ការផ្សាយពាណិជ្ជកម្ម រចនាស្លាកសញ្ញាសម្រាប់ទំនិញ និងរចនាគេហទំព័រ ជាដើម។

អ្នករចនាគំនូរក្រាហ្វិកតែងទទួលនូវវត្ថុសម្រាប់រចនាពីអ្នកបោះពុម្ព អ្នកនិពន្ធ អ្នកថតរូប និងអ្នកកុម្មង់ផ្សេងៗទៀត។ អ្នករចនាគំនូរក្រាហ្វិកត្រូវគិតតម្រូវស្នាដៃសិល្បៈរបស់ខ្លួនទៅតាមស្ថានភាព និងមហាជន ដោយលៃលកធ្វើបទបង្ហាញនូវស្នាដៃសិល្បៈរបស់ខ្លួនតាមរូបភាព ឬវិធីផ្សេងៗ។ ពួកគេក៏មានភារៈក្នុងការកំណត់នូវគោលគំនិតសំខាន់ៗរបស់អត្ថបទ ឬស្នាដៃផងដែរ ដូចជាចំណងជើងរបស់អត្ថបទ ឬស្លាកឈ្មោះរបស់ផលិតផលខ្លះ។ អ្នករចនាត្រូវកំណត់ពីគំរូ និងខ្នាតរបស់អក្សរ ព្រមទាំងពណ៌នានាដែលត្រូវប្រើប្រាស់។

សម្រាប់អ្នករចនាដែលបម្រើការឱ្យភ្នាក់ងារសារព័ត៌មាន ឬទស្សនាវដ្ដីដែលមានឈ្មោះបោះសម្ល្ងរួចហើយ ពួកគេត្រូវគោរពទៅតាមគំរូ ឬរចនាបថដែលមានពីមុនមក ដោយពុំចាំបាច់ធ្វើថ្មីនោះឡើយ។ អ្នករចនាគំនូរក្រាហ្វិកខ្លះទៀតធ្វើនិមិត្តសញ្ញាសម្រាប់ក្រុមហ៊ុន ឬគួរតាពាង និងក្រាហ្វិកផ្សេងៗសម្រាប់អត្ថបទពាក់ព័ន្ធនឹងស្ថិតិ។

សូមបញ្ជាក់ថា កិច្ចការរចនាគឺជាដំណើរការមួយដែលត្រូវបន្តធ្វើជាដំណាក់កាលៗ។ ឧទាហរណ៍ នៅពេលរចនាគម្របសៀវភៅមួយ អ្នករចនាត្រូវការគិត និងធ្វើគំនូរព្រាងជាច្រើនលើកច្រើនសារ មុននឹងអាចសម្រេចបានលទ្ធផលមួយដែលមានលក្ខណៈល្អគ្រប់ជ្រុងជ្រោយ ហើយដាក់ឱ្យអតិថិជន ឬអ្នកកុម្មង់ពិនិត្យសម្រេច។ អ្នករចនាអាចនឹងធ្វើការជ្រើសរើសនូវគំរូណាមួយដែលមានស្រេច ឬក៏ទទួលការកុម្មង់ពីអតិថិជនដើម្បីតម្រូវទៅតាមចិត្ត និងការចង់បាន។ បន្ទាប់ពីទទួលបានការកុម្មង់ និងសម្រេចលើគំរូម៉ូតរួចហើយ អ្នករចនាត្រូវខិតខំធ្វើកិច្ចការរបស់ខ្លួនឱ្យបានរហូតទាល់តែបញ្ចប់រួចរាល់ និងសមតាមបំណងរបស់ភ្ញៀវទើបចាត់ចែងបោះពុម្ព បង្ហាញតាមកុំព្យូទ័រ និងភាពយន្ត ជាដើម។



ជម្មតា វិធីក្នុងការរចនាមិនដូចគ្នាទេ ឧទាហរណ៍ អ្នករចនាដែលធ្វើកិច្ចការក្នុងវិស័យភាពយន្តរចនាអក្សរ និងបញ្ជីរាយឈ្មោះរបស់តួអង្គ ឬអ្នកឧបត្ថម្ភជាដើម ដើម្បីដាក់បង្ហាញនៅលើកញ្ចក់ ឬផ្ទាំងសំពត់ស (screen)។ ក្រៅពីនេះ ពួកគេក៏ត្រូវធ្វើកិច្ចការពាក់ព័ន្ធនឹងគំនូរជីវចល ផែនទី និងតារាងនានាផងដែរ។ ដោយឡែក សម្រាប់ការរចនាស្លាកសញ្ញាផលិតផលវិញ អ្នករចនាត្រូវរិះគិតនូវវិធីក្នុងការបង្ហាញអំពីភាពទាក់ទាញតាមបែបសិល្បៈ ដើម្បីធ្វើឱ្យអតិថិជនងាយមើលឃើញ និងចំណាំ។ ចំណែកឯ ការរចនាគេហទំព័រវិញ អ្នករចនាត្រូវមានភាពជំនាញកាន់តែខ្លាំងជាងការរចនាគំរូផ្សេងៗ អាស្រ័យដោយជាប្រភេទការងារមានការពាក់ព័ន្ធជាមួយនឹងកម្មវិធីកុំព្យូទ័រ (software) រូបភាព និងការរៀបចំដទៃទៀត។

សម្រាប់ទីផ្សារការងារ គេសង្កេតឃើញថាអ្នករចនាអាចបម្រើការឱ្យក្រុមហ៊ុន ឬស្ថាប័នណាមួយតាមឯកទេស និងកិច្ចការដូចបានពោលខាងលើ។ ម្យ៉ាងទៀត អ្នកខ្លះបានចាប់យកអាជីពជាអ្នករចនាឯករាជ្យ និងចុះកិច្ចសន្យាជាលក្ខណៈឯកជនតាមគម្រោងនីមួយៗ ដោយមិនសំដៅតែការធ្វើការតែមួយកន្លែងនោះឡើយ។

## ការអប់រំ និងការបណ្ដុះបណ្ដាល

G មុខវិជ្ជាមូលដ្ឋានដ៏សំខាន់សម្រាប់ជំនាញជាអ្នករចនាគឺ គណិតវិទ្យា សិល្បៈ សារព័ត៌មាន និងវិទ្យាសាស្ត្រកុំព្យូទ័រ ជាដើម។ គេក៏កត់សម្គាល់ផងដែរថានិយោជកហាក់មានទំនោរក្នុងការជួលអ្នករចនាទាំងឡាយណា ដែលមានសញ្ញាបត្រជាក់លាក់ខាងជំនាញរចនា។

ប្រសិនអ្នកមានចំណូលចិត្តក្នុងការងារបែបរចនា អ្នកគួរតែចាប់ផ្ដើមគិតបន្តការសិក្សាជំនាញនេះនៅតាមគ្រឹះស្ថានអប់រំណាមួយដែលមានបង្រៀនមុខវិជ្ជានេះ បន្ទាប់ពីអ្នកបានបញ្ចប់មធ្យមសិក្សាទុតិយភូមិ ដើម្បីទទួលបានបរិញ្ញាបត្រ និងសញ្ញាបត្រឯកទេស។ នៅប្រទេសកម្ពុជា គេសង្កេតឃើញមានគ្រឹះស្ថានអប់រំជាច្រើនដែលផ្ដល់នូវកម្មវិធីសិក្សាជំនាញរចនា ដែលរួមបញ្ចូលទាំងកម្រិតមហាវិទ្យាល័យ អប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ព្រមទាំងការបណ្ដុះបណ្ដាលជាវគ្គខ្លីៗនៅតាមអង្គការមិនមែនរដ្ឋាភិបាល ឬភ្នាក់ងារ



តទៅទំព័របន្ទាប់

ឯកជនតូចៗក៏មាន។

ដោយសារជំនាញកុំព្យូទ័រមានសារសំខាន់នៅក្នុងវិស័យបច្ចេកវិទ្យានាពេលបច្ចុប្បន្ន ដូច្នេះអ្នករចនាទាំងអស់គួរមានចំណេះដឹងក្នុងផ្នែកនេះឱ្យបានច្រើនទើបជាការប្រសើរ។

## Kry I dgi

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

សិល្បៈ ប្រវត្តិសិល្បៈ វិទ្យាសាស្ត្រកុំព្យូទ័រ

✦ កម្រិតអប់រំទាបបំផុត:

សិក្សាឯកទេសខាងរចនា ឬបរិញ្ញាបត្រ (កាន់តែប្រសើរ)

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

អ្នកដឹកនាំផ្នែកសិល្បៈ

សិល្បករ អ្នកថតរូប

អ្នកនិពន្ធ និងអ្នករចនាគេហទំព័រ ។ល។

## etIGkdgbeT?

កម្មវិធីកុំព្យូទ័រសម្រាប់ការរចនាមានការវិវត្ត និងផ្លាស់ប្តូរជានិរន្តរ៍ ដូច្នេះអ្នករចនាគួរគិតបំប៉នចំណេះ និងជំនាញរបស់ខ្លួនឱ្យបានទាន់សភាពការណ៍ ដើម្បីតម្រូវទៅតាមសេចក្តីត្រូវការរបស់អតិថិជន និងទីផ្សារដែលកំពុងតែមានការប្រកួតប្រជែងយ៉ាងខ្លាំង។

# វិស្វករមេកានិច

(Mechanical Engineers)

សង្ខេបអំពីជំនាញ

វិស្វករមេកានិចធ្វើការងារ៖

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

✦ ធ្វើកិច្ចការជាក្រុម

G

ជំនាញដែលត្រូវការប្រើ៖

✦ គណិតវិទ្យា

✦ ការដោះស្រាយបញ្ហា

✦ ការអាន និងសរសេរ

## តើវិស្វករមេកានិចបំពេញកិច្ចការអ្វីខ្លះ?

G វិស្វករមេកានិចរៀបចំផែនការ និងធ្វើការរចនានូវឧបករណ៍នានា គ្រឿងម៉ាស៊ីននិងគ្រឿងយន្ត ព្រមទាំងផលិតផលទាក់ទងនឹងប្រព័ន្ធមេកានិចផ្សេងទៀត ដែលបង្កើត និងបញ្ជូនថាមពល ឬកម្លាំងថាមពល។ ពួកគេច្រើនធ្វើការក្នុងវិស័យមួយចំនួនមានដូចជា ការរចនាគំរូឧបករណ៍ ការបង្កើតនូវសម្ភារ ការពិសោធន៍ ការធ្វើមនុស្សយន្ត ឬក៏ខាងវិស័យគមនាគមន៍ ជាដើម។

ជំនាញវិស្វកម្មមេកានិច គឺជាជំនាញដែលមានលក្ខណៈទូលំទូលាយជាងគេនៅក្នុងចំណោមវិស័យ ឬឯកទេសវិស្វកម្មដទៃទៀត។ ហេតុនេះ គេសង្កេតឃើញថា វិស្វករ

ខ្លះមានជំនាញខាងរចនាគំរូម៉ូតរបស់វត្ថុ (design engineers) ដែលមានតួនាទីក្នុងការគិត រចនា និងអភិវឌ្ឍនូវគ្រឿងយន្ត ព្រមទាំងគ្រឿងម៉ាស៊ីនថ្មីៗ។ ចំណែកឯវិស្វករមួយជំពូកផ្សេងទៀតមានតួនាទីជាអ្នករៀបចំធ្វើតេស្តសាកល្បងនូវឧបករណ៍នានាដែលបានផលិតរួចហើយ ដើម្បីធ្វើការបញ្ជាក់ថាឧបករណ៍ទាំងនោះមានដំណើរការត្រឹមត្រូវ និងមានគុណភាពតាមកម្រិតស្តង់ដារដែលបានកំណត់។

សម្រាប់វិស្វករខាងកម្មន្តសាល (manufacturing engineers) វិញតែងផ្តោតជាសំខាន់ទៅលើការផលិត និងបង្កើតនូវផលិតផលសម្រេចជាច្រើនប្រភេទក្នុងវិស័យឧស្សាហកម្ម។ ពួកគេធ្វើការជ្រើសរើស និងកែសម្រួលឧបករណ៍ រៀបចំមូលដ្ឋានគ្រឹះសម្រាប់តម្លើងរោងចក្រ វាយតម្លៃការចំណាយសម្រាប់កម្លាំងពលកម្ម និងគ្រឿងម៉ាស៊ីន។ វិស្វករខាងការថែទាំ និងប្រតិបត្តិការសម្ភារ (maintenance and operation engineers) ធ្វើការពិនិត្យតាមដាននូវដំណើរការរបស់ប្រព័ន្ធមេកានិចទាំងមូលដូចជា ប្រព័ន្ធនៃការផលិតថាមពលអគ្គិសនីដោយប្រើបច្ចេកវិទ្យានុយក្លេអែរ ដើម្បីធានាឱ្យបាននូវដំណើរការដោយរលូន និងមានសុវត្ថិភាព។

ទោះបីជា វិស្វករមេកានិចត្រូវបានបែងចែកជាជំនាញផ្សេងៗគ្នាហើយក៏ដោយ ប៉ុន្តែក្នុងនោះក៏នៅមានការបែងចែកជាឯកទេសបន្តបន្ទាប់ទៀត មានដូចជា អ្នកឯកទេសខាងថាមពល (energy specialists) ដែលធ្វើការផ្នែកផ្គត់ផ្គង់ថាមពលប្រកបដោយសុវត្ថិភាព ជៀសវាងការបំពុលបរិដ្ឋាន និងគ្មានគ្រោះថ្នាក់ទៅដល់លំនៅដ្ឋាន និងរោងចក្រសហគ្រាសនានា។ រីឯវិស្វករខាងកម្មវិធី (application engineers) មានឯកទេសខាងការរចនាប្រព័ន្ធដំណើរការរបស់រោងចក្រ ឬក៏កម្មន្តសាលដោយប្រើកម្មវិធីកុំព្យូទ័រ។ មានវិស្វករមួយជំពូកផ្សេងទៀត ធ្វើការក្នុងឯកទេសជាអ្នកគ្រប់គ្រងកាកសំណល់ជាតិពុលដែលបានបញ្ចេញពីរោងចក្រ ដើម្បីកុំឱ្យមានគ្រោះថ្នាក់ទៅដល់បរិដ្ឋាន និងមនុស្សសត្វរុក្ខជាតិនានា។



គេកត់សម្គាល់ឃើញថា វិស្វករមេកានិចភាគច្រើនធ្វើការងារនៅក្នុងការិយាល័យ មន្ទីរពិសោធន៍ និងគ្រប់គ្រងដំណើរការគ្រឿងយន្តក្នុងរោងចក្រ។ ពេលខ្លះទៀត ពួកគេត្រូវចុះជាប់ជាមួយការងារនៅកន្លែងការដ្ឋានសាងសង់របស់រោងចក្រក៏មាន។



## ការអប់រំ និងការបណ្តុះបណ្តាល

G ដើម្បីរៀបចំខ្លួនចូលទៅទីផ្សារការងារ និងអាជីពជាវិស្វករមេកានិច អ្នកគួរត្រៀមខ្លួនតាំងពីការសិក្សានៅវិទ្យាល័យ ដោយខំរៀនមុខវិជ្ជាគណិតវិទ្យា ជាពិសេសចំណេះផ្នែកធរណីមាត្រ និងខ្សែកោង (algebra) រូបវិទ្យា និងគីមីវិទ្យា។ ក្រៅពីនេះគួររៀនមុខវិជ្ជាខាងការរចនា ឬគំនូរនៅក្នុងកុំព្យូទ័រ។ សម្រាប់ការទំនាក់ទំនងជាមួយអតិថិជន និងក្នុងវង្វង់ការងារឱ្យមានប្រសិទ្ធភាព អ្នកគួររៀនមុខវិជ្ជាផ្នែកទំនាក់ទំនង ភាសាបរទេស ជំនាញក្នុងការធ្វើបទបង្ហាញទើបជាការប្រសើរ។



បន្ទាប់ពីបញ្ចប់មធ្យមសិក្សាទុតិយភូមិ អ្នកគួរជ្រើសរើសចូលរៀននៅគ្រឹះស្ថានអប់រំណាមួយតាមសមត្ថភាព និងចំណូលចិត្ត។ ដើម្បីទទួលបានបរិញ្ញាបត្រវិស្វករ អ្នកត្រូវការពេលវេលាយ៉ាងហោចណាស់បួនឆ្នាំ ហើយអាចបន្តការសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតទៀតក៏បាន ដែលកម្រិតចុងក្រោយនេះច្រើនសំដៅដល់តួនាទីជាអ្នកស្រាវជ្រាវ សាស្ត្រាចារ្យ និងកិច្ចការគ្រប់គ្រង។


តទៅទំព័របន្ទាប់

## Kry l dgi

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

វិទ្យាសាស្ត្រកុំព្យូទ័រ និងគណិតវិទ្យា

✦ កម្រិតអប់រំទាបបំផុត:

បរិញ្ញាបត្រ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

វិស្វករអគ្គិសនី និងអេឡិចត្រូនិច

វិស្វករ និងអ្នកបច្ចេកទេសជាន់ខ្ពស់ខាងឧស្សាហកម្ម

វិស្វករនុយក្លេអ៊ែរ និង

អ្នកបច្ចេកទេសជាន់ខ្ពស់ខាងជំនាញមេកានិច។ល។

## ចៅក្រម

(Judges)

**សង្ខេបអំពីជំនាញ**

**ចៅក្រមធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ ប្រើប្រាស់ភាពជាអ្នកដឹកនាំ

G

**ជំនាញដែលត្រូវការប្រើ៖**

✦ សេចក្តីសម្រេចចិត្ត

✦ ការអាន និងសរសេរ

✦ ការនិយាយ និងស្តាប់

## etGkdgbeT?

បច្ចុប្បន្ននេះ កម្ពុជាកំពុងតែបោះជំហានសន្សឹមៗទៅកាន់ការអភិវឌ្ឍប្រទេសបែបឧស្សាហូបនីយកម្ម ដោយប្រែក្លាយពីការពឹងផ្អែកភាគច្រើនតែលើ វិស័យកសិកម្ម។

ដូច្នេះ ក្នុងដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច និងមូលដ្ឋានគ្រឹះរបស់វិស័យឧស្សាហកម្ម កម្ពុជាកំពុងត្រូវការជាចាំបាច់នូវធនធានមនុស្ស ដែលមានជំនាញផ្នែកបច្ចេកទេសគ្រប់ប្រភេទ ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍប្រទេស។

## តើចៅក្រមបំពេញកិច្ចការអ្វីខ្លះ?

*G ចៅក្រមមានតួនាទីធ្វើជាអធិបតីនៅក្នុងអង្គសវនាការ ដើម្បីដោះស្រាយរាល់វិវាទទាំងពួង ហើយផ្តល់នូវឱវាទទៅដល់មេធាវី ក្រុមអាជ្ញាកណ្តាល ព្រមទាំងមហាជននានាពាក់ព័ន្ធនឹងករណីបណ្តឹងផ្នែកច្បាប់។ នៅប្រទេសកម្ពុជា ចៅក្រមត្រូវតែងតាំងឡើងដោយព្រះរាជក្រឹត្យ។*

*ចៅក្រមអាចចាប់ផ្តើមអាជីពដំបូងជាមេធាវី បន្ទាប់មកអាចបន្តការបណ្តុះបណ្តាលនៅឯ សាលាភូមិន្ទចៅក្រម* (Royal School of Judges) *មុននឹងអាចក្លាយជាចៅក្រម។ អ្នកខ្លះទៀត អាចចាប់ផ្តើមចេញពីការងារជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យ។*

ចៅក្រមនៃអង្គជំនុំជម្រះ (trial judges) ធ្វើជាអធិបតីនៅក្នុងអង្គសវនាការ និងធ្វើសេចក្តីសម្រេចចិត្តចំពោះចម្ងល់ទាំងឡាយពាក់ព័ន្ធបញ្ហាច្បាប់។ ចៅក្រមក៏មានអំណាចផងដែរក្នុងការកំណត់ និងអនុញ្ញាតទៅលើភ័ស្តុតាងនានាដែលត្រូវលើកយកមកប្រើនៅក្នុងអង្គជំនុំជម្រះ។ បន្ទាប់ពីបានឮ និងឃើញភ័ស្តុតាង ចៅក្រមអាចធ្វើសេចក្តីសម្រេចថាមានទោស ឬមិនមានទោសនៅក្នុងសំណុំរឿងនីមួយៗ។

ចំណែកឯចៅក្រមសាលាឧទ្ធរណ៍ (appellate judges) មានតួនាទីបើកនូវសវនាការលើករណីបណ្តឹងឧទ្ធរណ៍ចំពោះសំណុំរឿងដែលបានកាត់ក្តីរួចរាល់ហើយដោយសាលាដំបូង ដើម្បីពិនិត្យមើលថាការកាត់ក្តីនោះពិតជាត្រឹមត្រូវតាមមាត្រានៃច្បាប់ ឬអត់។ ហេតុនេះ មេធាវី និងកូនក្តីអាចធ្វើបណ្តឹងទៅសាលាឧទ្ធរណ៍ ដើម្បីស្នើសុំសើរើនូវសាលក្រមរបស់ចៅក្រមសាលាដំបូង។

ដោយឡែក ចៅក្រមតុលាការកំពូល (supreme court judges) ជាតុលាការដែលមានអំណាចធំជាងគេក្នុងការធ្វើសេចក្តីសម្រេចលើសាលក្រម និងពិនិត្យលើសាលក្រមក្នុងករណីមានការរំលោភលើមាត្រានៃច្បាប់ ជាពិសេសច្បាប់កំពូលរបស់ប្រទេស ពោលគឺរដ្ឋធម្មនុញ្ញ។



អគារតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជាស្ថិតនៅជិតព្រះបរមរាជវាំង

## ការអប់រំ និងការបណ្តុះបណ្តាល

G ដើម្បីតម្រង់ទិសអាជីព និងក្លាយខ្លួនជាចៅក្រមមួយរូប អ្នកត្រូវត្រង់ត្រាប់រៀននូវមុខវិជ្ជាសំខាន់ៗមួយចំនួនចាប់តាំងពីការសិក្សានៅកម្រិតវិទ្យាល័យឱ្យហើយទៅ ពោលគឺត្រូវព្យាយាមរៀនមុខវិជ្ជាពាក់ព័ន្ធរដ្ឋាភិបាល និងការគ្រប់គ្រង ប្រវត្តិសាស្ត្រ សិក្សាសង្គម សេដ្ឋកិច្ច ភាសាបរទេស និងការហាត់និយាយបែបថ្លែងសុន្ទរកថា ទើបជាការប្រសើរ។ យ៉ាងហោចណាស់ តួនាទីជាចៅក្រមត្រូវមានសញ្ញាបត្រកម្រិតបរិញ្ញាបត្រលើជំនាញមួយចំនួន ដូចជាៈ ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រនយោបាយ និងភាសាបរទេស ជាដើម។ បន្ទាប់មក អ្នកត្រូវចូលរៀន និងមានសញ្ញាបត្រពីសាលាភូមិន្ទចៅក្រម។

នៅក្នុងអំឡុងពេលសិក្សាមានមុខវិជ្ជាច្បាប់មួយចំនួនដែលត្រូវរួមបញ្ចូលដូចជា ច្បាប់កិច្ចសន្យា ច្បាប់ព្រហ្មទណ្ឌ ច្បាប់ស្តីពីមរតក ជាដើម។ បន្ថែមលើនេះ សិស្សត្រូវសិក្សាទៅលើករណីនៃសំណុំរឿងជាច្រើន ដើម្បីជាការអនុវត្ត និងអាចជាជម្រើសមួយសម្រាប់ពួកគេចាប់យកជំនាញឯកទេសជាក់លាក់មួយមុនពេលបញ្ចប់ការសិក្សា។

អ្នកដែលទើបបញ្ចប់ការសិក្សាថ្មីៗ ហើយមិនទាន់មានបទពិសោធន៍អាចធ្វើកម្មសិក្សាជាមួយភ្នាក់ងារផ្តល់សេវាផ្នែកច្បាប់ណាមួយ ដើម្បីហាត់រៀនពីករណីនៃសំណុំរឿងជាក់ស្តែងមុននឹងអាចក្លាយខ្លួនទៅជាចៅក្រមអាជីព។ សូមបញ្ជាក់ថា អាជីពជាអ្នកច្បាប់ ឬចៅក្រមត្រូវការពេលវេលាដ៏សមគួរមួយក្នុងការកសាងនូវកិត្តិនាម បទ-




តទៅទំព័របន្ទាប់

ពិសោធន៍ និងទំនុកចិត្តពីអតិថិជនដែលប្រើប្រាស់សេវាប្រឹក្សាយោបល់ ឬកិច្ចគាំពារផ្នែកច្បាប់។

ក្រៅពីនេះ ចៅក្រមក៏ត្រូវការបំប៉នបន្ថែមនូវចំណេះ និងជំនាញរបស់ខ្លួនឱ្យស្របទៅតាមការវិវត្តរបស់សង្គម ការធ្វើវិសោធនកម្មចំពោះមាត្រាច្បាប់ និងការលេចចេញនូវសំណុំរឿងថ្មីៗ។



## Kry I dgi

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

រដ្ឋាភិបាល និងការធ្វើបទបង្ហាញ ឬសុន្ទរកថា

✦ កម្រិតអប់រំទាបបំផុត:

បរិញ្ញាបត្រ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

មេធាវី មន្ត្រីប៉ូលីស និង

អ្នកនាំពាក្យក្នុងអង្គសវនាការ ជាដើម។



## etGkdgbeT?

ពេលបំពេញកិច្ចការក្នុងតុលាការចៅក្រមត្រូវ៖

- បំពេញកិច្ចការប្រកបដោយវិរិយភាព
- មានភាពទៀងត្រង់ និងយុត្តិធម៌
- ប្រតិបត្តិច្បាប់ឱ្យបានម៉ឺងម៉ាត់
- ផ្តល់នូវសមភាពនៃទណ្ឌកម្មចំពោះជនដែលធ្វើអំពើល្មើសដូចគ្នា
- សម្រេចសេចក្តីប្រកបដោយបញ្ញា និងភាពឆ្លាតវៃ

# មេធាវី

(Lawyers)

សង្ខេបអំពីជំនាញ

មេធាវីធ្វើការងារ៖

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

G

ជំនាញដែលត្រូវការប្រើ៖

✦ ការដោះស្រាយបញ្ហា

✦ ការអាន និងសរសេរ

✦ ការនិយាយ និងស្តាប់

## តើមេធាវីបំពេញកិច្ចការអ្វីខ្លះ?

G មេធាវី មានតួនាទីផ្តល់នូវការប្រឹក្សាយោបល់ទៅដល់អតិថិជន ឬមនុស្សនានាក្នុងការប្រព្រឹត្តនូវអំពីផ្សេងៗដែលអាច និងដែលមិនអាច ដោយយោងទៅតាមបទប្បញ្ញត្តិដែលមាននៅក្នុងច្បាប់។ ពួកគេអាចពន្យល់ទៅដល់មនុស្សទាំងពួងនូវសិទ្ធិតាមផ្លូវច្បាប់ និងតាមរដ្ឋធម្មនុញ្ញ ហើយការពារជនទាំងនោះនៅក្នុងតុលាការ ឬក៏ជួយសេវាផ្នែកច្បាប់ដល់ក្រុមហ៊ុននានាឱ្យមានភាពត្រឹមត្រូវ និងមានភាពស្របច្បាប់។

អតិថិជន (កូនក្តី) ដែលប្រើប្រាស់សេវាមេធាវីអាចមានទម្រង់ជាបុគ្គល ឬក៏ជាក្រុម ដូចជាក្រុមហ៊ុន ឬក្រុមមនុស្សដែលមានបញ្ហាផ្នែកច្បាប់ ជាដើម។

ក្នុងចំណោមសេវាផ្នែកច្បាប់ ដែលមេធាវីផ្តល់ទៅឱ្យអតិថិជនរបស់គេមានដូចជា ករណីពន្ធអាករ កិច្ចសន្យាទិញដូរ ឬលក់ ការធ្វើបណ្តាំមរតក ធ្វើលិខិតលែងលះ ។ល។ ជា

ទូទៅ មេធាវីតែងមានជំនាញឯកទេសជាក់លាក់មួយរបស់ខ្លួនដូចជា ច្បាប់ស្តីពីពន្ធអាករ ច្បាប់ស្តីពីអចលនវត្ថុ ច្បាប់ស្តីពីកម្មសិទ្ធបញ្ញា ឬក៏ច្បាប់ព្រហ្មទណ្ឌ ជាដើម។

មេធាវីផ្នែកពន្ធអាករ ធ្វើកិច្ចការពាក់ព័ន្ធនឹងករណីបង់ពន្ធទៅប្រាក់ចំណូល ទ្រព្យសម្បត្តិ និងជំនួញ។ ចំណែកមេធាវីផ្នែកអចលនទ្រព្យ ធ្វើកិច្ចការអំពីការគ្រប់គ្រងកម្មសិទ្ធ និងការលក់ទិញនានា។ ក្រៅពីនេះ គេឃើញមានមេធាវីដែលការពារក្តីច្រើនប្រភេទទៀតដូចជា មេធាវីការពារក្តីពាក់ព័ន្ធច្បាប់សមុទ្ទ មេធាវីការពារក្តីផ្នែកសំណង់ មេធាវីការពារក្តីផ្នែកការជំពាក់បំណុល មេធាវីការពារក្តីផ្នែកឧក្រិដ្ឋកម្ម។

ការពិត មេធាវីម្នាក់អាចការពារក្តីឱ្យករណីផ្សេងៗក្នុងទិដ្ឋភាពនៃច្បាប់មួយ ឬច្រើន ដរាបណាគេមានអាជ្ញាបណ្ណដែលផ្តល់ឱ្យដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ មេធាវីខ្លះអាចការពារក្តីទាំងករណីស៊ីវិល និងករណីឧក្រិដ្ឋ។ ក្នុងអាជីពជាមេធាវី ពួកគេអាចបន្តក្លាយជាសាស្ត្រាចារ្យ ចៅក្រម អ្នកនយោបាយ ឬក៏ជាអ្នកជំនួញក៏មាន។



## ការអប់រំ និងការបណ្តុះបណ្តាល

G មេធាវីគួរសិក្សាមុខវិជ្ជាមួយចំនួនពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាល វិទ្យាសាស្ត្រនយោបាយ ការធ្វើសុន្ទរកថា វិទ្យាសាស្ត្រកុំព្យូទ័រ ប្រវត្តិសាស្ត្រ និងភាសាបរទេស។ នៅប្រទេសកម្ពុជា និស្សិតអាចសិក្សានៅមហាវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បន្ទាប់មកប្រឡងចូលសាលាវិជ្ជាជីវៈមេធាវី ដើម្បីទទួលបានអាជ្ញាបណ្ណជាមេធាវីស្របច្បាប់មួយរូប។

ជម្មតា មេធាវីដែលទើបចាប់ផ្តើមវិជ្ជាជីវៈថ្មីថ្មោងតែងចូលទៅធ្វើការជាមួយមេធាវី ដែលមានបទពិសោធន៍យូរនៅក្នុងអាជីព ដើម្បីហាត់ដោះស្រាយរឿងក្តី និងសន្សំបទពិសោធន៍ឱ្យបានច្រើន មុននឹងអាចចេញប្រកបអាជីវកម្មដោយខ្លួនឯងបាន។ បន្ថែមលើនេះ មេធាវីក៏នៅតែបន្តការសិក្សាស្រាវជ្រាវជាប់ជានិច្ចនៅក្នុងអាជីពរបស់ខ្លួនពាក់ព័ន្ធជាមួយករណីរឿងក្តីថ្មីៗ ព្រមទាំងបទដ្ឋានគតិយុត្តថ្មីដែលទើបត្រូវបានបង្កើត។

### Kry I dgi

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ច្បាប់

រដ្ឋបាល និងរដ្ឋាភិបាល

ភាសាបរទេស

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

ចៅក្រម

អ្នកនាំពាក្យក្នុងអង្គសវនាការ

ជំនួយការផ្នែកច្បាប់ និង

ជំនួយការមេធាវី ជាដើម។

### etIGkdgbeT?

ភារៈកិច្ច និងការបំពេញកិច្ចការសំខាន់ៗរបស់មេធាវីត្រូវ:

- ចូលរួមបម្រើវិស័យយុត្តិធម៌
- តំណាងកូនក្តីតាមការយល់ព្រមពីកូនក្តី ឬជួយការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធី


តទៅទំព័របន្ទាប់

- ផ្តល់យោបល់ និងតាក់តែងលិខិតស្នាមផ្សេងៗក្នុងវិស័យគតិយុត្ត
- ផ្សះផ្សា ឬសម្រុះសម្រួល ឬជាអាជ្ញាកណ្តាល (ករណីមានការចាត់តាំងដោយគូភាគី ឬចៅក្រមអនុញ្ញាត ឬច្បាប់អនុញ្ញាត)
- ដោះស្រាយបញ្ហាដោយបញ្ញា និងភាពឆ្លាតវៃ



*អគារតុលាការរាជធានីភ្នំពេញ និងជាការិយាល័យគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។*

# អ្នកវិទ្យាសាស្ត្រផ្នែកកសិកម្ម

( Agricultural Scientists )

**សង្ខេបអំពីជំនាញ**

**អ្នកវិទ្យាសាស្ត្រផ្នែកកសិកម្មធ្វើការងារ៖**

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ បង្កើត ឬបង្កើនប្រព័ន្ធដំណើរការ

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការដោះស្រាយបញ្ហា

✦ ការពិចារណា ឬធ្វើកិច្ចការប្រកបដោយហេតុផល

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត

## តើអ្នកវិទ្យាសាស្ត្រផ្នែកកសិកម្មបំពេញកិច្ចការអ្វីខ្លះ?

G ជាទូទៅ អ្នកវិទ្យាសាស្ត្រផ្នែកកសិកម្មធ្វើការសិក្សាស្រាវជ្រាវអំពីរុក្ខជាតិ និងសត្វនៅក្នុងបរិដ្ឋានធម្មជាតិដែលគេរស់នៅ។ ការស្រាវជ្រាវអាចធ្វើឡើងនៅក្នុងមន្ទីរពិសោធន៍ ឬនៅកន្លែងផ្ទាល់ក្នុងធម្មជាតិ។ តាមរយៈលទ្ធផលដែលបានមកពីការសិក្សា ពួកគេអាចប្រើប្រាស់វាសម្រាប់ជាវិធីក្នុងការជួយបង្កើនទិន្នផលកសិកម្ម និងរក្សាលំនឹងបរិដ្ឋានផងដែរ។ ក្រៅពីនេះ ពួកគេក៏មានកម្មវិធី ឬគម្រោងក្នុងការរៀបចំពិសោធន៍ចំពោះចំណីអាហារ ឱសថ ឬថ្នាំសត្វ ព្រមទាំងផលិតផលជាច្រើនមុខផ្សេងទៀត។

អ្នកវិទ្យាសាស្ត្រផ្នែកនេះខ្លះអាចបម្រើការនៅក្នុងសួនសត្វ ដែលទទួលបន្ទុកការរៀបចំដាក់តាំងបង្ហាញសត្វ រុក្ខជាតិ និងឧទ្យានទាំងមូលទៅដល់សាធារណជន។ អ្នកខ្លះកាន់តួនាទីជាគ្រូបង្រៀននៅសាលាបច្ចេកទេសកសិកម្ម ឬសកលវិទ្យាល័យ ឬក៏ធ្វើជាអ្នកប្រឹក្សាយោបល់ក្នុងមុខជំនួញកសិកម្មនៅក្នុងវិស័យឯកជន ឬផ្នែករដ្ឋាភិបាល។ បន្ថែមលើនេះអ្នកវិទ្យាសាស្ត្រកសិកម្មខ្លះធ្វើការផ្នែកបម្រើសេវា ឬផ្នែកលក់នៅក្នុងក្រុមហ៊ុនដែលធ្វើផលិតផលកសិកម្ម។

គេកត់សម្គាល់ឃើញថា ប្រធាន ឬនាយកផ្នែកការស្រាវជ្រាវអំពីគម្រោងកសិកម្មក្នុងស្ថាប័នណាមួយ តែងមានកម្រិតសញ្ញាបត្រខ្ពស់ ដូចជាថ្នាក់បណ្ឌិតផ្នែកកសិកម្មជាដើម។ អ្នកវិទ្យាសាស្ត្រផ្នែកកសិកម្មភាគច្រើន ទោះបីជាបម្រើការនៅកន្លែងណា ឬទីណាក៏ដោយ ពួកគេតែងផ្តោតជាសំខាន់ទៅលើការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ជាមួយក្រុមអ្នកវិទ្យាសាស្ត្រ ឬវិស្វករផ្នែកកសិកម្ម។

អ្នកវិទ្យាសាស្ត្រផ្នែកកសិកម្មក៏ត្រូវបានបែងចែកជាឯកទេសផ្សេងៗគ្នាផងដែរ ឧទាហរណ៍ អ្នកបច្ចេកទេសផ្នែកដោះស្រាយបញ្ហា និងបង្កើនទិន្នផលស្រូវ ឬដំណាំធញ្ញជាតិ

 តទៅទំព័របន្ទាប់ 

(agronomist) ធ្វើការស្រាវជ្រាវទៅលើជម្ងឺរបស់ដំណាំ ថ្នាំសម្លាប់សត្វល្អិត គ្រាប់ធញ្ញជាតិ និងគុណភាព ឬប្រភេទរបស់ដីដែលតម្រូវទៅតាមដំណាំនីមួយៗ។ គោលបំណងនៃការសិក្សា គឺដើម្បីស្វែងរកវិធីក្នុងការបង្កើនកម្រិតលូតលាស់របស់រុក្ខជាតិ ទិន្នផល និងរសជាតិរបស់ដំណាំគ្រប់ប្រភេទ។

ដោយឡែក អ្នកវិទ្យាសាស្ត្រផ្នែកបង្កាត់ពូជសត្វ ឬរុក្ខជាតិ (horticulturists) ធ្វើការស្រាវជ្រាវអំពីពូជ រូបលក្ខណៈ និងធាតុផ្សំរបស់រុក្ខជាតិ ដើម្បីប្រែក្លាយឱ្យជាពូជល្អដែលមានគុណភាពខ្ពស់។ ពួកគេជួយជម្រុញ និងបង្កើនល្បឿន ទំហំ និងការធន់ទ្រាំទៅនឹងជម្ងឺក្នុងការលូតលាស់របស់ដំណាំមាន ដូចជា ពពួកផ្កា បន្លែ ផ្លែឈើ និងរុក្ខជាតិមើម ជាដើម។

រីឯ អ្នកដែលមានឯកទេសខាងថែរក្សាបសុសត្វវិញធ្វើការថែទាំសត្វនៅក្នុងជម្រក បង្កាត់ពូជ និងផ្តល់ចំណី។ ពួកគេព្យាយាមការពារជម្ងឺកុំឱ្យឆ្លងទៅកាន់សត្វ ដែលចិញ្ចឹមនៅក្នុងកសិដ្ឋាន។ ការសិក្សាខ្លះធ្វើការតាមដានពីដំណើរនៃការវិវឌ្ឍ និងរបបចំណីរបស់សត្វដែលចិញ្ចឹមយកទឹកដោះ។

## ការអប់រំ និងការបណ្តុះបណ្តាល

G អ្នកដែលចង់ក្លាយជាអ្នកវិទ្យាសាស្ត្រកសិកម្ម គួរចាប់ផ្តើមសិក្សានូវមុខវិជ្ជាសំខាន់ៗមួយចំនួនតាំងពីនៅវិទ្យាល័យ ដូចជា ភាសាបរទេស គណិតវិទ្យា ជីវវិទ្យា គីមីវិទ្យា រូបវិទ្យា ជាដើម។ ម្យ៉ាងទៀត គួររៀនជំនាញកុំព្យូទ័រ និងកម្មវិធីខ្លះៗទៀត។

បន្ទាប់ពីវិទ្យាល័យ គេគួរចូលរៀនយកបរិញ្ញាបត្រផ្នែកកសិកម្ម ដើម្បីទទួលបានជំនាញជាក់លាក់ណាមួយក្នុង វិស័យនេះ។ ប្រសិន ពួកគេមានបំណងក្លាយជាអ្នកស្រាវជ្រាវ ឬបង្រៀន គួរគិតបន្តការសិក្សាដល់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតទើបជាការប្រសើរ។ តាមរយៈការសិក្សាបន្តអាចអនុញ្ញាតឱ្យគេមានលទ្ធភាព និងចំណេះខ្ពង់ខ្ពស់ក្នុងការអនុវត្ត និងបង្កើតនូវការច្នៃប្រឌិតថ្មីៗពាក់ព័ន្ធកិច្ចកសិកម្ម។

### Kry I dgi

✦ មុខវិជ្ជាសិក្សាក្នុងសាលា៖
ជីវវិទ្យា និងគីមីវិទ្យា
✦ កម្រិតអប់រំទាបបំផុត៖
បរិញ្ញាបត្រ
✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា៖
អ្នកបច្ចេកទេសកសិពាណិជ្ជកម្ម
វិស្វករកសិកម្ម
អ្នកបច្ចេកទេសខាងការបង្កាត់ពូជ និង
អ្នកបច្ចេកទេសខាងគុណភាពដី ជាដើម។

## អ្នកឯកទេសគីមី

( Chemists )

សង្ខេបអំពីជំនាញ

អ្នកឯកទេសគីមីធ្វើការងារ៖

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ បង្រៀន
✦ ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

G

ជំនាញដែលត្រូវការប្រើ៖

✦ គណិតវិទ្យា
✦ ការដោះស្រាយបញ្ហា
✦ ការពិចារណា ឬធ្វើកិច្ចការប្រកបដោយហេតុផល


តទៅទំព័របន្ទាប់

## តើអ្នកឯកទេសគីមីបំពេញកិច្ចការអ្វីខ្លះ?

G គីមីវិទ្យា គឺសិក្សាអំពីរូបលក្ខណៈ និងសមាសធាតុគីមីរបស់វត្ថុ ឬអង្គធាតុ។ អ្នកឯកទេសគីមីរិះរកវិធីបង្កើនផលិតផល និងបង្កើតផលិតផលថ្មី ដូចជា ថ្នាំសង្កូវ វត្ថុធាតុផ្លាស្ទិក និងក្រណាត់។ ពួកគេក៏ធ្វើការផ្នែកថាមពល និងឥន្ទនៈ និងអភិវឌ្ឍនូវវត្ថុប្រើប្រាស់ជាលោហធាតុដែលទាញយកចេញពីសារធាតុរ៉ែជាច្រើនប្រភេទ ដូចជា អាលុយមីញ៉ូម ម៉ាញ៉េស្យូម និងទីតានីញ៉ូម ។ល។

អ្នកឯកទេសគីមីខាងម្ហូបអាហារ (food chemists) វិញ ខិតខំគិតបង្កើតនូវចំណីអាហារថ្មីៗ និងរិះរកវិធីរក្សាទុកឱ្យបានយូរ។ ពួកគេសិក្សាទៅលើវិធីសាស្ត្រក្នុងការចម្អិន វេចខ្ចប់ ដាក់កំប៉ុង និងបង្កក ដើម្បីកុំឱ្យប៉ះពាល់រសជាតិ រូបរាង និងគុណភាពរបស់ចំណីអាហារ។ បន្ថែមលើនេះ អ្នកគីមីម្ហូប-អាហារក៏ធ្វើការសាកល្បង និងពិសោធន៍នូវរាល់ផលិតផល ដើម្បីវាស់នូវកម្រិតស្តង់ដារ ដែលបានកំណត់ដោយស្ថាប័នមានសមត្ថកិច្ច។

អ្នកគីមីផ្នែកវិភាគ (analytical chemists) សិក្សាវិភាគអំពីសមាសធាតុរបស់វត្ថុ ឬធាតុផ្សំដែលប្រើសម្រាប់ផលិតសម្ភារផ្សេងៗ។ ពួកគេកំណត់ស្តង់ដារសុវត្ថិរបស់សារធាតុគីមីដែលប្រើនៅក្នុងម្ហូបអាហារ ភេសជ្ជៈ ព្រមទាំងពិនិត្យរកសារ-ជាតិពុល ដែលបញ្ចេញចោលដោយរោងចក្រទៅក្នុងបរិដ្ឋាន ឬទៅក្នុងទឹកទន្លេ និងសមុទ្រ។

អ្នកគីមីផ្នែកជីវរូប (biological chemists) សិក្សាអំពីសមាសធាតុ និងធាតុសកម្មរបស់គីមីដែលមាននៅក្នុងសរីរាង្គរបស់ភាវរូបមានជីវិតទាំងអស់។ ពួកគេវិភាគ និងកំណត់អំពីដំណើរការរបស់សាធាតុគីមី ដែលជាប់ពាក់ព័ន្ធទៅនឹងតួនាទីរបស់ជីវរូប ដូចជា ការឡើងទម្ងន់ ការបង្កកំណើត និងការសិក្សាអំពីហ្សែន (gene) ផងដែរ។

ចំណែកអ្នកគីមីសរីរាង្គ (organic chemists) សិក្សាអំពីធាតុផ្សំរបស់គីមីដែលមាននៅក្នុងសាធាតុកាបូន (carbon) និងអ៊ីដ្រូសែន។ អ្នកគីមីផ្នែករូប និងទ្រឹស្តី (physical and theo-retical chemists)សិក្សាអំពីរូបលក្ខណៈរបស់អាតូម (atoms) និងម៉ូលេគុល (molecules) ដើម្បីចង់ដឹងពីប្រតិកម្មរបស់សារធាតុគីមីនានា។



អ្នកគីមីផ្នែករូបអាចធ្វើការនៅក្នុងរោងចក្រនុយក្លេអ៊ែរ ដើម្បីសិក្សាទាញយកនូវផលប្រយោជន៍ជាថាមពលអគ្គិសនី ដោយប្រើប្រាស់សារធាតុប្រតិកម្មរបស់នុយក្លេអ៊ែរ។

អ្នកគីមីផ្នែកឱសថ (medicinal chemists) សិក្សាអំពីរចនាសម្ព័ន្ធរបស់សមាសធាតុផ្សំ ដែលនឹងត្រូវប្រើប្រាស់នៅក្នុងឱសថសម្រាប់ព្យាបាលជម្ងឺរបស់មនុស្ស។

## ការអប់រំ និងការបណ្តុះបណ្តាល

G ការសិក្សា និងបណ្តុះបណ្តាលជំនាញផ្នែកគីមី គឺត្រូវចាប់ផ្តើមឡើងពីពេលនៅសិក្សាក្នុងវិទ្យាល័យមកម្ល៉េះ។ អ្នកគួរសិក្សាមុខវិជ្ជាគណិតវិទ្យា ធរណីមាត្រ និងការគណនាឱ្យបានច្រើន។ ក្រៅពីនេះ ក៏ត្រូវសិក្សាផងដែរលើមុខវិជ្ជាវិទ្យាសាស្ត្រ ជីវវិទ្យា គីមីវិទ្យា និងរូបវិទ្យា។ គេក៏មិនគួរភ្លេចសិក្សាភាសាបរទេស និងជំនាញកុំព្យូទ័រនោះទេ។

បន្ទាប់មក គេត្រូវសិក្សាយកជំនាញនេះនៅកម្រិតបរិញ្ញាបត្រ ដែលជាកម្រិតគ្រប់គ្រាន់ល្មមសម្រាប់ចូលទៅ

បំពេញការងារសាមញ្ញៗ។ ប៉ុន្តែការងារបែបលំបាក និងស្មុគស្មាញតម្រូវឱ្យគេសិក្សា និងទទួលសញ្ញាបត្រកម្រិតខ្ពស់ជាងនេះជាបន្ថែមទៀត។

ប្រសិន អ្នកមានបំណងក្លាយជាអ្នកស្រាវជ្រាវនៅក្នុងវិស័យនេះ គួរតែសិក្សារហូតដល់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតជាការចាំបាច់។ គេក៏កត់សម្គាល់ផងដែរថា បុគ្គលិក ឬសាស្ត្រាចារ្យដែលមានជំនាញផ្នែកនេះក៏តម្រូវឱ្យមានកម្រិតសញ្ញាបត្រខ្ពស់ផងដែរ។

## Kry I dgi

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

ជីវវិទ្យា គីមីវិទ្យា គណិតវិទ្យា

✦ កម្រិតអប់រំទាបបំផុត:

បរិញ្ញាបត្រ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

អ្នកជីវវិទ្យា

វិស្វករគីមី

ឱសថការី ។ល។

## etGkdgbeT?

ប្រសិនអ្នកមានបំណងសិក្សាលើមុខជំនាញផ្នែកគីមី អ្នកអាចស្វែងរកសិក្សាមុខជំនាញនេះនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (Institute of Technology of Cambodia) ដែលជាគ្រឹះស្ថានអប់រំរបស់រដ្ឋ។ បច្ចុប្បន្នវិទ្យាស្ថាននេះមានទទួលសិស្សនិស្សិតឱ្យសិក្សាជំនាញបច្ចេកទេស និងវិស្វករជាច្រើនផ្នែក ដែលក្នុងនោះរួមមានទាំងជំនាញជាវិស្វករផ្នែកគីមី និងម្ហូបអាហារផងដែរ។

# គិលានុបដ្ឋាក

( Nurses )

**សង្ខេបអំពីជំនាញ**

**គិលានុបដ្ឋាកធ្វើការងារ៖**

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

✦ បង្រៀន

G

**ជំនាញដែលត្រូវការច្រើន៖**

✦ ការធ្វើសេចក្តីសម្រេចចិត្ត

✦ ការទទួលខុសត្រូវ

✦ ការនិយាយ និងការស្តាប់

## តើគិលានុបដ្ឋាកបំពេញកិច្ចការអ្វីខ្លះ?

G គិលានុបដ្ឋាកមានភារៈកិច្ចទទួលថែទាំអ្នកជម្ងឺ អ្នករងរបួស ឬអ្នកដែលមានសុខភាពមិនប្រក្រតី។ ពោលជារួម គិលានុបដ្ឋាកមានតួនាទី និងកិច្ចការច្រើនត្រូវអនុវត្ត ដូចជាការជួយកិច្ចការធ្ងន់ស្រាល និងធ្វើឱ្យអ្នកជម្ងឺមានភាពល្ហែល្ហើយ និងសះស្បើយពីរោគា ការផ្តល់ឱសថព្យាបាល និងតាមដានសភាពវិវឌ្ឍនៃជម្ងឺ ព្រមទាំងរៀបចំសម្ភារបរិក្ខាដែលត្រូវប្រើប្រាស់នៅក្នុងមន្ទីរពេទ្យ។

គិលានុបដ្ឋាកមួយរូបៗមិនមានការសិក្សា និងហ្វឹកហាត់ការងារដូចគ្នានោះទេ ហេតុនេះកិច្ចការដែលពួកគេធ្វើក៏មានភាពប្លែកគ្នាទៅតាមនោះដែរ។ គិលានុបដ្ឋាកខ្លះមានភារៈជួយកិច្ចការដល់វេជ្ជបណ្ឌិតផ្នែកវះកាត់ តាមដានដំណើរការនៃការផ្តល់ឱសថដល់អ្នកជម្ងឺ ព្រមទាំងជួយមើលកិច្ចការផ្នែកផ្តល់ឱវាទ និងបង្រៀនដល់គិលានុបដ្ឋាកផ្សេងទៀតដែលស្ថិតនៅក្រោមបង្គាប់។

អាស្រ័យដោយគិលានុបដ្ឋាកមានជំនាញ និងភារៈខុសៗគ្នាដូច្នេះហើយ ទើបគេសង្កេតឃើញមានគិលានុបដ្ឋាកផ្នែកផ្សេងៗដូចជា៖

- **គិលានុបដ្ឋាកទទួលបន្ទុកទូទៅ** ធ្វើការជាផ្នែកមួយនៃក្រុមថែទាំជម្ងឺ។ ក្រុមការងារនេះធ្វើការកំណត់ពីសភាពជម្ងឺរបស់អ្នកជម្ងឺ និងរៀបផែនការព្យាបាល ឬការថែទាំសុខភាព។ ពួកគេពិនិត្យកម្រិតសម្ពាធឈាម សីតុណ្ហភាព និងដំណើរជីពចររបស់អ្នកជម្ងឺ ព្រមទាំងផ្តល់ថ្នាំសង្កូវទៅដល់អ្នកជម្ងឺ។ ពួកគេពិនិត្យរោគសញ្ញារបស់អ្នកជម្ងឺ ផ្លាស់ប្តូរសម្លៀកបំពាក់ឱ្យអ្នកជម្ងឺ រៀបចំអ្នកជម្ងឺសម្រាប់ការវះកាត់ និងជាពិសេសបំពេញភារកិច្ចផ្សេងៗទៅតាមជំនាញ និងតម្រូវការរបស់អ្នកជម្ងឺគ្រប់ៗរូប។
- **គិលានុបដ្ឋាកផ្នែកវះកាត់** ជួយកិច្ចការដល់វេជ្ជបណ្ឌិតផ្នែកវះកាត់នៅក្នុងពេលធ្វើការវះកាត់។
- **គិលានុបដ្ឋាកផ្នែក-សម្ភព** ជួយកិច្ចការនៅក្នុងបន្ទប់សម្រាលកូន និងជួយមើលថែទាំទារកដែលទើបនឹងកើត។ ពួកគេបង្រៀនដល់ស្ត្រីជាម្តាយឱ្យយល់ដឹងពីការថែទាំ និងចិញ្ចឹមកូនង៉ែតឱ្យបានត្រឹមត្រូវតាមបច្ចេកទេស។
- **គិលានុបដ្ឋាកផ្នែកបង្រៀន** ជួយផ្តល់ឱវាទដល់សិស្សព្យាបាលជម្ងឺ ឬរបួសស្រាលៗបន្តិចបន្តួច និងផ្តល់យោបល់ទូទៅពាក់ព័ន្ធនឹងបញ្ហាសុខភាព។
- **គិលានុបដ្ឋាកផ្នែកសង្គ្រោះជម្ងឺធ្ងន់ធ្ងរ** ជួយមើលថែអ្នកជម្ងឺដែលមានអាការធ្ងន់ធ្ងរនៅក្នុងមន្ទីរពេទ្យ ឬធ្វើដំណើរទៅពិនិត្យ និងព្យាបាលជម្ងឺជារឿយៗ នៅតាមគេហដ្ឋានរបស់អ្នកជម្ងឺដែលមានអាការធ្ងន់ធ្ងរមិនអាចសម្រាកនៅមន្ទីរពេទ្យបាន។



ក្រៅពីនេះ គេក៏សង្កេតឃើញមានគិលានុបដ្ឋាកខ្លះទៀត ដែលទទួលបានការអប់រំវគ្គខ្លីសម្រាប់ជំនាញក្នុងការថែទាំទូទៅដល់អ្នកជម្ងឺ ផ្តល់ឱសថដល់អ្នកជម្ងឺ និងធ្វើកិច្ចការរដ្ឋបាល ឬស្មៀននៅក្នុងមន្ទីរពេទ្យផងដែរ។

## ការអប់រំ និងការបណ្តុះបណ្តាល

G អំឡុងពេលសិក្សានៅមធ្យមសិក្សាទុតិយភូមិ អ្នកគួរផ្តោតជាសំខាន់លើមុខវិជ្ជាជីវវិទ្យា សុខភាព គណិតវិទ្យា និងវិទ្យាសាស្ត្រសង្គម ដែលមុខវិជ្ជាទាំងអស់នេះនឹងផ្តល់នូវមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ឈានទៅការសិក្សានៅជំនាញផ្នែកគិលានុបដ្ឋាក។

បន្ទាប់ពីសិក្សានៅវិទ្យាល័យ អ្នកអាចបន្តការសិក្សាជំនាញឯកទេសគិលានុបដ្ឋាក ទៅតាមកម្រិតសញ្ញាបត្រដូចមានបង្ហាញក្នុងរូបខាងក្រោម៖





តទៅទំព័របន្ទាប់

## Kry l dgi

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

ជីវវិទ្យា និងគីមីវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ និងការបណ្តុះបណ្តាលវិជ្ជាជីវៈគិលានុបដ្ឋាក

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

ជំនួយការគិលានុបដ្ឋាក និង

គិលានុបដ្ឋាកផ្នែកជម្ងឺធ្ងន់ ។ល។

## etGkdgbeT?

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (Université des Sciences de la Santé) ជាគ្រឹះស្ថានអប់រំសាធារណៈរបស់រដ្ឋ ដែលមានទស្សនវិស័យក្នុងការអប់រំបណ្តុះបណ្តាលយុវជន យុវនារីខ្មែរឱ្យទទួលបាននូវចំណេះដឹងទូទៅ និងឯកទេសផ្នែកការថែទាំសុខភាព។ ម្យ៉ាងទៀត សាកលវិទ្យាល័យក៏ឈរនៅលើទស្សនៈនៃការផ្សព្វផ្សាយអំពីបញ្ហាសុខភាព ព្រមទាំងគុណភាព និងសុវត្ថិភាពនៃសេវាសុខភាពនៅទូទាំងប្រទេស។

សាកលវិទ្យាល័យនេះមានមហាវិទ្យាល័យចំនួន ៣ និងសាលាបច្ចេកទេសមួយគឺ៖ មហាវិទ្យាល័យវេជ្ជសាស្ត្រ មហាវិទ្យាល័យឱសថសាស្ត្រ មហាវិទ្យាល័យទន្តសាស្ត្រ និងសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ។

ក្រៅពីនេះ គេក៏សង្កេតឃើញមានសាកលវិទ្យាល័យ ឯកជនមួយចំនួនទៀត កំពុងផ្តល់ការអប់រំលើមុខជំនាញផ្នែកវេជ្ជសាស្ត្រផងដែរ។ ហេតុនេះ សិស្ស និស្សិតអាចធ្វើការជ្រើសរើសសិក្សាជំនាញណាមួយតាមការគួរ។

# បុគ្គលិកផ្នែកយុទ្ធនាការផ្សព្វផ្សាយ

( Campaign Workers )

**សង្ខេបអំពីជំនាញ**

**បុគ្គលិកផ្នែកយុទ្ធនាការផ្សព្វផ្សាយធ្វើការងារ៖**

✦ **បែងចែកមូលនិធិ និងធនធាន**

✦ **គ្រប់គ្រងក្រុមមនុស្ស ឬមហាជន**

✦ **បំពេញកិច្ចការជាក្រុម**

G

**ជំនាញដែលត្រូវការប្រើ៖**

✦ **ការអាន និងសរសេរ**

✦ **គណិតវិទ្យា**

✦ **ការនិយាយ និងស្តាប់**

## តើបុគ្គលិកផ្នែកយុទ្ធនាការផ្សព្វផ្សាយបំពេញកិច្ចការអ្វីខ្លះ?

G បុគ្គលិកផ្នែកយុទ្ធនាការផ្សព្វផ្សាយធ្វើការងារបែបជួយជ្រោមសកម្មភាពឃោសនាក្នុងដំណើរការបោះឆ្នោត និងជួយបេក្ខជនឈរឈ្មោះឱ្យទទួលបានការគាំទ្រព្រមទាំងជាប់ឆ្នោត។ ពួកគេធ្វើការពន្យល់អប់រំទៅដល់មហាជនអំពីសមាសភាព និងចំណុចខ្លាំងរបស់បេក្ខជនដែលឈរឈ្មោះ ចែកចាយព័ត៌មានតាមរយៈបណ្តាផ្សព្វផ្សាយ ឃោសនាតាមរយៈទូរទស្សន៍ វិទ្យុ និងបណ្តាញឃោសនាដទៃទៀត។

ហេតុនេះ បេក្ខជនឈរឈ្មោះនៅក្នុងរដ្ឋាភិបាល និងគណបក្សនយោបាយផ្សេងៗ ត្រូវការប្រើប្រាស់នូវសេវារបស់អ្នកជួយឃោសនាដើម្បីរៀបចំកិច្ចការលម្អិតនានាក្នុងដំណើរ

ការបោះឆ្នោតដូចជា ថវិកា និងការចំណាយ ការកៀរគររកជំនួយពីអ្នកឧបត្ថម្ភ ឬសប្បុរសជនដែលគាំទ្រ ព្រមទាំងរៀបចំការផ្សព្វផ្សាយតាមរយៈសន្និសីទសារព័ត៌មាន ជាដើម។

គេកត់សម្គាល់ថា យុទ្ធនាការឃោសនាបោះឆ្នោតដែលរៀបចំបានល្អ គឺមានសារសំខាន់ជាងចំណុចខ្លាំងរបស់បេក្ខជនផ្ទាល់ទៀតផង។ កិច្ចការនេះអាស្រ័យជាពិសេសទៅលើការស្ម័គ្រចិត្ត និងការពុះពាររបស់អ្នកឃោសនា ព្រមទាំងការរៀបចំបានល្អពីសំណាក់អ្នកគ្រប់គ្រង។ ជាទូទៅ ឧបករណ៍សម្រាប់ការឃោសនាមានច្រើនប្រភេទ និងទម្រង់ខុសៗគ្នា ដូចជា ការបោះពុម្ពស្លាកសញ្ញាលើអាវយឺត បណ្ណផ្ទត់ដែលពណ៌នាអំពីចំណុចល្អរបស់បេក្ខជន ផ្ទាំងរូបភាពអំពីខ្លឹមសារ ឬបាវចនារបស់គណបក្សបិទនៅតាមជញ្ជាំង ដើមឈើ និងទីវាលសាធារណ ទាំងអស់នេះសុទ្ធសឹងមានសារសំខាន់ក្នុងការចូលរួមចំណែកទាក់ទាញមហាជនឱ្យពិចារណា និងបោះឆ្នោតជូនបេក្ខជនតំណាង។

អ្នកឃោសនាក៏មានភារៈក្នុងការអភិវឌ្ឍបច្ចេកទេសជាយុទ្ធសាស្ត្រក្នុងការឃោសនាដូចជា គួរលើកយកបញ្ហា ឬគោលនយោបាយបែបណាមកបង្ហាញ ហើយគួរបង្ហាញពីប្រវត្តិនយោបាយរបស់បេក្ខជនតំណាងយ៉ាងដូចម្ដេច។ ក្រៅពីនេះ អ្នកឃោសនាត្រូវរៀបចំសុន្ទរកថា អត្ថបទសម្រាប់អ្នកសារព័ត៌មាន រៀបចំការជួបផ្ទាល់រវាងបេក្ខជនតំណាង និងអ្នកបោះឆ្នោតដើម្បីបង្ហាញខ្លួន និងជជែកជាសាធារណៈ។



## ការអប់រំ និងការបណ្ដុះបណ្ដាល

G អ្នកដែលមានបំណងចង់ក្លាយខ្លួនជាអ្នកឃោសនាគួរផ្ដោតការសិក្សាទៅលើមុខវិជ្ជាសំខាន់ៗមួយចំនួនដូចជា ប្រវត្តិសាស្ត្រ រដ្ឋបាល ឬរដ្ឋាភិបាល គណិតវិទ្យា កុំព្យូទ័រ និងផ្នែកធុរកិច្ច។ ក្រៅពីនេះ អ្នកគួររៀនភាសាបរទេស ការធ្វើបទបង្ហាញ ឬការធ្វើសុន្ទរកថា ដើម្បីជួយបង្កើនចំណេះ និងជំនាញក្នុងការនិយាយ ឬសរសេរទំនាក់ទំនងក្នុងកិច្ចការ។

សម្រាប់ការអនុវត្តជាក់ស្ដែង អ្នកគួរសាកល្បងចូលរួមក្នុងយុទ្ធនាការឃោសនាណាមួយ ដើម្បីជាការដកស្រង់បទពិសោធន៍ និងត្រៀមខ្លួនរៀបចំដោយខ្លួនឯងនៅក្នុងពេលអនាគត។ យ៉ាងណាមិញ នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតលំដាប់ជាតិ ដូចជាការបោះឆ្នោតសាកលជ្រើសរើសតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ជាដើម តម្រូវឱ្យអ្នកឃោសនាមានភាពស្ទាត់ជំនាញ មានបទពិសោធន៍ច្រើន និងស្វែងយល់ពីគោលនយោបាយរបស់គណបក្ស និងសមាសភាពរបស់បេក្ខជនតំណាង ដើម្បីអាចធ្វើការពន្យល់ ឬបង្ហាញនូវចំណុចខ្លាំងទាំងឡាយទៅដល់មហាជន និងអ្នកបោះឆ្នោត។





តទៅទំព័របន្ទាប់

# អ្នកបច្ចេកទេសខាងមូលដ្ឋានទិន្នន័យ

( Database Specialists )

សង្ខេបអំពីជំនាញ

អ្នកបច្ចេកទេសខាងមូលដ្ឋានទិន្នន័យធ្វើការងារ៖

- ✦ បង្កើត ឬអភិវឌ្ឍប្រព័ន្ធ
- ✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ✦ ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

G

ជំនាញដែលត្រូវការប្រើ៖

- ✦ ការធ្វើសេចក្ដីសម្រេចចិត្ត
- ✦ គណិតវិទ្យា
- ✦ ការដោះស្រាយបញ្ហា

## Kry I dgi

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ធុរកិច្ច ( ពាណិជ្ជកម្ម ) និងរដ្ឋបាល ឬរដ្ឋាភិបាល

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្ដីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកវិទ្យាសាស្ត្រនយោបាយ និង

អ្នកបញ្ចុះបញ្ចូល ជាដើម។

## តើអ្នកបច្ចេកទេសខាងមូលដ្ឋានទិន្នន័យធ្វើកិច្ចការអ្វីខ្លះ?

*G ការប្រមូលនូវព័ត៌មាន ឬទិន្នន័យដើម្បីបញ្ចូល និងរក្សាទុកនៅក្នុងប្រព័ន្ធកុំព្យូទ័រហៅថា «មូល-ដ្ឋានទិន្នន័យ» (database)។ អ្នកបច្ចេកទេសខាងមូលដ្ឋានទិន្នន័យធ្វើកិច្ចការនៅក្នុងក្រុមហ៊ុនផ្នែកលក់សម្ភារ ក្រុមហ៊ុនវិនិយោគ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនទូរគមនាគមន៍ និងក្រសួងស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាល។ ពួកគេរៀបចំបង្កើត និងថែទាំមូលដ្ឋានទិន្នន័យ ទិញសម្ភារកុំព្យូទ័រ បង្កើតកម្មវិធីកុំព្យូទ័រដើម្បីប្រមូល វិភាគ រក្សា និងផ្សព្វផ្សាយព័ត៌មាន។*

*អ្នកបច្ចេកទេសមូលដ្ឋានទិន្នន័យស្រាវជ្រាវនិងស្វែងរកប្រភេទប្រព័ន្ធកុំព្យូទ័រដែលក្រុមហ៊ុន ឬស្ថាប័នត្រូវការប្រើ។ ពួកគេត្រូវការជជែកពិភាក្សាជាមួយថ្នាក់ដឹកនាំកំពូលរបស់ក្រុមហ៊ុន ឬស្ថាប័នអំពីសេចក្ដីត្រូវការទាំងឡាយ។ បន្ទាប់មកភាគីទាំងពីរធ្វើសេចក្ដីសម្រេចចិត្តទៅលើប្រភេទនៃឧបករណ៍ និងកម្មវិធីដែលនឹងប្រើប្រាស់សម្រាប់បង្កើតមូលដ្ឋានទិន្នន័យ*

## etGkdgbeT?

នៅប្រទេសកម្ពុជា គណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត (គ.ជ.ប) មានភារៈទទួលខុសត្រូវលើការបោះឆ្នោតសំខាន់ៗដូចជា ការបោះឆ្នោតព្រឹទ្ធសភា ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ជាដើម។

តាមក្របខ័ណ្ឌគតិយុត្ត វិធាននៃការឃោសនាសម្រាប់ការបោះឆ្នោតត្រូវបានកំណត់ដោយច្បាប់បោះឆ្នោត។ ឧទាហរណ៍ នៅក្នុងមាត្រានៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅត្រង់ជំពូកទី ៧ បានចែងអំពីការឃោសនាបោះឆ្នោតដូច្នេះថា៖ យុទ្ធនា-ការឃោសនាបោះឆ្នោតមានរយៈពេល ៣០ថ្ងៃ ហើយគ្រប់សកម្មភាពនៃការឃោសនាបោះឆ្នោតត្រូវចប់ ២៤ម៉ោង មុនថ្ងៃបោះឆ្នោត។ ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ត្រូវគោរពតាមវិធានបទប្បញ្ញត្តិ និងគោលការណ៍ដែលចែងក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងក្រមសីលធម៌ បទបញ្ជា និងនិតិវិធីរបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោត គោរពតាមគោលការណ៍សិទ្ធិ-មនុស្ស និងលទ្ធិប្រជាធិបតេយ្យដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ *(មាត្រា៧២ និង៧៣ថ្មីនៃច្បាប់បោះឆ្នោត)*



តទៅទំព័របន្ទាប់

របស់ស្ថាប័ន។ អ្នកបច្ចេកទេសមូលដ្ឋានទិន្នន័យក៏ត្រូវធ្វើការប៉ាន់ស្មានតម្លៃ និងការចំណាយសម្រាប់សម្ភារដើម្បីលើកជាសំណើរក្នុងការទិញវត្ថុទាំងនោះ។

អ្នកបច្ចេកទេសខាងមូលដ្ឋានទិន្នន័យនឹងធ្វើការបង្កើតប្រព័ន្ធទិន្នន័យទៅតាមសម្ភារដែលបានទិញ។ ចំណែកអ្នកគ្រប់គ្រងមូលដ្ឋានទិន្នន័យ (database managers) វិញ នឹងសម្រេចអំពីវិធីក្នុងការរៀបចំ និងរក្សាទុកទិន្នន័យនៅក្នុងប្រព័ន្ធកុំព្យូទ័រ។ ការងារបន្ទាប់មកទៀតគឺ បង្ហាត់បង្ហាញបុគ្គលិកក្នុងក្រុមហ៊ុន ឬស្ថាប័នឱ្យចេះប្រើប្រាស់ និងទាញយកព័ត៌មាន ឬទិន្នន័យពីប្រព័ន្ធដែលបានបង្កើតរួច។



ជួនកាលកម្មវិធីកុំព្យូទ័រគាំងមិនដំណើរការ ឬខូចគាំង ដូច្នេះ អ្នកបច្ចេកទេសត្រូវប្រុងប្រយ័ត្ន និងថតចម្លងឯកសារដើម្បីរក្សាទុកជៀសវាងការបាត់បង់។ បន្ថែមលើនេះ អ្នកបច្ចេកទេសត្រូវរិះរកវិធីក្នុងរក្សា ឬការពារទិន្នន័យក្នុងករណីមានគោលការណ៍ហាមឃាត់មិនឱ្យអ្នកដទៃមើលឃើញ ឬទាញយកព័ត៌មានទាំងនោះ ពីព្រោះទិន្នន័យរបស់ស្ថាប័ន ឬក្រុមហ៊ុននីមួយៗតែងមានចំណុចសម្ងាត់ និងសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង។ ស្ថាប័នធំៗខ្លះអាចមានទិន្នន័យមួយ ឬច្រើនដែលមានតួនាទីខុសៗគ្នា ដូច្នេះ អ្នកបច្ចេកទេសត្រូវគិតអំពីវិធីក្នុងការចែករំលែកព័ត៌មានរវាងមូលដ្ឋានទិន្នន័យទាំងអស់នោះ ដើម្បីកំណត់ថាព័ត៌មានណាអាចចែករំលែកបាន និងព័ត៌មានបែបណាមិនអាចចែករំលែកបាន។

## ការអប់រំ និងការបណ្តុះបណ្តាល

ប្រសិន អ្នកមានបំណងក្លាយជាអ្នកបច្ចេកទេសខាងមូលដ្ឋានទិន្នន័យ អ្នកគួរខិតខំរៀននូវមុខវិជ្ជាពាក់ព័ន្ធកុំព្យូទ័រឱ្យបានច្រើន។ បន្ថែមលើនេះ អ្នកគួរសិក្សាគណិតវិទ្យា គណនេយ្យ វិទ្យាសាស្ត្រ ភាសាបរទេស និងមុខវិជ្ជាផ្នែកទំនាក់ទំនង។

អ្នកត្រូវមានសញ្ញាបត្រទាបបំផុត ត្រឹមកម្រិតបរិញ្ញាបត្ររង ឬបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ និងមុខវិជ្ជានានាពាក់ព័ន្ធបច្ចេកទេសកុំព្យូទ័រ និងការបញ្ចូលទិន្នន័យ ជាដើម។ ក្រៅពីនេះ អ្នកក៏ត្រូវមានជំនាញផ្នែកគ្រប់គ្រងពាណិជ្ជកម្មដើម្បីអាចកាន់តំណែង ឬមុខនាទីធំដុំនៅក្នុងការងារ។ អ្នកខ្លះអាចបន្តការសិក្សារហូតដល់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ដើម្បីអាចមានលទ្ធភាពកាន់តែច្រើន ចំពោះការប្រកួតប្រជែងនៅក្នុងទីផ្សារការងារ។





Kry I dgi

✦ មុខវិជ្ជាសិក្សាក្នុងសាលា:
វិទ្យាសាស្ត្រកុំព្យូទ័រ
គណិតវិទ្យា


តទៅទំព័របន្ទាប់

គីមីវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ ឬបរិញ្ញាបត្ររង

✦ **ព័ត៌មានគួរអានបន្ថែមស្ដីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកបង្កើតកម្មវិធីកុំព្យូទ័រ

អ្នកបង្រៀនកុំព្យូទ័រ

អ្នកឯកទេសខាងគំនូរក្រាហ្វិក និង

វិស្វករផ្នែករឹង និងផ្នែកទន់របស់កុំព្យូទ័រ ជាដើម។

## etGkdgbeT?

សព្វថ្ងៃនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារ កំពុងរៀបចំរចនាប្រព័ន្ធមូលដ្ឋានទិន្នន័យអំពីព័ត៌មានទីផ្សារការងារ។ ក្នុងពេលអនាគត ពេលដែលមូលដ្ឋានទិន្នន័យនេះកសាងចប់រួចរាល់ អ្នកស្វែងរកការងារធ្វើ និយោជក អ្នកផ្ដល់ការអប់រំបណ្ដុះបណ្ដាល អ្នករៀបចំគោលនយោបាយ និងសាធារណជនទូទៅអាចប្រើប្រាស់មូលដ្ឋានទិន្នន័យនេះដោយទូលំទូលាយ។

## និពន្ធនាយកសារព័ត៌មាន

(Newspaper Editors)

សង្ខេបអំពីជំនាញ

និពន្ធនាយកសារព័ត៌មានធ្វើការងារ៖

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ គ្រប់គ្រង និងបែងចែកបុគ្គលិក

G

ជំនាញដែលត្រូវការប្រើ៖

✦ ការធ្វើសេចក្ដីសម្រេចចិត្តចំពោះកិច្ចការ

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត

✦ ការអាន និងការសរសេរ

## តើនិពន្ធនាយកសារព័ត៌មានបំពេញកិច្ចការអ្វីខ្លះ?

G យើងដឹងហើយថា «សារព័ត៌មាន» គឺជាឧបករណ៍ និងជាមធ្យោបាយដ៏សំខាន់មួយក្នុងការប្រាស្រ័យទាក់ទងចំពោះរាល់អ្វីៗទាំងអស់ដែលកើតមាននៅក្នុងពិភពលោក ដោយគិតចាប់ពីដំណឹង ឬព្រឹត្តិការណ៍តូចៗនៅតាមទីក្រុង ប្រទេស តំបន់ រហូតដល់កម្រិតពិភពលោក។ ជារៀងរាល់ថ្ងៃ សារព័ត៌មានជាច្រើនប្រភេទកំពុងធ្វើចរាចរចែកចាយនូវដំណឹងផ្សេងៗដែលគ្របដណ្ដប់ទៅលើផ្នែកសំខាន់ដូចជា: នយោបាយ សេដ្ឋកិច្ច វប្បធម៌ និងការកំសាន្ត ជាដើម។ ជាទូទៅ ព័ត៌មានទាំងអស់នោះត្រូវបានទទួលពីប្រភពផ្សេងៗគ្នាដែលតម្រូវឱ្យមានការពិនិត្យពិច័យចំពោះភាពត្រឹមត្រូវ និងគុណភាពនៃប្រភេទព័ត៌មាននីមួយៗ។ អាស្រ័យហេតុនេះ និពន្ធនាយកសារព័ត៌មាននឹងធ្វើសេចក្ដីសម្រេចចិត្តចំពោះអត្ថបទ ឬដើមរឿងនៃព័ត៌មានដែលអ្នកសារព័ត៌មានត្រូវសរសេរនៅក្នុងទំព័រសារព័ត៌មាន។ ដូច្នេះ កិច្ចការប្រចាំថ្ងៃរបស់អ្នកសារព័ត៌មានគឺមានភាពមមាញឹកជាខ្លាំង។ ធម្មតា សារព័ត៌មានមួយអាចមាននិពន្ធនាយកមួយ ឬច្រើនអាស្រ័យតាមទំហំការងារ និងភាពល្បីល្បាញនៃសារព័ត៌មាននោះ។ ក្នុងនោះផងដែរ គេសង្កេតឃើញថានិពន្ធនាយកចាត់ចែងកិច្ចការទូទៅសម្រាប់ទំព័រសារព័ត៌មាន រួមទាំងការជ្រើសរើសអត្ថបទ ការចាត់តាំងអ្នកសារព័ត៌មានឱ្យបំពេញកិច្ចការទៅតាមប្រភេទព័ត៌មាន និងទីតាំង។ អ្នកសារព័ត៌មានមានភារៈផ្ដល់នូវព័ត៌មាន ឬដំណឹងផ្សេងៗឱ្យទៅនិពន្ធនាយកតាមឯកទេសរៀងៗខ្លួនដូចជា ផ្នែកជំនួញ និងសេដ្ឋកិច្ច វប្បធម៌ កីឡា ការកំសាន្ត និងនយោបាយ ជាដើម។



## ការអប់រំ និងការបណ្តុះបណ្តាល

G ប្រសិនបើ អ្នកមានបំណងក្លាយខ្លួនជានិពន្ធនាយកសារព័ត៌មាន អ្នកគួរចាប់ផ្តើមរៀនមុខវិជ្ជាសំខាន់ៗមួយចំនួនចាប់តាំងពីនៅវិទ្យាល័យ រហូតដល់កម្រិតឧត្តមសិក្សា ដូចជា ប្រវត្តិសាស្ត្រ ភាសាបរទេស អក្សរសាស្ត្រ វិទ្យាសាស្ត្រសង្គម សារព័ត៌មានវិទ្យា និងវិទ្យាសាស្ត្រកុំព្យូទ័រ។

ជម្មតា កិច្ចការនេះតម្រូវឱ្យមានសញ្ញាបត្រកម្រិតទាបបំផុតត្រឹមថ្នាក់បរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់កាន់តែប្រសើរ។ ក្រៅពីមុខវិជ្ជាសិក្សាដូចបានពោលខាងលើ ពួកគេក៏គួរសិក្សាមុខវិជ្ជាសេដ្ឋកិច្ច និងវិទ្យាសាស្ត្រនយោបាយបន្ថែមផងដែរ។ ក្រៅពីនេះ និពន្ធនាយកក៏គួរមានបទពិសោធន៍ក្នុងសកម្មភាពពាក់ព័ន្ធជំនាញដូចជា កម្មសិក្សាការងារ ការសរសេរអត្ថបទផ្សេងៗ ព្រមទាំងជំនាញផ្នែកកុំព្យូទ័រ និងការបោះពុម្ពនឹងរឹងរិតតែធ្វើឱ្យពួកគេមានសក្តានុពល និងការប្រកួតប្រជែងនៅក្នុងទីផ្សារការងារមួយកម្រិតថែមទៀត។

## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

ភាសាបរទេស និងសារព័ត៌មានវិទ្យា

✦ កម្រិតអប់រំទាបបំផុត:

បរិញ្ញាបត្រ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

និពន្ធនាយកទស្សនាវដ្តី

អ្នកសារព័ត៌មាន និងអ្នកឆ្លើយឆ្លងព័ត៌មាន

នាយកការផ្សាយតាមវិទ្យុ និងទូរទស្សន៍ ។ល។

## តើអ្នកដឹងឬទេ ?

ជនណាម្នាក់ដែលយល់ថាអត្ថបទណាមួយ ទោះជាសរសេរបញ្ចិតបញ្ចៀងក៏ដោយ រូបគំនូរ ឬរូបថតណាមួយនៃសារព័ត៌មានណាមួយ ដែលមានលក្ខណៈខុសពីការពិតធ្វើឱ្យខូចខាតដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន មានសិទ្ធិទាមទារឱ្យសារព័ត៌មាននោះធ្វើការកែតម្រូវ ឬមានសិទ្ធឆ្លើយតប និងធ្វើបណ្តឹងពីបទបរិហាកេរ្តិ៍ បទមួលបង្កាច់ ឬពីបទជេរប្រមាថចំពោះការប៉ះពាល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន។

*(មាត្រា ១០ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ១៩៩៥)*

ដោយឡែក មាត្រាស្តីពីការតម្កល់អត្ថបទសារព័ត៌មានបានចែងថា៖ និពន្ធនាយក ឬនាយកការផ្សាយត្រូវតម្កល់សារព័ត៌មានរាល់លេខរបស់ខ្លួនចំនួនពីរ (០២) ច្បាប់នៅបណ្ណាល័យជាតិ និងប្រាំមួយ (០៦) ច្បាប់ទៀតនៅក្រសួងព័ត៌មាន។ ការតម្កល់ទុកនេះត្រូវធ្វើឡើងក្នុង រយៈពេលដប់ប្រាំថ្ងៃចំពោះការបោះពុម្ពនៅភ្នំពេញ និងសែសិបប្រាំថ្ងៃនៅកន្លែងដទៃទៀត និងដោយគិតពីកាលបរិច្ឆេទនៃការចេញផ្សាយ។

*(មាត្រា ១៥ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ១៩៩៥)*

## អ្នកសារព័ត៌មាន

( Reporters )

សង្ខេបអំពីជំនាញ

អ្នកសារព័ត៌មានធ្វើការងារ៖

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ បង្រៀន

G


តទៅទំព័របន្ទាប់

**ជំនាញដែលត្រូវការប្រើ៖**

- ✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
- ✦ ការអាន និងការសរសេរ
- ✦ ការនិយាយ និងការស្តាប់

## តើអ្នកសារព័ត៌មានបំពេញកិច្ចការអ្វីខ្លះ?

G អ្នកសារព័ត៌មានមានភារៈក្នុងការប្រមូលនូវបណ្តាព័ត៌មានពីប្រភពផ្សេងៗ ហើយធ្វើសេចក្តីរាយការណ៍ទៅកាន់វិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី សារព័ត៌មាន និងបណ្តាញអ៊ីនធើណេតផងដែរ។ ពួកគេធ្វើការដោយគ្រប ដណ្តប់ទៅលើប្រភេទព័ត៌មានផ្សេងៗទាំងក្នុងស្រុក និងអន្តរជាតិ។ ព័ត៌មាន និងព្រឹត្តិការណ៍ខ្លះកើតឡើងតែក្នុងអំឡុងពេលមួយថ្ងៃតែប៉ុណ្ណោះ ដូចជា ការព្យាករណ៍អាកាសធាតុ ការរាយការណ៍ពីសន្តិសុខសង្គម និងព្រឹត្តិហេតុផ្សេងៗទៀត។ ប៉ុន្តែ ពេលខ្លះពួកគេត្រូវចំណាយពេលជាច្រើនថ្ងៃដើម្បីតាមដាននូវសភាពការណ៍ ឬហេតុការណ៍ដែលប្រព្រឹត្តិទៅក្នុងរយៈពេលយូរថ្ងៃ ដូចជា ការកាត់ក្តីក្នុងអង្គសាវនាការ ការស៊ើបអង្កេតសំណុំរឿង បាតុភូតគ្រោះមហន្តរាយធម្មជាតិ ព្រមទាំងហេតុការណ៍នានាដែលកើតមានក្នុងរង្វង់កិច្ចការរដ្ឋបាល ឬរដ្ឋាភិបាល។

ចំណែកឯ អ្នកឆ្លើយឆ្លងព័ត៌មាន (correspondents) វិញធ្វើសេចក្តីរាយការណ៍ និងគ្រប់ដណ្តប់លើព័ត៌មាននៅក្នុងទីតាំង ឬកន្លែងជាក់លាក់ណាមួយ ដូចជាការធ្វើសេចក្តីរាយការណ៍ពីខេត្តឆ្ងាយៗ ពីកិច្ចប្រជុំ ពីវិមានរដ្ឋសភា ។ល។ ក្នុងដំណើរការនៃការយកព័ត៌មាន និងរាយការណ៍ព័ត៌មាន អ្នកសារព័ត៌មាន និងអ្នកឆ្លើយឆ្លងព័ត៌មានត្រូវកត់ត្រា ថតសម្លេង ធ្វើបទសម្ភាសន៍នូវព័ត៌មានផ្សេងៗ។ ពួកគេក៏ធ្វើការវិភាគ និងពិនិត្យពិច័យទៅលើឯកសារនានាដែលជាប្រភព នៃព័ត៌មានផងដែរ។ មុនពេលពួកគេប្រាប់បញ្ចូលគ្នានូវព័ត៌មានទាំងអស់ គេត្រូវធ្វើការពិភាក្សាជាមួយនិពន្ធនាយក ដើម្បីសម្រេចថាព័ត៌មាន ឬដើមរឿងអ្វីដែលគួរផ្សព្វផ្សាយក្នុងថ្ងៃនីមួយៗ។



បន្ទាប់មកអ្នកសារព័ត៌មាននឹងរៀបចំព័ត៌មានទាំងនោះហើយសរសេរសម្រិតសម្រាំងលម្អិតឱ្យល្អមយល់សព្វសេចក្តីសម្រាប់អ្នកអានទាំងអស់។ ចំពោះអ្នកសារព័ត៌មាន និងអ្នកឆ្លើយឆ្លងព័ត៌មានដែលនៅឆ្ងាយពីការិយាល័យ ហើយលំបាកក្នុងការធ្វើដំណើរទៅមក ពួកគេនឹងរៀបចំព័ត៌មានរួចផ្ញើតាមរយៈអ៊ីម៉ែល ទូរសារ ឬក៏តាមទូរសព្ទក៏មាន។



ដោយហេតុថា ព្រឹត្តិការណ៍ និងព័ត៌មានទាំងអស់សុទ្ធសឹងសំដៅទៅដល់កាលបរិច្ឆេទ និងថ្ងៃផុតកំណត់ ហេតុដូច្នោះទើបគេសង្កេតឃើញថាជីវិត និងការងាររបស់អ្នកសារព័ត៌មាន និងអ្នកឆ្លើយឆ្លងព័ត៌មានគឺមានភាពមមាញឹក ព្រមទាំងជួបប្រទះនូវការរំភើបផង និងលំបាកផងស្ទើររាល់ពេល។ ចំពោះសាច់រឿង ឬអត្ថបទសម្រាប់ទូរទស្សន៍ដែលត្រូវដាក់ផ្សាយ ឬបញ្ចាំងនាពេលរាត្រីគឺត្រូវរៀបចំឱ្យបានលឿន និងដាក់ជូននិពន្ធនាយកពិនិត្យជាមុននៅក្នុងថ្ងៃនីមួយៗ។ រីឯអត្ថបទសម្រាប់សារព័ត៌មានវិញ គឺត្រូវរៀបចំឱ្យបានយ៉ាងលឿនមុនពេលបោះពុម្ព ដើម្បីមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យ និងកែសម្រួល។ ជួនកាល អ្នកសារព័ត៌មានត្រូវធ្វើការលើសម៉ោងក្នុងរវាង ១៨ ទៅ ២០ ម៉ោងក្នុងមួយថ្ងៃ ដើម្បីតាម

ជានទូវព័ត៌មាន ឬព្រឹត្តិការណ៍ដែលសំខាន់ណាមួយកំពុងកើតមានឡើង។ ភារកិច្ចខ្លះអាចជាការផ្សងគ្រោះថ្នាក់ដល់អាយុជីវិតដូចជាការយកព័ត៌មានក្នុងពេលសង្គ្រាម និងពេលមានគ្រោះមហន្តរាយធំៗដូចជារញ្ជួយដី ឬផ្ទុះភ្នំភ្លើងជាដើម។

## ការអប់រំ និងការបណ្តុះបណ្តាល

G ប្រសិនអ្នកមានចំណាប់អារម្មណ៍ចង់ក្លាយជាអ្នកសារព័ត៌មាន ពេលនៅសិក្សាឯវិទ្យាល័យអ្នកគួរគិតចាប់ផ្តើមសិក្សាមុខវិជ្ជាដែលពាក់ព័ន្ធសំខាន់ៗ ដូចជាភាសាបរទេស អក្សរសាស្ត្រ និងការសរសេរ ប្រវត្តិសាស្ត្រ និងកុំព្យូទ័រ។ បន្ទាប់មក នៅថ្នាក់ឧត្តមសិក្សាអ្នកគួរសិក្សាយកបរិញ្ញាបត្រលើឯកទេសសារព័ត៌មានវិទ្យា។ ប្រសិនអ្នកចង់បន្តការសិក្សាដល់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ទៀតនោះ ក៏រឹងរឹតតែប្រសើរ ដោយសារមានភាពប្រកួតប្រជែងខ្ពស់ក្នុងឱកាសការងារ ឬប្រសិនអ្នកមានបំណងចង់ក្លាយជាអ្នកជំនាញ ដែលបង្រៀនមុខវិជ្ជាផ្នែកសារព័ត៌មាន។

## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលាៈ

ភាសាបរទេស (អង់គ្លេស ឬបារាំង) និងសារព័ត៌មានវិទ្យា

✦ កម្រិតអប់រំទាបបំផុតៈ

បរិញ្ញាបត្រ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នាៈ

អ្នកឆ្លើយឆ្លងព័ត៌មាន

និពន្ធនាយកទស្សនាវដ្តី និងសារព័ត៌មាន

អ្នកផ្សព្វផ្សាយតាមវិទ្យុ និងកញ្ចក់ទូរទស្សន៍ ។ល។

## តើអ្នកដឹងឬទេ ?

យោងតាមច្បាប់ស្តីពីរបបសារព័ត៌មាន មាត្រា ៧ បានចែងពីក្រមសីលធម៌របស់អ្នកសារព័ត៌មានដែលមានជាច្រើនចំណុច ដូចជាៈ

១. គោរពសច្ចធម៌ និងសិទ្ធិយល់ដឹងនូវសច្ចធម៌របស់សាធារណជន។

២. ត្រូវផ្សាយនូវដំណឹងទាំងឡាយដោយសុចរិត ព្រមទាំងធ្វើអត្ថាធិប្បាយ ឬរិះគន់ឱ្យត្រឹមត្រូវ និងសមស្របតាមគតិយុត្តិធម៌។

៣. ត្រូវរាយការណ៍តែតាមហេតុការណ៍ដែលខ្លួនដឹង និងពីប្រភពដើមតែប៉ុណ្ណោះ មិនត្រូវបំបាត់ចោលនូវព័ត៌មានសំខាន់ៗ ឬកែបន្លំឯកសារទេ។

៤. ត្រូវជៀសវាងនូវការផ្សព្វផ្សាយព័ត៌មាន ដែលញុះញង់ឱ្យមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត។

៥. ត្រូវគោរពសិទ្ធ និងសេរីភាពរស់នៅក្នុងជីវភាពឯកជនរបស់បុគ្គល។

៦. ហាមបោះពុម្ពផ្សាយអត្ថបទ ឬរូបភាពអាសអាភាស និងរូបភាពនៃអំពើហិង្សា។

៧. ត្រូវគោរពឱ្យបានម៉ត់ចត់តាមក្បួនវេយ្យាករណ៍ខ្មែរក្នុងការសរសេរអត្ថបទ។ *(ច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ ១៩៩៥)*

## ប្រធានគ្រប់គ្រងភោជនីយដ្ឋាន

(Restaurant Managers)

សង្ខេបអំពីជំនាញ

ប្រធានគ្រប់គ្រងភោជនីយដ្ឋានធ្វើការងារៈ

✦ បែងចែកថវិកា និងធនធាន

✦ បំពេញកិច្ចការក្នុងភាពជាអ្នកដឹកនាំ

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

G

ជំនាញដែលត្រូវការប្រើ៖

✦ ការធ្វើសេចក្តីសម្រេចចិត្ត

✦ ការអាន និងការសរសេរ

✦ ការនិយាយ និងការស្តាប់

## តើប្រធានគ្រប់គ្រងភោជនីយដ្ឋានបំពេញកិច្ចការអ្វីខ្លះ?

ប្រធានគ្រប់គ្រងភោជនីយដ្ឋានមានភារកិច្ច និងការទទួលខុសត្រូវចំពោះដំណើរការទូទៅនៅក្នុងភោជនីយដ្ឋាន និងទីកន្លែងនានាដែលបម្រើសេវាផ្នែកម្ហូបអាហារដល់ភ្ញៀវ។ ប្រធានគ្រប់គ្រងក៏មានភារៈជ្រើសរើសបុគ្គលិកឱ្យចូលបម្រើការងារ និងបង្ហាត់បង្រៀនពួកគេអំពីកិច្ចការផងដែរ។ ប្រធានគ្រប់គ្រងផ្នែកសេវាម្ហូបអាហារតែងទទួលខុសត្រូវចំពោះការទិញឥវ៉ាន់ សម្ភារ និងគ្រឿងប្រើប្រាស់នានាសម្រាប់ធានាឱ្យដំណើរការប្រចាំថ្ងៃនៅក្នុងហាង។ ជួនកាល ប្រធានគ្រប់គ្រងផ្នែកនេះក៏ជួយមើលទៅលើការរៀបចំតាពាងមុខម្ហូបសម្រាប់ភោជនីយដ្ឋានផងដែរ។

ក្រៅពីនេះ ពួកគេក៏ធ្វើការត្រួតពិនិត្យទៅលើគុណភាពអនាម័យ និងសុវត្ថិភាពម្ហូបអាហារ ដើម្បីតម្រូវឱ្យស្របទៅតាមបទដ្ឋាន និងបទបញ្ញាដែលបានដាក់ចេញដោយក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធនានា។ គេសង្កេតឃើញថា ប្រធានគ្រប់គ្រង និងប្រធានផ្នែកសេវាម្ហូបអាហារបំពេញតួនាទីយ៉ាងច្រើនផ្នែកហិរញ្ញកិច្ច បញ្ជីស្ពាម វិក្កយបត្រ ការផ្ទេរសាច់ប្រាក់ និងការចុះបញ្ជីវត្ថុប្រើប្រាស់ដែលមាននៅក្នុងហាង។ ពេលខ្លះទៀត ប្រធានគ្រប់គ្រងក៏មានភារៈជួយផ្សព្វផ្សាយកម្មវិធីនៃការលក់ (ម្ហូប) ពិសេសៗរបស់ភោជនីយដ្ឋានផងដែរ។

ការងារប្រភេទនេះ ជាទូទៅមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយអតិថិជនជាប្រចាំថ្ងៃ។ ពួកគេជានិច្ចកាលទទួលយកនូវមតិយបល់ ឬការស្នើក្នុងន័យកែលម្អអំពីភ្ញៀវ ទទួលយកការទិតៀនស្តីបន្ទោស ព្រមទាំងព្យាយាមបង្កើតនូវបរិយាកាសដ៏មនោរម្យនៅក្នុងភោជនីយដ្ឋាន ដើម្បីឱ្យភ្ញៀវទាំងអស់សប្បាយចិត្ត និងទទួលទានអាហារបានឆ្ងាញ់។




នៅក្នុងភោជនីយដ្ឋានធំៗ ក្រៅតែពីប្រធានគ្រប់គ្រងគេឃើញមានអ្នកទទួលខុសត្រូវធំៗតាមផ្នែកមួយចំនួនទៀត ដូចជា ជំនួយការប្រធានគ្រប់គ្រង មេចុងភៅ ប្រធានគ្រប់គ្រងផ្នែកម្ហូប និងភេសជ្ជៈ ព្រមទាំងប្រធានផ្នែករក្សាទុកដាក់សុរា និងគ្រឿងស្រវឹងផ្សេងៗ។ ចំណែកអ្នករត់តុវិញ ទទួលបន្ទុកផ្នែកបម្រើភ្ញៀវ រៀបចំតុ និងសម្ភារលើតុ ថែទាំផ្ទះបាយ ព្រមទាំងរៀបចំភេសជ្ជៈតាមប្រភេទ និងតាមការកុម្ម៉ង់របស់ភ្ញៀវ។

ក្នុងករណីខ្លះ ប្រធានគ្រប់គ្រងគឺជាម្ចាស់ភោជនីយដ្ឋានផ្ទាល់។ ក្នុងលក្ខណៈនេះប្រធានគ្រប់គ្រងដែលជាម្ចាស់ច្រើនមើលការខុសត្រូវផ្នែកសេវាកម្ម ការទុកដាក់ប្រាក់កាសរង់ចាំទទួល និងជូនភ្ញៀវសំខាន់ៗដល់តុអាហារ ព្រមទាំងបំពេញនូវកិច្ចការជាច្រើនមុខផ្សេងទៀត។ ក្រៅតែពីបំពេញកិច្ចការនៅក្នុងភោជនីយដ្ឋាន ប្រធានគ្រប់គ្រងក៏ធ្វើការនៅតាមទីកន្លែងមួយចំនួនទៀតដែលបម្រើឱ្យសេវាហូបចុក ដូចជា ហាងបាយ សណ្ឋាគារ អាហារដ្ឋាននៅតាមសាលា និងទីផ្សេងៗទៀតជាច្រើន។


តទៅទំព័របន្ទាប់

## ការអប់រំ និងការបណ្តុះបណ្តាល

ប្រធានគ្រប់គ្រងភោជនីយដ្ឋានត្រូវការជាចាំបាច់នូវបទពិសោធន៍នានាពាក់ព័ន្ធនឹងកិច្ចការនៅក្នុងភោជនីយដ្ឋានមុនពេលអាចក្លាយខ្លួនជាប្រធានគ្រប់គ្រង។ ពួកគេត្រូវចេះរៀបចំអាហារ បម្រើអាហារ ក្បួនខ្នាតអនាម័យ និងកិច្ចការផ្នែកហិរញ្ញវត្ថុ។ បន្ថែមលើនេះ ពួកគេក៏គួរមានជំនាញផ្នែកជំនួញ ដើម្បីគ្រប់គ្រងថវិកា និងបុគ្គលិកឱ្យបានល្អ។ ពួកគេនឹងប្រើនូវជំនាញផ្នែកជំនួញនៅពេលពួកគេធ្វើការទិញដូរតវ៉ាន់ ម្ហូបអាហារ ឧបករណ៍ប្រើប្រាស់ក្នុងហាង។



កម្មវិធីសិក្សាអំពីការគ្រប់គ្រងភោជនីយដ្ឋានអាចស្វែងរកសិក្សាបាននៅតាមសាលាបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមួយចំនួន។ ការសិក្សាតម្រូវឱ្យមានការសិក្សាទាំងក្នុងសាលា និងការអនុវត្តជាក់ស្តែងក្នុងការងារ (on-the-job experience)។

## តើអ្នកដឹងឬទេ ?

វិស័យទេសចរណ៍នៅក្នុងខេត្តសៀមរាបកំពុងតែមានការរីកចម្រើនយ៉ាងខ្លាំង ទន្ទឹមនឹងនោះគេឃើញមានតម្រូវការកម្លាំងពលកម្មផ្នែកបម្រើសេវាកម្មក៏កាន់តែមានសន្ទុះខ្លាំងក្លា ជាពិសេសសម្រាប់បម្រើឱ្យសេវាសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងបដិសណ្ឋារកិច្ច ជាដើម។

ឆ្លើយតបទៅនឹងតម្រូវការខាងលើនេះ ការបណ្តុះបណ្តាលជំនាញ និងកម្លាំងពលកម្មដែលមានសក្តានុពល គឺជាកត្តាសំខាន់មិនអាចខានបាន ដើម្បីត្រៀមខ្លួនបម្រើភ្ញៀវទេសចរដែលកំពុងមានកំណើន និងកំពុងមានចំណាប់អារម្មណ៍ជ្រើសយកម្ពុជា ជាគោលដៅនៃដំណើរកំសាន្ត។

ជាក់ស្តែងនៅក្នុងខេត្តសៀមរាបផ្ទាល់សាលា Paul Dubrule កំពុងបំពេញតួនាទីយ៉ាងសកម្មក្នុងការបណ្តុះបណ្តាលនូវជំនាញមួយចំនួនសម្រាប់តម្រូវទៅតាមសេចក្តីត្រូវការនៃទីផ្សារការងារក្នុងវិស័យទេសចរណ៍។ ក្រៅពីនេះក៏នៅមានសាលាបណ្តុះបណ្តាលផ្សេងៗទៀតផងដែរ ប្រសិនលោកអ្នកមានបំណងស្វែងរកការកការងារ និងចង់បម្រើការងារក្នុងវិស័យដូចពោលមកនេះសូមលៃលកសិក្សារៀនសូត្រអំពីជំនាញណាមួយទៅតាមចំណូលចិត្តរបស់ខ្លួនតាមការគួរ។

## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:
ជំនួញ និងសុខភាព

✦ កម្រិតអប់រំទាបបំផុត:
មធ្យមសិក្សាទុតិយភូមិ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:
ប្រធានគ្រប់គ្រងធុរកិច្ច
ចុងភៅ និងអ្នកដុតនំ ។ល។

## មគ្គុទេសក៍ទេសចរណ៍

(Tour Guides)

**សង្ខេបអំពីជំនាញ**

**មគ្គុទេសក៍ទេសចរណ៍ធ្វើការងារ៖**

✦ ទំនាក់ទំនងផ្នែកគំនិត
✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន
✦ បំពេញកិច្ចការក្នុងភាពជាអ្នកដឹកនាំ

G
**ជំនាញដែលត្រូវការប្រើ៖**
- ✦ ការទទួលខុសត្រូវ
- ✦ ភាពរួសរាយរាក់ទាក់
- ✦ ការនិយាយ និងស្តាប់

## តើមគ្គុទេសក៍ទេសចរណ៍បំពេញកិច្ចការអ្វីខ្លះ?

G មគ្គទេសក៍ទេសចរណ៍មានភារៈដឹកនាំ និងបង្ហាញជូនភ្ញៀវនូវទីកន្លែងដូចជា សារមន្ទី ទីក្រុងប្រាសាទបុរាណ ទីរមណីយដ្ឋានផ្សេងៗ។ មគ្គទេសក៍ខ្លះក៏ដើរតួនាទីដូចជាភ្នាក់ងារធ្វើដំណើរ (travel agents) ដោយហេតុថាពួកគេកក់សំបុត្រយន្តហោះ ឬរថយន្ត សិក្សាស្វែងយល់ពីសណ្ឋាគារ និងផ្ទះសំណាក់នៅក្នុងតំបន់ដែលត្រូវទៅទស្សនា ព្រមទាំងរៀបចំកម្មវិធីធ្វើដំណើរទៀតផង។ ក្រៅពីនេះ មគ្គទេសក៍ព្យាយាមស្វែងយល់ចិត្តសាស្ត្រ និងតម្រូវការរបស់ភ្ញៀវ ឬក្រុមដើម្បីចង់ដឹងថាពួកគេចូលចិត្តអ្វី និងមានចំណាប់អារម្មណ៍លើអ្វី? មគ្គទេសក៍ត្រូវរៀបចំឱ្យមានជម្រើសសកម្មភាពផ្សេងៗសម្រាប់ភ្ញៀវទៅតាមវ័យ ភេទ និងសញ្ជាតិ ជាដើមក្នុងដំណើរកំសាន្តរបស់ពួកគេ។

នៅពេលដំណើរទេសចរណ៍អាចជួបប្រទះ ឬកើតមានជាយថាហេតុនូវបញ្ហាជំតូចៗ ក្នុងករណីនេះ មគ្គទេសក៍ត្រូវមានការទទួលខុសត្រូវខ្ពស់ និងព្យាយាមដោះស្រាយបញ្ហានោះដោយមានទំនុកចិត្ត រហ័សរហួន និងស្ងាត់ស្ងៀម។ មគ្គទេសក៍ត្រូវមានភាពវ៉យឆ្លាត និងងាយបត់បែនដើម្បីតម្រូវទៅតាមសេចក្តីត្រូវការរបស់ភ្ញៀវ ហើយព្យាយាមធ្វើខ្លួនឱ្យមានប្រយោជន៍ដ៏សំខាន់សម្រាប់ភ្ញៀវទាំងអស់។ បន្ថែមលើនេះពួកគេត្រូវស្គាល់ទីតាំង និងប្រភពសេវាកម្មដែលមានប្រយោជន៍នានាករណីមានហេតុបន្ទាន់ត្រូវប្រើប្រាស់ ដូចជា មន្ទីរពេទ្យ មន្ទីរប្រៃសណីយ៍ ការិយាល័យនគរបាល ។ល។

ម្យ៉ាងទៀត ពួកគេត្រូវហ៊ានទទួលឆ្លើយនូវសំណួរ ឬបញ្ហានានាដែលបានកើតឡើងចំពោះភ្ញៀវ ដូចជាករណី ប្តូររូបិយបណ្ណ ក្នុងភោជនីយដ្ឋាន និងហេតុការណ៍ផ្សេងទៀត។ មគ្គទេសក៍ត្រូវតែធានាថាម្ហូបអាហារ និងការស្នាក់អាស្រ័យបានផ្តល់នូវបទដ្ឋានមួយដែលភ្ញៀវរំពឹងចង់បាន។ ពេលភ្ញៀវត្រលប់ទៅវិញ មគ្គទេសក៍ត្រូវជួយមើលឥវ៉ាន់របស់ភ្ញៀវឱ្យបានផ្ញើជាស្ថាពរទៅដល់យន្តហោះ ឬរថយន្តព្រមទាំងតាមដានចំពោះការធ្វើដំណើរប្រកបដោយសុវត្ថិភាពរបស់ភ្ញៀវ។



ជាទូទៅ មគ្គទេសក៍គឺជាមនុស្សរួសរាយរាក់ទាក់ និងមានចំណេះជ្រៅជ្រះអំពីទីកន្លែងដែលគេរស់នៅ និងទស្សនា។ ហើយត្រូវមានទំនុកចិត្ត និងចេះស្វែងយល់ពីចិត្ត ឬអារម្មណ៍របស់ភ្ញៀវទៅតាមប្រភេទនីមួយៗទៀតផង។

## ការអប់រំ និងការបណ្តុះបណ្តាល

G ការងារជាមគ្គទេសក៍ទេសចរណ៍មិនតម្រូវឱ្យមានកម្រិតសញ្ញាបត្រ ឬការអប់រំខ្ពស់នោះទេ។ ប៉ុន្តែតម្រូវឱ្យមានចំណេះផ្នែកប្រវត្តិសាស្ត្រ ភូមិសាស្ត្រ សិល្បៈស្ថាបត្យកម្ម ភាសាបរទេស ការធ្វើបទបង្ហាញ និងជំនាញក្នុងការទំនាក់ទំនង។

បច្ចុប្បន្ននេះមានសាលាជាច្រើនបានផ្តល់ការអប់រំ និងវគ្គបណ្តុះបណ្តាលស្តីពីជំនាញទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច។ បន្ថែមលើនេះ ការអប់រំបណ្តុះបណ្តាលវគ្គមគ្គទេសក៍ទេសចរណ៍ក៏មានសកម្មភាពគួរឱ្យកត់សម្គាល់ផងដែរ។ ជាពិសេស មគ្គទេសក៍ទេសចរណ៍ដែលបម្រើភ្ញៀវនៅ

តាមគោលដៅទេសចរណ៍សំខាន់ៗ ដូចជា តំបន់ទេសចរណ៍វប្បធម៌ក្នុងខេត្តសៀមរាប និងទេសចរណ៍ធម្មជាតិ ជាដើម។

យោងតាមសារាចរណែនាំ ស្តីពីការគ្រប់គ្រងអាជីវកម្មមគ្គុទេសក៍ទេសចរណ៍ ដែលចេញដោយក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា៖ រាល់ការធ្វើអាជីវកម្មមគ្គុទេសក៍ទេសចរណ៍ សាមីជនត្រូវមានច្បាប់អនុញ្ញាតពីក្រសួងទេសចរណ៍។ ដូច្នេះ សាមីជនដែលមានបំណងចង់ប្រកបអាជីវកម្មមគ្គុទេសក៍ទេសចរណ៍ត្រូវស្នើសុំអាជ្ញាបណ្ណពីក្រសួងទេសចរណ៍ស្របទៅតាមមាត្រាដែលមានចែងនៅក្នុងប្រកាស ស្តីពីការផ្តល់អាជ្ញាបណ្ណទេសចរណ៍ដល់អាជីវកម្មមគ្គុទេសក៍ទេសចរណ៍។

## តើអ្នកដឹងឬទេ ?

ខ្មែរយើងច្រើននិយមហៅមគ្គុទេសក៍ទេសចរណ៍ថា «អ្នកនាំភ្ញៀវ» ជាពិសេស អ្នករស់នៅក្នុងខេត្តសៀមរាបដែលជាទីសម្បូរណ៍ទៅដោយបុរាណដ្ឋាន និងប្រាសាទចាស់ៗបន្សល់ទុកពីបុរាណសម័យនៃចក្រភពអង្គរដ៏រុងរឿង។

អ្នកនាំភ្ញៀវទាំងអស់នោះត្រូវទទួលការបណ្តុះបណ្តាល និងចេញអាជ្ញាបណ្ណដោយក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា។ ម្យ៉ាងទៀត មគ្គុទេសក៍ទាំងអស់ត្រូវស្លៀកពាក់នូវឯកសណ្ឋានដែលកំណត់ដោយប្រកាសស្តីពីឯកសណ្ឋានមគ្គុទេសក៍ទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ដែលចេញដោយក្រសួងទេសចរណ៍។

*ពីឆ្វេងទៅស្តាំ៖ ទេសចរទស្សនានៅតំបន់អង្គរ និងតំបន់ឆ្នេរលំហែរខេត្តព្រះសីហនុ*





## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

ភាសាបរទេស និងការនិយាយពណ៌នា

✦ កម្រិតអប់រំទាបបំផុត:

បរិញ្ញាបត្ររង ឬបរិញ្ញាបត្រ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

ភ្នាក់ងារធ្វើដំណើរ

បុគ្គលិកបម្រើការនៅតាមរមណីយដ្ឋាន

## ជាងកាត់ដេរ និងអ្នកច្នៃម៉ូត

(Tailors)

សង្ខេបអំពីជំនាញ

ជាងកាត់ដេរ និងអ្នកច្នៃម៉ូតធ្វើការងារ៖

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ បំពេញកិច្ចការក្នុងភាពជាអ្នកដឹកនាំ

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

G

**ជំនាញដែលត្រូវការប្រើ៖**

- ការគិតប្រកបដោយភាពច្នៃប្រឌិត
- ការអាន និងការសរសេរ
- ការនិយាយ និងការស្តាប់

## តើជាងកាត់ដេរ និងអ្នកច្នៃម៉ូតធ្វើកិច្ចការអ្វីខ្លះ?

ជាងកាត់ដេរ និងអ្នកច្នៃម៉ូតបំពេញកិច្ចការរាល់ថ្ងៃជាមួយនឹងការកាត់ ដេរ ប៉ះ ជួសជុល និងច្នៃម៉ូតសម្លៀកបំពាក់ឱ្យអតិថិជន។ ជាងកាត់ដេរភាគច្រើនដេរសម្លៀកបំពាក់សម្រាប់បុរស ដូចជា ខោ និងអាវធំ ឬសម្លៀកបំពាក់ទូទៅ។ ចំណែកអ្នកច្នៃម៉ូតវិញ ធ្វើការកាត់ដេរជាពិសេសចំពោះសម្លៀកបំពាក់របស់ស្ត្រីដែលមានតុបតែងលម្អទៅដោយម៉ូត និងគ្រឿងលម្អជាច្រើន ដូចជាសម្លៀកបំពាក់សម្រាប់រៀបអាពាហ៍ពិពាហ៍ ពិធីជប់លៀង និងម៉ូតផ្សេងៗទៀតជាច្រើនអាស្រ័យទៅតាមការកុម្ម៉ង់របស់អតិថិជន។

ជាងកាត់ដេរ និងអ្នកច្នៃម៉ូតអាចធ្វើការដោយខ្លួនឯងតាមរយៈការបើកហាង ឬកន្លែងកាត់ដេរ។ ម្យ៉ាងទៀត ពួកគេក៏អាចបំពេញកិច្ចការឱ្យក្រុមហ៊ុន ឬហាងកាត់ដេរធំៗដើម្បីទទួលបានមកវិញនូវប្រាក់បៀវត្សទៅតាមកម្រិតជំនាញ និងឯកទេសរបស់គេម្នាក់ៗ។

អ្នកកាត់ដេរ និងអ្នកច្នៃម៉ូតខ្លះទទួលកាត់សម្លៀកបំពាក់ និងជ្រើសរើសម៉ូត ព្រមទាំងប្រភេទក្រណាត់សម្រាប់ភ្ញៀវ ដោយការប្រើប្រាស់ជំនាញ និងបទពិសោធន៍របស់ពួកគេដែលមាននៅក្នុងវិស័យនេះ។ ជាទូទៅ រាល់ការកាត់សម្លៀកបំពាក់នីមួយៗ ជាងត្រូវការវាស់វែងនូវខ្នាតសំខាន់ៗរបស់អតិថិជន ឬម្ចាស់។ ជួនកាល គេអាចកាត់តាមគំរូម៉ូត ឬពុម្ពដែលមានស្រាប់ទៅតាមការចូលចិត្តរបស់អតិថិជន។ ធម្មតា ការកាត់សម្លៀកបំពាក់មិនប្រាកដថាពាក់សម ឬត្រូវចិត្តភ្ញៀវគ្រប់លក្ខណៈណាស់ ដូច្នេះជាងត្រូវលៃលកកែតម្រូវម្តង ឬពីរដងឱ្យពាក់ទៅឃើញសមមិនទាស់ចិត្តរបស់ភ្ញៀវម្នាក់ៗ។




ក្នុងការកាត់ដេរ ជាងត្រូវការប្រើប្រាស់កន្ត្រៃ ម្ជុល ចេសអំបោះ និងម៉ាស៊ីនដេរ ដើម្បីដេរផ្គុំភ្ជាប់នូវបំណែកនីមួយៗរបស់ក្រណាត់ឱ្យចេញជារូបរាងខោ ឬអាវ។ ក្រៅពីនេះ កិច្ចការបន្ទាប់បន្សំផ្សេងទៀតគឺការកាត់តម្រឹមចេសអំបោះ ការដាក់ឡេវ និងអ៊ុតតម្រង់ផ្នត់ឱ្យបានស្អាតល្អមុននឹងស្លៀក ឬពាក់ខោអាវនោះ។

ចំណែកឯ ជាងកាត់ដេរ ឬអ្នកច្នៃម៉ូតដែលធ្វើការនៅតាមហាងកាត់ដេរធំៗខ្លះ ទំនងជាមានឯកទេសជាក់លាក់តែរៀងៗខ្លួន ដូចជា អ្នកកាត់ពុម្ព អ្នកដេរ អ្នកកាត់ចេស និងដាក់ឡេវ ជាដើម។ និយាយជារួម ការកាត់ដេរឱ្យចេញជាម៉ូត ឬសម្លៀកបំពាក់គឺត្រូវការចំណាយពេល និងបច្ចេកទេសច្បាស់លាស់ដើម្បីឱ្យសមតាមបំណងរបស់អតិថិជន។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីទទួលបានជំនាញ និងក្លាយខ្លួនជាជាងកាត់ដេរ ឬអ្នកច្នៃម៉ូតមួយរូប គេត្រូវការនូវភាពអត់ធ្មត់ក្នុងការសិក្សាហាត់រៀន ដោយចាប់ផ្តើមចេញពីការអនុវត្តកិច្ចការនៅក្នុងផ្ទះ រហូតដល់បណ្តុះបណ្តាលបែបបច្ចេកទេស


តទៅទំព័របន្ទាប់

និងវិជ្ជាជីវៈនៅតាមហាងកាត់ដេរ ឬសាលាបង្រៀនកាត់ដេរ។

ជម្មតា ការសិក្សាវិជ្ជានេះហាក់មិនតម្រូវឱ្យមានចំណេះដឹងទូទៅខ្ពង់ខ្ពស់ពេកទេ។ មានន័យថា គេអាចសិក្សាត្រឹមកម្រិតមធ្យមសិក្សាទុតិយភូមិ ឬយ៉ាងហោចណាស់កម្រិតមធ្យមសិក្សាបឋមភូមិក៏បាន។ ប្រការដែលសំខាន់គឺបុគ្គលនោះត្រូវមានចំណូលចិត្ត និងការតាំងចិត្តហាត់រៀនឱ្យបានច្បាស់លាស់។ ប៉ុន្តែ ប្រសិនគេចង់បង្កើនចំណេះ និងជំនាញផ្នែកនេះឱ្យបានកាន់តែទូលំទូលាយ បុគ្គលនោះគួរតែហាត់រៀនឱ្យមានសញ្ញាបត្រកម្រិតណាមួយលើមុខជំនាញនេះនៅតាមលាសាបណ្តុះបណ្តាលបច្ចេកទេសនានា។



## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

សិល្បៈ កិច្ចការមេផ្ទះ (ដេរប៉ាក់) និងជំនួញ

✦ **កម្រិតអប់រំទាបបំផុត:**

មធ្យមសិក្សាបឋមភូមិ ឬមធ្យសិក្សាទុតិយភូមិ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកបង្ហាញម៉ូត

កម្មករផ្នែកវាយនភណ្ឌ

អ្នកសម្របសម្រួលខាងការបង្ហាញម៉ូត និង

អ្នកកាត់ដេរសម្លៀកបំពាក់ប្រពៃណី ។ល។

## តើអ្នកដឹងឬទេ ?

វិស័យវាយនភណ្ឌ និងរោងចក្រកាត់ដេរកម្ពុជានៅតែដើរតួនាទីជាវិស័យឧស្សាហកម្មដ៏នាំមុខគេមួយ នៅក្នុងចំណោមវិស័យឧស្សាហកម្មអាទិភាពផ្សេងៗទៀត។ វិស័យនេះបានកំពុងផ្តល់នូវសក្តានុពល និងផលទុនសម្រាប់លើកស្ទួយការរីកចម្រើននៃសេដ្ឋកិច្ចជាតិ។ រីឯ តម្រូវការកម្លាំងពលកម្មសម្រាប់បម្រើឱ្យវិស័យនេះទៀតសោតក៏មានទំហំធំធេង ដែលបានក្លាយជាការចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្តល់នូវឱកាសការងារក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ដល់យុវជន និងយុវនារីខ្មែរ ហើយដែលនាំទៅដល់ការបង្កើនប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

# អ្នកបង្កើតគំរូម៉ូតសម្រាប់ឧស្សាហកម្ម

( Industrial Designers )

**សង្ខេបអំពីជំនាញ**

**អ្នកបង្កើតគំរូម៉ូតសម្រាប់ឧស្សាហកម្មធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ បង្កើត ឬបង្កើនប្រព័ន្ធដំណើរការ

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត

✦ គណិតវិទ្យា

✦ ការដោះស្រាយបញ្ហា

## តើអ្នកបង្កើតគំរូម៉ូតសម្រាប់ឧស្សាហកម្មបំពេញកិច្ចការអ្វីខ្លះ?

អ្នកបង្កើតគំរូម៉ូតសម្រាប់ឧស្សាហកម្ម គឺជាផ្នែកមួយដ៏មានសារសំខាន់នៅក្នុងដំណើរការផលិត។ ពួកគេបង្កើតគំរូម៉ូតសម្រាប់សម្ភារថ្មីៗ និងកែច្នៃគំរូដែលមានស្រាប់ឱ្យកាន់តែមានភាពប្រសើរឡើងតាមរយៈរូបរាង តួនាទីក្នុងការប្រើប្រាស់ ប្រសិទ្ធភាព និងភាពងាយស្រួល។ អ្នកបង្កើតគំរូម៉ូតភាគច្រើនបានផ្តោតជាពិសេសទៅលើការបង្កើតនូវផលិតផលប្រភេទអ្វីមួយ ដូចជាឧបករណ៍ប្រើប្រាស់នៅក្នុងផ្ទះ រថយន្ត និងគ្រឿងសង្ហារឹម ជាដើម។ អ្នកខ្លះធ្វើការជាលក្ខណៈឯកជនដោយខ្លួនឯង ឯខ្លះទៀតបម្រើការនៅក្នុងរោងចក្រ ឬសហគ្រាស។

អ្នកបង្កើតគំរូម៉ូតក្នុងវិស័យឧស្សាហកម្មច្រើនធ្វើការជាផ្នែកមួយក្នុងក្រុមអភិវឌ្ឍផលិតផល ដែលព្យាយាមគិតអំពីមធ្យោបាយប្លែកៗក្នុងការធ្វើឱ្យផលិតផលថ្មីៗមានភាពទាក់ - ទាញពីសំណាក់អតិថិជន ឬអ្នកប្រើប្រាស់។ នៅក្នុងកិច្ចការនេះ ពួកគេត្រូវការគូរនូវគំនូរព្រាងជាច្រើនលើកច្រើនសារដើម្បីបង្កើត និងកែសម្រួលនូវរូបរាងរបស់វត្ថុបង្កើតថ្មីឱ្យមានភាពប្រសើរ។ ការគូរអាចជាគំនូរដោយដៃ ឬប្រើកុំព្យូទ័រ និងកម្មវិធីប្លែកៗ។ បន្ទាប់ពីគូរគំនូរព្រាងរួចរាល់ ពួកគេនឹងធ្វើការវាស់វែងនូវចំណុចលម្អិតៗរបស់វត្ថុ ឬឧបករណ៍ ដើម្បីកំណត់ពីលក្ខណៈរូប ធាតុផ្សំ សម្ភារសម្រាប់ផលិត ការប្រើប្រាស់ ពណ៌ និងសារធាតុផ្សេងៗជាច្រើនទៀត។ បន្ទាប់មកទៀត គំនូរព្រាង ខ្នាតរង្វាស់ និងកិនភាគទាំងអស់នឹងត្រូវបញ្ជូនទៅកាន់វិស្វករ ដើម្បីធ្វើការសិក្សាបង្កើតឱ្យចេញជារូបរាងពិត។

ក្នុងករណីខ្លះវិស្វករទទួលបង្កើតនូវឧបករណ៍ទៅតាមគំនូរព្រាង រួចហើយធ្វើការសាកល្បងអំពីដំណើរការរបស់ផលិតផល កម្លាំង ភាពធន់ និងកត្តាផ្សេងៗទៀត ដើម្បីធានាឱ្យបានច្បាស់លាស់ថាផលិតផលថ្មីមានដំណើរការដោយល្អទៅតាមការគ្រោងទុក មានសុវត្ថិភាព និងគោរពតាមបទដ្ឋានរបស់ឧស្សាហកម្ម។

## ការអប់រំ និងការបណ្តុះបណ្តាល

ប្រសិន អ្នកមានបំណងក្លាយខ្លួនជាអ្នកបង្កើតគំរូម៉ូតសម្រាប់វិស័យឧស្សាហកម្ម អ្នកគួរចាប់ផ្តើមសិក្សាមុខវិជ្ជាពាក់ព័ន្ធមួយចំនួនឱ្យបានច្រើន ដូចជា សិល្បៈគំនូរ និងសិល្បៈដទៃទៀត កុំព្យូទ័រក្រាហ្វិក នោះទើបជាការប្រសើរ។ បន្ថែមលើនេះ អ្នកត្រូវសិក្សាមុខវិជ្ជាការបង្កើតគំរូម៉ូតក្នុងវិស័យឧស្សាហកម្ម។ ជំនាញប្រភេទនេះអាចសិក្សានៅតាមសាលាបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ វិទ្យាស្ថានបច្ចេកទេស និងសាលាសិល្បៈ ជាដើម។ ការសិក្សាមុខវិជ្ជានេះតម្រូវឱ្យសិស្ស និស្សិតហាត់គូរនៅលើក្រដាស និងគូរជាគំនូរ 3D នៅក្នុងកុំព្យូទ័រ។

### គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលាៈ**

សិល្បៈ វិទ្យាសាស្ត្រកុំព្យូទ័រ និងគណិតវិទ្យា

✦ **កម្រិតអប់រំទាបបំផុតៈ**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នាៈ**

ស្ថាបត្យករ

វិស្វករអគ្គិសនី និងអេឡិចត្រូនិក

នាយកផ្នែកសិល្បៈ និង

អ្នកបច្ចេកទេសគំនូរក្រាហ្វិក ជាដើម។

# អ្នកបង្កើតកម្មវិធីកុំព្យូទ័រ

( Software Designers )

**សង្ខេបអំពីជំនាញ**

**អ្នកបង្កើតកម្មវិធីកុំព្យូទ័រធ្វើការងារ៖**

- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន
- ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកទេស

G

**ជំនាញដែលត្រូវការប្រើ៖**

- ការគិតប្រកបដោយភាពច្នៃប្រឌិត
- គណិតវិទ្យា
- ការដោះស្រាយបញ្ហា

## តើអ្នកបង្កើតកម្មវិធីកុំព្យូទ័របំពេញកិច្ចការអ្វីខ្លះ?

G គ្រប់កុំព្យូទ័រទាំងអស់ កាលណាមិនមានបញ្ចូលកម្មវិធី នោះគេមិនអាចប្រើប្រាស់វាបានទេ។ កម្មវិធីកុំព្យូទ័រ គឺជាប្រព័ន្ធផ្ដុំដោយលេខកូដដែលសម្រាប់ចង្អុលបង្ហាញ និងបញ្ជាឱ្យកុំព្យូទ័រមានដំណើរការ។ កម្មវិធីនីមួយៗត្រូវការតម្លើង (Install) ដោយឡែកៗពីគ្នាទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់ ដូចជា កម្មវិធីហ្គេម កម្មវិធីវាយអត្ថបទ និងកម្មវិធីសម្រាប់ធ្វើតារាង ជាដើម។ ក្រៅពីនេះ កម្មវិធីខ្លះទៀតក៏ត្រូវបានគេបង្កើតឡើងជាពិសេសសម្រាប់ការប្រើនៅក្នុងកិច្ចការជំនួញ ឬវិស័យអ្វីមួយផងដែរ។

នៅក្នុងការបង្កើតកម្មវិធីមួយ អ្នកបច្ចេកទេសត្រូវការរិះគិតយ៉ាងម៉ត់ចត់អំពីតួនាទី ដំណើរការ និងរូបលក្ខណៈរបស់កម្មវិធីនៅពេលប្រើប្រាស់។ អ្នកបង្កើតកម្មវិធីពិនិត្យ និងសម្រេចជាបឋមទៅលើកម្មវិធីបែបណាដែលគួរផលិត ឬបង្កើតបាន ឧទាហរណ៍ កម្មវិធិបង្កើតតារាង ការគ្រប់គ្រងបញ្ជីចំណូល និងចំណាយ ជាដើម។ នៅក្នុងការធ្វើកម្មវិធីទាំងនេះអ្នកបង្កើតកម្មវិធីត្រូវសម្រេចថាមាតិកា និងរូបបែបណាដែលគួរប្រើ ហើយរូបរាងរបស់កម្មវិធីគួរមានសភាពបែបណាដែលអាចបម្រើឱ្យផ្នែកសោភណភាព និងមុខងារនៅក្នុងការប្រើប្រាស់។

អ្នកបង្កើតកម្មវិធីខ្លះមានភារៈរៀបចំធ្វើកម្មវិធីប្រើប្រាស់ជាពិសេសមួយសម្រាប់ក្រុមហ៊ុន និងតម្រូវការជាក់លាក់មួយដើម្បីសម្រួលដល់ការគ្រប់គ្រងនៅក្នុងក្រុមហ៊ុន ឬស្ថាប័ននោះ។ ក្រុមហ៊ុន ឬស្ថាប័នខ្លះមានទំហំការងារ និងការគ្រប់គ្រងធំធេង ដែលតម្រូវឱ្យបង្កើតកម្មវិធីប្រើប្រាស់ផ្ទាល់សម្រាប់កុំព្យូទ័ររបស់ពួកគេ។ ក្នុងករណីនេះ អ្នកបង្កើតកម្មវិធីត្រូវសិក្សាអំពីប្រព័ន្ធកុំព្យូទ័រដែលមាននៅក្នុងស្ថាប័ន ដើម្បីសម្របសម្រួលបង្កើតចេញជាកម្មវិធីសមស្របមួយ។

ក្នុងការបង្កើតកម្មវិធីមួយ អ្នកបង្កើតកម្មវិធីត្រូវសិក្សាដោយលើកជាសំណើរអំពីការចំណាយ និងពេលវេលា។ បន្ទាប់ពីគម្រោងសិក្សាត្រូវបានទទួលការឯកភាព អ្នកបង្កើតកម្មវិធីត្រូវសហការជាមួយអ្នកជំនាញពាក់ព័ន្ធដើម្បីបង្កើតឱ្យចេញជារូបរាងកម្មវិធីដែលអាចប្រើប្រាស់បាន។ អ្នកបង្កើតកម្មវិធីត្រូវសរសេរពីលក្ខណៈពិសេសរបស់កម្មវិធី និងវិធីប្រើប្រាស់ដែលបង្កន្ទូវលក្ខណៈងាយស្រួលដល់អ្នកប្រើទូទៅ។

## ការអប់រំ និងការបណ្ដុះបណ្ដាល

G ដើម្បីអាចក្លាយខ្លួនជាអ្នកបង្កើតកម្មវិធីកុំព្យូទ័រ គេត្រូវសិក្សាកម្រិតបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូ - ទ័រ ព្រមទាំង តម្រូវការបទពិសោធន៍ការងារក្នុការប្រើប្រាស់ភាសាក្នុងកម្មវិធីកុំព្យូទ័រ។ បន្ថែមលើនេះ អ្នកត្រូវបច្ចេកទេសត្រូវមានចំណេះដឹងក្នុងផ្នែកដែលខ្លួនចង់រចនា ឬបង្កើតកម្ម


តទៅទំព័របន្ទាប់

វិធីនោះ ដូចជា វិស័យអប់រំ ជំនួញ និងវិទ្យាសាស្ត្រ ជាដើម។ ឧទាហរណ៍ អ្នកដែលមានឯកទេសខាងវិទ្យាសាស្ត្រកុំព្យូទ័ររួមជាមួយនិងជំនាញបន្ទាប់បន្សំផ្នែកជំនួញ ឬគណនេយ្យនឹងបង្កលក្ខណៈងាយស្រួលដល់ការបង្កើតកម្មវិធី ដែលពាក់ព័ន្ធនឹងការបង្កើតកម្មវិធីកុំព្យូទ័រផ្នែកជំនួញ និងគណនេយ្យ។

## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

វិទ្យាសាស្ត្រកុំព្យូទ័រ និងគណិតវិទ្យា

✦ កម្រិតអប់រំទាបបំផុត:

បរិញ្ញាបត្រ

✦ ព័ត៌មានគួរអានបន្ថែមស្ដីពីអ្នកមានជំនាញស្រដៀងគ្នា:

អ្នកឯកទេសផ្នែកមូលដ្ឋានទិន្នន័យ និង

វិស្វករផ្នែកកម្មវិធីកុំព្យូទ័រ ជាដើម។

# អ្នកផ្សាយកម្មវិធីវិទ្យុ និងទូរទស្សន៍

( Radio and Television Announcers )

សង្ខេបអំពីជំនាញ

អ្នកផ្សាយកម្មវិធីវិទ្យុ និងទូរទស្សន៍ធ្វើការងារ៖

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ បំពេញការងារជាក្រុម

G

ជំនាញដែលត្រូវការប្រើ៖

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត

✦ ការអាន និងការសរសេរ

✦ ការនិយាយ និងការស្ដាប់

## តើអ្នកផ្សាយកម្មវិធីវិទ្យុ និងទូរទស្សន៍បំពេញកិច្ចការអ្វីខ្លះ?

G អ្នកផ្សាយកម្មវិធីវិទ្យុ និងទូរទស្សន៍គឺជាអ្នកអានឈ្មោះ និងលេខរបស់ស្ថានីយ៍ ប្រកាសអំពីពេលម៉ោងសម្រាក ការផ្សាយបើក និងបិទកម្មវិធី ការប្រកាសផ្សាយអំពីសេវាសាធារណៈ។ អ្នកផ្សាយវិទ្យុធ្វើការសម្ភាសន៍ភ្ញៀវដែលចូលរួមកម្មវិធី ឬសម្របសម្រួលកម្មវិធីពិភាក្សា។

អ្នកផ្សព្វផ្សាយមានតួនាទីច្រើន ដូចជា អ្នកចាក់ភ្លេង ឬតន្ត្រី (disc jockeys) សម្រាប់កំដរក្នុងកម្មវិធីផ្សាយពាណិជ្ជកម្ម និងការជជែកផ្សេងៗ។ ជួនកាលពួកគេអានព័ត៌មាន ការព្យាករណ៍អាកាសធាតុ និងព័ត៌អំពីចរាចរណ៍។ ជាទូទៅ ការនិយាយរបស់ពួកគេពុំមានសរសេរព្រាងទុកទេ លើកលែងតែព័ត៌មានខ្លះៗដូចជា ការផ្សាយពាណិជ្ជកម្ម និងសេចក្ដីរាយការណ៍ព័ត៌មានតែប៉ុណ្ណោះ។

ចំណែកឯពិធីករផ្នែកកម្មវិធីកីឡានឹងធ្វើពិពណ៌នាអំពីព្រឹត្តិការណ៍កីឡា។ អ្នកផ្សព្វផ្សាយផ្នែកនេះត្រូវមានចំណេះដឹងអំពីកីឡាជាច្រើនប្រភេទ ដើម្បីអាចឱ្យគេធ្វើការផ្សព្វផ្សាយបានត្រឹមត្រូវ ឆាប់រហ័សទាន់ពេលវេលាទៅតាមព្រឹត្តិការណ៍នីមួយៗ។ គួរកត់សម្គាល់ថា កីឡាប្រភេទខ្លះដែលមានសកម្មភាពរហ័សរហួននៅពេលប្រកួត ដូចជាបាល់ទាត់ ជាដើម តម្រូវឱ្យអ្នកពិពណ៌នាមានភាពស្ទាត់ជំនាញក្នុងការបរិយាយអំពីសកម្មភាពរបស់កីឡាករ ដោយមិនបង្អង់ និងមិនមានការភ័ន្តច្រឡំ។

អ្នកផ្សព្វផ្សាយព័ត៌មានមានជំនាញក្នុងការរាយការណ៍ព័ត៌មាន ដែលរួមទាំងព្រឹត្តិការណ៍ក្នុងប្រទេស ក្នុងតំបន់ និង


តទៅទំព័របន្ទាប់

អន្តរជាតិ។ អ្នកផ្សព្វផ្សាយព័ត៌មានខ្លះអាចបរិយាយបន្ថែមបន្ថយទៅលើព័ត៌មានដោយបញ្ចូលគំនិត និងអំណះអំណាងផ្សេងៗ។ អ្នកផ្សព្វផ្សាយព័ត៌មានអាចសរសេរអត្ថបទព័ត៌មានដោយខ្លួនឯង ឬអានតែទៅតាមអ្វីដែលបានសរសេរបញ្ជូនមកដោយអ្នកយកព័ត៌មាន។ គួរកត់សម្គាល់ថា អ្នកផ្សាយព័ត៌មានអាចផ្សាយជាច្រើនលើកទៅតាមកម្មវិធី ឬផ្សាយព័ត៌មានខ្លីៗទាន់ហេតុការណ៍ក្នុងចន្លោះកម្មវិធីផ្សាយដទៃ។ គេសង្កេតឃើញថា អ្នកផ្សាយព័ត៌មានក៏ត្រូវបានបែងចែកជាជំនាញ ឬការទទួលខុសត្រូវតាមផ្នែកផ្សេងៗគ្នា ដូចជាព័ត៌មានសេដ្ឋកិច្ច នយោបាយ សុខភាព និងសន្តិសុខ ។ល។



## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:
ការធ្វើបទអត្ថាធិប្បាយ និងភាសាបរទេស
✦ កម្រិតអប់រំទាបបំផុត:
បរិញ្ញាបត្រ ឬបរិញ្ញាបត្ររង
✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:
វិស្វករផ្នែកការផ្សព្វផ្សាយ
អ្នកចាក់បទភ្លេង
អ្នកផលិតកម្មវិធីវិទ្យុ និង
អ្នកនិពន្ធ ។ល។




## ការអប់រំ និងការបណ្តុះបណ្តាល

G អ្នកធ្វើការផ្នែកផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ គួរមានកម្រិតអប់រំទាបបំផុតត្រឹមបរិញ្ញាបត្រលើមុខវិជ្ជាសំខាន់ៗមួយចំនួនដូចជា ផ្នែកអក្សរសាស្ត្រ សារព័ត៌មានវិទ្យា និងភាសាបរទេស ជាដើម។ ក្រៅពីនេះពួកគេគួរសិក្សាបន្ថែមលើជំនាញក្នុងការធ្វើអត្ថាធិប្បាយ និងវិភាគអំពីព័ត៌មាន។ នៅប្រទេសកម្ពុជា គេសង្កេតឃើញថាការងារផ្នែកផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ច្រើនតែហាត់រៀន ឬទទួលបានចំណេះតាមរយៈការបំពេញការងារផ្ទាល់នៅតាមស្ថានីយ៍វិទ្យុ ឬទូរទស្សន៍ ដោយពុំទាន់មានសាលាបច្ចេកទេស ឬសាលាបណ្តុះបណ្តាលណាមួយផ្តល់នូវការអប់រំជាពិសេសបែបនេះនៅឡើយទេ។

## វេជ្ជបណ្ឌិតផ្នែកការវះកាត់
( Surgeons )

សង្ខេបអំពីជំនាញ
វេជ្ជបណ្ឌិតផ្នែកការវះកាត់ធ្វើការងារ៖
✦ ដឹកនាំការងារក្នុងភាពជាអ្នកដឹកនាំ
✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន
✦ បំពេញការងារជាក្រុម
G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
✦ ការអនុវត្តកិច្ចការប្រកបដោយហេតុផល
✦ ការនិយាយ និងការស្តាប់

## តើវេជ្ជបណ្ឌិតផ្នែកការវះកាត់បំពេញកិច្ចការអ្វីខ្លះ?

G វេជ្ជបណ្ឌិតផ្នែកការវះកាត់មានឯកទេសក្នុងការវះកាត់ទៅលើអ្នកជម្ងឺ ដើម្បីធ្វើការព្យាបាលកន្លែងដែលមានរបួស ឬបាក់ស្រាំ វះកាត់យកផ្នែកខ្លះដែលជាជម្ងឺចេញពីរាងកាយរបស់មនុស្ស។ បន្ថែមលើនេះ វេជ្ជបណ្ឌិតផ្នែកវះកាត់ក៏បំពេញការងារផ្នែកវះកាត់កែសម្រួលផ្នែកខ្លះនៃរាងកាយដែលមិនមានដំណើរការទៅតាមប្រក្រតីភាព។

វេជ្ជបណ្ឌិតខ្លះបំពេញការងារក្នុងការវះកាត់ទូទៅ រីឯវេជ្ជបណ្ឌិតផ្សេងទៀតមានឯកទេសពិសេសចំពោះតែការវះ - កាត់ផ្នែកណាមួយនៃរាងកាយ ឬសរីរាង្គរបស់មនុស្សតែប៉ុណ្ណោះ។ ក្នុងចំណោមនោះ គេសង្កេតឃើញមានវេជ្ជបណ្ឌិតឯកទេសខាងការតឆ្អឹងបាក់ស្រាំ (ឆ្អឹងដៃ ឬជើង) ព្រមទាំងធ្វើការវះកាត់ និងព្យាបាលជម្ងឺដែលពាក់ព័ន្ធឆ្អឹង ឬនៅក្នុងខួរឆ្អឹងផងដែរ។

វេជ្ជបណ្ឌិតផ្នែកជម្ងឺខួរក្បាល និងសរសៃឈាមក្នុងខួរក្បាលមានឯកទេសផ្នែកថតឆ្លុះ និងកំណត់មុខសញ្ញាជម្ងឺមុននឹងធ្វើការវះកាត់ ឬព្យាបាល។ ចំណែកវេជ្ជបណ្ឌិតខ្លះទៀតមានឯកទេសខាងការវះកាត់ និងព្យាបាលរបួស ឬជម្ងឺនៅក្នុងទ្រូងដូចជា សួត បេះដូង និងបំពង់អាហារ ជាដើម។ ដោយឡែកវេជ្ជបណ្ឌិតផ្នែកវះកាត់កែសម្ផស្សវិញមានតួនាទី និងឯកទេសខាងវះកាត់បន្ថែមទៅលើផ្នែកណាមួយនៃរាងកាយខាងក្រៅរបស់មនុស្ស ដូចជាការកែវះកាត់កែតម្រូវទៅលើភាពខុសប្រក្រតីនៃសរីរាង្គពីកំណើត របួស និងស្លាកស្នាមរលាកភ្លើង ជាដើម។



វេជ្ជបណ្ឌិតនឹងធ្វើការពិនិត្យជាបឋមទៅលើអ្នកជម្ងឺ ឬជនរងគ្រោះ បន្ទាប់មកសិក្សាអំពីប្រវត្តិនៃការព្យាបាល ឬការប្រើប្រាស់ឱសថពីមុនមក ព្រមទាំងលទ្ធផលនៃការធ្វើតេស្តសាកល្បងចំពោះរាងកាយ។ បន្ទាប់ពីពិនិត្យល្អិតល្អន់ទៅលើចំណុចសំខាន់ៗទាំងអស់នោះរួចហើយ វេជ្ជបណ្ឌិតនឹងវាយតម្លៃសម្រេចជាមួយអ្នកឯកទេសផ្សេងទៀតអំពីសភាពជម្ងឺ ឬអាការៈ តើវិធីវះកាត់ដែលល្អ និងសមស្របទៅនឹងសភាពរបស់អ្នកជម្ងឺបំផុត។ មុននឹងធ្វើការវះកាត់ វេជ្ជបណ្ឌិតនឹងពិគ្រោះជាមួយអ្នកជម្ងឺ ដើម្បីសុំការសម្រេចចិត្តចុងក្រោយ។



នៅក្នុងអំឡុងពេលវះកាត់ វេជ្ជបណ្ឌិតផ្នែកនេះគឺជាប្រធានដឹកនាំក្រុមវះកាត់។ ក្រុមវះកាត់រួមបញ្ចូលនូវអ្នកឯកទេសជាច្រើនដូចជា ផ្នែកថ្នាំស្ពឹក ផ្នែកជំនួយការ និងគិលានុបដ្ឋាក។ បន្ទាប់ពីការវះកាត់រួចរាល់ជាស្ថាពរ វេជ្ជបណ្ឌិតនៅតែបន្តតាមដានសភាពរបស់អ្នកជម្ងឺ ដើម្បីបញ្ជាក់ថាពួកគេជាសះស្បើយ និងវិលត្រលប់មករកប្រក្រតីភាពឡើងវិញ។

តទៅទំព័របន្ទាប់

វេជ្ជបណ្ឌិតផ្នែកវះកាត់អាចធ្វើការនៅក្នុងមន្ទីរពេទ្យ និងគ្លីនិកក៏បាន។ វេជ្ជបណ្ឌិតផ្នែកនេះអាចធ្វើការវះកាត់នៅពេលយប់ ពេលថ្ងៃឈប់សម្រាក និងថ្ងៃចុងសប្តាហ៍ផងដែរ។ ចំពោះការវះកាត់ដែលមានសភាពធ្ងន់ធ្ងរ និងលំបាកអាចត្រូវចំណាយពេលជាច្រើនម៉ោងដើម្បីសម្រេចឱ្យចប់ជាស្ថាពរ។ នៅក្នុងលក្ខខ័ណ្ឌបែបនោះ វេជ្ជបណ្ឌិតត្រូវឈរច្រើនម៉ោង ផ្តោតអារម្មណ៍ឱ្យបានល្អ អនុវត្តនូវជំនាញជំប៉ិនប្រសប់ និងឈរនៅមួយកន្លែង។



## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីអាចក្លាយខ្លួនជាវេជ្ជបណ្ឌិតផ្នែកវះកាត់ដ៏ល្អ មានជំនាញ និងឯកទេសជាក់លាក់គឺតម្រូវឱ្យសិក្សារៀនសូត្រក្នុងរយៈពេលដ៏យូរឆ្នាំ។ ពួកគេត្រូវចាប់ផ្តើមពីការសិក្សា និងបណ្តុះបណ្តាលលើមុខវិជ្ជាសំខាន់ៗ ដូចជា ជីវវិទ្យា គីមីវិទ្យា សុខភាព គណិតវិទ្យា និងភាសាបរទេសតាំងពីនៅវិទ្យាល័យ។ ជាពិសេស ពួកគេគួរសិក្សាឱ្យបានច្បាស់បន្ថែមទៀតចំពោះមុខវិជ្ជាជីវវិទ្យា និងគីមីវិទ្យា។ បន្ទាប់មកបន្តគួរការសិក្សានៅមហាវិទ្យាល័យដោយជ្រើសរើសយកឯកទេសខាងវះកាត់ និងមន្ទីរពិសោធន៍។ បន្ទាប់ពីបញ្ចប់ ការសិក្សា អ្នកអាចហាត់បម្រើការងារនៅក្នុងមន្ទីរពេទ្យណាមួយ ដើម្បីដកស្រង់នូវបទពិសោធន៍ និងពង្រីកជំនាញមុនពេលអាចអនុវត្តកិច្ចការវះកាត់ក្នុងពេលអនាគត។



## គួរយល់ដឹង!

✦ មុខវិជ្ជាសិក្សាក្នុងសាលា៖

ជីវវិទ្យា គីមីវិទ្យា និងសុខភាព

✦ កម្រិតអប់រំទាបបំផុត៖

សញ្ញាបត្រវេជ្ជបណ្ឌិត

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា៖

គិលានុបដ្ឋាក

វេជ្ជបណ្ឌិតផ្នែកវះកាត់កែសម្ផស្ស និង

វេជ្ជបណ្ឌិតផ្នែកជម្ងឺបេះដូង ជាដើម។

## ឱសថការី

(Pharmacists)

សង្ខេបអំពីជំនាញ

ឱសថការីធ្វើការងារ៖

✦ ទំនាក់ទំនងផ្នែកគំនិត

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

✦ បង្រៀន

G


តទៅទំព័របន្ទាប់

**ជំនាញដែលត្រូវការប្រើ៖**

- ✦ គណិតវិទ្យា
- ✦ ការអាន/ការសរសេរ
- ✦ ការនិយាយ/ការស្តាប់

## តើឱសថការីធ្វើកិច្ចការអ្វីខ្លះ?

ឱសថការីពិនិត្យ ផ្តល់ និងលក់ឱសថដែលវេជ្ជបណ្ឌិត ទន្តពេទ្យ និងអ្នកឯកទេសវិជ្ជាជីវៈផ្នែកព្យាបាលជម្ងឺដទៃទៀតចេញវេជ្ជបញ្ជាទៅដល់អ្នកជម្ងឺ ឬអតិថិជនរបស់ពួកគេ។

គេសង្កេតឃើញថា មានឱសថរាប់ពាន់ប្រភេទត្រូវបានផលិត និងកំពុងចរាចរនៅក្នុងទីផ្សារ ដូច្នេះឱសថការីត្រូវមានចំណេះដឹងច្បាស់លាស់អំពីសារជាតិគីមីនានា ដែលមាននៅក្នុងឱសថមួយប្រភេទៗ ដើម្បីតម្រូវទៅតាមអាការៈជម្ងឺ និងសរីរាង្គរបស់អ្នកជម្ងឺ ក៏ដូចជាភាពស័ក្តិសិទ្ធិ និងផលប៉ះពាល់នៃឱសថទាំងនោះនៅគ្រប់ពេលនៃការព្យាបាល។

ឱសថការីត្រូវតែមានចំណេះ និងលទ្ធភាពក្នុងការពន្យល់អំពីឱសថនីមួយៗទៅដល់អ្នកជម្ងឺ ឬអតិថិជន អំពីការប្រើប្រាស់ និងផលប៉ះពាល់ផ្សេងទៀតក្រៅតែពីលទ្ធភាពនៅក្នុងការព្យាបាលជម្ងឺរបស់ឱសថទាំងនោះ។ បន្ថែមពីលើនេះ ឱសថការីក៏ត្រូវមានចំណេះដឹងក្នុងការលក់ និងផ្តល់នូវឱសថជាច្រើនប្រភេទទៀត ដែលមិនត្រូវការចេញវេជ្ជបញ្ជា ដូចជា ឱសថព្យាបាលជម្ងឺក្អក ផ្តាសាយ ប្រភេទថ្នាំវីតាមីន និងឧបករណ៍ខ្លះៗដូចជា ប្រដាប់វាស់ស្ទង់កម្តៅ ជាដើម។

ឱសថការីដែលគ្រប់គ្រងឱសថស្ថានដោយខ្លួនឯងមានតួនាទី និងបំពេញការងារបន្ទាប់បន្សំជាច្រើនប្រៀបដូចជាអ្នកគ្រប់គ្រង និងចែកចាយឱសថដូច្នោះដែរ។ ពួកគេបញ្ជាទិញឱសថសម្រាប់លក់រាយ និងជុំ គ្រប់គ្រងបុគ្គលិកក្នុងឱសថស្ថាន និងគ្រប់គ្រងចាត់ចែងចំពោះហិរញ្ញវត្ថុទៀតផង។

នៅតាមមន្ទីរពេទ្យ គ្លីនីក និងស្ថាប័នព្យាបាលជម្ងឺផ្សេងៗតែងមានឱសថការីបម្រើការជាបុគ្គលិក។ ឱសថការីទាំងនោះមានភារៈផ្តល់ថ្នាំ ពន្យល់អប់រំអ្នកជម្ងឺ និងពិនិត្យទៅលើឯកសារ ឬរបាយការណ៍ឱសថនៅក្នុងស្ថាប័នទាំងមូល។ ឱសថការីខ្លះបង្រៀនជំនាញផ្នែកនេះទៅដល់និស្សិតនៅតាមមហាវិទ្យាល័យផ្នែកសុខាភិបាល និងផ្នែកគិលានុបដ្ឋាក។ អ្នកខ្លះទៀតធ្វើការនៅក្នុងក្រុមហ៊ុនផលិតឱសថ ដែលការងារផ្នែកនេះ ទំនងជាមានពាក់ព័ន្ធជាមួយនឹងការស្រាវជ្រាវអំពីឱសថថ្មីៗ ដើម្បីផ្សំបង្កើតជាប្រភេទថ្នាំគ្រាប់ ថ្នាំទឹក ជាដើម។ ឱសថការីខ្លះមានភារៈធ្វើតេស្តសាកល្បងចំពោះធាតុផ្សំ ឬសារធាតុគីមីនៅក្នុងឱសថមុនពេលធ្វើការផលិតសម្រេច។

ដើម្បីអាចក្លាយខ្លួនជា ឱសថការីដ៏ល្អមួយរូប អ្នកត្រូវការនូវជំនាញទំនាក់ទំនងដែលអាចជួយសម្រួលក្នុងការជួបពិគ្រោះជាមួយអ្នកជម្ងឺ ឱសថការី និងអ្នកឯកទេសវិជ្ជាជីវៈផ្នែកព្យាបាលជម្ងឺផ្សេងទៀត។ បន្ថែមលើនេះ ឥរិយាបថរួសរាយរាក់ទាក់ ក៏ជាកត្តាជួយឱ្យបំពេញការងារបានប្រសើរនៅក្នុងមន្ទីរពេទ្យ គ្លីនីក និងមន្ទីរព្យាបាលផ្សេងៗ ជាពិសេសត្រូវកត់ចំណាំថា តួនាទីរបស់ឱសថការី គឺផ្តល់នូវដំបូន្មាន និងយោបល់ទៅដល់អ្នកជម្ងឺ។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីអាចក្លាយខ្លួនទៅជាឱសថការីស្របទៅតាមបច្ចេកទេសវេជ្ជសាស្ត្រ អ្នកត្រូវសិក្សាជំនាញនេះនៅមហាវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។ ជំនាញផ្នែកឱសថសាស្ត្រ គឺតម្រូវឱ្យនិស្សិតសិក្សាលើមុខវិជ្ជាសំខាន់ៗមួយចំនួនដូចជា វិទ្យាសាស្ត្រផ្នែកឱសថ គីមីនៃភាវរូបមានជីវិត ច្បាប់ និងក្រមសីលធម៌ផ្នែកឱសថសាស្ត្រ ព្រមទាំងការថែទាំឱសថសាស្ត្រ។ បន្ថែមលើនេះ ការអប់រំក៏ត្រូវរួមបញ្ចូល

នូវការធ្វើកម្មសិក្សាការងារ ដែលបម្រើការនៅក្រោមការគ្រប់គ្រង និងផ្តល់យោបល់របស់អ្នកឯកទេសវិជ្ជាជីវៈ។

គួរបញ្ជាក់ផងដែរថា ការបម្រើការងារជាឱសថការីតម្រូវឱ្យមានអាជ្ញាប័ណ្ណដែលចេញដោយក្រសួងពាក់ព័ន្ធមុននឹងអាចប្រកបរបរវិជ្ជាជីវៈ ឬអាជីវកម្ម។

## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលាៈ

គីមីវិទ្យា និងគណិតវិទ្យា

✦ កម្រិតអប់រំទាបបំផុតៈ

បណ្ឌិតផ្នែកឱសថសាស្ត្រ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នាៈ

អ្នកគីមីផ្នែកភាវរូបមានជីវិត

អ្នកគីមីវិទ្យា

អ្នករូបវិទ្យា និង អ្នកផលិតឱសថ ជាដើម។

## មន្ត្រីផ្នែករដ្ឋបាលក្នុងការិយាល័យ

(Office Administrators)

សង្ខេបអំពីជំនាញ

មន្ត្រីផ្នែករដ្ឋបាលក្នុងការិយាល័យធ្វើការងារ៖

✦ គ្រប់គ្រងបុគ្គលិក និងមនុស្ស

✦ គ្រប់គ្រង និងចាត់ចែងពេលវេលា

✦ បំពេញកិច្ចការក្នុងភាពជាអ្នកដឹកនាំ

G

ជំនាញដែលត្រូវការប្រើ៖

✦ ការដោះស្រាយបញ្ហា

✦ ការធ្វើសេចក្តីសម្រេចចិត្ត

✦ ការទទួលខុសត្រូវ

## តើមន្ត្រីរដ្ឋបាលក្នុងការិយាល័យបំពេញកិច្ចការអ្វីខ្លះ?

G រាល់គ្រប់ការងារ និងសកម្មភាពនានានៅក្នុងការិយាល័យត្រូវបានដឹកនាំ និងសម្របសម្រួលដោយមន្ត្រីរដ្ឋបាល។ មន្ត្រីរដ្ឋបាលមានភារៈគ្រប់គ្រង និងត្រួតកិច្ចការរបស់ជំនួយការរដ្ឋបាល ស្មៀន ឬហិរញ្ញិក លេខាធិការ ព្រមទាំងបុគ្គលិកដទៃផ្សេងទៀត ដើម្បីធានាថាការិយាល័យ និងការងារប្រព្រឹត្តទៅដោយរលូន និងប្រកបដោយប្រសិទ្ធភាព។ ហេតុនេះ កិច្ចការចម្បងរបស់ពួកគេគឺការគ្រប់គ្រងការិយាល័យ តាមរយៈការរៀបចំផែនការ និងដឹកនាំផ្នែក ឬក្រុមការងារ កិច្ចការរបស់បុគ្គលិក ព្រមទាំងសកម្មភាពទាំងអស់ដើម្បីធានាឱ្យបាននូវលំហូររបស់ការងារ និងលទ្ធផលពិតប្រាកដ។



ដោយអាស្រ័យទៅតាមទំហំការងារ និងស្ថានភាពរបស់ការិយាល័យនីមួយៗ មន្ត្រីការិយាល័យរដ្ឋបាលធ្វើការកំណត់អំពីប្រតិបត្តិការទៅតាមតម្រូវការរបស់បុគ្គលិក។ មន្ត្រីរដ្ឋបាលក៏ធ្វើការសម្ភាសបេក្ខជនថ្មីៗដែលបានដាក់ពាក្យស្នើសុំការងារផងដែរ។ បន្ថែមលើនេះ ពួកគេក៏បង្ហាត់បង្រៀនបុគ្គលិកថ្មីៗឱ្យស្គាល់ពីបែបបទការងារ ការប្រើប្រាស់ឧបករណ៍ ដំណើរការការងាររបស់ស្ថាប័ន តួនាទីនិងភារកិច្ចដែលត្រូវបំពេញជាប្រយោជន៍ដើម្បីទទួលបានជោគជ័យ និងប្រសិទ្ធភាព។

លើសពីនេះទៀត មន្ត្រីរដ្ឋបាលមានភារៈទទួលខុស

ត្រូវ និងធានាទូវការគោរពគោលនយោបាយ ឬបទប្បញ្ញត្តិការងារ ព្រមទាំងប្រសិទ្ធភាពនៃការបំពេញការងាររបស់បុគ្គលិកនីមួយៗ។ ហេតុនេះ មន្ត្រីរដ្ឋបាលនឹងពិនិត្យមើលលើការតម្លើងតំណែង ប្រាក់បៀវត្ស និងបញ្ឈប់ការងារបុគ្គលិក។

អ្នកដែលពូកែខាងជំនាញទំនាក់ទំនង និងអន្តរបុគ្គលនឹងមានភាពស័ក្តិសមជាមួយតំណែងនេះខ្លាំងណាស់។ ក្រៅពីនេះជំនាញក្នុងការសរសេរ និងនិយាយក៏ដើរតួនាទីសំខាន់ផងដែរ ដើម្បីធានាទូវប្រសិទ្ធភាពការងារ។ ហើយពួកគេក៏ត្រូវចេះលើកទឹកចិត្តបុគ្គលិក និងដោះស្រាយទំនាស់ផងដែរ។

## ការអប់រំ និងការបណ្តុះបណ្តាល

G ដើម្បីអាចក្លាយខ្លួនជាមន្ត្រីរដ្ឋបាល អ្នកត្រូវសិក្សាលើមុខវិជ្ជាសំខាន់ៗមួយចំនួនដូចជា មុខវិជ្ជាពាក់ព័ន្ធនឹងផ្នែកជំនួញ ឬគ្រប់គ្រងពាណិជ្ជកម្ម ច្បាប់ ភាសាបរទេស រួមផ្សំនឹងការចេះវាយអត្ថបទក្នុងកុំព្យូទ័រ និងកម្មវិធីកុំព្យូទ័រផ្សេងៗ ការរក្សាទុកសៀវភៅ ឬឯកសារ ព្រមទាំងជំនាញផ្នែកទំនាក់ទំនង សង្គមវិទ្យា និងគណិតវិទ្យា នោះនឹងរួមចំណែកធ្វើឱ្យការងាររបស់អ្នកមានភាពល្អ

## គួរយល់ដឹង!

✦ មុខវិជ្ជាសិក្សាក្នុងសាលា:
ភាសាបរទេស គណិតវិទ្យា និងសង្គមវិទ្យា
✦ កម្រិតអប់រំទាបបំផុត:
មធ្យមសិក្សាទុតិយភូមិ ឬបរិញ្ញាបត្រ
✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:
អ្នកគ្រប់គ្រងជំនួញ
ជំនួយការផ្នែកច្បាប់
ស្មៀនក្នុងការិយាល័យ និង
លេខាធិការ ជាដើម។

# អាកាសយានិក

( Pilots )

សង្ខេបអំពីជំនាញ

អាកាសយានិកធ្វើការងារ:

✦ បំពេញកិច្ចការក្នុងភាពជាអ្នកដឹកនាំ
✦ ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា
✦ បំពេញការងារជាក្រុម

G

ជំនាញដែលត្រូវការប្រើ:

✦ ការធ្វើសេចក្តីសម្រេចចិត្ត
✦ ការទទួលខុសត្រូវ
✦ ការនិយាយ និងការស្តាប់



## តើអាកាសយានិកបំពេញកិច្ចការអ្វីខ្លះ?

G អាកាសយានិកបញ្ជា និងប្រតិបត្តិការយន្តហោះដឹកជញ្ជូនអ្នកដំណើរ ឥវ៉ាន់ បញ្ញើ និងអនុវត្តនូវកិច្ចការសំខាន់ៗផ្សេងទៀតពាក់ព័ន្ធជាមួយនឹងជំនួញ។ គួរកត់សម្គាល់ថា អាកាសយានិកដ៏សំខាន់ជាងគេ គឺអាកាស-យានិកផ្នែកយន្តហោះពាណិជ្ជកម្មដែលបញ្ជានូវប្រភេទយន្ត-ហោះធុនធំអាចផ្ទុកអ្នកដំណើរ និងឥវ៉ាន់បានច្រើន។ ពួកគេត្រូវត្រួតពិនិត្យសហសេវិក អ្នកបម្រើតាមយន្តហោះ គ្រប់គ្រងបញ្ជាយន្តហោះទាំងមូល ព្រមទាំងធានាសុវត្ថិភាពរបស់អ្នកដំណើរ ព្រមទាំងការហោះហើរ និងការចុះសំចត។

មុនពេលហោះហើរ អាកាសយានិកនឹងធ្វើការត្រួតពិនិត្យនូវអាកាសធាតុ ស្ថានភាពហោះហើរ ផ្លូវ ឬគម្រោងហោះហើរ ដែលបានអនុញ្ញាតដោយអាជ្ញាធរអាកាសចរ


តទៅទំព័របន្ទាប់

ស៊ីវិល និងមន្ត្រីផ្នែកបញ្ជាការហោះហើរនៅក្នុងអាកាសយានដ្ឋាន។ នៅក្នុងយន្តហោះ អាកាសយានិក និងសហសេវិកធ្វើការត្រួតពិនិត្យ ឬសាកល្បងឧបករណ៍បញ្ជា គ្រឿងអេឡិក-ត្រូនិក និងប្រព័ន្ធមេកានិក។ បន្ទាប់មកអាកាសយានិកត្រូវ រង់ចាំបញ្ជារបស់អ្នកគ្រប់គ្រងការហោះហើរ ដើម្បីចូលកាន់ផ្លូវហោះហើរឱ្យបានត្រឹមត្រូវ និងចាប់ផ្តើមហោះហើរ។



ពេលនៅលើអាកាស យន្តហោះនឹងត្រូវគ្រប់គ្រងបញ្ជាជាពិសេសដោយប្រព័ន្ធហោះហើរស្វ័យប្រវត្តិ (automatic pilot)។ ខណៈនោះអាកាសយានិក និងសហការីមានភារៈរាយការណ៍ពីស្ថានភាពហោះហើរតាមវិទ្យុទាក់ទងមកកាន់មូលដ្ឋានលើដី ពិនិត្យអំពីរយៈកម្ពស់ ល្បឿន ស្ថានភាពអាកាសធាតុ និងកិច្ចការបន្ទាប់បន្សំជាច្រើនផ្សេងទៀត។

មុនពេលចុះសំចត អាកាសយានិកត្រូវពិនិត្យមើលនូវគ្រប់ស្ថានភាពស្រដៀងគ្នាទៅនឹងពេលចាប់ផ្តើហោះហើរ។

សុខភាពផ្នែកសម្លេង និងអារម្មណ៍គឺត្រូវការជាចាំបាច់សម្រាប់ការងារជាអាកាសយានិក។ អារម្មណ៍នឹងនរគឺសំខាន់ ព្រោះអ្នកដំណើរទាំងអស់ពឹងពាក់លើការបើកបររបស់អ្នក។ ដូច្នេះ ត្រូវមានកាយសម្បទាល្អគ្រប់បែបយ៉ាងទើបប្រសើរ។

## ការអប់រំ និងការបណ្តុះបណ្តាល

G ការងារជាអាកាសយានិកតម្រូវឱ្យមានចំណេះដឹងផ្នែកឧត្តុនិយម ពេជគណិត និងធរណីមាត្រ។ ក្រៅពីនេះ ពួកគេត្រូវទទួលនូវការហ្វឹកហាត់ដោយម៉ត់ចត់បំផុត ជាពិសេសអ្នកដែលបញ្ជាយន្តហោះដឹកអ្នកដំណើរ។ បន្ទាប់ពីបញ្ចប់ការហ្វឹកហាត់ពួកគេក៏ត្រូវមានការប្រឡង និងត្រូវសន្សំម៉ោងហោះហើរឱ្យគ្រប់តាមតម្រូវការ ដើម្បីទទួលបានអាជ្ញាបណ្ណហោះហើរ ស្របតាមបញ្ញត្តិច្បាប់របស់ប្រទេស។ ដូច្នេះ ការងារជាអាកាសយានិកគឺត្រូវទទួលបន្ទុកធ្ងន់ធ្ងរចំពោះបច្ចេកទេស និងសុវត្ថិភាពដើម្បីសន្សំនូវពិន្ទុល្អៗក្នុងប្រវត្តិហោះហើររបស់ពួកគេម្នាក់ៗ។

## គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
គណិតវិទ្យា និងរូបវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**
ការបណ្តុះបណ្តាលក្រោយមធ្យមសិក្សាទុតិយភូមិ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**
អ្នកគ្រប់គ្រងផ្លូវចរាចរហោះហើរ និង
អ្នកបម្រើការតាមយន្តហោះ ជាដើម។

## បណ្ណារក្ស
(Librarians)

**សង្ខេបអំពីជំនាញ**

**បណ្ណារក្សធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ បំពេញការងារក្នុងភាពជាអ្នកដឹកនាំ
✦ ជួយកិច្ចការដល់អតិថិជន ឬភ្ញៀវ

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការធ្វើសេចក្តីសម្រេចចិត្ត
✦ ការអាន និងការសរសេរ
✦ ការនិយាយ និងការស្តាប់

## តើបណ្ណារក្សបំពេញកិច្ចការអ្វីខ្លះ?

G បណ្ណារក្សទទួលខុសត្រូវចំពោះកិច្ចការថែទាំ និងរៀបចំទុកដាក់សៀវភៅ ឯកសារ ទស្សនាវដ្ដី សារព័ត៌មាន ឯកសារជាសម្លេង ព្រមទាំងសម្ភារ និងឯកសារជាច្រើនប្រភេទផ្សេងទៀតដែលមាននៅក្នុងបណ្ណាល័យ។ ពួកគេធ្វើការបញ្ជាទិញ និងរៀបចំទុកដាក់ឱ្យមានរបៀប ហើយអនុញ្ញាតឱ្យសិស្សនិស្សិត ឬសាធារណជនខ្ចីអាន។ ក្រៅពីនេះ បណ្ណារក្សក៏មានតួនាទីក្នុងការជួយស្វែងរកព័ត៌មាន ឬឆ្លើយទៅនឹងចម្ងល់របស់អ្នកអានក្នុងការរកឯកសារអ្វីមួយ។

បណ្ណារក្សមានច្រើនប្រភេទ និងធ្វើការនៅតាមទីកន្លែង ឬបណ្ណាល័យប្រភេទផ្សេងៗ ដូចជា៖ បណ្ណារក្សធ្វើការនៅតាមបណ្ណាល័យសាធារណៈរបស់រដ្ឋ ឧទាហរណ៍ បណ្ណាល័យជាតិ។ បណ្ណារក្សទទួលបន្ទុកផ្នែកបញ្ជាទិញសៀវភៅ ឬឯកសារថ្មីៗសម្រាប់បណ្ណាល័យ។ បណ្ណារក្សផ្នែករៀបចំបណ្ណកាតាឡុករបស់សៀវភៅទៅតាមប្រភេទ ឯកទេស លេខកូដ និងឆ្នាំបោះពុម្ព នៅលើកាត ឬបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ។ បណ្ណារក្សខ្លះបំពេញការងារជាជំនួយក្នុងការរកឯកសារនានាសម្រាប់អ្នកស្រាវជ្រាវ ឬអ្នកអាន។ រីឯ បណ្ណារក្សផ្នែកសៀវភៅកុមារវិញជួយស្វែងរកសៀវភៅ ឬផ្ដល់ឱកាសឱ្យកុមារអានសៀវភៅដែលសមតាមចំណូលចិត្ត និងវ័យរបស់កុមារ។



ដោយឡែក បណ្ណារក្សដែលបម្រើការនៅតាមសាលា ឬសាកលវិទ្យាល័យក៏មានតួនា-ទីក្នុងការរក្សាសៀវភៅ និង ឱ្យសិស្ស-និស្សិតខ្ចីសៀវភៅសម្រាប់អាន។ ពួកគេអាចជួយសិស្សស្វែងរកសៀវភៅសម្រាប់ប្រើជាឯកសារនៅក្នុងការធ្វើលំ-ហាត់ ឬកិច្ចសាលាដែលបានគ្រូដាក់ឱ្យ។ បណ្ណារក្សខ្លះធ្វើការនៅក្នុងវិទ្យាស្ថាន ឬមជ្ឈមណ្ឌលស្រាវជ្រាវជាពិសេសដោយឡែកលើឯកទេសណាមួយ ដូចជា វេជ្ជសាស្ត្រ វិទ្យាសាស្ត្រ បច្ចេកទេសខាងវិស្វករ និងផ្នែកច្បាប់ ជាដើម។



## ការអប់រំ និងការបណ្ដុះបណ្ដាល

G ពេលនៅវិទ្យាល័យ អ្នកគួរសិក្សាលើមុខវិជ្ជាប្រវត្តិសាស្ត្រ ភាសាបរទេស កុំព្យូទ័រ និងសារព័ត៌មាន។ ចំណែកនៅថ្នាក់បរិញ្ញាបត្រគួរសិក្សាមុខវិជ្ជាពាក់ព័ន្ធនឹងវិទ្យាសាស្ត្រសង្គម ហើយអាចបន្តយកបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្របណ្ណាល័យទៀតក៏បាន។



## គួរយល់ដឹង!

✦ មុខវិជ្ជាសិក្សាក្នុងសាលា:
វិទ្យាសាស្ត្រកុំព្យូទ័រ និងភាសាបរទេស
✦ កម្រិតអប់រំទាបបំផុត:
បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រសង្គម
✦ ព័ត៌មានគួរអានបន្ថែមស្ដីពីអ្នកមានជំនាញស្រដៀងគ្នា:
អ្នកអភិរក្សសៀវភៅ
អ្នកធ្វើការក្នុងបណ្ណសារ និង
អ្នកបច្ចេកទេសខាងការថែទាំ និងអភិរក្ស ជាដើម។



# អ្នកបច្ចេកទេសខាងការវេចខ្ចប់

( Packaging Engineers )

**សង្ខេបអំពីជំនាញ**

**អ្នកបច្ចេកទេសខាងការវេចខ្ចប់ធ្វើការងារ៖**

- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- បង្កើត ឬអភិវឌ្ឍប្រព័ន្ធ
- ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

G

**ជំនាញដែលត្រូវការប្រើ៖**

- ការគិតប្រកដោយភាពច្នៃប្រឌិត
- ការដោះស្រាយបញ្ហា
- ការនិយាយ និងការស្តាប់

## តើអ្នកបច្ចេកទេសខាងការវេចខ្ចប់បំពេញកិច្ចការអ្វីខ្លះ?

G ឧបករណ៍ ឬវត្ថុប្រើប្រាស់ដែលយើងបានទិញពីផ្សារភាគច្រើនត្រូវបានវេចខ្ចប់តាមទម្រង់ផ្សេងៗរបស់វា ដោយគិតចាប់ពីរបស់ធ្ងន់ៗ ដូចជាម៉ាស៊ីនទូទឹកកករហូតដល់កញ្ចប់តូចៗដូចជាប្រអប់ដាក់ឱសថ និងគេសជ្ជៈជាដើម។ សូមបញ្ជាក់ថា ប្រអប់ធំតូចទាំងអស់នោះសុទ្ធសឹងតែរៀបចំរចនា និងបង្កើតដោយអ្នកបច្ចេកទេសខាងការវេចខ្ចប់ទាំងអស់។

កិច្ចការដំបូងគេ ដែលអ្នកបច្ចេកទេសខាងការវេចខ្ចប់ត្រូវអនុវត្តក្នុងការរចនាប្រអប់ គឺសិក្សាអំពីប្រភេទទំនិញដែលត្រូវរក្សា ឬផ្ទុកនៅក្នុងប្រអប់នោះ។ គេត្រូវគិតថា ទំនិញ ឬវត្ថុនោះជាប្រភេទវត្ថុរាវ ឬក៏រឹង ស្រាល ឬធ្ងន់ ផុយស្រួយ ឬរឹងមាំ អាចរក្សាទុកបានយូរ ឬក៏អត់។ បន្ទាប់មក គេគួរគំនូរព្រាងរបស់ប្រអប់ និងធ្វើការជ្រើសរើសយកវត្ថុធាតុឱ្យត្រូវទៅតាមប្រភេទរបស់ផលិតផល។

អ្នកផលិតតែងបានគិតអំពីកត្តាសំខាន់ៗនៃតួនាទីរបស់ប្រអប់ ដូចជាភាពសមស្របរវាងវត្ថុធាតុផលិតប្រអប់ និងផលិតផលដែលផ្ទុកក្នុងនោះ។ ម្យ៉ាងទៀត



គេក៏ត្រូវគិតអំពីរូបរាងនៃការរចនាឱ្យមានភាពទាក់ទាញចំពោះអ្នកទិញ ងាយស្រួលប្រើ ចំណាយតម្លៃផលិតតិច និងជាពិសេសជ្រើសរើសវត្ថុធាតុណាដែលអាចប្រើឡើងវិញបាន ហើយមិនសូវប៉ះពាល់ដល់ការបំផ្លាញបរិដ្ឋាន។

បន្ទាប់ពីទទួលបានការឯកភាពលើម៉ូត និងវត្ថុធាតុ អ្នកបច្ចេកទេសចាប់ផ្តើមផលិត និងប្រើសាកល្បងៗ ពេលខ្លះអ្នកបច្ចេកទេសក៏បង្កើតម៉ាស៊ីនសម្រាប់វេចខ្ចប់វត្ថុដោយស្វ័យប្រវត្តិដើម្បីសម្រួលដល់សង្វាក់ផលិតកម្ម។



## ការអប់រំ និងការបណ្តុះបណ្តាល

អ្នកបច្ចេកទេសខាងការវេចខ្ចប់ត្រូវការនូវកម្រិតអប់រំយ៉ាងហោចណាស់ត្រឹមមធ្យមសិក្សាទុតិយភូមិ ឬបរិញ្ញាបត្រផ្នែកបច្ចេកទេសវេចខ្ចប់។ ក្រៅពីនេះ ពួកគេក៏គួរមានចំណេះផ្នែកវិទ្យាសាស្ត្រ ការរចនា ផ្នែកទីផ្សារ ការគ្រប់គ្រងជំនួញ វិទ្យាសាស្ត្រកុំព្យូទ័រ ការលក់ និងផ្សព្វផ្សាយពាណិជ្ជកម្ម។ ម្យ៉ាងវិញទៀត អ្នកដែលមានចំណាប់អារម្មណ៍ចំពោះរឿងនេះក៏គួរសិក្សាមុខវិជ្ជា ឬឯកទេសផ្នែកកម្មន្តសាល គីមីសាស្ត្រ ឧស្សាហកម្ម និងមេកានិក ជាដើម។



បន្ទាប់បម្រើការក្នុងអាជីពនេះហើយ អ្នកបច្ចេកទេសក៏

គួរបន្តអភិវឌ្ឍន៍នូវជំនាញរបស់ខ្លួន ដើម្បីសម្របទៅនឹងតម្រូវការ ឬការផ្លាស់ប្តូរក្នុងទីផ្សារ។ វិធីល្អសម្រាប់កិច្ចការនេះគឺការចូលរួមក្នុងសិក្ខាសាលាផ្នែកអភិវឌ្ឍន៍ជំនាញ។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

គណិតវិទ្យា និងរូបវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកបច្ចេកទេសខាងការរចនាក្នុងកុំព្យូទ័រ

អ្នករចនាគំរូម៉ូតក្នុងវិស័យឧស្សាហកម្ម

អ្នកបច្ចេកទេសខាងការវេចខ្ចប់ដោយម៉ាស៊ីន និង

វិស្វករផ្នែកឧស្សាហកម្ម ជាដើម។

## អ្នកឯកទេសស្ថិតិ

( Statisticians )

**សង្ខេបអំពីជំនាញ**

**អ្នកឯកទេសស្ថិតិធ្វើការងារៈ**

✦ **ប្រាស្រ័យទាក់ទងផ្នែកគំនិត**

✦ **វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន**

✦ **ជួយកិច្ចការដល់អតិថិជន ឬភ្ញៀវ**

G

**ជំនាញដែលត្រូវការប្រើៈ**

✦ **ការគិតប្រកបដោយភាពច្នៃប្រឌិត**

✦ **គណិតវិទ្យា**

✦ **ការអាន និងការសរសេរ**

## តើអ្នកឯកទេសស្ថិតិបំពេញកិច្ចការអ្វីខ្លះ?

G អ្នកស្ថិតិប្រើប្រាស់ទ្រឹស្តីគណិតវិទ្យា និងស្ថិតិដើម្បីប្រមូល និងបកស្រាយនូវទិន្នន័យក្នុងវិស័យជាក់លាក់ណាមួយ។ អ្នកស្ថិតិធ្វើការនៅស្ទើរគ្រប់មុខរបរទាំងអស់ ប៉ុន្តែ អ្នកស្ថិតិភាគច្រើនធ្វើការជាសាស្ត្រាចារ្យ ឬអ្នកស្រាវជ្រាវនៅមហាវិទ្យាល័យ ឬធ្វើការនៅក្នុងវិស័យរដ្ឋ ដូចជាវិទ្យាស្ថានជាតិស្ថិតិ ជាដើម។ ខ្លះទៀតធ្វើការក្នុងវិស័យឧស្សាហកម្ម និងធ្វើអង្កេតសម្រាប់ក្រុមហ៊ុន។ ទិន្នន័យរបស់អ្នកស្ថិតិជាទូទៅបានផ្តល់នូវព័ត៌មានសំខាន់ៗសម្រាប់ការយល់ដឹងពីនិន្នាការ ឬទំនោររបស់សេដ្ឋកិច្ច និងវិស័យផ្សេងៗទៀត។

អ្នកស្ថិតិអាចមានឯកទេសសំខាន់ៗពីរគឺ ស្ថិតិបែបរូបមន្តតាមក្បួនគណិតវិទ្យា (mathematical statisticians) ដែលគិតស្រាវជ្រាវអំពីរូបមន្ត និងទ្រឹស្តីថ្មីៗសម្រាប់ស្ថិតិ ហើយរិះរកវិធីដើម្បីប្រើប្រាស់រូបមន្ត ឬទ្រឹស្តីទាំងនោះ។ ម្យ៉ាងវិញទៀត អ្នកស្ថិតិខ្លះមានឯកទេសខាងប្រើរូបមន្តដែលបានបង្កើតរួច (applied statisticians) ដើម្បីចងជាកម្រងសំណួរក្នុងការស្រាវជ្រាវ។ ពួកគេអាចសិក្សាវិភាគ និងព្យាករណ៍អំពីកំណើនប្រជាសាស្ត្រ ឬស្ថានភាពសេដ្ឋកិច្ច ឬក៏ទស្សន៍ទាយអំពីកំណើនផលិតកម្ម ជាដើម។



ពេលខ្លះ អ្នកស្ថិតិបានធ្វើការប្រមូលទិន្នន័យពីខាងក្រៅដោយខ្លួនឯងទៅតាមអ្វីដែលពួកគេត្រូវការ។ ប៉ុន្តែការពិត ការងារប្រភេទនេះគឺច្រើនតែធ្វើដោយអ្នកជំនាញដែល

ទទួលបានហ្វឹកហ្វឺនផ្នែកប្រមូលទិន្នន័យ។ ឧទាហរណ៍ នៅពេលធ្វើជំរឿន មន្ត្រីស្ថិតិបានជួលអ្នកជំនាញខាងប្រមូលទិន្នន័យស្ថិតិជាច្រើនរយនាក់ដើម្បីស្រង់ព័ត៌មានឱ្យបានលឿន។ បន្ទាប់មក អ្នកបច្ចេកទេសស្ថិតិនឹងចងក្រងនូវទិន្នន័យ និងវិភាគ ហើយធ្វើសេចក្តីសន្និដ្ឋាន និងបោះផ្សាយសម្រេច។

## ការអប់រំ និងការបណ្តុះបណ្តាល

អ្នកឯកទេសស្ថិតិត្រូវតែមានចំណេះច្បាស់លាស់ផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រកុំព្យូទ័រ។ អ្នកគួរសិក្សាមុខវិជ្ជាសំខាន់ៗ ដូចជា ភាសាបរទេស វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រធម្មជាតិ។ គេសង្កេតឃើញថា ការអប់រំត្រឹមបរិញ្ញាបត្រគឺជាកម្រិតទាបបំផុតសម្រាប់កិច្ចការជាអ្នកស្ថិតិ។ សម្រាប់តំណែងខ្លះទៀត គេត្រូវការកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតក៏មាន។ ដូច្នេះ កិច្ចការបែបស្ថិតិគឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងចំណេះ ឬជំនាញផ្នែកគណិតវិទ្យា និងលេខ។ ប្រសិន អ្នកមានបំណងបំពេញការងារផ្នែកស្ថិតិសូមចាប់ផ្តើមសិក្សាឱ្យបានពូកែនូវមុខវិជ្ជាដូចបានពោលខាងលើ។

## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:
គណិតវិទ្យា និងវិទ្យាសាស្ត្រកុំព្យូទ័រ
✦ កម្រិតអប់រំទាបបំផុត:
បរិញ្ញាបត្រ
✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:
អ្នកវាយតម្លៃផ្នែកការធានារ៉ាប់រង
អ្នកប្រជាសាស្ត្រ
អ្នកសេដ្ឋកិច្ច និង
អ្នកឯកទេសគណិតវិទ្យា ជាដើម។

# អ្នកជំនាញខាងវិទ្យាសាស្ត្រនយោបាយ

( Political Scientists )

**សង្ខេបអំពីជំនាញ**

**អ្នកជំនាញខាងវិទ្យាសាស្ត្រនយោបាយធ្វើការងារ:**
✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ បង្រៀន

**ជំនាញដែលត្រូវការប្រើ:**
✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
✦ ការអាន និងការសរសេរ
✦ ការគិតប្រកបដោយហេតុផលជាក់លាក់

## តើអ្នកជំនាញខាងវិទ្យាសាស្ត្រនយោបាយបំពេញកិច្ចការអ្វីខ្លះ?

អ្នកវិទ្យាសាស្ត្រនយោបាយធ្វើការសិក្សាអំពីរដ្ឋាភិបាល និងនយោបាយ។ ពួកគេបង្រៀននៅតាមមហាវិទ្យាល័យ និពន្ធអត្ថបទ ឬសៀវភៅ ព្រមទាំងធ្វើការសិក្សាស្រាវជ្រាវដើម្បីដោះស្រាយបញ្ហា និងបង្កើតនូវទស្សនៈ ឬទ្រឹស្តីថ្មីក្នុងវិស័យនយោបាយ។ លើសពីនេះ ពួកគេក៏ដើរតួនាទីជាទីប្រឹក្សាដល់អ្នកនយោបាយ ឬបក្សនយោបាយ អ្នកជំនួញ និងផ្នែកឧស្សាហកម្មមួយចំនួនផងដែរ។

អ្នកវិទ្យាសាស្ត្រនយោបាយច្រើនតែផ្តោតលើឯកទេសជាក់លាក់ណាមួយក្នុងទស្សនវិស័យផ្នែករដ្ឋាភិបាល ឬក៏ផ្នែកនយោបាយ ឧទាហរណ៍ ផ្នែកទំនាក់ទំនងអន្តរជាតិ ច្បាប់គណបក្សនយោបាយ ឬក៏ប្រវត្តិនៃទស្សនៈគំនិតនយោបាយដែលបានលើកឡើងដោយអ្នកប្រាជ្ញនានា។ ម្យ៉ាងវិញទៀត ឯកទេសផ្នែកវិទ្យាសាស្ត្រនយោបាយ ក៏រួមបញ្ចូលផងដែរនូវមុខវិជ្ជាជាច្រើនដូចជា សិទ្ធិ និងករណីយកិច្ចស្របតាមច្បាប់


តទៅទំព័របន្ទាប់

របស់ពលរដ្ឋ ការសិក្សាប្រៀបធៀបអំពីទម្រង់របស់រដ្ឋាភិបាលរបស់ប្រទេសនានា រដ្ឋបាលសាធារណៈ ការបញ្ចេញមតិជាសាធារណៈ និងនីតិរដ្ឋធម្មនុញ្ញ ជាដើម។

កិច្ចការរបស់អ្នកវិទ្យាសាស្ត្រនយោបាយបានផ្សារភ្ជាប់យ៉ាងសកម្មជាមួយអ្នកជំនាញខាងប្រវត្តិសាស្ត្រ អ្នកសេដ្ឋកិច្ច អ្នកវិភាគគោលនយោបាយ ព្រមទាំងអ្នកជំនាញពាក់ព័ន្ធនានាដើម្បីបង្កើត និងចងក្រងនូវឯកសារ ឬព័ត៌មាន។ តាមរយៈគោលបំណងខាងលើនេះពួកគេបានប្រើប្រាស់នូវប្រភពឯកសារផ្សេងៗដូចជា បណ្ណាល័យ និងអ៊ីនធើរណិតដើម្បីស្រាវជ្រាវឯកសាររបស់រដ្ឋាភិបាល អាននូវព្រឹត្តិបត្របែបបច្ចេកទេស និងសៀវភៅច្បាប់ ជាដើម ដើម្បីបន្ថែមទៅលើការយល់ដឹងរបស់ពួកគេ។ នៅពេលពួកគេប្រមូលបានព័ត៌មានគ្រប់គ្រាន់ហើយ គេធ្វើការវិភាគ បន្ទាប់មកបង្កើតនូវទ្រឹស្តីអំពីព្រឹត្តិការណ៍អ្វីមួយដែលបានកើតឡើងនៅក្នុងវិស័យនយោបាយ។ ទ្រឹស្តីរបស់គេនឹងជួយដល់រដ្ឋាភិបាល ឬអ្នកដឹកនាំឲ្យមានការសម្រេចចិត្តបានត្រឹមត្រូវ ឬក៏ជួយផ្នែកជំនួញឲ្យចរចាជាមួយភាគីម្ខាងផ្សេងទៀត។

អ្នកវិទ្យាសាស្ត្រនយោបាយច្រើនធ្វើជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យតាមរយៈការបង្រៀន និងការស្រាវជ្រាវ។ ពួកគេក៏បម្រើការឲ្យរដ្ឋាភិបា-ល និងផ្នែកសាធារណៈផងដែរក្នុងការផ្តល់យោបល់អំពីទំនាក់ទំនងអន្តរជាតិ បង្កើតគោលនយោបាយ និងកាន់តំណែងផ្នែករដ្ឋបាលជាដើម។ អ្នកវិទ្យាសាស្ត្រនយោបាយត្រូវមានរបៀបក្នុងការរៀបចំឯកសារ ឬបែបផែនការងារឲ្យបានល្អដោយសារតែគេត្រូវប្រមូល និងស្រាវជ្រាវនូវឯកសារពីប្រភពផ្សេងៗជាច្រើនសម្រាប់កិច្ចការរបស់គេ។

## ការអប់រំ និងការបណ្តុះបណ្តាល

## ការអប់រំ និងការបណ្តុះបណ្តាល

G ពេលសិក្សានៅវិទ្យាល័យ គេគួរតែផ្តោតការយកចិត្តទុកដាក់ទៅលើមុខវិជ្ជាផ្នែករដ្ឋាភិបាល ប្រវត្តិសាស្ត្រ និងនយោបាយ។ ក្រៅពីនេះមុខវិជ្ជាគណិតវិទ្យាក៏មានសារសំខាន់ក្នុងការវាយតម្លៃ និងវិភាគស្ថិតិ ប្រជាសាស្ត្រ ព្រមទាំងទិន្នន័យជាតួលេខជាច្រើនទៀត។ រីឯមុខវិជ្ជាផ្នែកភាសាបរទេសវិញនឹងជួយឲ្យគេពូកែក្នុងការសរសេរ និយាយ និងទំនាក់ទំនងក្នុងពេលបង្រៀន បោះផ្សាយ និងការធ្វើបទបង្ហាញ។ ទោះបីជាអ្នកអាចបញ្ចប់ការសិក្សាត្រឹមកម្រិតបរិញ្ញាបត្រ ហើយស្វែងរកការងារក្នុងរដ្ឋាភិបាលក៏ដោយក្តី ប៉ុន្តែ អ្នកមិនអាចបន្តការងារនៅក្នុងវិស័យអប់រំ និងស្រាវជ្រាវបានទេ ប្រសិនអ្នកមិនមានសញ្ញាបត្រថ្នាក់បណ្ឌិតទេនោះ។

ការសិក្សានៅកម្រិតបរិញ្ញាបត្រគឺតម្រូវឲ្យសិក្សាលើមុខវិជ្ជាជាច្រើន ដូចជា ភាសាបរទេស សេដ្ឋកិច្ចស្ថិតិ ប្រវត្តិសាស្ត្រ ព្រមទាំង នយោបាយ នយោបាយអន្តរជាតិ និងទ្រឹស្តីនយោបាយ ។ល។

### គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលាៈ**

រដ្ឋាភិបាល ប្រវត្តិសាស្ត្រ

✦ **កម្រិតអប់រំទាបបំផុតៈ**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នាៈ**

អ្នកឆ្លើយឆ្លងព័ត៌មានអន្តរជាតិ
មន្ត្រីផ្នែកបម្រើការអន្តរជាតិ
អ្នកឃោសនាបញ្ចុះបញ្ចូល និង
អ្នកបម្រើការផ្នែកប្រព័ន្ធឃោសនា ។ល។


តទៅទំព័របន្ទាប់

# អ្នកបម្រើសេវាតាមប្រព័ន្ធទូរសព្ទ

( Telephone Operators )

សង្ខេបអំពីជំនាញ

អ្នកបម្រើសេវាតាមប្រព័ន្ធទូរសព្ទធ្វើការងារ៖

- ✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
- ✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

G

ជំនាញដែលត្រូវការប្រើ៖

- ✦ ការធ្វើសេចក្តីសម្រេចចិត្ត
- ✦ ការអាន និងការសរសេរ
- ✦ ការស្តាប់ និងការនិយាយ

## តើអ្នកបម្រើសេវាតាមប្រព័ន្ធទូរសព្ទបំពេញកិច្ចការអ្វីខ្លះ?



អ្នកបម្រើសេវាតាមប្រព័ន្ធទូរសព្ទជួយផ្តល់នូវព័ត៌មានជាច្រើនប្រភេទទៅដល់អតិថិជន។ ពួកគេជួយអតិថិជនទាំងឡាយដែលត្រូវការជំនួយ ហើយទូរសព្ទហៅមកពីទីជិត និងទីឆ្ងាយ។ អ្នកបម្រើសេវាផ្នែកនេះអាចជាអ្នកដែលជួយផ្តល់នូវលេខទូរសព្ទទៅកាន់អតិថិជនតាមរយៈសៀវភៅបញ្ជីលេខទូរសព្ទនៅពេលមានការសាកសួរ។

អ្នកផ្តល់សេវាផ្នែកនេះ ភាគច្រើនធ្វើការនៅតាមក្រុមហ៊ុនទូរសព្ទដែលរង់ចាំជួយអតិថិជនរបស់គេ។ ប៉ុន្តែសម្រាប់សេវាសាធារណៈគេពុំទាន់ឃើញមាននៅឡើយទេ។ អ្នកបម្រើការងារផ្នែកនេះ ត្រូវតែជាមនុស្សដែលមានចរិតរួសរាយរាក់ទាក់ សុភាពទន់ភ្លន់ និងមានសម្តីពិរោះ។ ការងារបែបនេះតម្រូវឲ្យអង្គុយនៅមួយកន្លែងក្នុងរយៈពេលយូរ។



បន្ថែមលើនេះ ពួកគេត្រូវតែមានជំនាញក្នុងការស្តាប់ ពូកែអាន និងសរសេរនូវពាក្យពេចន៍សម្រាប់ឆ្លើយតបទៅកាន់អតិថិជននានា។ ម្យ៉ាងវិញទៀត ពួកគេត្រូវពូកែធ្វើការដោយភាពរស់រវើកទាំងដៃទាំងភ្នែក ទោះបីជាស្ថិតក្រោមសម្ពាធការងារយ៉ាងណាក្តី។



## ការអប់រំ និងការបណ្តុះបណ្តាល



នៅវិទ្យាល័យគេគួរសិក្សាឲ្យបានច្រើនលើមុខវិជ្ជាផ្នែកការនិយាយ ការធ្វើបទបង្ហាញ និងទំនាក់ទំនង។ ក្រៅពីនេះ រៀនកុំព្យូទ័របន្ថែមទៀតនឹងរឹងរឹតតែប្រសើរ។ ការពិត មិនមានសាលា ឬការអប់រំសម្រាប់ជំនាញនេះទេ ប៉ុន្តែអ្នកបម្រើការងារនេះយ៉ាងហោចណាស់គួរមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងអាចហាត់ការនៅកន្លែងការងារផ្ទាល់តែម្តង។ ការហ្វឹកហាត់អាចផ្តោតទៅលើវិធីសាស្ត្រក្នុងការទទួល និងឆ្លើយសំណួររបស់អតិថិជន។



## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

ជំនួញ ការធ្វើបទបង្ហាញ និងភាសាបរទេស

✦ កម្រិតអប់រំទាបបំផុត:

មធ្យមសិក្សាទុតិយភូមិ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

អ្នកទទួលភ្ញៀវ

ភ្នាក់ងារលក់ និងកក់សំបុត្រ និង

អ្នកបច្ចេកទេសខាងទូរគមនាគមន៍ ជាដើម។

# មន្ត្រីគយ

( Customs Officials )

សង្ខេបអំពីជំនាញ

មន្ត្រីគយធ្វើការងារ៖

- ✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ✦ បំពេញកិច្ចការក្នុងភាពជាអ្នកដឹកនាំ
- ✦ គ្រប់គ្រង និងចាត់ចែងបុគ្គលិក ឬមនុស្ស

G

ជំនាញដែលត្រូវការប្រើ៖

- ✦ ការធ្វើសេចក្តីសម្រេចចិត្ត
- ✦ ការអាន និងការសរសេរ
- ✦ ការនិយាយ និងការស្តាប់

## តើមន្ត្រីគយបំពេញកិច្ចការអ្វីខ្លះ?

មន្ត្រីគយបំពេញការងារ និងកំណត់ឲ្យច្បាស់តាមបច្ចេកទេសថាទំនិញខុសច្បាប់ ឬទំនិញគេចពន្ធមិនត្រូវបានគេរត់ពន្ធឆ្លងដែនចេញ និងចូលប្រទេសតាមច្រកព្រំដែន។ ឱសថ ឬសារធាតុគីមីគឺជាមុខទំនិញដែលត្រូវយកចិត្តទុកដាក់បំផុត។ មន្ត្រីគយត្រូវបានជ្រើសរើស និងហ្វឹកហ្វឺនដោយរដ្ឋាភិបាលតាមរយៈអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ដើម្បីទទួលបានចំណេះដឹងអំពីទំនិញស្របច្បាប់ និងទំនិញហាមឃាត់ដែលត្រូវនាំចេញ និងនាំចូលប្រទេស។

មន្ត្រីគយធ្វើការនៅឯព្រលានយន្តហោះ កំពង់ផែ និងច្រកព្រំដែនអន្តរជាតិរវាងប្រទេសជិតខាង។ មន្ត្រីគយត្រូវមានការប្រុងប្រយ័ត្ននិងសង្កេតយ៉ាងម៉ត់ចត់ក្នុងការពិនិត្យ ឬឆែកឆេររកទំនិញគេចពន្ធដែលលាក់ទុកនៅក្នុងវ៉ាលិស ឬប្រអប់ឥវ៉ាន់របស់អ្នកដំណើរ។

នៅឯអាកាសយានដ្ឋាន និងកំពង់ផែរមន្ត្រីគយនឹងធ្វើការពិនិត្យលើទំនិញ និងឥវ៉ាន់ទាំងអស់របស់អ្នកដំណើរ និងបុគ្គលិកបម្រើតាមយន្តហោះ។ ហេតុដូច្នេះ អ្នកដំណើរ និងបុគ្គលិកទាំងអស់ត្រូវរាយការណ៍ប្រាប់ទៅមន្ត្រីគយអំពីឥវ៉ាន់ដែលពួកគេមានទុកនៅក្នុងវ៉ាលិស។ ក្រៅពីនេះមន្ត្រីគយក៏ពិនិត្យលើឥវ៉ាន់ដែលដឹកជញ្ជូនតាមយន្តហោះផងដែរ ដើម្បីផ្ទៀងផ្ទាត់ជាមួយបញ្ជីរាយមុខទំនិញដែលបានប្រកាស និងបង្ការក្រែងមានករណីទំនិញគេចពន្ធ ឬខុសច្បាប់ជាដើម។

ជួនកាល អ្នកដំណើរមានបំណងក្នុងការលាក់បាំងនូវប្រភេទទំនិញដែលមានតម្លៃថ្លៃដើម្បីគេចវេះពីការបង់ពន្ធជូនរដ្ឋ ដូច្នេះមន្ត្រីគយត្រូវចាប់អារម្មណ៍ខ្ពស់ចំពោះបញ្ហានេះ។




## ការអប់រំ និងការបណ្តុះបណ្តាល

នៅវិទ្យាល័យគួរសិក្សាមុខវិជ្ជាអំពីរដ្ឋាភិបាល ភូមិសាស្ត្រ សង្គមវិទ្យា ភាសាបរទេស ប្រវត្តិសាស្ត្រ និងការអប់រំកាយសម្បទា។ ក្រៅពីនេះអ្នកអាចសិក្សាមុខវិជ្ជាខ្លះៗពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ ឬគីមីវិទ្យាដើម្បីមានចំណេះដឹងក្នុងការពិនិត្យទំនិញដែលមានផ្ទុកដោយសារធាតុគីមី។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
ភាសាបរទេស និងរដ្ឋាភិបាល
✦ **កម្រិតអប់រំទាបបំផុត:**
បរិញ្ញាបត្រ
✦ **ព័ត៌មានគួរអានបន្ថែមស្ដីពីអ្នកមានជំនាញស្រដៀងគ្នា:**
មន្ត្រីនគរបាលផ្នែកល្បាតតាមព្រំដែន
មន្ត្រីប៉ូលីសផ្នែកឧក្រិដ្ឋកម្ម និងការស៊ើបអង្កេត និង
មន្ត្រីប៉ូលីស ជាដើម។



## អ្នកសិល្បៈផ្នែកការតុបតែងមុខ
(Makeup Artists)

**សង្ខេបអំពីជំនាញ**

**អ្នកសិល្បៈផ្នែកការតុបតែងមុខធ្វើការងារ៖**

✦ **ប្រាស្រ័យទាក់ទងផ្នែកគំនិត**
✦ **បំពេញកិច្ចការប្រកបដោយភាពជាអ្នកដឹកនាំ**
✦ **ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន**

G

**ជំនាញដែលត្រូវការប្រើ៖**

✦ **ការគិតប្រកបដោយភាពច្នៃប្រឌិត**
✦ **ការធ្វើសេចក្ដីសម្រេចចិត្ត**
✦ **ការស្ដាប់ និងការនិយាយ**

## តើអ្នកសិល្បៈផ្នែកការតុបតែងមុខបំពេញកិច្ចការអ្វីខ្លះ?



អ្នកសិល្បៈផ្នែកការតុបតែងមុខធ្វើការរចនា និងតុបតែងមុខមាត់សម្រាប់សិល្បករដែលត្រូវសម្ដែងនៅលើឆាក និងក្នុងភាពយន្ត។ ពួកគេអានទូវអត្ថបទសម្ដែងរួចហើយជួបពិភាក្សាជាមួយអ្នកដឹកនាំរឿង អ្នកផលិតកម្មវិធី និងអ្នកបច្ចេកទេស។ ពួកអ្នកតុបតែងនឹងបង្កើតនូវរូបភាពពិសេសទៅលើមុខមាត់របស់តួសម្ដែងដែលរាប់ចាប់ពីការធ្វើជាស្នាកស្នាមប្លែកៗ រហូតដល់ការការធ្វើជាអវយវៈ ឬផ្នែកណាមួយរបស់ដងខ្លួនតាមបែបសិប្បនិម្មិត្ត។ ពេលខ្លះអ្នកតុបតែងមុខត្រូវកែច្នៃលាបមុខមាត់ ដើម្បីឲ្យមើលទៅហាក់ដូចជាលក្ខណៈធម្មជាតិពិតៗ ដូចជាតុបតែងមុខបំបាត់ស្នាមជ្រីវជ្រួញ ស្នាមសាក់ ឬសម្វាក។

នៅពេលតុបតែងមុខ ពួកគេត្រូវគិតគូរអំពីអាយុរបស់សិល្បករមួយរូប ពេលដែលត្រូវសម្ដែងនៅក្នុងសាច់រឿង និងការប្រើប្រាស់ពន្លឺនៅពេលសម្ដែង។ ម្យ៉ាងទៀត ការតុបតែងសម្រាប់តួសម្ដែងក្នុងរឿងបែបបុរាណ ឬប្រវត្តិសាស្ត្រតម្រូវឲ្យមានការសិក្សាស្រាវជ្រាវអំពីម៉ូតសក់ សម្លៀកបំពាក់ និងរូបរាងមុខមាត់របស់មនុស្សសម័យកាលនោះៗ។ ក្នុងខណៈពេលដែលសិល្បករកំពុងសម្ដែង អ្នកតុបតែងមុខក៏មានភារៈយកចិត្តទុកដាក់ពិនិត្យទៅលើតួអង្គនីមួយៗ



ក្រែងមានចំណុចត្រូវការកែលំអបន្ថែមចំពោះការតុបតែងរបស់ខ្លួន។ ដូច្នេះហើយពួកគេត្រូវតែតុបតែងបន្ថែមជារឿយៗនៅពេលសម្រាក និងរហូតដល់ការថតបានបញ្ចប់។

## ការអប់រំ និងការបណ្តុះបណ្តាល

អ្នកតុបតែងមុខច្រើនតែរៀនជំនាញនេះតាមរយៈការបណ្តុះបណ្តាលបច្ចេកទេសនៅតាមសាលាតុបតែងមុខ និងកែសម្ផស្ស។ ម្យ៉ាងទៀត អ្នកខ្លះអាចបន្តការសិក្សាជំនាញនេះឲ្យកាន់តែជ្រៅជ្រះនៅបរទេសក៏មាន។ ដូច្នេះ ពួកគេត្រូវមានចំណេះដឹងផ្នែករូបភាព ម៉ូត សម្លៀកបំពាក់ សិល្បៈ និងប្រវត្តិសាស្ត្រជាដើម។ អ្នកតុបតែងមុខគួរសិក្សាលើមុខវិជ្ជាសំខាន់ៗ ដូចជាប្រវត្តិសិល្បៈ រូបថតឬគំនូរ កាយវិភាគសាស្ត្រ ការចម្លាក់រូប កុំព្យូទ័រ និងគីមីសាស្ត្រ។




## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

សិល្បៈ ល្ខោន និងរបាំ

✦ កម្រិតអប់រំទាបបំផុត:

មធ្យមសិក្សាទុតិយភូមិ ឬការអប់រំជំនាញ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

សិល្បករ

អ្នកកាត់សក់

អ្នកថតរូបម៉ូត និង

អ្នកតុបតែងក្រចក ជាដើម។

## វិស្វករផ្នែកចរាចរណ៍

(Traffic Engineers)

**សង្ខេបអំពីជំនាញ**

**វិស្វករផ្នែកចរាចរណ៍ធ្វើការងារ៖**

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

✦ ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

G

**ជំនាញដែលត្រូវការប្រើ៖**

✦ គណិតវិទ្យា

✦ ការដោះស្រាយបញ្ហា

✦ ការសរសេរ និងការអាន

## តើវិស្វករផ្នែកចរាចរណ៍បំពេញកិច្ចការអ្វីខ្លះ?

វិស្វករផ្នែកចរាចរណ៍គឺអនុវត្តការងារក្នុងការជួយសម្រួល និងបង្កើនទូវសុវត្ថិភាព និងលំហូរទិសដៅរបស់ចរាចរណ៍នៅលើដងផ្លូវសាធារណៈ។ ពួកគេធ្វើការសិក្សាអំពីស្ថានភាពរបស់ចរាចរណ៍ដូចជា នាទីរបស់ភ្លើងសញ្ញា លំហូរចរាចរណ៍ ទីកន្លែងដែលមានគ្រោះថ្នាក់ចរាចរណ៍ច្រើន ការដាក់ភ្លើងបំភ្លឺ ការសិក្សាពីច្រកចេញចូលរបស់ចរាចរណ៍ និងលទ្ធភាពរបស់ដងផ្លូវដែលអាចផ្ទុកយានយន្តក្នុងពេលធ្វើចរាចរណ៍ឆ្លងកាត់។

នៅពេលពួកគេសិក្សានិងបង្កើតគម្រោងអ្វីមួយ ពួកគេត្រូវគិតឲ្យល្អិតល្អន់អំពីកត្តានានាដែលអាចប៉ះពាល់ទៅដល់លំហូររបស់ចរាចរណ៍ ដូចជាការសាងសង់ផ្សារ ផ្លូវរថភ្លើង

អាកាសយានដ្ឋាន ឬកំពង់ចក្រជាដើម។ វិស្វករត្រូវប្រើប្រាស់ការគន់គូរទៅតាមក្បួនខ្នាតគណិតវិទ្យា ដើម្បីកំណត់អំពីពេលវេលារបស់ភ្លើងសញ្ញា និងល្បឿនរបស់យានយន្ត។ ពួកគេរៀបចំគូរគំនូរព្រាង ដើម្បីបង្ហាញអំពីទីតាំងដែលត្រូវដាក់ភ្លើងសញ្ញានិងការបំពាក់ឧបករណ៍ត្រួតពិនិត្យផ្សេងៗទៀត។ ពេលខ្លះវិស្វករអាចសិក្សាពីស្ថានភាពរបស់ចរាចរណ៍ បន្ទាប់មកធ្វើសេចក្តីស្នើឲ្យផ្លាស់ប្តូរទិសដៅ ឬបទបញ្ជាថ្មីសម្រាប់គ្រប់គ្រងចរាចរណ៍។


គម្រោងប្លង់ស្ពាបនាស្ពានអាកាសសម្រួលចរាចរណ៍នៅស្ទឹងមានជ័យ

វិស្វករផ្នែកចរាចរណ៍ដែលបំពេញការងារសម្រាប់រដ្ឋាភិបាលនឹងរៀបចំគម្រោងសិក្សាអំពីផ្លូវគមនាគមន៍ ឬក៏ប្រព័ន្ធគមនាគមន៍សាធារណៈទាំងមូល តាមរយៈការសិក្សាបង្កើតនូវផ្លូវថ្នល់ថ្មីៗសម្រាប់គ្រប់គ្រងនិងបញ្ចៀសបញ្ហាចរាចរណ៍។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីចាប់យកអាជីពនិងការងារក្នុងវិស័យនេះអ្នកត្រូវសិក្សាជាពិសេសនូវមុខវិជ្ជាគណិតវិទ្យានិងធរណីមាត្រ ព្រមទាំងមុខវិជ្ជាផ្នែកគ្រប់គ្រង ភាសាបរទេស ការធ្វើបទបង្ហាញ និងមុខវិជ្ជាវិទ្យាសាស្ត្រដូចជាផ្នែកភូមិសាស្ត្រជាដើម។ អ្នកត្រូវតែមានសញ្ញាបត្រកម្រិតបរិញ្ញាបត្រផ្នែកវិស្វករសំណង់ស៊ីវិល អគ្គិសនី មេកានិក និងផ្នែកគីមីដើម្បីអាចក្លាយជាវិស្វករផ្នែកចរាចរណ៍។ ចំណុចសំខាន់គឺថាវិស្វករក្នុងវិស័យចរាចរណ៍មានសភាពទូលំទូលាយដែលតម្រូវឲ្យគេមានចំណេះដឹងនិងជំនាញផ្សេងៗនៅក្នុងវិស័យវិទ្យាសាស្ត្រ នគរូបនីយកម្ម វិទ្យាសាស្ត្រកុំព្យូទ័រ និងការរៀបចំគ្រប់គ្រងបរិដ្ឋានថែមទៀត។

បន្ថែមលើនេះ អ្នកនិងទទួលបានជំនាញផ្នែកនេះតាមរយៈបទពិសោធន៍ក្នុងការងារផ្ទាល់ សិក្ខាសាលា និងវគ្គសិក្សាផ្សេងៗទៀត។

### គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
ភូមិសាស្ត្រ ការគ្រប់គ្រង និងគណិតវិទ្យា
✦ **កម្រិតអប់រំទាបបំផុត:**
បរិញ្ញាបត្រ
✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**
អ្នកនគរូបនីយកម្ម
អ្នកបច្ចេកទេសសំណង់ស៊ីវិល
វិស្វករសំណង់ស៊ីវិល និង
អ្នកស្ថិតិ ជាដើម។


បញ្ហានៃការកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ

# អ្នកតំណាងផ្នែកលក់

( Sales Representatives )

**សង្ខេបអំពីជំនាញ**

**អ្នកតំណាងផ្នែកលក់ធ្វើការងារ៖**

- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន
- បំពេញកិច្ចការប្រកបដោយភាពជាអ្នកដឹកនាំ

G

**ជំនាញដែលត្រូវការប្រើ៖**

- គណិតវិទ្យា
- ការអាន និងការសរសេរ
- ការនិយាយ និងការស្តាប់

## តើអ្នកតំណាងផ្នែកលក់បំពេញកិច្ចការអ្វីខ្លះ?



អ្នកតំណាងផ្នែកលក់ គឺជាអ្នកលក់ផលិតផលទៅឲ្យហាងលក់រាយ រោងចក្រផ្សេងៗ អ្នកលក់ដុំ ភ្នាក់ងាររដ្ឋាភិបាល និងស្ថាប័នផ្សេងៗ។ ជាទូទៅពួកគេទទួលខុសត្រូវទៅលើទីតាំងភូមិសាស្ត្រមួយជាក់លាក់ក្នុងការផ្សព្វផ្សាយលក់ផលិតផល។ អ្នកតំណាងផ្នែកលក់មួយចំនួនផ្តោតទៅលើប្រភេទនៃផលិតផលមួយចំនួនតែប៉ុណ្ណោះ។ ឧទាហរណ៍ អ្នកលក់គ្រឿងបរិក្ខាអគ្គិសនីអាចលក់ឧបករណ៍ផ្សេងៗចំនួនពី ១០ ទៅ៣០ ប្រភេទដូចជាឧបករណ៍ផ្ទះបាយ ម៉ាស៊ីនត្រជាក់ កង្ហារ ឆ្នាំងអ៊ុត និងអំពូលភ្លើងជាដើម។ រីឯអ្នកតំណាងឲ្យការលក់ដុំក្នុងឱសថស្ថានវិញអាចលក់ឱសថផ្សេងគ្នាបានជាច្រើនមុខ។

អ្នកតំណាងផ្នែកលក់ម្នាក់ៗត្រូវកំណត់អំពីទីកន្លែងនិងធ្វើការទាក់ទងជាមួយអតិថិជន ហើយថែមទាំងរក្សាទំនាក់ទំនងជាមួយអ្នកប្រើប្រាស់ ឬអតិថិជនចាស់ៗ និងព្យាយាមស្វែងយល់អំពីតំម្រូវការរបស់អតិថិជន ព្រមទាំងជូនដំណឹងដល់អតិថិជននូវប្រភេទនៃផលិតផល និងតម្លៃរបស់មុខទំនិញនីមួយៗ។ ពួកគេត្រូវទៅជួបដោយផ្ទាល់ជាមួយអតិថិជនដើម្បីបង្ហាញពីគម្រូមុខទំនិញ ទទួលការបញ្ជាទិញ រៀបចំការដឹកជញ្ជូន និងការតម្លើងឧបករណ៍ផ្សេងៗផងដែរ។ម្យ៉ាងវិញទៀត អ្នកតំណាងផ្នែកលក់ក៏ត្រូវធ្វើការដោះស្រាយចំពោះការត្អូញត្អែរ ការតវ៉ា សំណើ ឬសំណូមពររបស់អតិថិជន តាមដានចំពោះផលិតផលថ្មីៗដែលមានក្នុងទីផ្សារ និងរៀបចំរបាយការណ៍ផងដែរ។ អ្នកតំណាងផ្នែកលក់ជាច្រើនបានចូលរួមសន្និសិទស្តីពីការធ្វើពាណិជ្ជកម្ម ដែលពួកគេអាចដឹងពីផលិតជាច្រើន ព្រមទាំងទំនាក់ទំនងជាមួយអតិថិជនថ្មីៗដើម្បីធ្វើកិច្ចសន្យាលក់ទំនិញ។

គេសង្កេតឃើញថា ផលិតផលជាច្រើនមុខដែលលក់ដោយអ្នកតំណាងផ្នែកលក់អាចរួមចំណែកដោយផ្ទាល់ក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរនៅក្នុងបរិបទការងារ។ ឧទាហរណ៍ អ្នកលក់ផលិតផលកីឡាអាចចំណាយជាច្រើនធ្វើដំណើរពីទីកន្លែងមួយទៅទីកន្លែងមួយទៀត ដើម្បីធ្វើការទំនាក់ទំនងជាមួយហាងលក់ឧបករណ៍កីឡានានា។ ពួកគេក៏អាចទៅជួបជាមួយគ្រូបង្វឹកកីឡា និងអ្នកដឹកនាំអត្តពលិកនៅតាមបណ្ដាសាលា។ អ្នកតំណាងផ្នែកលក់ប្រភេទនេះអាចជាអតីតអត្តពលិក រឺជាគ្រូបង្វឹកកីឡាដែលដឹងយ៉ាងច្បាស់ពីការតម្រូវការរបស់អតិថិជនពួកគេ។

សិប្បកម្មផលិតនិងលក់ដុំអាហារ ឬចំណីតែងជួលអ្នកតំណាងផ្នែកលក់ជាច្រើននាក់ ដែលអាចធ្វើការចរចាជាមួយឈ្មួញលក់រាយ និងរកហាងដែលអាចតាំងបង្ហាញនូវផលិតផលរបស់ពួកគេ។ ការលក់ដោយផ្ទាល់ចំពោះអតិថិជន


តទៅទំព័របន្ទាប់

តាមផ្ទះ គឺជាមធ្យោបាយធ្វើទីផ្សារដ៏មានប្រសិទ្ធភាពចំពោះផលិតផលជាច្រើនដូចជា សម្ភារផ្ទះបាយ ម្ហូបអាហារ ឱសថ គ្រឿងសម្អាង និងសម្លៀកបំពាក់ ជាដើម។

## ការអប់រំ និងការបណ្ដុះបណ្ដាល

មុខតំណែងផ្នែកលក់គួរមានកម្រិតអប់រំទាបបំផុតត្រឹមសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ប៉ុន្តែសព្វថ្ងៃនេះចំនួនកើនឡើងនៃអ្នកធ្វើការផ្នែកនេះ ភាគច្រើនបានបញ្ចប់ការសិក្សានៅកម្រិតឧត្តមសិក្សា។ កិច្ចការលក់នៅក្នុងវិស័យមួយចំនួនទាមទារនូវជំនាញពាក់ព័ន្ធច្បាស់លាស់ ឧទាហរណ៍អ្នកលក់ផ្នែកវិស្វកម្ម ជាទូទៅពួកគេត្រូវមានសញ្ញាបត្រ ឬជំនាញវិស្វករ។ ក្រៅពីនេះគេឃើញមានផ្នែកផ្សេងៗទៀត ដែលទាមទារឲ្យអ្នកលក់ត្រូវតែមានសញ្ញាបត្រច្បាស់លាស់មានដូចជា ការលក់សារធាតុគីមី ការរៀបចំប្រព័ន្ធក្នុងការិយាល័យ




## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

ធុរៈកិច្ច និងគណិតវិទ្យា

✦ កម្រិតអប់រំទាបបំផុត:

មធ្យមសិក្សាទុតិយភូមិ ឬបរិញ្ញាបត្រ

✦ ព័ត៌មានគួរអានបន្ថែមស្ដីពីអ្នកមានជំនាញស្រដៀងគ្នា:

អ្នកទិញ អ្នកតាំងបង្ហាញទំនិញ អ្នកលក់រាយ

អ្នកគ្រប់គ្រងហាងលក់ទំនិញរាយ និង

អ្នកតំណាងការលក់ផ្នែកសេវាកម្ម ជាដើម។

## អ្នកបង្ហាញម៉ូត

(Models)

### សង្ខេបអំពីជំនាញ

អ្នកបង្ហាញម៉ូតធ្វើការងារ៖

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

✦ បំពេញកិច្ចការជាក្រុម

G

ជំនាញដែលត្រូវការប្រើ៖

✦ ការមានជំនឿចិត្តចំពោះខ្លួនឯង

✦ ការគ្រប់គ្រងខ្លួនឯង

✦ ការនិយាយ និងការស្តាប់

## តើអ្នកបង្ហាញម៉ូតបំពេញកិច្ចការអ្វីខ្លះ?

មានមនុស្សភាគច្រើនដឹងអំពីភាពឆើតឆាយរបស់អ្នកដើរបង្ហាញម៉ូតល្បីៗ តាមរយៈសម្លៀកបំពាក់ថ្ងៃៗ និងរូបថតរបស់ពួកគេនៅគ្រប់ទីកន្លែង។ ប៉ុន្តែក៏មានមនុស្សគ្រប់វ័យ និងប្រភេទដែលជាអ្នកធ្វើការ ក្នុងវិស័យនេះផងដែរ។ ពួកគេសម្ដែងក្នុងទូរទស្សន៍ ការថតរូប សិល្បៈករដើរបង្ហាញម៉ូត ហើយនិងជួយលក់ផលិតផលនៅក្នុងហាង។

អ្នកបង្ហាញម៉ូតធ្វើការនៅក្នុងផ្នែកផ្សេងៗជាច្រើន ដូចជាការតាំងបង្ហាញសម្លៀកបំពាក់ និងផលិតផលផ្សេងៗ។ ទោះបីជាការងារនេះហាក់មានភាពសប្បាយ និងរំជួលចិត្តក៏ដោយ ប៉ុន្តែវាទាមទារនូវការអត់ធ្មត់ និងមានភាពលំបាក។ អ្នកបង្ហាញម៉ូតជាច្រើនបានថតរូបដើម្បីធ្វើការផ្សព្វផ្សាយ។ រូបភាពខ្លះអាចថតនៅក្នុងស្ទូឌីយោ ដែលស្ថិតក្រោមពន្លឺភ្លើងក្តៅហើយតម្រូវឲ្យពាក់អាវក្រាស់ៗធ្ងន់ៗ។ ចំណែកឯអ្នក បង្ហាញម៉ូតផ្សេងទៀតអាចថតរូបនៅខាងក្រៅស្ថិតក្រោមអា-កាសធាតុត្រជាក់ដោយគ្រាន់តែពាក់អាវហែលទឹកស្តើងៗ។ ការងារខ្លះអាចចំណាយពេលតែ១ម៉ោង ប៉ុន្តែពេលខ្លះត្រូវចំណាយពេលពេញមួយថ្ងៃក៏មាន។ អ្នកបង្ហាញម៉ូតខ្លះអាចធ្វើដំណើរទៅតាមបណ្តាខេត្ត និងក្រៅប្រទេសដើម្បីថតរូបបង្ហាញម៉ូតនៅទីកន្លែងល្អៗផងដែរ។



## ការអប់រំ និងការបណ្តុះបណ្តាល

ជម្មតា មិនមានស្តង់ដារអប់រំណាមួយសម្រាប់តម្រូវទៅនឹងអ្នកបង្ហាញម៉ូតនោះទេ។ ប៉ុន្តែ ទោះបីជា អ្នកបង្ហាញម៉ូតសម្រាប់តែការថតរូបក៏គួរមានកម្រិតអប់រំត្រឹមមធ្យមសិក្សាទុតិយភូមិដែរ។ វគ្គសិក្សាខ្លះអាចមានប្រយោជន៍ដូចជា ដេរប៉ាក់ សិល្បៈ សេដ្ឋកិច្ច និងការថតរូប។ ការពិត មិនមានវិធីពិសេសណាមួយដើម្បីក្លាយទៅជាអ្នកបង្ហាញម៉ូតទេ។ រូបសម្បត្តិខាងក្រៅនិងសមត្ថភាពអាចបង្ហាញសម្លៀកបំពាក់ និងផលិតផលប្រកបដោយភាពទាក់ទាញការអត់ធ្មត់នៅក្រោមសម្ពាធនៃការដើរបង្ហាញម៉ូត គឺជាចំណុចដ៏សំខាន់បំផុត។ អ្នកបង្ហាញម៉ូតជាច្រើនបានចូលសាលាបង្ហាញម៉ូតដើម្បីសិក្សាជំនាញ និងរបៀបនៃការធ្វើអាជីវកម្ម។ ចំណែកឯ អ្នកបង្ហាញម៉ូតផ្សេងទៀតបានរៀនវគ្គរាំ ឬការហ្វឹកហាត់រាងកាយដើម្បីធ្វើអោយសុខភាពល្អ និងរៀនក្នុងការដើរ ឬបំលាស់ទីឲ្យបានកាន់តែល្អគួរជាទីគយគន់។

## គួរយល់ដឹង!

✦ មុខវិជ្ជាសិក្សាក្នុងសាលាៈ

សិល្បៈ ល្ខោន និងរបាំ

✦ កម្រិតអប់រំទាបបំផុតៈ

មធ្យមសិក្សាទុតិយភូមិ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នាៈ

សិល្បករ

វិចិត្រករ

អ្នកច្នៃម៉ូតសម្លៀកបំពាក់ និង

អ្នកថតរូប ជាដើម។

## បសុពេទ្យ

( Veterinarians )

**សង្ខេបអំពីជំនាញ**

**បសុពេទ្យធ្វើការងារៈ**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ បំពេញកិច្ចការក្នុងភាពជាអ្នកដឹកនាំ

✦ ជួយកិច្ចការដល់អតិថិជន ឬភ្ញៀវ

G


តទៅទំព័របន្ទាប់

**ជំនាញដែលត្រូវការប្រើ៖**

✦ ការដោះស្រាយបញ្ហា

✦ ការអាន និងការសរសេរ

✦ ការនិយាយ និងការស្តាប់

## តើបសុពេទ្យបំពេញកិច្ចការអ្វីខ្លះ?



បសុពេទ្យ គឺជាពេទ្យដែលព្យាបាលជម្ងឺនិងរបួសរបស់សត្វ និងផ្តល់ដំបូន្មានពីរបៀបថែរក្សាសុខភាពនិងការចិញ្ចឹមសត្វ។ បសុពេទ្យព្យាបាលសត្វឆ្កែ ឆ្មា បក្សី និងបសុសត្វផ្សេងៗទៀត ប៉ុន្តែបសុពេទ្យខ្លះធ្វើការនៅក្នុងកសិដ្ឋាននិងសួនសត្វ។ ពួកគេធ្វើការវះកាត់ព្យាបាលជម្ងឺស្រាលៗ និងរក្សាសត្វដែលមានជម្ងឺ និងមានសុខភាពល្អដែលហើយត្រូវការជម្រកស្នាក់នៅជាបណ្តោះអាសន្ន។ ពេលខ្លះ ពួកគេក៏ទៅពិនិត្យជម្ងឺសត្វនៅតាមផ្ទះជាបន្ទាន់ផងដែរ ប៉ុន្តែ បសុពេទ្យភាគច្រើនប្រកបអាជីវកម្មផ្ទាល់ខ្លួនតាមម៉ោងធម្មតា។ បសុពេទ្យខ្លះទៀតព្យាបាល ឬថែទាំជម្ងឺសត្វពាហនៈធំៗដូចជា សេះ គោ ក្របី និងជ្រូក។ ខ្លះទៀតព្យាបាលត្រី និងបក្សី ដូចជាមាន់ ទានិងក្ងាន ជាដើម។



ជួនកាល បសុពេទ្យត្រូវធ្វើដំណើរទៅទីជនបទដិតឆ្ងាយដើម្បីព្យាបាល និងចាក់វ៉ាក់សាំងសត្វ។ ចំណែកនៅតាមកសិដ្ឋានចិញ្ចឹមសត្វវិញ គឺមានបុគ្គលិកបសុពេទ្យផ្ទាល់តែ ម្តងៗ រីឯសួនសត្វជាច្រើនក៏មានជួលបសុពេទ្យដើម្បីថែរក្សាសុខភាពឲ្យចំណី និងព្យាបាលសត្វផងដែរ។ បសុពេទ្យខ្លះទៀតធ្វើជាអ្នកត្រួតពិនិត្យនៅក្នុងគ្រឹះស្ថានឧស្សាហកម្មចំណីអាហារ ឬការវិចខ្ចប់សាច់។ ពួកគេធ្វើការត្រួតពិនិត្យទៅលើសាច់ដែលឃើញថាមានជំងឺ។ ប្រសិនបើអ្នកចាប់អារម្មណ៍ក្នុងការធ្វើជាពេទ្យសត្វ អ្នកគួរតែមានចំណូលចិត្ត ឬជំនាញក្នុងការសាកសួរ និងការសង្កេត។ លទ្ធភាពក្នុងការរៀន និងចំណាប់អារម្មណ៍លើមុខវិជ្ជាវិទ្យាសាស្ត្រផ្នែកជីវសាស្ត្រគឺមានសារសំខាន់ជាខ្លាំង។ អ្នកត្រូវការសិក្សាក្នុងរយៈពេលវែងខាងផ្នែកវិទ្យាសាស្ត្រនិងព្យាយាមទំនាក់ទំនងឬ ការយល់ដឹងពី សត្វ។ ម្យ៉ាងទៀត ការធ្វើទំនាក់ទំនងជាមួយម្ចាស់របស់សត្វ ក៏មានសារសំខាន់ដូចជំនាញ



## ការអប់រំ និងការបណ្តុះបណ្តាល



ដើម្បីរៀបចំផែនការអាជីព ឬក្លាយខ្លួនជាបសុ-ពេទ្យ អ្នកត្រូវចាប់ផ្តើមពីការសិក្សាមុខវិជ្ជាសំខាន់ៗមួយចំនួនតាំងពីនៅមធ្យមសិក្សាទុតិយភូមិ ដូចជា ជីវវិទ្យា គីមីវិទ្យា គណិតវិទ្យា សុខភាព ព្រមទាំងហាត់ធ្វើបទបង្ហាញ ឬសុន្ទរកថាជាដើម។ ម្យ៉ាងទៀត ដើម្បីអាចបើកអាជីវកម្មព្យាបាលជម្ងឺសត្វ អ្នកត្រូវមានសញ្ញាបត្រឯកទេស ឬវិជ្ជាជីវៈខាងបសុពេទ្យ។

### គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា៖**

ជីវវិទ្យា គីមីវិទ្យា និងសុខភាព

✦ **កម្រិតអប់រំទាបបំផុត៖**

សញ្ញាបត្រវេជ្ជសាស្ត្រខាងបសុពេទ្យ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា៖**

អ្នកបច្ចេកទេសខាងបង្កាត់ពូជសត្វ និង

អ្នកថែទាំសួនសត្វ ជាដើម។

# អ្នកគ្រប់គ្រង និងថែទាំគេហទំព័រ

( Webmaster )

**សង្ខេបអំពីជំនាញ**

**អ្នកគ្រប់គ្រងនិងថែទាំគេហទំព័រធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
✦ ការអាន និងការសរសេរ
✦ ការស្តាប់ និងការនិយាយ

## តើអ្នកគ្រប់គ្រង និងថែទាំគេហទំព័របំពេញកិច្ចការអ្វីខ្លះ?



អ្នកគ្រប់គ្រងនិងថែទាំគេហទំព័រ (Webmasters) គឺជាអ្នកបង្កើត និងគ្រប់គ្រងគេហទំព័រសម្រាប់ក្រុម-ហ៊ុន អាជីវកម្ម អង្គការ ភ្នាក់ងាររដ្ឋាភិបាល សាលារៀន និងបុគ្គល។ Webmaster ខ្លះធ្វើការអភិវឌ្ឍឲ្យប្រសើរឡើងនូវមាតិការបស់គេហទំព័រដែលគេគ្រប់គ្រង។ ពួកគេអាចសរសេរអត្ថបទ បញ្ចូលអត្ថបទដែលទទួលបានពីអ្នកនិពន្ធផ្សេងទៀត។ Webmaster បញ្ចូលកូដទៅក្នុងអត្ថបទនៅក្នុងទម្រង់ HTML (Hyper Text Markup Language)។ កូដបែប HTML នឹងបញ្ជាទៅកុំព្យូទ័រអំពីរបៀបក្នុងការរៀបចំ និងរូបរាងឬទ្រង់ទ្រាយរបស់អត្ថបទ។ Webmaster ត្រូវតែរៀបចំអត្ថបទក្នុង គេហទំព័រឲ្យបានល្អ ងាយស្រួលស្វែងរក ងាយស្រួលមើល ឬអាន។ គេអាចប្រើពណ៌ផ្សេងៗគ្នា រូបភាព និងតារាងដើម្បីលំអទៅលើទំព័រ។ រូបគំនូរ ឬក្រាភិចទាំងនោះអាចយកចេញមកពីឯកសាររូបភាពដែលមានក្នុងគេហទំព័រនានាស្រាប់ ឬរូបដែលចម្លងបញ្ចូលពីខាងក្រៅ។ ក្នុងករណីខ្លះ អ្នកគ្រប់គ្រងគេហទំព័រត្រូវរៀបចំទំព័រផ្សព្វផ្សាយពាណិ-ជ្ជកម្ម ផលិតផលឬសេវាកម្មរបស់ក្រុមហ៊ុន ដែលពេលនោះគេអាចធ្វើការជាមួយអ្នកជំនាញផ្នែកទីផ្សារ ឬផ្នែកអភិវឌ្ឍគេហទំព័រ។ បន្ថែមលើនេះ គេត្រូវពិនិត្យលើការភ្ជាប់ (link) ជាមួយទំព័រឬគេហទំព័រផ្សេងៗទៀត ហើយត្រូវមានភាពប្រាកដថា អ្នកចូលទស្សនាអាចភ្ជាប់ទៅរកព័ត៌មានផ្សេងៗដែលគេត្រូវការបានយ៉ាងងាយស្រួល។ ពួកគេក៏ធ្វើការកត់សម្គាល់ផងដែរថា តើមានមនុស្សប៉ុន្មានចូលទៅមើលគេហទំព័ររបស់ពួកគេ។ ម្យ៉ាងទៀតពួកគេឆ្លើយនឹងសំណួរ និងការទទួលយោបល់ត្រឡប់ពីអ្នកចូលទៅទស្សនាគេហទំព័រដោយសារអ៊ីម៉េល។ ចំណែកឯ Webmaster ខ្លះទទួលខុសត្រូវទៅលើដំណើរការនៃការបញ្ជាទិញផលិតផល និងសេវាកម្មរបស់អតិថិជនផងដែរ។





## ការអប់រំ និងការបណ្តុះបណ្តាល



ដើម្បីរៀបចំសម្រាប់អាជីពនៅក្នុងវិស័យនេះ អ្នកត្រូវរៀនផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ ភាសាអង់គ្លេស និងគណិតវិទ្យា។ Webmaster ជាច្រើនមានសញ្ញាបត្របរិញ្ញាបត្រផ្នែកសិល្បៈក្នុងការគិត វិស្វកម្ម ឬវិទ្យាសាស្ត្រកុំ- ព្យូទ័រ។ អ្នកខ្លះទៀតអាចសិក្សានិងទទួលសញ្ញាបត្រពីសាលាបណ្តុះបណ្តាលបច្ចេកទេស។ មនុស្សខ្លះដែលបម្រើការក្នុងវិស័យនេះច្រើនតែមានបទពិសោធន៍ផ្នែកបច្ចេកទេសកុំព្យូទ័រ។ និយោជិកច្រើនប្រាថ្នាចង់បានបុគ្គលិកដែលមានបទពិសោធន៍យ៉ាងហោចណាស់២ឆ្នាំ ផ្នែកបច្ចេកទេសគេហ-


តទៅទំព័របន្ទាប់

*ទំព័រ ព្រមទាំងចំណេះដឹងផ្នែក HTML, JavaScript, និង SQL សម្រាប់មុខតំណែងជា Webmaster។*

## គួរយល់ដឹង !

**✦ មុខវិជ្ជាសិក្សាក្នុងសាលា:**

វិទ្យាសាស្ត្រកុំព្យូទ័រ និងគណិតវិទ្យា

**✦ កម្រិតអប់រំទាបបំផុត:**

ការបណ្តុះបណ្តាលបច្ចេកទេស ឬបរិញ្ញាបត្រ

**✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកឯកទេសខាងតបណ្តាញកុំព្យូទ័រ

អ្នកឯកទេសខាងកម្មវិធីកុំព្យូទ័រ

អ្នកបង្ហាត់កុំព្យូទ័រ និង

អ្នកសរសេរអត្ថបទក្នុងអ៊ីនធើណេត ជាដើម។




# កម្មករផ្នែកជួសជុលផ្លូវថ្នល់

( Road Crew Workers )

**សង្ខេបអំពីជំនាញ**

**កម្មករផ្នែកជួសជុលផ្លូវថ្នល់ធ្វើការងារ៖**

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

✦ បំពេញការងារជាក្រុម

G

**ជំនាញដែលត្រូវការប្រើ៖**

✦ គណិតវិទ្យា

✦ ការទទួលខុសត្រូវ

✦ ការនិយាយ និងការស្តាប់

## តើកម្មករផ្នែកជួសជុលផ្លូវថ្នល់បំពេញកិច្ចការអ្វីខ្លះ?

*ការធ្វើចរាចរណ៍ដោយឡានធុនធ្ងន់ និងឡានដឹកទំនិញបានធ្វើឲ្យផ្លូវថ្នល់មានការខូចខាតជាច្រើន។ អាកាសធាតុក្តៅខ្លាំង ឬភ្លៀងខ្លាំងក៏បណ្តាលឲ្យខូចខាតថ្នល់ បង្កើតជាជង្ហុក និងបែកបាក់ចិញ្ចើមផ្លូវ។ កម្មករជួលជុលផ្លូវជួយរក្សានិងជួសជុលផ្លូវតូចធំនានាដូចជាផ្លូវលំ និងផ្លូវជាតិ។ ពួកគេសាងសង់ផ្លូវថ្មី ជួសជុលផ្លូវចាស់ សម្អាតដីនិងកាត់ស្មៅតាមបណ្តោយផ្លូវ។ កិច្ចការងារផ្សេងទៀតអាចរួមបញ្ចូលទាំងការដាក់ស្លាកសញ្ញា ការត្រួតពិនិត្យចរាចរណ៍ ការបើកឡានដឹកជញ្ជូននិងត្រាក់ទ័រ ព្រមទាំងរៀបចំកៅស៊ូនិងបេតុងសម្រាប់ក្រាលថ្នល់។ អ្នកគ្រប់គ្រងកម្មករជួលជុលផ្លូវត្រូវសិក្សាអំពីប្លង់ គូរគំនូរព្រាង និងធ្វើអង្កេតដើម្បីកំណត់អំពី*

សម្ភារ ឧបករណ៍ ពេលវេលា និងចំនួនកម្មករដើម្បីធ្វើគម្រោងអ្វីមួយ។ កម្មករជួលជុលផ្លូវផ្សេងទៀតមានភារៈដាក់របាំង និងដាក់ភ្លើងដើម្បីកុំឲ្យអ្នកបើកបរឆ្លងកាត់លើកំណាត់ផ្លូវដែលកំពុងតែសាងសង់ ហើយចង្អុលបង្ហាញទិសផ្លូវឲ្យអ្នកបើកបរបង្វែរទៅផ្លូវផ្សេង និងដាក់ល្បឿនកំណត់ផងដែរ។ ចំពោះអ្នកដែលចង្អុលបង្ហាញទិសផ្លូវអាចតម្រូវឲ្យឈរលើផ្លូវដោយកាន់ស្លាកសញ្ញា និងធ្វើការទំនាក់ទំនងជាមួយកម្មករជួលជុលផ្លូវផ្សេងទៀតដោយប្រើវិទ្យុទាក់ទង។ កម្មករជួលជុលផ្លូវតែងតែពាក់អាវកាក់ដែលចាំងពន្លឺដើម្បីឲ្យអ្នកបើកបរងាយមើលឃើញ ឬជាសញ្ញាប្រុងប្រយ័ត្ន។ នៅក្នុងការសាងសង់ ឬជួសជុលថ្នល់ ជំហានដំបូងបំផុតគឺសំអាតដី។ កម្មករជួលជុលផ្លូវធ្វើឲ្យដីរាបស្មើហើយបាចថ្មនិងគ្រួស។ កម្មករអាចដាក់ដែកនិងចងខ្សែលួសដើម្បីធ្វើឲ្យគ្រឹះផ្លូវរឹងមាំ។ កម្មករជួលជុលផ្លូវក៏ត្រូវចេះបើកឡានដឹកទំនិញ និងត្រាក់ទ័រសម្រាប់រាប់ប្រតិបត្តិការផងដែរ។ នៅពេលដែលកៅស៊ូនិងបេតុងរៀបចំរួចរាល់ហើយ ពួកគេចាក់និងក្រាលវាចេញពីម៉ាស៊ីនលាយវត្ថុធាតុទាំងអស់នោះ។



## ការអប់រំ និងការបណ្តុះបណ្តាល



កម្មករជួសជុលផ្លូវថ្នល់មិនតម្រូវឲ្យមានកម្រិតអប់រំនោះទេ ប៉ុន្តែ ជាការប្រសើរប្រសិនពួកគេបានទទួលការអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ ផ្ទុយទៅវិញការងារប្រភេទនេះគឺ ត្រូវការជាចាំបាច់នូវបទពិសោធន៍ក្នុងការសាងសង់ ការងារក្នុងកសិដ្ឋានដែលអាចជួយឲ្យអ្នកដឹងពីការប្រើប្រាស់និងជួសជុលម៉ាស៊ីនឬឡានដឹកទំនិញ។

ហេតុនេះ អ្នកត្រូវការហ្វឹកហាត់ និងប្រមូលបទពិសោធន៍ឲ្យបានច្រើន ប្រសិនបើអ្នកចង់បានមុខងារដែលទទួលបានប្រាក់បៀវត្សខ្ពស់។



## គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

គណិតវិទ្យា បច្ចេកទេស និងរោងជាង

✦ **កម្រិតអប់រំទាបបំផុត:**

មធ្យមសិក្សាទុតិយភូមិ ឬទាបជាងនេះ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកឯកទេសមន្ទីរពិសោធន៍ខាងសំណង់

អ្នកបច្ចេកទេសគ្រឿងចក្រឧស្សាហកម្ម

វិស្វករប្រតិបត្តិការ និង

អ្នកបើកបររថយន្តធុនធ្ងន់ ជាដើម។

## អ្នកបម្រើការលើយន្តហោះ

(Flight Attendants)

**សង្ខេបអំពីជំនាញ**

**អ្នកបម្រើការលើយន្តហោះធ្វើការងារ៖**

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

✦ គ្រប់គ្រងមនុស្ស (អ្នកដំណើរ)

✦ បំពេញការងារជាក្រុម

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការទទួលខុសត្រូវ

✦ ការទំនាក់ទំនង

✦ ការនិយាយ និងការស្តាប់


តទៅទំព័របន្ទាប់

## តើអ្នកបម្រើការលើយន្តហោះបំពេញកិច្ចការអ្វីខ្លះ?

អ្នកបម្រើការលើយន្តហោះផ្តល់នូវសេវាកម្មជាច្រើន ដើម្បីធ្វើឲ្យអ្នកដំណើរលើយន្តហោះមានផាសុខភាព និងសុវត្ថិភាពក្នុងអំឡុងពេលហោះហើរ។ ពួកគេអាចបម្រើតាមជើងហោះហើរអន្តរជាតិរាប់ពាន់គីឡូម៉ែត្រជុំវិញពិភពលោក។

មុននឹងធ្វើការហោះហើរ អ្នកបម្រើការលើយន្តហោះត្រូវចូលរួមការប្រជុំខ្លីមួយជាមួយនឹងបុគ្គលិកផ្សេងទៀត។ ពួកគេត្រូវធ្វើការត្រួតពិនិត្យបរិក្ខាផ្គត់ផ្គង់ក្នុងពេលហោះហើរដោយប្រុងប្រយ័ត្នដូចជា អាវសម្រាប់សង្គ្រោះជីវិត, ឧបករណ៍អុកស៊ីសែននិងឧបករណ៍សុវត្ថិភាពផ្សេងទៀតរបស់អ្នកដំណើរ។ ពួកគេត្រូវរៀបចំបន្ទប់អ្នកដំណើរឲ្យមានសណ្តាប់ធ្នាប់ដូចជាដាក់ខ្នើយ និងភួយ។ ពួកគេក៏ធ្វើការត្រួតពិនិត្យអាហារនិងភេសជ្ជៈដែលមាននៅក្នុងយន្តហោះ និងពិនិត្យថាអ្វីៗទាំងអស់គឺស្ថិតក្នុងលក្ខខណ្ឌសុវត្ថិភាពសម្រាប់ការចុះចត។ ពួកគេធ្វើការស្វាគមន៍ភ្ញៀវ និងត្រួតពិនិត្យសំបុត្ររបស់ភ្ញៀវ នៅពេលដែលភ្ញៀវឡើងយន្តហោះ, បង្ហាញភ្ញៀវនូវកន្លែងសម្រាប់រក្សាទុកឥវ៉ាន់ និងកន្លែងអង្គុយ។ ជារឿយៗ ពួកគេយកចិត្តទុកដាក់ជាពិសេសចំពោះភ្ញៀវដែលជាមនុស្សចាស់ និងជនពិការ និងភ្ញៀវទេសចរណ៍ដែលមានកូនតូច ជាដើម។

មុននឹងធ្វើការហោះហើរ អ្នកបម្រើលើយន្តហោះ និយាយទៅកាន់ភ្ញៀវ តាមរយៈឧបករណ៍បំពងសម្លេងអំពីអាកាសធាតុ និងព័ត៌មានសុវត្ថិភាពផ្សេងៗ។

ចាប់ពីការចេញដំណើររហូតដល់ការចុះចត អ្នកបម្រើលើយន្តហោះត្រូវត្រួតពិនិត្យ ដើម្បីឲ្យអ្នកដំណើរពាក់ខ្សែក្រវាត់សុវត្ថិភាពដោយត្រឹមត្រូវ និងអង្គុយឲ្យត្រឹមត្រូវតាមទីកន្លែង។ ពួកគេអាចចែកកាសែត ឬទស្សនាវដ្តីទៅដល់អ្នកដំណើរ និងឆ្លើយនូវសំណួរដែលពាក់ព័ន្ធនឹងតារាងពេលវេលាហោះហើរ និងភូមិសាស្ត្រដែលកំពុងឆ្លងកាត់។ ពួកគេធ្វើការសង្កេតអ្នកធ្វើដំណើរកំឡុងពេលហោះហើរ ដើម្បីធានានូវផាសុខភាព និងជួយសង្គ្រោះភ្លាមៗចំពោះអ្នកដែលមានអាការៈឈឺ។

អ្នកបម្រើត្រូវចែកម្ហូបអាហារ, ភេសជ្ជៈដល់ភ្ញៀវនិងទទួលខុសត្រូវក្នុងការបំពេញរបាយការណ៍អ្នកដំណើរ។

ទោះបីការងារជាអ្នកបម្រើលើយន្តហោះមិនតម្រូវឲ្យមានកម្រិតសញ្ញាបត្រខ្ពស់ក៏ដោយប៉ុន្តែប្រសិនបេក្ខជនបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនោះគឺជាការប្រសើរ។ ម្យ៉ាងទៀត ការចេះភាសាបរទេសផ្សេងៗស្ទាត់ជំនាញ ក៏ជាសក្តានុពលក្នុងការទទួលបានឱកាសការងារនិងការប្រកួតប្រជែង។

បន្ថែមលើនេះ រូបសម្បត្តិនិងចរិយាសម្បត្តិក៏ចំណែកមួយនៃការកំណត់លក្ខខណ្ឌជ្រើសរើសចំពោះបេក្ខជនផងដែរ។ ជាទូទៅ បុគ្គលិកផ្នែកនេះតែងទទួលការហ្វឹកហ្វឺនបន្ថែមលើបច្ចេកទេសនិងបែបបទការងារក្នុងយន្តហោះដែលអាចផ្តល់ភ្នាក់ងារហោះហើរផ្ទាល់ ឬសាលាឯកទេសផ្នែកនេះដើម្បីយល់ដឹងពីប្រតិបត្តិការ, តារាងពេលវេលានៃការហោះហើរ, បទបញ្ជានិងតួនាទីក្នុងការហោះហើរ, ការសង្គ្រោះបឋម, ប្រតិបត្តិការបន្ទាន់ និងទំនាក់ទំនងសាធារណៈជាដើម។

អ្នកបម្រើការលើយន្តហោះ តែងទទួលការហ្វឹកហាត់បន្ថែមជាប្រចាំដើម្បីរំឭកពីបច្ចេកទេស និងការសម្របយកនូវស្ថានភាពវិវត្តថ្មីក្នុងវិស័យអាកាសចរនិងការដឹកជញ្ជូន។ រីឯការហោះហើរជាអន្តរជាតិ គឺត្រូវបានបង្រៀនពីបញ្ញត្តិច្បាប់ផ្សេងៗរបស់ដែនអាកាស និងប្រទេសចុះសំចត។





តទៅទំព័របន្ទាប់

## គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
ចិត្តវិជ្ជា និងថ្លែងសុន្ទរកថា

✦ **កម្រិតអប់រំទាបបំផុត:**
បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**
អ្នកធ្វើការតាមកប៉ាល់, អ្នកតំណាងផ្នែកសេវាកម្ម, អ្នកបំរើក្នុងសណ្ឋាគារ, ភ្នាក់ងារកក់សំបុត្រនិងកន្លែងស្នាក់នៅ, ភ្នាក់ងារកន្លែងកំសាន្ត ។ល។

## អ្នកភូមិសាស្ត្រ

( Geographers )

**សង្ខេបអំពីជំនាញ**

**អ្នកបង្ហាញម៉ូតធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ បង្រៀន

G

**ជំនាញដែលត្រូវការប្រើ៖**

✦ គណិតវិទ្យា
✦ ការអាន និងការសរសេរ
✦ ការគិតប្រកបដោយហេតុផល

## តើអ្នកភូមិសាស្ត្របំពេញកិច្ចការអ្វីខ្លះ?



*អ្នកភូមិសាស្ត្រសិក្សាពីផ្ទៃខាងក្រៅរបស់ផែនដី ដូចជាភ្នំ និងទន្លេ ប៉ុន្តែពួកគេក៏សិក្សាអំពីជីវិតរុក្ខជាតិ, សត្វ, អាកាសធាតុ, សេដ្ឋកិច្ចនិងនយោបាយដែលជះឥទ្ធិពលលើតំបន់ និងពិភពលោកផងដែរ។*

*អ្នកភូមិសាស្ត្រភាគច្រើនធ្វើការនៅឯវិទ្យាល័យ ឬមហាវិទ្យាល័យ ឬជាភ្នាក់ងាររដ្ឋាភិបាលដែលទាក់ទងនឹងការបង្រៀន ឬការស្រាវជ្រាវ។ អ្នកភូមិសាស្ត្រផ្សេងទៀតធ្វើការឲ្យក្រុមហ៊ុនផែនទី, សៀវភៅសិក្សា, អ្នកបោះពុម្ពផ្សាយវចនាធិប្បាយ និងភ្នាក់ងារធ្វើដំណើរ។ ក្រុមហ៊ុនអចលនវត្ថុ, ក្រុមហ៊ុនផលិតកម្ម, អង្គភាពស្រាវជ្រាវទីផ្សារ និងក្រុមហ៊ុនទូរគមនាគមន៍ក៏ត្រូវការជ្រើសរើសអ្នកភូមិសាស្ត្រដែរ។*

*អ្នកភូមិសាស្ត្រដែលមានការងារជាអ្នកស្រាវជ្រាវតែងសិក្សាពីលក្ខខណ្ឌនៃតំបន់ជាក់លាក់មួយដូចជា ដី, រុក្ខជាតិ, អាកាសធាតុ, ទឹក និងធនធានរ៉ែ។ អ្នកភូមិសាស្ត្រត្រូវការចំណាយពេលជាច្រើននៅលើតំបន់ដែលពួកគេកំពុងសិក្សាដើម្បីប្រមូលទិន្នន័យស្ថិតិ និងរៀបចំព័ត៌មានផ្សេងៗ។*

*អ្នកភូមិសាស្ត្រមានជំនាញផ្សេងៗ ក្នុងវិស័យភូមិ-សាស្ត្រដូចជា អ្នកគូផែនទី និងប្រមូលព័ត៌មានចាំបាច់សម្រាប់ផែនទី។ អ្នកភូមិសាស្ត្រពាក់ព័ន្ធសេដ្ឋកិច្ចធ្វើការវិភាគសកម្មភាពសេដ្ឋ-កិច្ចនៃរបាយភូមិសាស្ត្រ ដូចជារោងចក្រ, ការទាញយករ៉ែ, កសិកម្ម និងគមនាគមន៍។ ចំណែកអ្នកភូមិសាស្ត្រក្នុងតំបន់ សិក្សាអំពីទិដ្ឋភាពភូមិសាស្ត្រនៅក្នុងតំបន់មួយជាក់លាក់ ដូចជាអាងទឹកទន្លេ, កោះ, ប្រទេស ឬទ្វីបមួ-យ។ អ្នកភូមិសាស្ត្រទីក្រុង សិក្សាពីបញ្ហាដែលត្រូវដោះ*

---

*អត្ថបទដកស្រង់ និងប្រែសម្រួលចេញពីឯកសារ Career Discovery Encyclopedia. Infobase Publishing. Seven Edition, 2009. ដោយ **ហៃ ហ៊ុនឡេង**។*
*ប្រសិនលោកអ្នកចង់ជ្រាបនូវព័ត៌មានបន្ថែមស្តីពីឯកសារនេះសូមអញ្ជើញរកអាននៅ **«បណ្ណាល័យការងារ»** របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារដោយមេត្រី។*

ស្រាយជាមួយនឹងភូមិសាស្ត្រទីក្រុង។ ពួកគេជួយក្នុងការធ្វើគម្រោងអភិវឌ្ឍទីក្រុង និងជាយក្រុងដូចជាការអភិវឌ្ឍលំនៅដ្ឋាន, ប្រព័ន្ធគ្រប់គ្រងចរាចរណ៍, មជ្ឈមណ្ឌលពាណិជ្ជកម្ម និងតំបន់សួនឧទ្យាន។ ពួកគេណែនាំពាណិជ្ជកម្ម និងឧស្សាហកម្មអំពីទីតាំងរោងចក្រ និងបញ្ហាផ្សេងៗ។ អ្នកភូមិសាស្ត្រនយោបាយ សិក្សាពី ធនធានធម្មជាតិ, ព្រំដែនប្រទេស និងលក្ខណៈរូបសាស្ត្រ របស់ទឹកដីដែលជាប់ទាក់ទងនឹងកិច្ចការក្នុងតំបន់, ជាតិ និងអន្តរជាតិ។ អ្នកភូមិសាស្ត្រផ្នែករូបវន្តសិក្សាពីចរិកលក្ខណៈធម្មជាតិនៃតំបន់មួយដូចជាភ្នំ, ជ្រលងភ្នំ, មហាសមុទ្រ ឬអាកាសធាតុ។

## ការអប់រំ និងការបណ្តុះបណ្តាល

ជំនាញមូលដ្ឋានគ្រឹះដ៏ល្អសម្រាប់សិក្សាវិស័យនេះ មានដូចជា មេរៀនភូមិសាស្ត្រ, វិទ្យាសាស្ត្រផែនដី, សង្គមវិទ្យា, វិទ្យាសាស្ត្រកុំព្យូទ័រ, ភាសាអង់គ្លេស, ប្រវត្តិវិទ្យា និងគណិតវិទ្យា។ ដើម្បីក្លាយជាអ្នកភូមិសាស្ត្រអ្នកត្រូវការបរិញ្ញាបត្រផ្នែកភូមិសាស្ត្រ ឬអាចបន្តការសិក្សាដល់កម្រិតខ្ពស់ជាងនេះទៀតក៏បាន ប្រសិនអ្នកចង់មានអាជីពជាអ្នកស្រាវជ្រាវ និងបង្រៀន។




## គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលាៈ**

វិទ្យាសាស្ត្រផែនដី, ភូមិសាស្ត្រ និងគណិតវិទ្យា

✦ **កម្រិតអប់រំទាបបំផុតៈ**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នាៈ**

បុរាណវិទូ, អ្នកគូរផែនទី, អ្នកធ្វើគំរោងទីក្រុង
អ្នកភូគព្ភសាស្ត្រ, អ្នកឯកទេសខាងឧត្តុនិយម
អ្នកបច្ចេកទេសវាស់ស្ទង់ដី និងគូរផែនទី ។ល។

## អ្នកលក់ទំនិញតាមទូរសព្ទ

(Telemarketers)

**សង្ខេបអំពីជំនាញ**

**បរិយាកាសធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ ជួយកិច្ចការដល់អតិថិជន ឬភ្ញៀវ

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការមានជំនឿចិត្ត
✦ ការទំនាក់ទំនង
✦ ការនិយាយ និងការស្តាប់


តទៅទំព័របន្ទាប់

## តើអ្នកលក់ទំនិញតាមទូរសព្ទបំពេញកិច្ចការអ្វីខ្លះ?

អ្នកលក់ទំនិញតាមទូរសព្ទ ផ្សព្វផ្សាយលក់ទំនិញ និងសេវាកម្មតាមទូរសព្ទ។ ពួកគេទទួលការបញ្ជាទិញ, ដោះស្រាយបញ្ហាអំពីការត្អូញត្អែរបស់អតិថិជន និងធ្វើការស្ទាបស្ទង់មតិជាមួយអតិថិជនតាមរយៈទូរសព្ទ។ ជំនាញក្នុងការទំនាក់ទំនងតាមទូរសព្ទរបស់ពួកគេ គឺជាការប្រើប្រាស់ដ៏ទូលំទូលាយនៅក្នុងផ្នែកពាណិជ្ជកម្ម និងអង្គភាពផ្សេងទៀត។

នៅតាមហាង និងក្រុមហ៊ុនជាច្រើនបានផ្ដល់ឲ្យអតិថិជននូវលេខទូរសព្ទដែលអាចហៅចូលដោយឥតគិតថ្លៃ និងលើកទឹកចិត្តឲ្យធ្វើការហៅចូលប្រសិនបើពួកគេមានសំណួរ ការត្អូញត្អែ និងចម្ងល់ផ្សេងៗទៀត។ ការលក់តាមទូរសព្ទតែងទទួលការហៅទូរសព្ទចូលពីអតិថិជនជាច្រើន ប្រៀបដូចជាអតិថិជនចូលមកក្នុងហាងទិញឥវ៉ាន់ដោយផ្ទាល់ដូច្នោះដែរ។ អ្នកលក់ទំនិញតាមទូរសព្ទ គឺត្រូវបានជួលដោយក្រុមហ៊ុនដែលលក់ទំនិញ និងសេវាកម្ម ឬដោយភ្នាក់ងារដែលលក់ សេវាកម្មប្រភេទនេះសម្រាប់រយៈពេលកំណត់ណាមួយ។

អ្នកលក់តាមទូរសព្ទធ្វើការហៅចេញ និងទទួលការហៅចូល។ ការហៅទូរសព្ទចេញអាចធ្វើឡើងចំពោះមនុស្សដែលបង្ហាញចំណាប់អារម្មណ៍ទៅលើផលិតផល និងសេវាកម្ម។ ពេលខ្លះ អ្នកលក់តាមទូរសព្ទអាចធ្វើការហៅទៅកាន់អតិថិជនណាម្នាក់ដែលគេបានជ្រើសរើសដោយចៃដន្យ និងពុំបានព្រាងទុកជាមុន។ ចំណែកឯការហៅត្រលប់ពីអតិថិជនមកវិញច្រើនជាការបញ្ជាទិញទំនិញផ្សេងៗ, ការកក់សំបុត្រយន្តហោះ និងការសាកសួរព័ត៌មានជាច្រើនផ្សេងទៀត។

ជម្មតា អ្នកលក់ទំនិញតាមទូរសព្ទច្រើនធ្វើការក្នុងការិយាល័យរបស់ក្រុមហ៊ុន ឬទីស្នាក់ការកណ្ដាល ដែលអាចមានបុគ្គលិករួមការងារមួយចំនួនទៀត។ មនុស្សដែលធ្វើការជាអ្នកលក់តាមទូរសព្ទគួរតែមានការអត់ធ្មត់, អាកប្បកិរិយាល្អ និងត្រូវមានវិធីនិយាយជាមួយអតិថិជនដែលខ្វះការគួរសម។







## ការអប់រំ និងការបណ្ដុះបណ្ដាល

ដើម្បីរៀបចំខ្លួនបម្រើការងារជាអ្នកលក់តាមទូរសព្ទ អ្នកគួររៀនមុខវិជ្ជាសំខាន់ៗមួយចំនួននៅវិទ្យាល័យដូចជា ការថ្លែងសុន្ទរកថា, ភាសាអង់គ្លេស, ការទំនាក់ទំនង និងពាណិជ្ជកម្ម។ បន្ថែមលើនេះ មុខវិជ្ជាចិត្តវិទ្យា និងសង្គមវិទ្យាក៏មានអត្ថប្រយោជន៍ផងដែរ។ បុគ្គលិកបម្រើការផ្នែកលក់តាមទូរសព្ទគួរមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬនិស្សិតដែលទើបតែបញ្ចប់ពីមហាវិទ្យាល័យ។

អ្នកលក់តាមទូរសព្ទ ជាទូទៅទទួលបានការហ្វឹកហ្វាត់ជាច្រើនពីរបៀបប្រើប្រាស់ឧបករណ៍ និងរបៀបអានអត្ថបទ។ ពួកគេរៀនពីបច្ចេកទេសលក់, ការនិយាយជាមួយភ្ញៀវ, និងត្រូវអភិវឌ្ឍន៍ជំនាញស្ដាប់ផងដែរ។


តទៅទំព័របន្ទាប់

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
ពាណិជ្ជកម្ម
និងការថ្លែងសុន្ទរកថា
✦ **កម្រិតអប់រំទាបបំផុត:**
សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬបរិញ្ញាបត្រ
✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**
បុគ្គលិកផ្សព្វផ្សាយលក់,
បុគ្គលិកប្រមូលព័ត៌មានឬទិន្នន័យ,
អ្នកស្រាវជ្រាវទីផ្សារ,
អ្នកទទួលភ្ញៀវ, ភ្នាក់ងារកក់សំបុត្រ,
និងការីទូរសព្ទ ។ល។

## អ្នកគ្រប់គ្រងកន្លែងហាត់កីឡា

(Sport Facility Managers)

**សង្ខេបអំពីជំនាញ**

**អ្នកគ្រប់គ្រងនិងថែទាំគេហទំព័រធ្វើការងារ៖**

✦ បំពេញការងារប្រកបដោយភាពជាអ្នកដឹកនាំ
✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន
✦ បំពេញកិច្ចការជាក្រុម

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការដោះស្រាយបញ្ហា
✦ កាសម្រេចចិត្ត
✦ ការស្តាប់ និងការនិយាយ

## តើអ្នកគ្រប់គ្រងកន្លែងហាត់កីឡាបំពេញកិច្ចការអ្វីខ្លះ?



អ្នកគ្រប់គ្រងកន្លែងហាត់កីឡា ជួនកាលត្រូវបានគេហៅថាអ្នកគ្រប់គ្រងកីឡដ្ឋាន គឺត្រូវទទួលខុសត្រូវចំពោះប្រតិបត្តិការប្រចាំថ្ងៃ ដែលទាក់ទងនឹងដំណើរការនៅកន្លែងលេងកីឡា។

អ្នកគ្រប់គ្រងកន្លែងកីឡាត្រូវធ្វើការងារទាក់ទងការរៀបចំផ្ញើគម្រោងដែលក្នុងនោះមានដូចជា ការទិញ, ការលក់, ការជួលទីតាំង, ការកែច្នៃទីកន្លែងឡើងវិញ និងជួលជុល។ ពួកគេគ្រប់គ្រងឧបករណ៍កីឡារួមទាំងរចនាសម្ព័ន្ធ និងបរិវេណ ព្រមទាំងបុគ្គលិកផ្នែកបង្ហាត់ផងដែរ។ អ្នកគ្រប់គ្រងត្រូវចំណាយជាច្រើនក្នុងការរៀបចំគម្រោងដូចជា ពិចារណាលើទីកន្លែងសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មី, វិភាគនិងវាយតម្លៃលើបរិដ្ឋានឬការគាំទ្រពីសំណាក់អ្នករស់នៅជុំវិញ, ច្បាប់ឬបទបញ្ញាក្នុងការសាងសង់អាគារថ្មី។

អ្នកគ្រប់គ្រងកន្លែងលេងកីឡា ឬកីឡដ្ឋានដែលមិនជាប់ពាក់ព័ន្ធក្នុងការសាងសង់កន្លែងថ្មី ឬការរៀបចំឡើងវិញនូវអាគារដែលមានស្រាប់ត្រូវចំណាយពេលរបស់ពួកគេនៅក្នុងការិយាល័យ ឬទីកន្លែងផ្សេងទៀតនៅក្នុងកីឡដ្ឋានផ្ទាល់។ ពួកគេជាញឹកញាប់កំណត់រចនាសម្ព័ន្ធអង្គភាព និងគ្រប់គ្រងឬផ្គត់ផ្គង់រាល់តម្រូវការរបស់បុគ្គលិក។

អ្នកគ្រប់គ្រងកន្លែងលេងកីឡាជួយអភិវឌ្ឍ និងការសម្របសម្រួលដំណើរការការងារប្រចាំឆ្នាំរបស់កីឡដ្ឋាន, តារាងពេល វេលានិងម៉ោងធ្វើការ និងប្រាក់ចំណូលផងដែរ។

អ្នកគ្រប់គ្រងកន្លែងលេងកីឡាក៏មានភារៈចចារ, ធ្វើកិច្ចសន្យាជាមួយភ្នាក់ងារឧស្សាហកម្ម, អ្នកផ្គត់ផ្គង់ និងអ្នកលក់ដូរ។ ទោះបីជាយ៉ាងណា សេវាកម្មមួយចំនួនដូចជាសេវាកម្មអាហារនិងសន្តិសុខអាចគ្រប់គ្រងដោយអ្នកលក់ និងក្រុមហ៊ុនពីខាងក្រៅ។


តទៅទំព័របន្ទាប់




## ការអប់រំ និងការបណ្តុះបណ្តាល

មុខវិជ្ជាសិក្សាមួយចំនួននៅឯវិទ្យាល័យអាចផ្តល់ឲ្យអ្នកនូវចំណេះដឹងទូទៅសម្រាប់ការងារគ្រប់គ្រងកន្លែងលេងកីឡា រួមទាំងមុខវិជ្ជាពាណិជ្ជកម្ម, គណិតវិទ្យា, ការគ្រប់គ្រង និងវិទ្យាសាស្ត្រកុំព្យូទ័រ។ ចំណែកឯការនិយាយ និងសរសេរអាចជួយបង្កើនជំនាញក្នុងការទំនាក់ទំនង។

ជាទូទៅបេក្ខជនគួរមានកម្រិតសញ្ញាបត្របរិញ្ញាបត្រ ដើម្បីអាចមានលទ្ធភាពល្អប្រសើរក្នុងការគ្រប់គ្រងការងារនេះ។

## គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
ពាណិជ្ជកម្ម និងភាសាបរទេស
✦ **កម្រិតអប់រំទាបបំផុត:**
បរិញ្ញាបត្រ
✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**
អ្នកគ្រប់គ្រងពាណិជ្ជកម្ម និង
អ្នកនាំភ្ញៀវក្នុងពហុកីឡដ្ឋាន ។ល។

# និពន្ធនាយកទស្សនាវដ្តី

( Magazine Editors )

**សង្ខេបអំពីជំនាញ**

**កម្មករផ្នែកជួសជុលផ្លូវថ្នល់ធ្វើការងារ៖**

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ បំពេញការងារជាក្រុម

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
✦ ការធ្វើសេចក្តីសម្រេចចិត្ត
✦ ការអាន និងការសរសេរ

## តើនិពន្ធនាយកទស្សនាវដ្តីបំពេញកិច្ចការអ្វីខ្លះ?

និពន្ធនាយករៀបចំមាតិកាសម្រាប់ទស្សនាវដ្តី និងចាត់ចែងអត្ថបទដល់អ្នកនិពន្ធទាំងឡាយ ព្រមទាំងពិនិត្យនិងគ្រប់គ្រងរាល់ការបោះផ្សាយផងដែរ។ ពេលខ្លះនិពន្ធនាយកក៏សរសេរអត្ថបទផ្ទាល់ខ្លួនឯងផងដែរ ប៉ុន្តែភាគច្រើនពួកគេកែសម្រួលនិងផ្តល់យោបល់ទៅដល់អត្ថបទដែលត្រូវចុះផ្សាយ។ បន្ថែមលើនេះ និពន្ធនាយកក៏មានសិទ្ធិក្នុងការជ្រើសរើសឬបញ្ឈប់បុគ្គលិកនិពន្ធណាម្នាក់ផងដែរ។ ជាទូទៅទំហំការងារនេះអាស្រ័យតាមប្រភេទនៃទស្សនាវដ្តី និងមាតិកាច្រើនឬតិចដែលត្រូវសរសេរផ្សព្វផ្សាយដូចជា ទំព័រសេដ្ឋកិច្ច, នយោបាយ, កីឡា, ការកំសាន្ត និងព័ត៌មានផ្សេងៗទៀត។ និពន្ធនាយកត្រូវពិនិត្យជាចាំបាច់ចំពោះទំព័រអត្ថបទទាំងអស់មុនការចេញផ្សាយគ្រប់លើក។ ក្រៅពីនេះកិច្ចការរៀបចំ និងរចនាទំព័រត្រូវគ្រប់គ្រងពិនិត្យដោយផ្នែកផលិតនិងបោះពុម្ព។ សម្រាប់អត្ថបទខ្លះត្រូវការជំនួយពីអ្នកស្រាវជ្រាវដើម្បីសរសេរព័ត៌អំពីទិន្នន័យផ្សេងៗ។

និពន្ធនាយក ក៏មានការជួយជ្រោមជ្រែងពីជំនួយការមួយចំនួនដែលមានភារៈពិនិត្យអត្ថបទដែលអ្នកនិពន្ធផ្ញើមក, កែតម្រូវពាក្យខុសនិងវេយ្យាករណ៍ជាដើម។ ជំនួយការអាចកែសម្រួលឃ្លាឃ្លោងមួយចំនួនដើម្បីធ្វើឲ្យមានន័យពេញលេញងាយយល់ ឬក៏ដកព័ត៌មានដែលមិនត្រឹមត្រូវចេញ។

## ការអប់រំ និងការបណ្តុះបណ្តាល

ពេលសិក្សានៅវិទ្យាល័យ អ្នកគួរយកចិត្តទុកដាក់លើមុខ-វិជ្ជាសំខាន់ៗមួយចំនួនដូចជា អក្សរសាស្ត្រ, ភាសាបរទេស, ការសរសេរបែបតែងសេចក្តី និងប្រវត្តិសាស្ត្រជាដើម។

បន្ទាប់មកសិក្សានៅមហាវិទ្យាល័យផ្នែកសារព័ត៌មាន, ឯកទេសផ្នែកសិល្បៈបែបការច្នៃប្រឌិត, ឯកទេសផ្នែកទំនាក់ទំនង និងភាសាបរទេសជាដើម។ គួរបញ្ជាក់ថា បុគ្គលភាគច្រើនទទួលតំណែងនេះតាមលំដាប់លំដោយនៃបទពិសោធន៍ក្នុងការងារដូចជា ចាប់ផ្តើមអាជីពពីអ្នកសារព័ត៌មាននិង ជំនួយការនិពន្ធជាដើម ពីព្រោះកិច្ចចាំបាច់គឺពាក់ព័ន្ធការសរសេរ។




## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ភាសាបរទេស និងសារព័ត៌មាន

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកគ្រប់គ្រងសិល្បៈ, អ្នកនិពន្ធសៀវភៅ, និពន្ធនាយកសារព័ត៌មាន, អ្នករាយការណ៍ព័ត៌មាន, អ្នកនិពន្ធ។ល។

## ជាងកាត់សក់

( Barbers )

**សង្ខេបអំពីជំនាញ**

**ជាងកាត់សក់ធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន
✦ ជ្រើសរើសនិងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការប្រាស្រ័យរាក់ទាក់
✦ ការគ្រប់គ្រងខ្លួនឯង
✦ ការនិយាយ និងការស្តាប់

## តើជាងកាត់សក់បំពេញកិច្ចការអ្វីខ្លះ?

ជាងកាត់សក់បំពេញកិច្ចការមួយចំនួនដល់អតិថិជន ដូចជា កក់សក់, កាត់សក់, ធ្វើម៉ូតសក់ និងកោរឬតម្រឹមពុកចង្កា។ ទោះបីជាជាងកាត់សក់ត្រូវបានបង្ហាត់បង្រៀនលើជំនាញនិងបច្ចេកទេសជាច្រើនដូចជា លាបពណ៌សក់ និងអ៊ុតសក់ក៏ដោយ ប៉ុន្តែជាងកាត់សក់ភាគច្រើនមិនមានផ្តល់សេវាកម្មគ្រប់ផ្នែកនោះទេ។ មានន័យថាជាងកាត់សក់ខ្លះកាត់សក់មួយមុខសម្រាប់អតិថិជនរបស់គេ។ ដោយឡែក អតិថិជនដែលចង់កែច្នៃម៉ូតសក់ និងទទួលបានសេវាផ្សេងៗពាក់ព័ន្ធសក់អាចទៅរកអ្នកធ្វើម៉ូតសក់នៅហាងដែលមានបម្រើសេវាផ្នែកនោះ។ ជួនកាលជាងកាត់សក់ក៏អាចហៅខ្លួនគេថាជាជាងធ្វើសក់ផងដែរ។

ឧបករណ៍ដែលជាងកាត់សក់ប្រើមានដូចជា កន្ត្រៃ, កាំបិតកោរ, កន្ត្រៃធំ, ក្រាសសិតសក់។ល។ ហើយឧបករណ៍ទាំងនោះត្រូវតែរក្សាទុកឲ្យបានល្អនិងគ្មានមេរោគ។ ជម្មតា ជាងកាត់សក់ត្រូវមានសព្វឧបករណ៍សម្រាប់បម្រើអតិថិជន។

ជាងកាត់សក់គឺអាចរកចិញ្ចឹមជីវិតដោយខ្លួនឯង ឬធ្វើការនៅក្នុងហាងតូចៗ។ ដូច្នេះ ពួកគេមិនទទួលបានកម្រៃច្រើននោះទេ។ ប៉ុន្តែ ក៏មានជាងកាត់សក់ភាគច្រើនមានអារម្មណ៍ថាការងាររបស់ពួកគេមិនសូវមានភាពតានតឹង ឬតប់ប្រមល់,មានសុវត្ថិភាព ព្រមទាំងរីករាយជាមួយការបម្រើអតិថិជន។

ជាងកាត់សក់ដែលបើកហាងផ្ទាល់ខ្លួន ត្រូវតែដោះស្រាយបញ្ហាគ្រប់ជំពូកក្នុងសេវាកម្មរបស់គេដូចជា ការគ្រប់គ្រងហាង, គ្រប់គ្រងបុគ្គលិក, ការទទួលភ្ញៀវនិងការណាត់ជួប, បញ្ជាទិញឧបករណ៍,បង់វិក្កយបត្រ, រក្សាឧបករណ៍ និងធ្វើការកត់ត្រាផ្សេងៗ។

ជាងកាត់សក់ទាមទារឲ្យមានទេពកោសល្យល្អក្នុងការប្រើប្រាស់ដៃ, ម្រាមដៃ និងភាពអំណត់ក្នុងការងារ ដោយសារពួកគេត្រូវឈរធ្វើការពេញមួយថ្ងៃ។ ជាងកាត់សក់គួរតែចេះរៀបចំនិងតុបតែងខ្លួនឲ្យបានល្អ និងមានអនាម័យ ពីព្រោះពួកគេធ្វើការនៅជាប់ជិតដល់ជាមួយនឹងអតិថិជនជាប្រចាំ។ ភាពវៃឆ្លាត, ការអត់ធ្មត់, ការពូកែស្តាប់គឺជាបុគ្គលិកលក្ខណៈដ៏សំខាន់សម្រាប់ការងារជាជាងកាត់សក់។

ដើម្បីទទួលបានជោគជ័យក្នុងការងារ ជាងកាត់សក់ត្រូវតែពូកែស្វែងយល់ពីលក្ខណៈរបស់អតិថិជនម្នាក់ៗ និងព្យាយាមឲ្យអស់លទ្ធភាពក្នុងការផ្តល់នូវភាពស្រស់ស្អាតដែលបំពេញតាមចិត្តនិងតម្រូវការរបស់អតិថិជនពួកគេ។ ជាងកាត់សក់គួរតែមានការយល់ដឹងពីរូបរាងនិងម៉ូត ដើម្បីកំណត់នូវរូបសម្រស់ដែលគួរជាទីចាប់អារមណ៍សំរាប់អតិថិជន។ ជាងកាត់សក់ត្រូវតែដឹងនៅពេលដែលម៉ូតដែលអតិថិជនចង់បាន តែវាមិនសាកសមនិងលក្ខណៈ រឺប្រភេទភេទសក់របស់អតិថិជន ដើម្បីចៀសវៀងការមិនពេញចិត្តរបស់អតិថិជន។ សំរាប់ស្ថានភាពនេះ ជាងកាត់សក់ត្រូវទាមទារភាពប៉ិនប្រសប់ និងភាពមឹងម៉ាត់។

## ការអប់រំ និងការបណ្តុះបណ្តាល

ទោះបីជាងកាត់សក់មិនទាមទារសញ្ញាបត្រខ្ពស់ក៏ដោយ ប៉ុន្តែគួរតែបានបញ្ចប់ការសិក្សាកម្រិតមូលដ្ឋាន។ បន្ថែមលើនេះ ការសិក្សាផ្នែកសុខភាព និងជំនួញអាចមានអត្ថប្រយោជន៍សម្រាប់ការងារជាជាងកាត់សក់។ ជាពិសេសការសិក្សាផ្នែកចិត្តវិទ្យា និងទំនាក់ទំនងក៏មានសារៈសំខាន់ខ្លាំងណាស់ដែរ ពីព្រោះភាពជោគជ័យរបស់ពួកគេ គឺពឹងផ្អែកទៅលើសមត្ថភាពក្នុងការបំពេញចិត្តអតិថិជននិងទាក់ទាញការគាំទ្រ។

ជម្មតា ជាងកាត់សក់អាចសិក្សាវគ្គខ្លីតាមសាលាវិជ្ជាជីវៈផ្នែកកាត់សក់ ស្របតាមពេលវេលាកំណត់មួយ។ បន្ទាប់

មកអាចសាកល្បងចេញប្រកបអាជីវកម្មដោយខ្លួនឯង ឬធ្វើការឲ្យហាងកាត់សក់ៗ ការគាំទ្ររបស់អតិថិជនគឺជាការវាយតម្លៃដែលបង្ហាញពីកម្រិតជំនាញ ឬភាពប៉ិនប្រសប់របស់ជាងៗ




## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:
ចិត្តវិទ្យា និងសុខភាព
✦ កម្រិតអប់រំទាបបំផុត:
ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ
✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:
អ្នកថែរក្សាសម្ផស្ស និងសក់
អ្នកបច្ចេកទេសខាងការកែសម្ផស្ស, និង
អ្នកតុបតែងមុខ ជាដើម។

# ជាងឈើ

(Carpenters)

**សង្ខេបអំពីជំនាញ**
**ជាងឈើធ្វើការងារៈ**

✦ ជ្រើសរើសនិងប្រើប្រាស់ឧបករណ៍ឬបច្ចេកទេស
✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ បំពេញការងារជាក្រុម

G

**ជំនាញដែលត្រូវការប្រើៈ**

✦ ការធ្វើសេចក្តីសម្រេចចិត្ត
✦ គណិតវិទ្យា
✦ ការដោះស្រាយបញ្ហា

## តើជាងឈើបំពេញកិច្ចការអ្វីខ្លះ?

ជាងឈើធ្វើការកាត់បន្ទះក្តារ និងឈើឲ្យមានរូបរាងភ្ជាប់បំណែកឈើ, និងក្តារបន្ទះក្នុងដំណើរការសាងសង់ ឬជួសជុលផ្ទះនិងអាគារផ្សេងៗទៀត។ ជាងឈើធ្វើការក្នុងនិងក្រៅអាគារ។ ជាងឈើធ្វើការជាមួយឧបករណ៍ដែលប្រើដោយដៃដូចជាញញួរ, រណា, ម៉ែត្រវាស់ និងទួរណឺវីស។ ពួកគេក៏ធ្វើការជាមួយនឹងឧបករណ៍មួយចំនួនទៀតដូចជា

ម៉ាស៊ីនអារឈើ និងម៉ាស៊ីនស្ទាន។

មានការងារសំខាន់ពីរបែបសម្រាប់ការងារជាជាងឈើ គឺ ការសាងសង់ និងការតម្លើងរចនាសម្ព័នខាងក្នុងអាគារ ឧទាហរណ៍ ធ្វើគ្រោងឈើនៃអាគារ, គ្រោងជញ្ជាំង, ការសង់រន្ទាបណ្តោះអាសន្នសម្រាប់ការសាងសង់។ ក្រុមជាងឈើមួយផ្នែកទៀតគឺធ្វើការពាក់ព័ន្ធនឹងការរៀបកម្រាលឈើ, ជ្រើ, ទូ និងគ្រឿងឈើផ្សេងទៀត។ ធម្មតាក្រុមជាងផ្នែកនេះត្រូវមានជំនាញជាក់លាក់ក្នុងរចនាសម្ព័ន្ធអ្វីមួយ។ គេសង្កេតឃើញថាជាងឈើផ្នែកធ្វើជណ្តើរឬគ្រឿងសំណង់ និងជាងធ្វើគ្រឿងសង្ហារឹមគឺមានជំនាញដោយឡែកពីគ្នា។ ជាងឈើត្រូវមានភាពប៉ិនប្រសប់ផ្នែកហត្ថកម្ម, ធ្វើការប្រកបដោយភាពវាងវៃទាំងដៃទាំងភ្នែក ព្រមទាំងពូកែក្នុងការវាស់និងប៉ាន់ស្មានចំពោះវត្ថុឬខ្នាត។ បន្ថែមលើនេះត្រូវមានកាយសម្បទាល្អមាំមួនសម្រាប់បំពេញការងារ។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីរៀបចំខ្លួននៅក្នុងការងារប្រភេទនេះ គេគួរសិក្សាផ្នែកជាងឈើ និងការងារគ្រឿងឈើផ្សេងទៀត។ អ្នកគួរតែស្រាវស្រទេញចាប់យកឱកាសសិក្សា និងបទពិសោធន៍ពាក់ព័ន្ធការគូរគំនូរផ្នែកមេកានិក និងវិធីក្នុងការមើលប្លង់។ គួររៀនមេរៀនមួយចំនួនមានអត្ថប្រយោជន៍ដូចជាពីជគណិត, ធរណីមាត្រ និងវិទ្យាសាស្ត្រ។ គេសង្កេតឃើញថាជាងឈើភាគច្រើនសិក្សាជំនាញនេះតាមរយៈការអនុវត្តផ្ទាល់ជាមួយមេជាងក្នុងរយៈពេលជាក់លាក់មួយ។

## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:
គណិតវិទ្យា និងបច្ចេកទេស

✦ កម្រិតអប់រំទាបបំផុត:
ការហាត់ធ្វើការងារដោយផ្ទាល់ជាមួយមេជាង

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:
អ្នកក្រាលឥដ្ឋ, កម្មករសាងសង់,
អ្នកលាបថ្នាំ, អ្នកប្រក់ដំបូល ។ល។

## អ្នកលក់ផ្កា

( Florists )

**សង្ខេបអំពីជំនាញ**

**អ្នកលក់ផ្កាធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ បំពេញការងារជាក្រុម
✦ ជួយកិច្ចការដល់អតិថិជន ឬភ្ញៀវ

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
✦ ការសម្រេចចិត្ត
✦ ការដោះស្រាយបញ្ហា

## តើអ្នកលក់ផ្កាបំពេញកិច្ចការអ្វីខ្លះ?

អ្នកលក់ផ្កាធ្វើកិច្ចការផ្នែកតុបតែងផ្កា និងរុក្ខជាតិជាច្រើនប្រភេទ។ អ្នកលក់ផ្កាខ្លះធ្វើការក្នុងចំការ ដើម្បីមើលថែរក្សាផ្កា និងរុក្ខជាតិដែលនឹងត្រូវលក់ទៅឲ្យហាងផ្កា។ ធម្មតា ផ្កានិងរុក្ខជាតិជាច្រើនងាយរុះរោយ ដូច្នេះតម្រូវឲ្យមានការថែទាំយ៉ាងពិសេសទៅតាមប្រភេទផ្កា និងរុក្ខជាតិនីមួយៗតាមរយៈការដាក់ជី, ស្រោចទឹក, និងទទួលបានពន្លឺគ្រប់គ្រាន់។ ម្យ៉ាង


តទៅទំព័របន្ទាប់

ទៀតពួកគេត្រូវកំណត់ថាគួរដាំនិងកាត់ផ្កា ឬរុក្ខជាតិនៅពេលណា។ បន្ទាប់មកពួកគេកាត់និងចងផ្កាឬរុក្ខជាតិជាបាច់ៗ ហើយលក់ទៅឲ្យហាងលក់ផ្កា។ អ្នកលក់ផ្កាមួយប្រភេទទៀត គឺជាអ្នករៀបចំតុបតែងផ្កា។ អ្នករៀបចំតុបតែងផ្កាដែលធ្វើការក្នុងហាងលក់ផ្កាដើម្បីទទួលបានកម្រៃ ឬលក់ផ្កាដោយខ្លួនឯង។ ពួកគេអាចធ្វើបាច់ផ្កា ឬកម្រងផ្កា។ ជាទូទៅ អ្នកលក់ផ្កា រៀបចំតុបតែងផ្កាទៅតាមការបញ្ជាទិញរបស់អតិថិ-ជនដែលតម្រូវទៅតាមតម្លៃ, របៀបនៃការរៀបចំ, ពេលវេលា និងកន្លែងដែលត្រូវផ្ញើទៅឲ្យជាដើម។ បន្ថែមលើនេះការបញ្ជាទិញក៏រួមបញ្ចូលទាំងប្រភេទ និងពណ៌ផ្កា ឬក៏អ្នករៀបចំផ្កាខ្លួនឯងជាអ្នកសម្រេចចិត្តជំនួស។ ដើម្បីជ្រើសរើសផ្កាសម្រាប់ការរៀបចំឲ្យស្របតាមឱកាសនីមួយៗ អ្នកលក់ផ្កាត្រូវគិតថាតើប្រភេទផ្កាឬរុក្ខជាតិណាដែលសាកសមជាងគេ ដោយយោងទៅលើតម្លៃនិងសម្ភារសម្រាប់ការតុបតែង។ ដូចបានដឹងហើយថា ការតុបតែងផ្កាមួយបាច់ឬមួយកន្ត្រកត្រូវរៀបលាយឡំជាមួយស្លឹកឈើ, ផ្លែឈើស្រស់, មែកឈើតូចៗ ព្រមទាំងតុបតែងលាយជាមួយនឹងវត្ថុផ្សេងៗទៀតដូចជា ទៀន និងរូបតុក្កតាជាដើម។ បច្ចុប្បន្ននេះ អ្នករៀបចំផ្កាមានជំនាញឯកទេសក្នុងការរៀបចំផ្កាសម្រាប់អាពាហ៍ពិពាហ៍ និងកម្មវិធីផ្សេងទៀតតាមការចង់បាន។

## ការអប់រំ និងការបណ្តុះបណ្តាល

អ្នកលក់ផ្ការៀនជំនាញនេះតាមរយៈធ្វើការជាជំនួយការ ឬកូនជាងនៅក្នុងហាងផ្កា ឬក៏រៀននៅសាលាវិជ្ជាជីវៈផ្សេងៗ។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលាៈ**

កសិកម្ម, សិល្បៈ និងជំនួញ

✦ **កម្រិតអប់រំទាបបំផុតៈ**

សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នាៈ**

អ្នកបច្ចេកទេសដាំដំណាំ, អ្នកព្យាបាលដំណាំ, អ្នកតុបតែងទេសភាព

# អ្នកប្រឹក្សាយោបល់ផ្នែកសេវាធានារ៉ាប់រង

( Actuaries )

**សង្ខេបអំពីជំនាញ**

**អ្នកប្រឹក្សាយោបល់ផ្នែកសេវាធានារ៉ាប់រងធ្វើការងារ៖**

✦ វាយតម្លៃនិងគ្រប់គ្រងព័ត៌មាន

✦ ការគ្រប់គ្រងពេលវេលា

✦ បំពេញកិច្ចការជាក្រុម

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការដោះស្រាយបញ្ហា

✦ គណិតវិទ្យា

✦ ការគិតប្រកបដោយហេតុផល

## តើអ្នកប្រឹក្សាយោបល់ផ្នែកសេវាធានារ៉ាប់រងធ្វើកិច្ចការអ្វីខ្លះ?

អ្នកប្រឹក្សាយោបល់ផ្នែកសេវាធានារ៉ាប់រង គឺជាអ្នកជំនាញផ្នែកគណិតវិទ្យាដែលរៀបចំនិងធ្វើគម្រោងគោលនយោបាយធានារ៉ាប់រង និងកម្មវិធីចូលនិវត្តន៍សម្រាប់ឧស្សាហកម្មនានា។ ពួកគេធ្វើការគណនាអំពីតម្លៃ ឬការចំណាយដើម្បីផ្តល់ព័ត៌មានដល់ក្រុមហ៊ុនធានារ៉ាប់រងក្នុងការសម្រេចថា តើប្រាក់ចំនួនប៉ុន្មានដែលពួកគេគួរតែចំណាយទៅលើអាជីវកម្ម និងបុគ្គលិកដែលស្ថិតក្នុងកម្មវិធីធានារ៉ាប់រង។ ពួកគេក៏ធ្វើការវាយតម្លៃផងដែរចំពោះតម្លៃនៃកិច្ចសន្យាធានារ៉ាប់រង។

ករណីមានការខូចខាត ឬបាត់បង់ពីសំណាក់អ្នកប្រើសេវាធានារ៉ាប់រង អ្នកប្រឹក្សាយោបល់ផ្នែកសេវាធានារ៉ាប់រងត្រូវបានគេជួលដើម្បីឲ្យវាយតម្លៃទៅលើការចំណាយធានារ៉ាប់រងដែលត្រូវសងដោយក្រុមហ៊ុនធានារ៉ាប់រង ចៀសវាងទទួលបានសំណងតិចពេក ឬច្រើនពេក និងត្រូវប៉ាន់ស្មានសំណងឲ្យស្របតាមគោលនយោបាយរបស់ក្រុមហ៊ុន។ អ្នកប្រឹក្សាយោបល់ផ្នែកសេវាធានារ៉ាប់រងតែងតែប្រើប្រាស់ចំណេះដឹងរបស់ពួកគេផ្នែកគណិតវិទ្យា, ការប៉ាន់ប្រមាណ, ស្ថិតិ, គោលការណ៍ហិរញ្ញវត្ថុនិងពាណិជ្ជកម្មនៅក្នុងការងាររបស់ពួក

## ការអប់រំ និងការបណ្ដុះបណ្ដាល

ដើម្បីក្លាយជាអ្នកប្រឹក្សាយោបល់ផ្នែកសេវាធានារ៉ាប់រង អ្នកត្រូវតែរៀនមុខវិជ្ជាគណិតវិទ្យា ព្រមជំនាញក្នុងការធ្វើការងារដោយប្រុងប្រយ័ត្ននិងល្អិតល្អន់។ បន្ថែមលើនេះ ការសិក្សាវិទ្យាសាស្ត្រកុំព្យូទ័រក៏មានសារសំខាន់ផងដែរ។ បន្ទាប់ពីបញ្ចប់វិទ្យាល័យ អ្នកត្រូវចូលរៀនមហាវិទ្យាល័យដើម្បីទទួលបានបរិញ្ញាបត្រផ្នែកគណិតវិទ្យា, ស្ថិតិ, សេដ្ឋកិច្ចនិងពាណិជ្ជកម្មដោយផ្ដោតជាពិសេសលើមុខវិជ្ជាគណិតវិទ្យា។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
ពាណិជ្ជកម្ម, គណិតវិទ្យា
និងវិទ្យាសាស្ត្រកុំព្យូទ័រ

✦ **កម្រិតអប់រំទាបបំផុត:**
បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្ដីពីអ្នកមានជំនាញស្រដៀងគ្នា:**
អ្នកគ្រប់គ្រងសៀវភៅ, អ្នកវិភាគផ្នែកក្រេឌីត,
អ្នកតំណាងផ្នែកសេវាធានារ៉ាប់រង,
អ្នកគណិតវិទ្យា,
អ្នកគ្រប់គ្រងហានិភ័យ
និង អ្នកស្ថិតិ ។ល។

# តន្ត្រីករ

(Musicians)

**សង្ខេបអំពីជំនាញ**

**តន្ត្រីករធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ បំពេញការងារប្រកដោយភាពជាអ្នកដឹកនាំ

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
✦ ការគ្រប់គ្រងខ្លួនឯង
✦ ការនិយាយ និងការស្ដាប់

## តើតន្ត្រីករបំពេញកិច្ចការអ្វីខ្លះ?

តន្ត្រីករបំពេញការងារនៅក្នុងតួនាទីមួយចំនួនដូចជា ការសម្ដែង, បង្រៀន, និពន្ធ, រៀបចំ និងដឹកនាំវង់ភ្លេង។ ឧបករណ៍តន្ត្រីមួយ ឬច្រើនត្រូវបានគេយកមកលេងជាក្រុមដូចជាក្រុមតន្ត្រីសម័យ, តន្ត្រីមហោរី, តន្ត្រីញាក់កន្ត្រាក់អារម្មណ៍ និងក្រុមដទៃទៀត។

តន្ត្រីករបុរាណច្រើនតែសម្ដែងនៅក្នុងមហោស្រព, ល្ខោន និង របាំ ដែលអមទៅដោយអ្នកចំរៀង។ ចំណែកតន្ត្រីករខាងភ្លេងហ្សាស ឬតន្ត្រីកន្ត្រាក់អារម្មណ៍ច្រើនតែលេងនៅក្នុងរង្គសាល, ក្លឹប, ព្រឹត្តិការណ៍តន្ត្រីឬការប្រគុំតន្ត្រី។ តន្ត្រីករអាចប្រគំបទភ្លេងសម្រាប់ការថតខ្សែអាត់សម្លេង, ទូរទស្សន៍, វីដេអូ, និងភាពយន្ត។ តន្ត្រីករដែលប្រគំតន្ត្រីប្រជាប្រិយភាគច្រើនបង្កើតចង្វាក់ភ្លេងតាមរយៈឧបករណ៍មួយចំនួនដូចជា ព្យ៉ាណូ, បាស់, ស្គរ, និងហ្គីតា។ បន្ថែមលើនេះ ពួកគេបញ្ចូលនូវទំនុក និងចង្វាក់ភ្លេងរួមជាមួយនឹងសូរសម្លេងរបស់ឧបករណ៍អេឡិចត្រូនិចផ្សេងទៀតដូចជា ត្រែ និងខ្លុយជាដើម។

គួរកត់សម្គាល់ថា ឧបករណ៍មួយចំនួនត្រូវបានប្រគំតម្រូវទៅនឹងប្រភេទបទភ្លេងតែមួយគត់ ឧទាហរណ៍បទភ្លេងប្រពៃណីរបស់លោកខាងលិចដែលមានលក្ខណៈពិសេសស្ថិតលើការដេញហ្គីតា,ចាប៉ី, និងវីយ៉ូឡុងជាដើម។ ផ្ទុយទៅវិញ តន្ត្រីករដែលមានភាពប៉ិនប្រសប់អាចប្រគំភ្លេងដោយប្រើប្រាស់នូវឧបករណ៍បានជាច្រើនមុខ។

## ការអប់រំ និងការបណ្តុះបណ្តាល

តន្ត្រីករច្រើនតែចាប់ផ្តើមអាជីព និងការប្រើប្រាស់ឧបករណ៍ភ្លេងតាំងពីនៅវ័យក្មេង ហើយតែងបន្តការសិក្សានិងការអនុវត្តជាប្រចាំ។ តន្ត្រីករខ្លះទទួលការបណ្តុះបណ្តាលពីតន្ត្រីករដែលមានបទពិសោធន៍ដោយសិក្សាពីបច្ចេកទេសនិងទ្រឹស្តី។

### គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
ភាសាបរទេស និងតន្ត្រី
✦ **កម្រិតអប់រំទាបបំផុត:**
មធ្យមសិក្សាទុតិយភូមិ
✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**
អ្នកជួសជុលឧបករណ៍ភ្លេង, អ្នកដឹកនាំក្រុមតន្ត្រី, គ្រូបង្រៀនភ្លេង
អ្នកចំរៀង និងអ្នកនិពន្ធបទចំរៀង ជាដើម។

## អ្នកផលិតកម្មវិធីវិទ្យុ

(Radio Producers)

**សង្ខេបអំពីជំនាញ**

**អ្នកផលិតកម្មវិធីវិទ្យុធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ បំពេញកិច្ចក្នុងភាពជាអ្នកដឹកនាំ

G

**ជំនាញដែលត្រូវការច្រើន៖**

✦ ការធ្វើសេចក្តីសម្រេចចិត្ត
✦ ការដោះស្រាយបញ្ហា
✦ ការនិយាយ និងការស្តាប់

### តើអ្នកផលិតកម្មវិធីវិទ្យុបំពេញកិច្ចការអ្វីខ្លះ?

អ្នកផលិតកម្មវិធីវិទ្យុធ្វើគម្រោង ហាត់សម និងផលិតកម្មវិធីផ្សាយផ្ទាល់ និងកម្មវិធីថតទុកសម្រាប់ចាក់ផ្សាយក្នុងវិទ្យុ។ ដើម្បីរៀបចំកម្មវិធីផ្សាយក្នុងវិទ្យុ ពួកគេត្រូវធ្វើការជាមួយបុគ្គលិកដែលផ្សាយតាមរលកធាតុអាកាស អ្នកធ្វើការក្រៅឆាក ការជ្រើសរើសតន្ត្រី អ្នកសម្រួលសំឡេង និងបច្ចេកទេសដើម្បីដាក់រួមបញ្ចូលគ្នាទៅក្នុងការចាក់ផ្សាយតាមវិទ្យុ។ នៅតាមកន្លែងជាច្រើន ជាពិសេសតាមស្ថានីយវិទ្យុតូចៗ ពិធីករនិយាយតាមវិទ្យុនិងអ្នកផលិតកម្មវិធីគឺជាមនុស្សតែម្នាក់។

អ្នកផលិតកម្មវិធីវិទ្យុ សិក្សាពីទីផ្សារដោយការស្តាប់ស្ថានីយ៍វិទ្យុដទៃទៀត និងធ្វើការកំណត់ពីតម្រូវការ និងការពេញចិត្តរបស់អ្នកស្តាប់ដែលរស់នៅក្នុងដែនផ្សព្វផ្សាយ។ ពួកគេធ្វើការស្ទង់មតិនិងសម្ភាស ដើម្បីស្វែងយល់អំពីចំណូលចិត្តរបស់មិត្តអ្នកស្តាប់និងសាធារណៈជនទាំងអស់។ បន្ថែមលើនេះ ពួកគេត្រូវសម្រេចចិត្តរៀបចំកម្មវិធីការផ្សាយឲ្យសមស្របទៅតាមក្រុមអាយុចាស់ ឬក្មេងដើម្បីអភិវឌ្ឍន៍នូវទម្រង់នៃការផ្សាយដែលអាស្រ័យទៅលើអ្វីដែលអ្នកស្តាប់ទាំងអស់ចង់បាន។

យោងទៅតាមមតិយោបល់ និងការផ្តល់ព័ត៌មានត្រឡប់របស់អ្នកស្តាប់និងការស្រាវជ្រាវរបស់ទីផ្សារ ពិធីករតាមវិទ្យុ


តទៅទំព័របន្ទាប់

និងអ្នកផលិតកម្មវិធី ត្រូវកំណត់នូវប្រភេទបទចម្រៀងដែលត្រូវចាក់ និងស្តុកទុកនូវប្រភេទតន្ត្រីទាំងនោះឲ្យបានច្រើន ដើម្បីធ្វើឲ្យស្ថានីយ៍មានភាពប្លែកពិសេសជាងគេសម្រាប់ការផ្សាយតាមរលកធាតុអាកាសរបស់ខ្លួន។ អ្នកផលិតកម្មវិធីក៏ធ្វើការតាមដានទៅលើហេតុការណ៍ថ្មីៗតាមរយៈសារព័ត៌មាន និងកម្មវិធីតាមវិទ្យុ ដើម្បីកំណត់អំពីប្រធានបទផ្សេងៗដែលគួរលើកយកមកពិភាក្សានៅក្នុងកម្មវិធីផ្សាយរបស់គេ។ អ្នកផលិតកម្មវិធីត្រូវតែរក្សាពេលវេលាក្នុងការផ្សាយឲ្យបានត្រឹមត្រូវនិងទៀងទាត់ ពីព្រោះកម្មវិធីនីមួយៗមានទាក់ទងនឹងការចាក់ផ្សាយផ្សេងៗទៀតដូចជា បទចម្រៀង របាយការណ៍ព័ត៌មាន បទសម្ភាសន៍ និងការផ្សាយពាណិជ្ជកម្ម។

## ការអប់រំ និងការបណ្តុះបណ្តាល

ជំនាញក្នុងការសរសេរអត្ថបទគឺមានសារសំខាន់ខ្លាំណាស់ ប្រសិនបើអ្នកចង់ធ្វើការក្នុងស្ថានីយ៍វិទ្យុ។ ដូច្នេះគួរៀនភាសាអង់គ្លេសនិងវិទ្យាសាស្ត្រសង្គមដែលតម្រូវឲ្យមានការសរសេរអត្ថបទនិងតែងសេចក្តី។ ម្យ៉ាងទៀតការសិក្សាអំពីសារព័ត៌មានមិនត្រឹមតែជួយអភិវឌ្ឍន៍ជំនាញនៃការសរសេរអត្ថបទរបស់អ្នកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្រៀនអ្នកអំពីរបៀបនិងប្រវត្តិនៃប្រព័ន្ធផ្សព្វផ្សាយទៀតផង។

បន្ទាប់ពីបញ្ចប់ការសិក្សានៅវិទ្យាល័យ អ្នកគួរតែសិក្សានៅមហាវិទ្យាល័យផ្នែកសារព័ត៌មាន ឬផ្នែកទំនាក់ទំនងដែលមានផ្តល់នូវកម្មវិធីសិក្សាផ្នែកផ្សព្វផ្សាយតាមរលកធាតុអាកាស។ ចំណែកមុខវិជ្ជាជំនួញក៏ជួយដល់អ្នកដែលមានបំណងរៀបចំអាជីពជាអ្នកផលិតកម្មវិធីផងដែរ។ ដូច្នេះ អ្នកផលិតកម្មវិធីវិទ្យុ ជារឿយៗចាប់ផ្តើមហ្វឹកហ្វាត់ជំនាញរបស់ពួកគេក្នុងសាលាសារព័ត៌មាន និងបន្ទាប់មកហាត់ធ្វើការងារនៅឯស្ថានីយ៍វិទ្យុ។ ចាងហ្វាងព័ត៌មាន និងអ្នកគ្រប់គ្រងកម្មវិធីរបស់ស្ថានីយវិទ្យុជាទូទៅ ចូលចិត្តជ្រើសរើសមនុស្សដែលបានសិក្សានិងមានចំណេះដឹងផ្នែកប្រវត្តិសាស្ត្រ ភូមិសាស្ត្រ វិទ្យាសាស្ត្រនយោបាយ និងអក្សរសាស្ត្រសម្រាប់ប្រើការនៅក្នុងស្ថានីយ៍វិទ្យុ។




### គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
ភាសាអង់គ្លេស សារព័ត៌មាន និងការធ្វើអត្ថាធិប្បាយ

✦ **កម្រិតអប់រំទាបបំផុត:**
បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**
អ្នកចាក់បទភ្លេង
អ្នកផ្សាយកម្មវិធីតាមវិទ្យុ និងទូរទស្សន៍
ប្រធានគ្រប់គ្រងកម្មវិធីវិទ្យុ និងទូរទស្សន៍

# លេខាធិការ

( Secretaries )

**សង្ខេបអំពីជំនាញ**

**លេខាធិការធ្វើការងារ៖**

- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន
- គ្រប់គ្រងពេលវេលា

**ជំនាញដែលត្រូវការច្រើន៖**

- ការអាន និងការសរសេរ
- ការទទួលខុសត្រូវ
- ការនិយាយ និងការស្តាប់

## តើលេខាធិការបំពេញកិច្ចការអ្វីខ្លះ?

លេខាធិការបំពេញតួនាទី និងចាត់ចែងការងារជាច្រើនផ្នែករដ្ឋបាលនិងស្មៀន។ គោលដៅសំខាន់នៃសកម្មភាពការងាររបស់ពួកគេ គឺជួយសម្រួលនិយោជកក្នុងការបំពេញការងារឲ្យសម្រេចតាមផែនការ និងជួយឲ្យក្រុមហ៊ុនមានដំណើរការប្រកបដោយប្រសិទ្ធភាព និងស្របតាមលក្ខណៈវិជ្ជាជីវៈ។ ការងាររបស់លេខាធិការរួមបញ្ចូលនូវការបញ្ជូន និងផ្តល់ព័ត៌មានទៅកាន់បុគ្គលិកក្នុងការិយាល័យ និងទៅអង្គភាពផ្សេងៗទៀត។ ពួកគេប្រើប្រាស់និងបញ្ជាម៉ាស៊ីនឬឧបករណ៍ក្នុងការិយាល័យ និងរៀបចំសម្រាប់ការជួសជុលករណីមានការខូចខាត។ លេខាធិការធ្វើការបញ្ជាទិញសម្ភារការិយាល័យ និងប្រតិបត្តិនូវមុខងារមួយចំនួនទៀតដូចជាទទួលទូរសព្ទ បែងចែកលិខិតចេញចូល គ្រប់គ្រងឯកសារ ធ្វើកំណត់ហេតុឬរបាយការណ៍ និងវាយសំបុត្រឬអត្ថបទ។

ប្រសិនបើ នៅក្នុងការិយាល័យមានអ្នកវាយអត្ថបទជំនួសដូច្នេះ កិច្ចការរបស់លេខាធិការគឺទទួលបន្ទុកតែផ្នែកការងាររដ្ឋបាលប៉ុណ្ណោះ។ ករណីនេះពួកគេមានពេលទំនេរដើម្បីឆ្លើយតបសំបុត្រ រៀបចំរបាយការណ៍ ធ្វើការស្រាវជ្រាវ និងបង្ហាញលទ្ធផលទៅនិយោជករបស់ពួកគេ ឬជួយកិច្ចការអ្នកជំនាញ។ ការិយាល័យខ្លះមានលេខាធិការបី ឬបួននាក់ធ្វើការជាក្រុម ដើម្បីអាចជួយសម្រាលកិច្ចការគ្នាទៅវិញទៅមកករណីលេខាណាមួយមានការងារច្រើនឬរវល់ខ្លាំងពេក។

## ការអប់រំ និងការបណ្តុះបណ្តាល

លេខាត្រូវការកម្រិតសិក្សាថ្នាក់មធ្យមសិក្សាទុតិយភូមិ និងការហ្វឹកហ្វាត់ការងារខ្លះៗ។ សិស្សមួយចំនួនរៀនផ្នែកពាណិជ្ជកម្ម ការវាយអត្ថបទ ការរៀនកត់ត្រាឲ្យបានលឿន និងភាសាអង់គ្លេសបែបពាណិជ្ជកម្ម។ អ្នកអាចទទួលបទពិសោធន៍ការងារតាមរយៈការងារក្រៅម៉ោងដូចជា ស្មៀនផ្នែកឯកសារ អ្នកវាយអត្ថបទ និងអ្នកទទួលភ្ញៀវ។ លេខាធិការត្រូវអានឲ្យស្ទាត់ សរសេរឲ្យត្រឹមត្រូវនិងតាមក្បួនវេយ្យាករណ៍ និងជំនាញគណិតវិទ្យាផងដែរ។

## គួរយល់ដឹង!

- **មុខវិជ្ជាសិក្សាក្នុងសាលា:** ជំនួញ និងភាសាអង់គ្លេស
- **កម្រិតអប់រំទាបបំផុត:** ធម្យមសិក្សាទុតិយភូមិ
- **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:** អ្នកថែទាំសៀវភៅ និងអ្នកទទួលភ្ញៀវ

# អ្នកនិពន្ធ

( Writers )

**សង្ខេបអំពីជំនាញ**

**អ្នកនិពន្ធធ្វើការងារ៖**

- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- ការវាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ជួយកិច្ចការដល់អតិថិជន ឬភ្ញៀវ

G

**ជំនាញដែលត្រូវការប្រើ៖**

- ការគិតប្រកបដោយភាពច្នៃប្រឌិត
- ការអាន និងការសរសេរ
- ការនិយាយ និងការស្តាប់

## តើអ្នកនិពន្ធបំពេញកិច្ចការអ្វីខ្លះ?

អ្នកនិពន្ធបញ្ចេញមតិរបស់ពួកគេតាមរយៈការប្រើប្រាស់ពាក្យពេចន៍នៅក្នុងសៀវភៅ ទស្សនាវដ្តី កាសែត ការផ្សាយពាណិជ្ជកម្ម វិទ្យុ ទូរទស្សន៍ និងអ៊ិនធើណិត។ ការងាររបស់អ្នកនិពន្ធគឺប្រកបដោយគំនិតច្នៃប្រឌិត និងការខិតខំប្រឹងប្រែង។ ធម្មតា អ្នកនិពន្ធមានឯកទេសក្នុងការសរសេរដោយឡែកពីគ្នា ឧទាហរណ៍ ចំពោះអ្នកនិពន្ធដែលរៀបចំអត្ថបទសម្រាប់ភាពយន្តឬទូរទស្សន៍ អ្នកនិពន្ធសម្រាប់ការសម្តែងសិល្បៈក្នុងមហោស្រព អ្នកសរសេរព័ត៌មានរៀបចំអត្ថបទសម្រាប់កាសែត ទស្សនាវដ្តី វិទ្យុ និងទូរទស្សន៍។ អ្នកនិពន្ធការសែតមានឯកទេសក្នុងការសរសេររឿងរ៉ាវដែលចេញពីគំនិតផ្ទាល់ខ្លួន។ ចំណែកអ្នកនិពន្ធបែបរិះគន់គឺពិនិត្យមើល និងផ្តល់គំនិតទៅលើការងាររបស់អ្នកនិពន្ធផ្សេងទៀត។ អ្នកនិពន្ធបែបបច្ចេកទេសបញ្ចេញគំនិតបច្ចេកទេស និងវិទ្យាសាស្ត្រនៅក្នុងភាសាដែលងាយស្រួលយល់។ បន្ថែមលើនេះក៏មានអ្នកនិពន្ធដែលមានគំនិតច្នៃប្រឌិតខ្លះទៀតដូចជា អ្នកនិពន្ធរឿងប្រលោមលោក អ្នកនិពន្ធជីវប្រវត្តិ កវីនិពន្ធ អ្នករៀបរៀង អ្នកនិពន្ធរឿងកំប្លែង និងអ្នកនិពន្ធរឿងខ្លីៗជាដើម។

អ្នកនិពន្ធដែលពូកែត្រូវចេះប្រមូលព័ត៌មានឲ្យបានច្រើនអំពីប្រធានបទមួយ និងបន្ទាប់មកគេត្រួតពិនិត្យ មើលយ៉ាងត្រឹមត្រូវ និងប្រុងប្រយ័ត្ននូវប្រភពព័ត៌មានរបស់ពួកគេ។ ទាំងនេះអាចទាក់ទងនឹងការស្រាវជ្រាវតាមបណ្ណាល័យ ការសម្ភាស និងបទពិសោធន៍ផ្ទាល់ខ្លួន។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីរៀបចំអាជីពជាអ្នកនិពន្ធ អ្នកគួរតែរៀនភាសាអង់គ្លេស ផ្នែកសារព័ត៌មាន ការថ្លែងសុន្ទរកថា វិទ្យាសាស្ត្រទូទៅ ការសិក្សាពីសង្គម វិទ្យាសាស្ត្រសង្គម និងការវាយកុំព្យូទ័រ។ បន្ថែមលើនេះ អ្នកត្រូវមានការអប់រំនៅកម្រិតឧត្តមសិក្សា។ អ្នកគួរតែចេះពីរបៀបប្រើកុំព្យូទ័រ និងអាចដោះស្រាយបញ្ហាការងារនៅក្រោមសម្ពាធនៃពេលវេលា។

## គួរយល់ដឹង!

- **មុខវិជ្ជាសិក្សាក្នុងសាលា:**
  ភាសាបរទេស និងសារព័ត៌មាន
- **កម្រិតអប់រំទាបបំផុត:**
  បរិញ្ញាបត្រ
- **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**
  អ្នកឆ្លើយឆ្លងព័ត៌មាន អ្នករៀបរៀងសៀវភៅ ។ល។


តទៅទំព័របន្ទាប់

# កម្មករផលិតក្រដាស

( Paper Making Workers )

**សង្ខេបអំពីជំនាញ**

**កម្មករផលិតក្រដាសធ្វើការងារ៖**

- វាយតម្លៃនិងគ្រប់គ្រងព័ត៌មាន
- ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន
- ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ឬបច្ចេកវិទ្យា

G

**ជំនាញដែលត្រូវការប្រើ៖**

- ការដោះស្រាយបញ្ហា
- ការគិតប្រកបដោយហេតុផល
- ការនិយាយ និងការស្តាប់

## តើកម្មករផលិតក្រដាសធ្វើកិច្ចការអ្វីខ្លះ?

ការផលិតក្រដាសចេញពីឈើ គឺជាដំណើរការដ៏ស្មុគស្មាញមួយដែលត្រូវការជំនាញរបស់បុគ្គលិក និងកម្មករផ្សេងៗជាច្រើនដូចជា កម្មករផ្នែកបកសម្បកឈើ និងជៀកបំណែកឈើ បន្ទាប់មកកំណាត់ឈើត្រូវបានគេដាក់ចូលទៅក្នុងម៉ាស៊ីន និងដុតចម្អិនអោយទៅជាម្សៅខាប់ទន់ និងសើម។ ចំណែកវិស្វករផ្នែកលាយម្សៅត្រូវគ្រប់គ្រងលើសារធាតុគីមី និងថ្នាំពណ៌ដែលត្រូវលាយបញ្ចូលគ្នា។ បន្ទាប់មកម្សៅត្រូវបានគេចម្អិន និងលាយបញ្ចូលគ្នារហូតទាល់តែភ្ជីរលោង និងចូលពណ៌តែមួយ។ ចំណែកអ្នកដំណើរការម៉ាស៊ីនផលិតក្រដាសត្រូវចាក់ម្សៅចូលទៅលើបន្ទះសំណាញ់លួស ដើម្បីសម្ងួតជាតិទឹកចេញពីម្សៅមុននឹងគាបពីលើ។ ចុងក្រោយគេគឺអ្នកត្រួតពិនិត្យបន្ទះក្រដាសមុននឹងប្រើប្រាស់។ ទោះបីជាការងារផ្នែកនេះភាគច្រើនប្រើប្រាស់ម៉ាស៊ីនស្វ័យប្រវត្តិ ប៉ុន្តែកម្មករនៅក្នុងវិស័យនេះ ទាមទារនូវបុគ្គលិកកម្មករដែលមានភាពរឹងមាំផ្នែករាងកាយ ភាពវាងវៃ រហ័សរហួន ភាពប្រុងប្រយ័ត្ន និងការមើលបានល្អគឺជាចំនុចដែលសំខាន់ក្នុងការធ្វើការជាមួយម៉ាស៊ីននិងត្រួតពិនិត្យមើលគុណភាពក្រដាស។

## ការអប់រំ និងការបណ្តុះបណ្តាល

កម្មករផលិតក្រដាសយ៉ាងហោចណាស់គួរមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ហើយគួរសិក្សាទៅលើមុខវិជ្ជាគីមីវិទ្យា រូបវិទ្យានិងគណិតវិទ្យា។ បច្ចុប្បន្ននេះ ដំណើរការផលិតក្រដាស់កាន់តែមានបច្ចេកវិទ្យាខ្ពស់ ដូច្នេះក្រុមហ៊ុនមួយចំនួនតម្រូវឲ្យកម្មកររបស់ពួកគេមានជំនាញក្នុងការប្រើប្រាស់កុំព្យូទ័រ។ ដើម្បីធ្វើការក្នុងមន្ទីរពិសោធន៍អ្នកត្រូវតែមានបរិញ្ញាបត្រពីមហាវិទ្យាល័យ ឬវិទ្យាស្ថានបច្ចេកទេស។

## គួរយល់ដឹង!

- **មុខវិជ្ជាសិក្សាក្នុងសាលា:**

  គីមីវិទ្យា

  និងបច្ចេកទេស

- **កម្រិតអប់រំទាបបំផុត:**

  មធ្យមសិក្សាទុតិយភូមិ

- **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

  អ្នកបច្ចេកទេសខាងព្រៃឈើ

  កម្មករផ្នែកឈើហ៊ុប និងក្តារបន្ទះ

# អ្នកថតរូប

( Photographers )

**សង្ខេបអំពីជំនាញ**

**អ្នកថតរូបធ្វើការងារ៖**

- ✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
- ✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ✦ បំពេញការងារក្នុងភាពជាអ្នកដឹកនាំ

G

**ជំនាញដែលត្រូវការប្រើ៖**

- ✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
- ✦ ការគ្រប់គ្រងខ្លួនឯង
- ✦ ការនិយាយ និងការស្តាប់

## តើអ្នកថតរូបបំពេញកិច្ចការអ្វីខ្លះ?

អ្នកថតរូបបញ្ចេញនូវសមត្ថភាពរបស់គេតាមរយៈការថតរូបអំពីហេតុការណ៍ ការផ្សាយលក់ផលិតផល និងរូបទេសភាពសម្រាប់ប្រើក្នុងគោលបំណងផ្សេងៗជាច្រើនទៀត។ ពួកគេមានជំនាញក្នុងការប្រើប្រាស់ម៉ាស៊ីនថតរូប និងគ្រឿងបន្ទាស់ផ្សេងៗរបស់ម៉ាស៊ីនរួមទាំងពន្លឺផងដែរ។ ដើម្បីរៀបចំថតរូបឲ្យបានល្អ អ្នកថតរូបធ្វើការជ្រើសរើសហ្វីលដែលត្រឹមត្រូវស្របតាមលក្ខខណ្ឌពន្លឺ និងប្រភេទកញ្ចក់ផ្សេងៗរបស់ម៉ាស៊ីនថត។ ជាងថតរូបក៏ដឹងពីរបៀបធ្វើឲ្យហ្វីល និងការផ្តិតរូបមានគុណភាពកាន់តែប្រសើរឡើង។ ពួកគេលាយសារធាតុគីមីតាមការកំណត់ត្រឹមត្រូវ និងត្រាំហ្វីលក្នុងរយៈពេលជាក់លាក់។ បន្ទាប់ពីហាលហ្វីល ជាងថតរូបដាក់ហ្វីលក្នុងម៉ាស៊ីនពង្រីកដើម្បីផ្តិតឲ្យចេញជារូបនៅលើក្រដាស។ ជាទូទៅ ជាងថតរូបមានជំនាញឯកទេសច្បាស់លាស់ដោយឡែកៗក្នុងការថតរូប ឧទាហរណ៍ អ្នកថតរូបមនុស្ស ថតរូបក្នុងស្ទូឌីយោ ឬនៅក្នុងពិធីមង្គលការ និងពិធីជប់លៀង។ អ្នកថតរូបពាណិជ្ជកម្ម ផ្តិតយករូបភាពផលិតផល ម៉ូតសម្លៀកបំពាក់ ម្ហូបអាហារ និងគ្រឿងម៉ាស៊ីន។ អ្នកថតរូបសារព័ត៌មានផ្តិតយករូបភាពព្រឹត្តិការណ៍ រូបមនុស្ស ទីកន្លែង ឬវត្ថុផ្សេងៗទៀតសម្រាប់សារព័ត៌មាន ទស្សនាវដ្តី និងអ៊ីនធើរណិត។ ចំណែកអ្នកថតរូបវិទ្យាសាស្ត្រថតរូបសម្រាប់ទស្សនាវដ្តី និងសៀវភៅវិទ្យាសាស្ត្រ ជាដើម។ ដើម្បីក្លាយជាអ្នកថតរូប អ្នកគួរតែមានភាពពូកែ និងរហ័សរហួនចំពោះការងារដោយដៃ ខ្សែភ្នែកល្អ ការបែងចែកពណ៌ និងសមត្ថភាពផ្នែកសិល្បៈ។

## ការអប់រំ និងការបណ្តុះបណ្តាល

សិក្សាផ្នែកថតរូប គីមីវិទ្យា និងសិល្បៈជួយអ្នកក្នុងការរៀបចំអាជីពនេះ។ ប្រសិនបើអ្នកមានចំណាប់អារម្មណ៍ផ្នែកថតរូបឌីជីថល អ្នកគួរតែរៀនកុំព្យូទ័រ និងរៀនពីរបៀបប្រើកម្មវិធីកាត់តរូបភាព។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា៖**

សិល្បៈ និងគីមីវិទ្យា

✦ **កម្រិតអប់រំទាបបំផុត៖**

ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា៖**

អ្នកថតភាពយន្ត អ្នកថតរូបបង្ហាញម៉ូត។


តទៅទំព័របន្ទាប់

# វិស្វករបង្កើតកម្មវិធីកុំព្យូទ័រ

( Software Engineers )

**សង្ខេបអំពីជំនាញ**

**វិស្វករបង្កើតកម្មវិធីកុំព្យូទ័រធ្វើការងារ៖**

- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- ជួយកិច្ចការដល់ភ្ញៀវឬអតិថិជន
- ជ្រើសរើសនិងប្រើប្រាស់ឧបករណ៍ឬបច្ចេកវិទ្យា

G

**ជំនាញដែលត្រូវការប្រើ៖**

- ការគិតប្រកបដោយភាពច្នៃប្រឌិត
- ការដោះស្រាយបញ្ហា
- គណិតវិទ្យា

## តើវិស្វករបង្កើតកម្មវិធីកុំព្យូទ័របំពេញកិច្ចការអ្វីខ្លះ?

ជាទូទៅ កុំព្យូទ័រត្រូវបានគេប្រើដើម្បីធ្វើកិច្ចការលំបាកស្មុគស្មាញនៅក្នុងវិស័យជំនួញនិងពាណិជ្ជកម្ម។ នៅក្នុងករណីខ្លះ តម្រូវការប្រើប្រាស់មានលក្ខណៈឯកទេសពេកកម្មវិធីកុំព្យូទ័រទូទៅមិនអាចបំពេញកិច្ចការបានទេ ដូច្នេះ វិស្វករផ្នែកទន់ (កម្មវិធី) កុំព្យូទ័រត្រូវធ្វើការផ្លាស់ប្តូរ កម្មវិធីដែលធ្លាប់ប្រើ ឬបង្កើតកម្មវិធីថ្មីដើម្បីដោះស្រាយបញ្ហាក្នុងវិស័យជាច្រើនដូចជា ពាណិជ្ជកម្ម វេជ្ជសាស្ត្រ ច្បាប់ ការទំនាក់ទំនង ប្រព័ន្ធអាកាសចរណ៍ និងវិទ្យាសាស្ត្រ។

ដំបូង វិស្វករពិភាក្សាជាមួយអតិថិជនដើម្បីស្វែងយល់ពីតម្រូវការរបស់ពួកគេ ដើម្បីកំណត់បញ្ហាដែលពួកគេកំពុងតែជួបប្រទះ។ បន្ទាប់មកវិស្វករពិនិត្យមើលកម្មវិធីដែលបានប្រើប្រាស់ដោយអតិថិជន ដើម្បីចង់ដឹងថាតើអាចផ្លាស់ប្តូរបាន ឬត្រូវការបង្កើតប្រព័ន្ធថ្មីទាំងស្រុង។ នៅពេលគេស្វែងយល់ពីស្ថានភាពរួចហើយវិស្វករកម្មវិធីប្រើប្រាស់វិធីសាស្ត្រវិទ្យាសាស្ត្រនិងក្បួនគណិតវិទ្យាដើម្បីរិះរក ដំណោះស្រាយចំពោះបញ្ហា។ ក្រោយមកពួកគេជ្រើសរើសដំណោះស្រាយដ៏ល្អបំផុតនិងរៀបចំសំណើជា លាយលក្ខណ៍អក្សរទៅកាន់ប្រធានគ្រប់គ្រង និងវិស្វករដទៃទៀត។ បន្ទាប់ពីសំណើត្រូវបានទទួលយក វិស្វករកម្មវិធីនិងអ្នកបច្ចេកទេសត្រួតពិនិត្យមើលជាមួយនឹង វិស្វករផ្នែករឹងដើម្បីកំណត់ថាកុំព្យូទ័រមានសមត្ថភាពគ្រប់គ្រាន់ដើម្បីដំណើរការកម្មវិធីថ្មី ហើយ ចាប់ផ្តើមធ្វើគម្រោងលម្អិតសម្រាប់បង្កើតកម្មវិធីថ្មី។

នៅក្នុងដំណើរការបង្កើតកម្មវិធីវិស្វករ និងអ្នកបច្ចេកទេសធ្វើតេស្តសាកល្បងទៅលើកម្មវិធី ដើម្បីបញ្ជាក់ថាដំណើរការប្រព្រឹត្តិទៅដោយរលូន និងល្អគ្រប់ដំណាក់កាលទាំងអស់។ បន្ថែមលើនេះ វិស្វករត្រូវជួបជាមួយអតិថិជនជាប្រចាំដើម្បីបញ្ជាក់ថាកិច្ចការកំពុងតែឆ្ពោះទៅរកគោលដៅដែលពួកគេចង់បាន និងដើម្បីសិក្សាស្វែងយល់អំពីការផ្លាស់ប្តូរនានាដែលអតិថិជនចង់បាន។

នោះពេលដែលគម្រោងកម្មវិធីថ្មីបានបង្កើតរួចរាល់ហើយ វិស្វកររៀបចំការបង្ហាញចំពោះអតិថិជន។ព្រមជាមួយគ្នានេះ វិស្វករអាចដំឡើងកម្មវិធី បង្ហាត់បង្ហាញដល់អ្នកប្រើប្រាស់និងជួយដោះស្រាយបញ្ហា ទាំងឡាយដែលអាចកើតមានឡើងនាពេលអនាគត។



## ការអប់រំ និងការបណ្តុះបណ្តាល

វគ្គសិក្សាផ្នែកកុំព្យូទ័រ គណិតវិទ្យា និងវិទ្យាសាស្ត្រ នឹងជួយបង្រៀនអ្នកពីជំនាញមូលដ្ឋានគ្រឹះ និងជំនាញក្នុងការវិភាគ។ យ៉ាងហោចណាស់ អ្នកត្រូវមានកម្រិតបរិញ្ញាបត្ររងផ្នែកវិស្វករកុំព្យូទ័រ ឬការបង្កើតកម្មវិធី។ សាលាបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមួយចំនួនក៏មានកម្មវិធីសិក្សាសម្រាប់ការរៀបចំខ្លួនជាអ្នកបច្ចេកទេសកម្មវិធីកុំព្យូទ័រ និង

ការងារក្នុងវិស័យនេះផងដែរ។ សម្រាប់កម្រិតវិស្វករកុំព្យូទ័រ តម្រូវឲ្យមានបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ។ ទោះបីជាអ្នកមានកម្រិតចេះដឹងផ្នែកកុំព្យូទ័រប្រហាក់ប្រហែលនេះ រួមទាំងបទពិសោធន៍ការងារអាចធ្វើកិច្ចការនេះក៏ដោយ ប៉ុន្តែអ្នកបច្ចេកទេសកុំព្យូទ័រភាគច្រើនតែងទទួលការអប់រំជំនាញនេះនៅក្នុងសាលាជាដំបូង។ ប្រសិនវិស្វករកម្មវិធីកុំព្យូទ័រមានបំណងធ្វើការក្នុងវិស័យបច្ចេកទេសមួយច្បាស់លាស់ ដូចជាវេជ្ជសាស្ត្រ ច្បាប់ ឬពាណិជ្ជកម្ម គេគួរតែហ្វឹកហ្វាត់ជំនាញនិងបច្ចេកទេសពាក់ព័ន្ធផ្នែកនោះ។

❷អ្ហូ! រឿងនេះគួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់..! ប៉ុន្តែ យើងគួរគិតបង្កើតកម្មវិធីអ្វីផ្សេងទៀត.. ដើម្បីជំនួសកម្មវិធីដែលសុខឯងចង់យកមកប្រើជំនួស Facebook ដែរឬទេ?!!




❶អ្ហេ! ផល ឯងដឹងហើយថាសព្វថ្ងៃនេះ Facebook ហាក់ចូលមកជំនួសការប្រើប្រាស់ E-mail ស្ទើរគ្រប់ពេលទៅហើយ.. .. ខ្ញុំកំពុងតែគិតថាបើ Facebook ប្រើជំនួស E-mail ដូច្នេះតើយើងគួរមានអ្វីមកជំនួស Facebook បន្តទៀត..!? ជួយគិតគ្នាផងមើល៍!!

## គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
វិទ្យាសាស្ត្រកុំព្យូទ័រ និងគណិតវិទ្យា
✦ **កម្រិតអប់រំទាបបំផុត:**
បរិញ្ញាបត្រ
✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**
អ្នកឯកទេសប្រព័ន្ធកុំព្យូទ័រ
អ្នកបច្ចេកទេសកម្មវិធីកុំព្យូទ័រ អ្នកឯកទេសទិន្នន័យ
អ្នកឯកទេសធ្វើជំនួញតាមអ៊ិនធើរណិត និង
អ្នកពិនិត្យចំពោះការធានាគុណភាព។

# អ្នកសរសេរសុន្ទរកថា

(Speech Writers)

**សង្ខេបអំពីជំនាញ**

**លេខាធិការធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ គ្រប់គ្រង និងវាយតម្លៃព័ត៌មាន
✦ ជួយកិច្ចការដល់ភ្ញៀវ និងអតិថិជន

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
✦ ការអាន និងការសរសេរ
✦ ការនិយាយ និងការស្តាប់

## តើអ្នកសរសេរសុន្ទរកថាបំពេញកិច្ចការអ្វីខ្លះ?

អ្នកសរសេរសុន្ទរកថារៀបចំសុន្ទរកថាសម្រាប់អ្នកនយោបាយនៅក្នុងជួររដ្ឋាភិបាលគិតចាប់ពីថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ រួមទាំងអត្ថបទសម្រាប់នាយករដ្ឋមន្ត្រី និងអ្នកជំនួញជាដើម។ អ្នកនយោបាយ និងនាយកប្រតិបត្តិផ្នែកពាណិជ្ជកម្មតែងមានភាពមមាញឹកក្នុងការងារនិងមិនមានពេលដើម្បីសរសេរសុន្ទរកថាសម្រាប់ថ្ងៃងក្នុងពិធីអ្វីមួយនោះទេ។ អ្នកខ្លះទៀតអាចមិនមានទំនុកចិត្តក្នុងការសរសេរអត្ថបទសុន្ទរកថាដោយផ្ទាល់ដៃ ដូច្នេះទាមទារឲ្យមានអ្នកសរសេរសុន្ទរកថាជំនួស ដើម្បីកត់ត្រានូវអ្វីដែលចង់និយាយនិងវិធីល្អៗក្នុងការផ្តល់នូវគំនិតនិងអនុសាសន៍ក្នុងពេលថ្លែងសុន្ទរកថា។ អ្នកខ្លះមានគំនិតល្អសម្រាប់ធ្វើសុន្ទរកថា ប៉ុន្តែនៅតែត្រូវការជំនួយពីអ្នកសរសេរសុន្ទរកថាម្នាក់ផ្សេងទៀត។ អ្នកសរសេរសុន្ទរកថានឹងធ្វើការស្រាវជ្រាវទៅលើប្រធានបទដែលគេបានពិភាក្សាដោយការប្រើព័ត៌មានក្នុងបណ្ណាល័យ អ៊ិនធើរណិត ឬបទ-

សម្ភាសផ្សេងៗ។ សុន្ទរកថា ត្រូវតែរៀបចំសរសេរឲ្យសមស្រប ទៅឋានៈ តួនាទីនិងស្ដាប់ទៅហាក់សរសេរចេញពីចិត្តរបស់ថ្លៃងសុន្ទរកថាផ្ទាល់។ បន្ថែមលើនេះ សុន្ទរកថាត្រូវសរសេរក្នុងរបៀបដែលងាយស្ដាប់យល់ស្របទៅតាមកម្រិតរបស់អ្នកស្ដាប់ ស្របទៅតាមឱកាស និងស្ថានភាពនៃការថ្លែង។ អ្នកសរសេរអត្ថបទសុន្ទរកថាដែលពូកែ គឺជាមនុស្សដែលតាមដានជាប់ជាមួយនឹងហេតុការណ៍ថ្មីៗ និងព័ត៌មានប្រចាំថ្ងៃ។ បន្ថែមលើនេះ ពួកគេត្រូវធ្វើការក្រោមសម្ពាធនៃពេលកំណត់របស់អត្ថបទ។

## ការអប់រំ និងការបណ្ដុះបណ្ដាល

អ្នកសរសេរសុន្ទកថាគេគួរតែរៀនភាសាអង់គ្លេស និងភាសាបរទេសផ្សេងៗ ការទំនាក់ទំនង មុខវិជ្ជាពលរដ្ឋវិទ្យា ប្រវត្តិវិទ្យា និងរដ្ឋបាលផងដែរ។ ដើម្បីក្លាយជាអ្នកសរសេរសុន្ទរកថាសម្រាប់អ្នកនយោបាយ គេគួរតែមានបរិញ្ញបត្រផ្នែកវិទ្យាសាស្ត្រនយោបាយ។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
ភាសាអង់គ្លេស រដ្ឋបាល និងការថ្លែងសុន្ទរកថា
✦ **កម្រិតអប់រំទាបបំផុត:**
បរិញ្ញាបត្រ
✦ **ព័ត៌មានគួរអានបន្ថែមស្ដីពីអ្នកមានជំនាញស្រដៀងគ្នា:**
អ្នកនិពន្ធសារព័ត៌មាននយោបាយ និងអ្នករាយការណ៍នយោបាយ..

# ភ្នាក់ងារ ឬឈ្មួញផ្នែកអចលនវត្ថុ

( Real Estate Agents and Brokers )

**សង្ខេបអំពីជំនាញ**

**ឆ្នាក់ងារ ឬឈ្មួញផ្នែកងចលនវត្ថុធ្វើការងារៈ**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ ជួយកិច្ចការដល់ភ្ញៀវឬអតិថិជន
✦ បំពេញកិច្ចការក្រុបកដោយភាពជាអ្នកដឹកនាំ

G

**ជំនាញដែលត្រូវការប្រើៈ**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
✦ ការអាន និងការសរសេរ
✦ ការនិយាយ និងការស្ដាប់

## តើឆ្នាក់ងារ ឬឈ្មួលអចលនវត្ថុបំពេញកិច្ចការអ្វីខ្លះ?

ការទិញផ្ទះសម្បែងគឺការសម្រេចចិត្តដ៏សំខាន់ ដូច្នេះមនុស្សតែងស្វែងរកជំនួយពីភ្នាក់ងារ និងឈ្មួញ កណ្ដាលផ្នែកអចលនវត្ថុនៅពេលដែលគេចង់ទិញឬលក់ផ្ទះ។ ភ្នាក់ងារ និងឈ្មួញកណ្ដាលអចលនវត្ថុជួយអតិថិជនក្នុងដំណើរការនៃការទិញនិងលក់អចលនទ្រព្យ ហើយពួកគេដើរតួរជាអន្តរការីក្នុងការចចារតម្លៃរវាងអ្នកលក់និងអ្នកទិញ ដោយសារពួកគេយល់ពីបទដ្ឋានច្បាប់សំខាន់ៗក្នុងការលក់ និងដឹងពីរបៀបទទួលបានប្រាក់កម្ចីតាមរយៈការបញ្ចាំទ្រព្យសម្បត្តិ។ ភ្នាក់ងារ និងឈ្មួញកណ្ដាលផ្ដល់នូវជំនាញដែលមនុស្សជា

ច្រើនត្រូវការនៅពេលដែលពួកគេទិញ ឬលក់ទ្រព្យសម្បត្តិ។

ភ្នាក់ងារដើរមើលអចលនវត្ថុដើម្បីទទួលបាលគំនិតល្អៗពីតម្លៃ និងដើម្បីកំណត់ពីល័ក្ខខ័ណ្ឌមួយចំនួនដែលអាចទាក់ទាញអ្នកទិញ។ ភ្នាក់ងារឬឈ្មួញកណ្តាលប្រឹក្សាយោបល់ជា- មួយម្ចាស់ផ្ទះអំពីតម្លៃរបស់អចលនវត្ថុដែលចង់លក់។ បន្ទាប់មកម្ចាស់នឹងចុះកិច្ចសន្យាយល់ព្រមបង់ថ្លៃជាភាគរយនៃតម្លៃលក់ទៅភ្នាក់ងារប្រសិនបើគេលក់ដាច់វត្ថុនោះក្នុងរយៈពេលកំណត់ណាមួយ។ នៅពេលដែលអតិថិ-ជនចាប់អារម្មណ៍ក្នុងការទិញផ្ទះ ភ្នាក់ងារនឹងសាកសួរអតិថិ-ជនដើម្បីដឹងពី ប្រភេទផ្ទះដែលអតិថិជននោះកំពុងស្វែងរក។ បន្ទាប់មកភ្នាក់ងាររកមើលបញ្ជីផ្ទះណាដែលនៅទំនេរ ហើយជូនអតិថិ-ជនទៅមើលផ្ទះដែលពួកគេចង់បានឲ្យសាកសមទៅនឹងប្រាក់ចំណូល។

## ការអប់រំ និងការបណ្តុះបណ្តាល

ទោះបីជា មិនមានការទាមទារការសិក្សាណាមួយជាក់លាក់សម្រាប់ភ្នាក់ងារអចលនវត្ថុក៏ដោយ ប៉ុន្តែយ៉ាងហោចណាស់ភ្នាក់ងារគួរតែមានណាស់ការសិក្សាត្រឹមថ្នាក់វិទ្យាល័-យ ឬសិក្សាកម្រិតឧត្តមសិក្សាផ្នែកអចលនវត្ថុកាន់តែប្រសើរ។ បន្ថែមលើនេះ គេគួរមានការបញ្ជាក់ពីកម្រិតយល់ដឹងផ្នែកច្បាប់ពាក់ព័ន្ធនឹងការលក់ទិញអចលនទ្រព្យ។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
ពាណិជ្ជកម្ម ភាសាអង់គ្លេស និងគណិតវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**
មធ្យមសិក្សាទុតិយភូមិ ឬបរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**
អ្នកប៉ាន់តម្លៃ និងអ្នកវាយតម្លៃ អ្នកធ្វើគម្រោងហិរញ្ញវត្ថុ អ្នកអភិវឌ្ឍន៍ទ្រព្យសម្បត្តិ និងអចលនទ្រព្យ

# អ្នកច្នៃម៉ូតសម្លៀកបំពាក់

(Fashion Designers)

**សង្ខេបអំពីជំនាញ**

**អ្នកច្នៃម៉ូតសម្លៀកបំពាក់ធ្វើការងារ៖**

✦ វាយតម្លៃនិងគ្រប់គ្រងព័ត៌មាន
✦ បំពេញការងារជាក្រុម
✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
✦ ការធ្វើសេចក្តីសម្រេចចិត្ត
✦ ការមានជំនឿចិត្តចំពោះខ្លួនឯង

## តើអ្នកច្នៃម៉ូតសម្លៀកបំពាក់ធ្វើកិច្ចការអ្វីខ្លះ?

អ្នកច្នៃម៉ូតសម្លៀកបំពាក់ច្នៃអាវធំ សំពត់រ៉ូប អាវយឺត និងសម្លៀកបំពាក់ដទៃទៀត។ ពួកគេអាចច្នៃម៉ូតទាំងខាងក្នុង និងខាងក្រៅរបស់សម្លៀកបំពាក់ មួក កាបូប ស្បែកជើង ស្រោមដៃ សម្លៀកបំពាក់សម្រាប់ហែលទឹក ពួកគេក៏អាចមានជំនាញក្នុងការច្នៃម៉ូតសម្លៀកបំពាក់អាពាហ៍ពិពាហ៍ និងសម្លៀកបំពាក់កីឡាផងដែរ។ អ្នកច្នៃម៉ូត ជាច្រើនដែលធ្វើការក្នុងឧស្សាហកម្មនិងរោងចក្រក្នុងការបង្កើតការច្នៃម៉ូតសម្រាប់ការផលិតដែលលក់ចេញ សម្រាប់មនុស្សរាប់លាននាក់។ ក្នុងការអភិវឌ្ឍន៍ការច្នៃម៉ូតថ្មីមួយ ឬការផ្លាស់ប្តូរម៉ូតដែលមានស្រាប់ ដំបូងអ្នកច្នៃម៉ូតកំណត់ពីតម្រូវការរបស់អតិថិជននិងបង្កើតគំរូម៉ូត។ គេយកចម្រៀកកំណាត់ទៅដេរភ្ជាប់គ្នា និងធ្វើអោយសាកសមនឹងអ្នកបង្ហាញម៉ូត។ គំរូម៉ូតនេះត្រូវបានបង្ហាញទៅអ្នកទិញ និងទទួលការបញ្ជាទិញសម្រាប់ប្រភេទនីមួយៗ។ កិច្ចការរបស់អ្នកច្នៃម៉ូតគឺជាប់ពាក់ព័ន្ធគ្រប់ផ្នែកនៃ



តទៅទំព័របន្ទាប់

ខ្សែចង្វាក់ផលិតកម្មដោយគិតចាប់ពីគំនិតដំបូង រហូតដល់សម្លៀកបំពាក់បានកាត់រួចរាល់។ អ្នកច្នៃម៉ូតសម្លៀកបំពាក់ត្រូវបង្កើតម៉ូតសម្លៀកបំពាក់ជាច្រើនប្រភេទសម្រាប់តម្រូវចិត្តអតិថិជនតាមឆ្នាំនិងស៊េរីដោយត្រូវជ្រើសរើសកំណាត់ និងពណ៌ដែលមានការពេញនិយម។

## ការអប់រំ និងការបណ្តុះបណ្តាល

ប្រសិនបើអ្នកចាប់អារម្មណ៍ក្នុងការច្នៃម៉ូតសម្លៀកបំពាក់អ្នកអាចសិក្សាជំនាញសិល្បៈ ការដេរប៉ាក់ និងការច្នៃម៉ូតតាមកុំព្យូទ័រ។ វិធីសាស្ត្រដ៏ល្អបំផុតដើម្បីក្លាយជាអ្នកច្នៃម៉ូតសម្លៀកបំពាក់ គឺគួរសិក្សាផ្នែកច្នៃម៉ូតពីសាលាច្នៃម៉ូត ឬសាលាបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

## គួរយល់ដឹង!

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

សិល្បៈ និងវិទ្យាសាស្ត្រគ្រួសារ និងតម្រូវការអ្នកប្រើប្រាស់

✦ កម្រិតអប់រំទាបបំផុត:

បរិញ្ញាបត្ររង ឬវិញ្ញាបនបត្រពីសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

អ្នកសម្របសម្រួលការច្នៃម៉ូត

វិចិត្រករច្នៃម៉ូត និងអ្នកថតរូប

ភ្នាក់ងារអ្នកដើរបង្ហាញម៉ូត អ្នកកែសម្រួលការច្នៃម៉ូត និងជាងកាត់ដេរ

# បុគ្គលិកផ្នែកសេវាអតិថិជនក្នុងសណ្ឋាគារ

( Concierges )

**សង្ខេបអំពីជំនាញ**

**អ្នកថតរូបធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ បំពេញការងារក្នុងភាពជាអ្នកដឹកនាំ

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត

✦ ការគ្រប់គ្រងខ្លួនឯង

✦ ការនិយាយ និងការស្តាប់

## តើបុគ្គលិកផ្នែកសេវាអតិថិជនបំពេញកិច្ចការអ្វីខ្លះ?

បុគ្គលិកផ្តល់សេវាអតិថិជនក្នុងសណ្ឋាគារ គឺជាបុគ្គលិកដ៏សកម្មក្នុងការធ្វើបដិសណ្ឋារកិច្ចចំពោះភ្ញៀវដែលស្នាក់នៅក្នុងសណ្ឋាគារ។ ភារកិច្ចមូលដ្ឋានរបស់ពួកគេគឺផ្តល់ដល់ភ្ញៀវនូវទិសដៅឬផែនទីទៅកាន់ទីកន្លែងផ្សេងៗក្នុងទីក្រុង ផ្តល់យោបល់សម្រាប់ដំណើរកំសាន្ត បង្ហាញភោជនីយដ្ឋាន ឬជួយសម្រួលដល់ការជួលយានជំនិះ និងកក់សំបុត្រយន្តហោះជាដើម។ បុគ្គលិកផ្តល់សេវាអតិថិជនក្នុងសណ្ឋាគារត្រូវយកចិត្តទុកដាក់ចំពោះការងារមួយចំនួនដូចជា រក្សាទុកកាសែត រៀបចំសេវាកម្មបោកអ៊ុត ឬកក់សំបុត្រមហោស្រព។ បុគ្គលិកផ្តល់សេវាអតិថិជនក្នុងសណ្ឋាគារធំៗផ្តល់សេវាកម្ម

ពិសេសដល់ភ្ញៀវដូចជាការស្វាគមន៍ដោយមានកន្ត្រកផ្កាឬផ្លែឈើ និងការធ្វើបដិសណ្ឋារកិច្ច។ ពេលខ្លះ បុគ្គលិកផ្តល់សេវាអតិថិជនត្រូវគ្រោងរៀបចំនូវអាហារពេលល្ងាចសម្រាប់ពិធីបដិសណ្ឋាកិច្ច និងពិធីជប់លៀងផ្សេងៗ។ កិច្ចការដ៏ស្មុគស្មាញផ្សេងៗទៀតអាចរួមបញ្ចូលទាំងការធ្វើគម្រោងដំណើរកំសាន្តសម្រាប់វិស្សមកាល ការជួលយានជំនិះ ការទទួលការកក់កៅអីសម្រាប់ព្រឹត្តិការណ៍កីឡា ឬការរៀបចំផ្កានៅក្នុងបន្ទប់ជាដើម។ បុគ្គលិកផ្តល់សេវាអតិថិជនក្នុងសណ្ឋាគារត្រូវបានបង្ហាត់ឲ្យចេះប្រើប្រាស់ធនធានរបស់ពួកគេប្រកបដោយប្រសិទ្ធភាពក្នុងការទំនាក់ទំនង និងផ្តល់សេវាដល់អតិថិជននៅគ្រប់ពេលដែលត្រូវការ។

## ការអប់រំ និងការបណ្តុះបណ្តាល

សិក្សាពីរបៀបនៃការនិយាយប្រាស្រ័យទាក់ទង និងភាសាបរទេសដើម្បីបង្កើនជំនាញទំនាក់ទំនង។ មុខតំណែងនេះភាគច្រើនទទួលការបណ្តុះបណ្តាលនៅក្នុងកន្លែងការងារផ្ទាល់។ បុគ្គលិកថ្មីមិនត្រូវបានអនុញ្ញាតឲ្យប្រចាំការនៅលើទីតាំងដោយគ្មានការហ្វឹកហ្វាត់និងបទពិសោធន៍នោះទេ។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ពាណិជ្ជកម្ម គណិតវិទ្យា និងការនិយាយជាសាធារណៈ

✦ **កម្រិតអប់រំទាបបំផុត:**

មធ្យមសិក្សាទុតិយភូមិ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

ស្មៀនសណ្ឋាគារ ភ្នាក់ងារកក់សំបុត្រ និងបុគ្គលិកកន្លែងកំសាន្ត...

# អ្នកទទួលភ្ញៀវ

( Receptionists )

**សង្ខេបអំពីជំនាញ**

**អ្នកទទួលភ្ញៀវធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ គ្រប់គ្រងពេលវេលា

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការអាន និងការសរសេរ

✦ ការទទួលខុសត្រូវ

✦ ការនិយាយ និងការស្តាប់

## តើអ្នកទទួលភ្ញៀវបំពេញកិច្ចការអ្វីខ្លះ?

ជាធម្មតា អ្នកទទួលភ្ញៀវគឺជាមនុស្សដំបូងគេដែលធ្វើការស្វាគមន៍ភ្ញៀវឬអតិថិជន នៅពេលដែលពួកគេមកទស្សនាក្រុមហ៊ុនមួយ។ ហេតុនេះអ្នកទទួលភ្ញៀវមានភារកិច្ចទទួលខុសត្រូវ ដើម្បីធ្វើឲ្យការអញ្ជើញមកដល់របស់ភ្ញៀវមានភាពកក់ក្តៅ និងមានអារម្មណ៍ល្អចំពោះក្រុមហ៊ុនឬស្ថាប័ននោះ។ ការទទួលខុសត្រូវរបស់អ្នកទទួលភ្ញៀវគឺខុសគ្នាអាស្រ័យទៅតាមកន្លែងដែលពួកគេធ្វើការ។ ភាគច្រើនពួកគេធ្វើការស្វាគមន៍ភ្ញៀវ អតិថិជន ហើយឆ្លើយតបនឹងសំណួរ ព្រមទាំងនាំភ្ញៀវទៅកាន់កន្លែងណាត់ជួប ឬមនុស្សដែលពួកគេចង់ជួបនៅក្នុងការិយាល័យ។ អ្នកទទួលភ្ញៀវក៏ត្រូវទទួលទូរសព្ទ ទទួលលិខិត ពីនិយោជិតដទៃទៀត ទទួល និងបញ្ជូនសំបុត្រទៅតាមគោលដៅ។ នៅក្នុងក្រុមហ៊ុនឬអាជីវកម្មដែលនិយោជិតត្រូវមានដំណើរចេញទៅខាងក្រៅការិយាល័យជាញឹកញាប់ដើម្បីធ្វើកិច្ចការមួយចំនួន អ្នកទទួលភ្ញៀវអាច


តទៅទំព័របន្ទាប់



មើលខុសត្រូវកន្លែងជំនួស ករណីមានទូរសព្ទ និងសំបុត្រសំខាន់ៗផ្ញើចូល។ ដោយសារត្រូវទទួលឆ្លើយសំណួរផ្សេងៗអំពីក្រុមហ៊ុន អ្នកទទួលភ្ញៀវត្រូវដឹងឲ្យបានច្រើនពីផលិតផលសេវាកម្ម គោលនយោបាយ និងការអនុវត្តផ្សេងៗទៀតរបស់ក្រុមហ៊ុន ហើយពួកគេត្រូវតែស្គាល់ឈ្មោះ និងការទទួលខុសត្រូវរបស់និយោជិតទាំងអស់។ ការដឹងនូវព័ត៌មានទាំងនេះ គឺជាផ្នែកមួយដ៏សំខាន់សម្រាប់ការងារជាអ្នកទទួលភ្ញៀវ ដែលក្រុមហ៊ុនមួយចំនួនហៅអ្នកទទួលភ្ញៀវ ថាលេខាធិការផ្នែកព័ត៌មាន។

នៅក្នុងក្រុមហ៊ុនមួយចំនួន អ្នកទទួលភ្ញៀវតាមដានវត្តមានរបស់និយោជិតដទៃទៀត រក្សាសន្តិសុខការិយាល័យដោយសុំឲ្យភ្ញៀវចុះឈ្មោះពេលចូល និងចេញពីការិយាល័យ។ បន្ថែមលើនេះ ពួកគេធ្វើការងារផ្នែកស្មៀនផងដែរដូចជាវាយអត្ថបទ រៀបចំឯកសារ បញ្ជូន និងចាត់ចែងឯកសារតាមម៉ាស៊ីនទូរសារ និងកាន់បញ្ជី។ អ្នកទទួលភ្ញៀវក្នុងការិយាល័យពេទ្យធ្មេញនិងគ្រូពេទ្យ ទទួលចុះឈ្មោះអ្នកជម្ងឺ ជូនទៅបន្ទប់ពិនិត្យ កំណត់ពេលណាត់ជួប រៀបចំរបាយការណ៍ និងប្រមូលវិក្កយបត្រ។ អ្នកទទួលភ្ញៀវនៅក្នុងហាងកែសម្ផស្ស រៀបចំការណាត់ជួបសម្រាប់អតិថិជន។ អ្នកធ្វើការក្នុងក្រុមហ៊ុនឡានក្រុងត្រូវចេះឆ្លើយសំណួរអំពីការចេញដំណើរ និងការមកដល់របស់ឡានក្រុង។ ចំណែកអ្នកកាន់បញ្ជីនិងជំនួយការព័ត៌មានទេសចរណ៍ អាចត្រូវបានគេជួលឲ្យធ្វើជាអ្នកទទួលភ្ញៀវនៅក្នុងស្ថាប័នរដ្ឋឬឯកជន។ ភារៈកិច្ចរបស់ពួកគេអាចរួមបញ្ចូលទាំងការកត់ត្រាចំនួនភ្ញៀវចូល និងចេញពីស្ថាប័ន ហើយពួកគេក៏ត្រូវផ្តល់ពត៌មានពីសេវាកម្មដែលស្ថាប័ននោះផ្តល់ឲ្យ។ ទោះបីជាធ្វើការនៅកន្លែងណាក៏ដោយ អ្នកទទួលភ្ញៀវត្រូវតែរីករាយនឹងជួបមនុស្សថ្មីៗ មានបុគ្គលិកលក្ខណៈរួសរាយរាក់ទាក់ និងមានបំណងចង់ជួយកិច្ចការធូន់ស្រាលដល់មនុស្សទូទៅ។

## ការអប់រំ និងការបណ្តុះបណ្តាល

ជាការពិត និយោជកចង់បានឲ្យអ្នកទទួលភ្ញៀវរបស់ពួកគេមានកម្រិតសិក្សាត្រឹមវិទ្យាល័យ ឬថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាល ឬគ្រប់គ្រង។ ដោយសារតែមុខតំណែងជាអ្នកទទួលភ្ញៀវភាគច្រើន ស្ថិតក្នុងកម្រិតបឋមក្នុងឋានានុក្រមការងារ ដូច្នេះក្រុមហ៊ុនមិនទាមទារបទពិសោធន៍ច្រើននោះទេ។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលាៈ**
ជំនួញ និងភាសាបរទេស
✦ **កម្រិតអប់រំទាបបំផុតៈ**
មធ្យមសិក្សាទុតិយភូមិ
✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នាៈ**
ស្មៀន
អ្នកតំណាងសេវាកម្មអតិថិជន
លេខាធិការ
បុគ្គលិកបណ្ណោត...


តទៅទំព័របន្ទាប់

# អធិការផ្នែកសំណង់

( Construction Inspectors )

**សង្ខេបអំពីជំនាញ**

**អធិការផ្នែកសំណង់ធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ បំពេញការងារប្រកបដោយភាពជាអ្នកដឹកនាំ

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការធ្វើសេចក្ដីសម្រេចចិត្ត

✦ ភាពស្មោះត្រង់

✦ ការអាន និងការសរសេរ

## តើអធិការផ្នែកសំណង់បំពេញកិច្ចការអ្វីខ្លះ?

អធិការផ្នែកសំណង់ ត្រូវត្រួតពិនិត្យការសាងសង់សំណង់ថ្មីទាំងអស់រួមបញ្ចូលទាំង មន្ទីរពេទ្យ សាលារៀន ផ្ទះ អគាររដ្ឋបាល ស្ពាន ផ្លូវ ទំនប់ទឹក ប្រពន្ធទឹក និងការសារសង់ផ្សេងៗទៀត ដើម្បីឲ្យស្របទៅតាមទិដ្ឋភាពច្បាប់ សុវត្ថិភាព និងតម្លៃ។ ពួកគេទៅពិនិត្យតំបន់សាងសង់ ធ្វើតេស្តរកភាពខ្វះចន្លោះ និងថតរូប។ អធិការសំណង់ប្រើខ្សែម៉ែតស្ទង់មើលឧបករណ៍ អង្កេតឧបករណ៍ប្រើប្រាស់ និងសម្ភារសម្រាប់វាស់កម្រិតរឹងរបស់បេតុង។ បន្ទាប់មកកត់ត្រាការងារ និងសរសេររបាយការណ៍។ របាយការណ៍ទាំងនេះពិពណ៌នាអំពីដំណើរការការសាងសង់ ពិនិត្យគុណភាពនៃរចនាសម្ព័ន្ធសំណង់ និងតាមដានទៅលើបទដ្ឋានចាំបាច់ទាំងអស់ ដែលមានចែងក្នុងកិច្ចសន្យា។ គេសង្កេតឃើញមានអធិការសំណង់ចំនួន៧ប្រភេទផ្សេងគ្នាដូចជា អធិការផ្នែកអគារ អគ្គីសនី ជណ្ដើរយន្ត គេហដ្ឋាន មេកានិក បណ្ដាញទឹក និងសាធារណការ។

អធិការផ្នែកអគារពិនិត្យមើលការសាងសង់ដើម្បីធានានូវភាពរឹងមាំ និងឋិតថេរដោយគោរពនិងអនុវត្តតាមក្បួនខ្នាតទាំងអស់របស់សំណង់។ ពួកគេពិនិត្យគម្រោងប្លង់របស់អគារ ទៅពិនិត្យផ្ទាល់ដល់ការដ្ឋានសំណង់ ហើយធ្វើអធិការកិច្ចជាចុងក្រោយ នៅពេលដែលអគារសាងសង់រួចរាល់។ អ្នកត្រួពិនិត្យបណ្ដាញអគ្គិសនី ឆែកមើលរចនាសម្ព័ន្ធនៃប្រព័ន្ធអគ្គិសនីដូចជា ខ្សែភ្លើង អំពូលភ្លើង ប្រព័ន្ធសំឡេងនិងសុវត្ថិភាព និងម៉ាស៊ីនភ្លើង។

អ្នកត្រួតពិនិត្យជណ្ដើរយន្ត ពិនិត្យមើលទាំងជណ្ដើរយន្តគ្រប់ប្រភេទក្នុងអគារ។ អ្នកត្រួតពិនិត្យគេហដ្ឋានធ្វើការជាមួយមនុស្សដែលមានចំណាប់អារម្មណ៍ក្នុងការទិញផ្ទះ។ ពួកគេត្រួតពិនិត្យទូទៅចំពោះ ដំបូល ប្រព័ន្ធទឹក និងប្រព័ន្ធអគ្គិសនីដើម្បីបញ្ជាក់ថាមានដំណើរការដោយត្រឹមត្រូវ។ អ្នកត្រួតពិនិត្យមេកានិក ត្រួតពិនិត្យមើលផ្នែកពាក់ព័ន្ធគ្រឿងម៉ាស៊ីន បំពង់ហ្គាស ធុងហ្គាស និងសម្ភារក្នុងផ្ទះបាយ។ អ្នកត្រួតពិនិត្យបណ្ដាញទឹក ឆែកមើលប្រព័ន្ធបំពង់ទឹក របៀបផ្គត់ផ្គង់ទឹក និងការបង្ហូរចោលកាកសំណល់។ អ្នកត្រួតពិនិត្យសាធារណការ ត្រួតពិនិត្យមើលគុណភាពនិងសុវត្ថិភាពរបស់អគារទាំងអស់ដែលសាងសង់ដោយរដ្ឋាភិបាល រួមបញ្ចូលទាំងប្រព័ន្ធទឹក លូ ផ្លូវថ្នល់ ស្ពាន ទំនប់ទឹក។

## ការអប់រំ និងការបណ្ដុះបណ្ដាល

ដើម្បីក្លាយជាអធិការផ្នែកសំណង់ អ្នកត្រូវបញ្ចប់ថ្នាក់បរិញ្ញាបត្រពាក់ព័ន្ធចំណេះដឹងក្នុងការងារ និងការប្រើប្រាស់សម្ភារក្នុងការសាងសង់។ យកល្អគួរសិក្សាគណិតវិទ្យា និងបច្ចេកទេស ភាសាអង់គ្លេស និងគំនូរព្រាង។ អ្នកដែលបានបញ្ចប់បរិញ្ញាបត្រផ្នែកវិស្វកម្ម ឬស្ថាបត្យកម្មទំនងជាមានឱកាសល្អប្រសើរក្នុងការស្វែងរកការងារ។ម្យ៉ាងទៀតគេអាច

*រៀននៅតាមសាលាបណ្តុះបណ្តាលបច្ចេកទេសផ្នែកសំណង់ក៏បាន។ អ្នកត្រួតពិនិត្យភាគច្រើនទទួលបានការហ្វឹកហ្វឺនការងារ និងមានបទពិសោធន៍ក្នុងវិស័យឯកជន ២ ទៅ៣ឆ្នាំ។ បទពិសោធន៍ទាំងនេះ អាចជាអ្នកទទួលម៉ៅការសំណង់ ឬជាជាងឈើ ជាងអគ្គីសនី ឬជាងតបណ្តាញទឹក។*

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
ជំនួញ គណិតវិទ្យា និងបច្ចេកទេស
✦ **កម្រិតអប់រំទាបបំផុត:**
បរិញ្ញាបត្រ
✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**
ជាងឈើ កម្មករសំណង់ ជាងអគ្គីសនី
វិស្វករ និងអ្នកបច្ចេកទេសឧស្សាហកម្ម
វិស្វករ និងអ្នកបច្ចេកទេសគ្រឿងយន្ត
វិស្វករគ្រឿងយន្ត




# អ្នកតំណាងផ្នែកទាមទារសំណងធានារ៉ាប់រង

( Insurance Claims Representatives )

**សង្ខេបអំពីជំនាញ**

**អ្នកតំណាងផ្នែកទាមទារសំណងធានារ៉ាប់រងធ្វើការងារ៖**

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ បំពេញកិច្ចការក្របកដោយភាពជាអ្នកដឹកនាំ
✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
✦ ការអាន និងការសរសេរ
✦ ការនិយាយ និងការស្តាប់

## តើអ្នកតំណាងផ្នែកធានារ៉ាប់រងបំពេញកិច្ចការអ្វីខ្លះ?

*មនុស្សម្នានាំគ្នាទិញសេវាធានារ៉ាប់រង ដើម្បីការពារពីការខាតបង់ទ្រព្យសម្បត្តិមានជាអាទិ៍ ផ្ទះសម្បែង រថយន្ត ទ្រព្យសម្បត្តិផ្ទាល់ខ្លួន សុខភាព និងអាយុជីវិតរបស់ពួកគេ។ ដូច្នេះនៅពេលដែលពួកគេទទួលរងការបាត់បង់ដូចជា ឡានត្រូវបានចោរលួច ឬបញ្ហាសុខភាពធ្ងន់ធ្ងរ ពួកគេទាក់ទងអ្នកតំណាងផ្នែកសេវាធានារ៉ាប់រង ដើម្បីដោះស្រាយបញ្ហានិងទាមទារត្រឡប់មកវិញនូវសំណងខូចខាតទាំងនោះ។ អ្នកតំណាងនេះ គេហៅថាអ្នកសម្របសម្រួលសំណងត្រូវធ្វើការស៊ើបអង្កេតទៅលើការបាត់បង់ ឬខូចខាតដែលស្ថិតក្នុងដែននៃការទទួលខុសត្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រង បន្ទាប់មកធ្វើការទូទាត់ដល់បុគ្គលដែលរងការបាត់បង់ ឬខូចខាតនោះ។*

*ស្មៀនផ្នែកទូទាត់សំណងធ្វើការនៅក្នុងការិយាល័យក្រុម-*

ហ៊ុនធានារ៉ាប់រងដោយត្រួតពិនិត្យទម្រង់បែបបទធានារ៉ាប់រងឲ្យបំពេញបានគ្រប់ចំណុចនិងដោយត្រឹមត្រូវ។ នៅពេលមានករណីទាមទារសំណង ពួកគេត្រួតពិនិត្យមើលគោលនយោបាយរបស់ក្រុមហ៊ុនដើម្បីវាយតម្លៃលើទំហំ និងប្រភេទណាដែលក្រុមហ៊ុនធានារ៉ាប់រងត្រូវផ្តល់ឲ្យអតិថិជន។ ឧទាហរណ៍ ប្រសិនបើការទាមទារសំណងមានសភាពសាមញ្ញ ដូចជាការពិនិត្យធ្មេញ ដែលមានកំណត់ក្នុងគោលនយោបាយធានារ៉ាប់រង ដូច្នេះស្មៀនត្រូវរៀបចំសំណងដោយផ្ទាល់ទៅកាន់ទន្តពេទ្យ។ អ្នកសម្របសម្រួលការទាមទារសំណងអាចដើរតួនាទីដូចជាស្មៀនទាមទារសំណង។ លើសពីនេះទៀត អ្នកសម្របសម្រួលធ្វើការស៊ើបអង្កេតការទាមទារសំណង ដើម្បីកំណត់អំពីកម្រិតខូចខាត។ អ្នកសម្របសម្រួលការទាមទារសំណងមានឯកទេសក្នុងការធានារ៉ាប់រងតាមប្រភេទ ដូចជាការធានារ៉ាប់រងអគ្គីភ័យ នាវា ឬរថយន្ត។

នៅក្នុងក្រុមហ៊ុនធានារ៉ាប់រងផ្នែកអាយុជីវិត និងសុខភាព អ្នកតំណាងផ្នែកសំណងត្រូវធ្វើការត្រួតពិនិត្យមើលការសងសំណងឲ្យសមស្របទៅនឹងនិតិវិធី និងគោលនយោបាយរបស់ក្រុមហ៊ុន ព្រមទាំងធ្វើសេចក្តីរាយការណ៍ចំពោះភាពមិនប្រក្រតីនានាដែលបានកើតឡើង។ នៅក្នុងករណីពាក់ព័ន្ធនឹងការប្តឹងផ្តល់នានាពួកគេប្រគល់ភារៈឲ្យមេធាវីជាអ្នកដោះស្រាយជំនួស។ នៅពេលមានពាក់ព័ន្ធជាមួយការទាមទារសំណងដ៏ច្រើនលើសលប់ អ្នកត្រួតពិនិត្យថ្នាក់ខ្ពស់ជាអ្នកទទួលដោះស្រាយលើករណីនោះ។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីរៀបចំខ្លួនសម្រាប់អាជីពក្នុងវិស័យនេះ គេគួរតែសិក្សាផ្នែកជំនួញ វិទ្យាសាស្ត្រកុំព្យូទ័រ និងគណិតវិទ្យា។ ក្រុមហ៊ុនធានារ៉ាប់រងប្រាថ្នាជ្រើសរើសអ្នកដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រសម្រាប់ធ្វើជាតំណាងផ្នែកទាមទារសំណង។

ប៉ុន្តែ ក៏មានករណីលើកលែងផងដែរសម្រាប់អ្នកដែលមានបទពិសោធន៍ច្រើន ឧទាហរណ៍ អ្នកជំនាញជួសជុលរថយន្តមិនចាំបាច់មានសញ្ញាបត្រទេក៏អាចធ្វើជាអ្នកជួលជុលរថយន្តបានយ៉ាងល្អ។ ក្នុងការងារប្រភេទនេះមិនមានជំនាញជាក់លាក់ណាមួយដែលទាមទារនោះទេ មានមុខជំនាញខ្លះអាចនឹងមានប្រយោជន៍នៅក្នុងឧស្សាហកម្មធានារ៉ាប់រង ឧទាហរណ៍ សញ្ញាបត្រវិស្វករអាចមានតម្លៃសម្រាប់ធ្វើការសម្របសម្រួលក្នុងការទាមទារសំណងផ្នែកឧស្សាហកម្ម។

## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

ជំនួញ និងគណិតវិទ្យា

✦ កម្រិតអប់រំទាបបំផុត:

បរិញ្ញាបត្រ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

អ្នកវាយតម្លៃការខូចខាត

ឈ្មួញកណ្តាល និងទីភ្នាក់ងារធានារ៉ាប់រងអាយុជីវិត

ភ្នាក់ងារធានារ៉ាប់រងទ្រព្យសម្បត្តិ និងឧបទ្ទវហេតុ

...អឺ! និយាយអ៊ីចឹង ថ្មីៗនេះខ្ញុំបានទិញសេវាធានារ៉ាប់រងស្ទើរគ្រប់ផ្នែកអស់ហើយ.... ផ្ទះ ឡានអាយុជីវិត... ប៉ុន្តែខ្ញុំឆ្ងល់ណាស់មួយរយៈចុងក្រោយនេះប្តីខ្ញុំដូចជាចូលចិត្តដើរលេងបាត់ៗពីផ្ទះ... តើលោកមានសេវាធានាអីពាក់ព័ន្ធរឿងនេះឬទេ?!!



# អ្នកអភិរក្សសារមន្ទីរ

( Museum Curators )

**សង្ខេបអំពីជំនាញ**

**អ្នកអភិរក្សសារមន្ទីរធ្វើការងារៈ**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ បង្រៀន

G

**ជំនាញដែលត្រូវការប្រើៈ**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
✦ ការធ្វើសេចក្តីសម្រេចចិត្ត
✦ ការនិយាយ និងការស្តាប់

## តើអ្នកអភិរក្សសារមន្ទីរធ្វើកិច្ចការអ្វីខ្លះ?

អ្នកអភិរក្ស មានតួនាទីថែរក្សាវត្ថុទាំងអស់នៅក្នុងសារមន្ទីររួមបញ្ចូលទាំងវត្ថុដែលបានរក្សាទុក វត្ថុដែលបានដាក់តាំងបង្ហាញ ស្វែងរកវត្ថុថ្មីៗសម្រាប់សារមន្ទីរ តាមរយៈការទិញ ធ្វើជំនួញ ឬទទួលពីការបរិច្ចាគ។ អ្នកអភិរក្សត្រូវធ្វើបញ្ជីកាតាឡុក និងដាក់ឈ្មោះវត្ថុសិល្បៈទាំងអស់ឲ្យបានត្រឹមត្រូវតាមប្រភេទ សម័យកាល និងវត្ថុធាតុ។ ដូច្នេះការរក្សាទុកកំណត់ឯកសារ គឺជាផ្នែកមួយដ៏សំខាន់នៃការងាររបស់អ្នកអភិរក្ស។

អ្នកអភិរក្សធ្វើការរក្សាវត្ថុសិល្បៈដែលប្រមូលបានដោយធ្វើការជួលជុល និងរក្សាទុកបំណែកដែលខូចឲ្យស្ថិតក្នុងលក្ខខណ្ឌល្អប្រសើរ។ វត្ថុដែលងាយនឹងបាក់បែកត្រូវទុកឲ្យឆ្ងាយពីពន្លឺព្រះអាទិត្យ ឬរក្សាទុកនៅកន្លែងដែលមានសំណើមតិចៗ អ្នកអភិរក្សមួយចំនួនមានជំនាញជាក់លាក់តាមផ្នែកដូចជាគំនូរ ឈើ ក្រណាត់ ឬកុលាលភាជន៍។

អ្នកអភិរក្សសារមន្ទីរ សម្រេចចិត្តចំពោះប្រភេទវត្ថុដែលត្រូវដាក់តាំងបង្ហាញនិងជួយជាគំនិតសម្រាប់ការរៀបចំតាំងបង្ហាញ។ ពួកគេធ្វើការជាមួយគ្រូបង្រៀនផ្នែកសារមន្ទីរដើម្បីស្រាវជ្រាវ និងប្រមូលព័ត៌មានសម្រាប់បោះពុម្ពផ្សាយដូចជា សៀវភៅតូចៗ តារាងពិពណ៌នា ផែនទី ស្លាកសញ្ញាសម្រាប់វត្ថុសិល្បៈនិងសម្រាប់ការតាំងបង្ហាញ។ ពេលខ្លះ អ្នកអភិរក្សធ្វើការប្រមូលមូលនិធិ តាមរយៈការរៀបចំព្រឹត្តិការណ៍រៃអង្គាសវិភាគទាន ដើម្បីប្រមូលថវិកាសម្រាប់សារមន្ទីរ។ បន្ថែមលើនេះ អ្នកអភិរក្សក៏ត្រូវដើរឲ្យទាន់នឹងបច្ចេកវិទ្យាកុំព្យូទ័រ ទំនើប និងការបង្កើតមូលដ្ឋានទិន្នន័យវត្ថុសិល្បៈដែលអាចស្រាវជ្រាវតាមរយៈអ៊ីនធើណិតផងដែរ។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីក្លាយជាអ្នកអភិរក្សសារមន្ទីរ គេគួរសិក្សាកម្រិតទាបបំផុតត្រឹមបរិញ្ញាបត្រផ្នែកប្រវត្តិវិទ្យា វិទ្យាសាស្ត្រ ប្រវត្តិសិល្បៈ បុរាណវិទ្យា ឬស្ថាបត្យកម្ម។

## គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលាៈ**
សិល្បៈ និងជំនួញ

✦ **កម្រិតអប់រំទាបបំផុតៈ**
បរិញ្ញាបត្ររង

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នាៈ**
នរវិទូ បុរាណវត្ថុវិទូ អ្នករក្សាបណ្ណាសារ នាយកអប់រំ និងគ្រូបង្រៀនសារមន្ទីរ និង អ្នកប្រវត្តិសាស្ត្រ...

# អ្នកបច្ចេកទេសផលិតផលប្លាស្ទិក

( Plastics Technicians )

**សង្ខេបអំពីជំនាញ**

**អ្នកបច្ចេកទេសផលិតផលប្លាស្ទិកធ្វើការងារ៖**

- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- បង្កើត និងបង្កើនប្រព័ន្ធដំណើរការ
- បំពេញការងារជាក្រុម

G

**ជំនាញដែលត្រូវការប្រើ៖**

- ការគិតប្រកបដោយភាពច្នៃប្រឌិត
- ការគិតប្រកបដោយហេតុផល
- ការនិយាយ និងការស្តាប់

## តើអ្នកបច្ចេកទេសផលិតផលប្លាស្ទិកបំពេញកិច្ចការអ្វីខ្លះ?

អ្នកបច្ចេកទេសផលិតផលប្លាស្ទិក សហការជាមួយវិស្វករ អ្នកវិទ្យាសាស្ត្រ និងឧស្សាហករនៅក្នុងឧស្សាហកម្មប្លាស្ទិក ដើម្បីជួយអភិវឌ្ឍន៍ផលិតផល និងលក់ផលិតផលប្លាស្ទិក។ អ្នកបច្ចេកទេសប្លាស្ទិកធ្វើកិច្ចការជាច្រើនចាប់ផ្តើមពីការស្រាវជ្រាវ ការអភិវឌ្ឍ ការពិសោធដើម្បីបង្កើតសម្ភារប្លាស្ទិក ឬដើម្បីអភិវឌ្ឍន៍បន្ថែមលើសម្ភារដែលមានស្រាប់។ អ្នកបច្ចេក-ទេសស្រាវជ្រាវ និងអភិវឌ្ឍន៍ធ្វើការសិក្សាអំពីពីប្រតិកម្មគីមី សាកល្បងសម្ភារថ្មី វាយតម្លៃលទ្ធផលនៃការសាកល្បង រក្សាកំណត់ហេតុការងាររបស់ពួកគេយ៉ាងលម្អិត និងប្រើប្រាស់ការកត់ត្រាទាំងនោះដើម្បីសរសេររបាយការណ៍លម្អិត។ អ្នកបច្ចេកទេសប្លាស្ទិកក៏ធ្វើការជាអ្នកបង្កើតពុម្ព និងឧបករណ៍ផងដែរ។ ការច្នៃពុម្ពគឺអាស្រ័យនៅលើគោលការណ៍ណែនាំរបស់ម្ចាស់ផលិតកម្ម បន្ទាប់មកគេត្រូវច្នៃបង្កើតឧបករណ៍ និងម៉ាស៊ីនដើម្បីជួយក្នុងដំណើរការផលិតឲ្យបានលឿន និងមានគុណភាព។ បន្ថែមលើនេះ អ្នកបច្ចេកទេសខ្លះមានតួនាទីដំឡើងពុម្ព ត្រួតពិនិត្យដំណើរការចាក់ពុម្ព តាមដានកាលវិភាគផលិតកម្ម និងធ្វើតេស្តសាកល្បងលើវត្ថុធាតុដើមនិងផលិតផលសម្រេច។ ដើម្បីក្លាយជាអ្នកបច្ចេកទេសផលិតផលប្លាស្ទិក អ្នកគួរតែមានភាពរហ័សរហួន និងភាពប៉ិនប្រសប់ក្នុងការប្រើប្រាស់ដៃដើម្បីធ្វើការផ្សេងៗជាច្រើន។ បន្ថែមលើនេះគួរតែមានជំនាញទំនាក់ទំនង ពីព្រោះគេត្រូវធ្វើការជាមួយវិស្វករ អ្នកគីមី អ្នកគ្រប់គ្រង អ្នកច្នៃម៉ូត អ្នកព្យាករណ៍ និងអ្នកបច្ចេកទេសជាច្រើនទៀត។

## ការអប់រំ និងការបណ្តុះបណ្តាល

ការងារជាអ្នកបច្ចេកទេសផលិតផលប្លាស្ទិក គួរតែមានចំណេះដឹងផ្នែកពីជគណិត ធរណីមាត្រ វិទ្យាសាស្ត្រក្នុងមន្ទីរពិសោធន៍ គីមីសរីរាង្គ។ គេគួរទទួលការអប់រំជំនាញនេះនៅតាមសាលាបច្ចេកផ្នែកឧស្សាហកម្ម។

## គួរយល់ដឹង !

- **មុខវិជ្ជាសិក្សាក្នុងសាលា:** គីមីវិទ្យា និងគណិតវិទ្យា
- **កម្រិតអប់រំទាបបំផុត:** វគ្គអប់រំបណ្តុះបណ្តាលបច្ចេកទេស
- **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:** វិស្វករគីមី អ្នកបច្ចេកទេសគីមី អ្នកធ្វើពុម្ព វិស្វករផលិតផលប្លាស្ទិក កម្មករផលិតផលិតផលប្លាស្ទិក...



តទៅទំព័របន្ទាប់

# វិស្វករយន្តហោះ

( Aerospace Engineers )

**សង្ខេបអំពីជំនាញ**

**វិស្វករយន្តហោះធ្វើការងារ៖**

- វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- បំពេញការងារជាក្រុម
- ជ្រើសរើស និងប្រើប្រាស់សម្ភារ ឬបច្ចេកវិទ្យា

G

**ជំនាញដែលត្រូវការប្រើ៖**

- ការដោះស្រាយបញ្ហា
- គណិតវិទ្យា
- ការគិតប្រកបដោយភាពច្នៃប្រឌិត

## តើវិស្វករយន្តហោះបំពេញកិច្ចការអ្វីខ្លះ?

វិស្វករយន្តហោះ រចនា និងបង្កើតយន្តហោះ ដូចជាយន្តហោះពាណិជ្ជកម្ម ឬចំបាំង និងយានអវកាស។ ពួកគេធ្វើការជាក្រុមដើម្បី រចនា បង្កើត និងសាកល្បងម៉ាស៊ីនដែលត្រូវហោះហើរក្នុងបរិយាកាសផែនដី និងក្នុងលំហ។ វិស្វករយន្តហោះខ្លះមានឯកទេសចំពោះយន្តហោះតែមួយប្រភេទ ឬធ្វើការទៅលើតែផ្នែកណាមួយនៃយន្តហោះដែលទើបបង្កើតថ្មី ដូចជាការរចនាលំអផ្ទៃខាងក្រៅរបស់យាន។

វិស្វករយន្តហោះផ្សេងទៀតមានភារៈគ្រប់គ្រងការស្ថាបនាយន្តហោះ ដោយធ្វើការក្នុងរោងចក្រ ដើម្បីចង្អុលបង្ហាញ និងណែនាំកម្មករអំពីរបៀបរៀបចំបំពាក់គ្រឿងម៉ាស៊ីន ឬរបៀបផ្គុំឧបករណ៍។ បន្ថែមលើនេះ វិស្វករក៏ត្រូវរៀបចំផែនការ ការចំណាយ និងរយៈពេលដែលត្រូវផលិតយន្តហោះ។ វិស្វករយន្តហោះខ្លះទៀតធ្វើតេស្តសាកល្បងចំពោះយន្តហោះដែលទើបស្ថាបនារួច។ ពួកគេត្រួតពិនិត្យលក្ខណៈនៃការហោះហើរ និងសាកល្បងបញ្ហាយន្តហោះនៅរយៈកំពស់ខ្ពស់។ វិស្វករអាចធ្វើការងារនេះនៅឯវាលយន្តហោះ ឬត្រួតពិនិត្យការសាកល្បងហោះហើរតាមកុំព្យូទ័រក៏បាន។

## ការអប់រំ និងការបណ្តុះបណ្តាល

ប្រសិនបើ អ្នកចាប់អារម្មណ៍ក្នុងអាជីពជាវិស្វករយន្តហោះ អ្នកគួរតែសិក្សាគណិតវិទ្យា និងវិទ្យាសាស្ត្រឲ្យបានច្រើនតាមលទ្ធភាព។ ម្យ៉ាងទៀត រូបវិទ្យា វិទ្យាសាស្ត្រនៃការធ្វើចលនាក៏ជាមុខវិជ្ជាដ៏សំខាន់សម្រាប់ការងារជាវិស្វករយន្តហោះ។ បន្ថែមលើនេះ ភាសាអង់គ្លេស ការថ្លែងសុន្ទរកថា និងការទំនាក់ទំនង ក៏ជាមុខវិជ្ជាសំខាន់ផងដែរ ដោយសារវិស្វករត្រូវតែចេះពន្យល់គម្រោងបែបលំអិត និងស្មុគស្មាញឲ្យបានច្បាស់-លាស់ និងត្រឹមត្រូវ។ ម្យ៉ាងទៀត វគ្គសិក្សាផ្នែក វិទ្យាសាស្ត្រកុំព្យូទ័រក៏មានអត្ថប្រយោជន៍ផងដែរ នៅពេលដែលឧស្សាហ-កម្មកាន់តែមានការវិវត្តបែបបច្ចេកវិទ្យាទំនើប។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

វិទ្យាសាស្ត្រកុំព្យូទ័រ គណិតវិទ្យា និងរូបវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកបច្ចេកទេសយន្តហោះ និងវិទ្យាសាស្ត្រយន្តហោះ

ជាងម៉ាស៊ីនយន្តហោះ

អវកាសយានិក

វិស្វករឧស្សាហកម្ម និងវិស្វកម្មបច្ចេកទេស


តទៅទំព័របន្ទាប់

អ្នករូបនិយម និង
អ្នកបើកយន្តហោះ ។

# គ្រូបង្រៀនកុំព្យូទ័រ

(Computer Trainers)

**សង្ខេបអំពីជំនាញ**

**គ្រូបង្រៀនកុំព្យូទ័រធ្វើការងារ៖**

- ជួយកិច្ចការដល់អតិថិជន ឬភ្ញៀវ
- ជ្រើសរើស និងប្រើប្រាស់សម្ភារ ឬបច្ចេកវិទ្យា
- បង្រៀន

G

**ជំនាញដែលត្រូវការប្រើ៖**

- ការទំនាក់ទំនង
- ការនិយាយ និងការស្តាប់
- ការគិតប្រកបដោយហេតុផល

## តើគ្រូបង្រៀនកុំព្យូទ័របំពេញកិច្ចការអ្វីខ្លះ?

សព្វថ្ងៃនេះ និយោជិត និងសិស្ស និស្សិត ត្រូវដឹងពីរៀបបញ្ចូនសារ របៀបប្រើអ៊ិនធើណិតនិងរបៀបប្រើកម្មវិធីរៀបចំឯកសារមួយចំនួនទៀត។ ទោះជាយ៉ាងណាក៏ដោយ មនុស្សជាច្រើននឹងខ្វះជំនឿចិត្ត នៅពេលដែលពួកគេអង្គុយពីមុខអេក្រង់កុំព្យូទ័រទទេស្អាត និងសៀវភៅណែនាំដ៏គ្រាស់មួយក្បាល។ ពេលខ្វះ កុំព្យូទ័រនិងកម្មវិធីកុំព្យូទ័រមានភាពស្មុគស្មាញខ្លាំងពេករហូតដល់មិនអាចពន្យល់ឲ្យបានពេញលេញ និងច្បាស់លាស់តាមរយៈសៀវភៅណែនាំ។ ករណីនេះ គ្រូបង្រៀនកុំព្យូទ័រត្រូវបង្រៀនមនុស្សពីរបៀបប្រើប្រាស់កុំព្យូទ័រ ប្រើកម្មវិធីផ្សេងៗ និងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ។ នៅពេលដែលក្នុងក្រុមហ៊ុនឬអាជីវកម្មមានការដំឡើងកុំព្យូទ័រ និងកម្មវិធីថ្មី គ្រូបង្រៀនកុំព្យូទ័រត្រូវពន្យល់ណែនាំឬបង្រៀននិយោជិតម្នាក់ម្តងៗឬមួយក្រុមម្តងៗ។

គ្រូបង្រៀនកុំព្យូទ័រ បង្រៀនមនុស្សពីរបៀបប្រើប្រាស់កម្មវិធីកុំព្យូទ័រ។ ឧទាហរណ៍ នៅក្នុងនាយកដ្ឋានគណនេយ្យរបស់ក្រុមហ៊ុនមួយត្រូវការគ្រូបង្រៀនកុំព្យូទ័រ ដើម្បីបង្រៀនបុគ្គលិកគណនេយ្យពីរបៀបប្រើកម្មវិធីគណនាហិរញ្ញវត្ថុក្នុងការបង្កើតក្រាហ្វិច តារាង និងគណនាផលបូកសរុប។ ក្រៅពីនេះមានកម្មវិធីអាជីវកម្មផ្សេងៗទៀត ដូចជាកម្មវិធីគ្រប់គ្រងទិន្នន័យ ដើម្បីកត់ត្រានិងរក្សាឈ្មោះ អាស័យដ្ឋាន និងលេខទូរស័ព្ទអតិថិជន ព្រមទាំងកម្មវិធីវាយឯកសារដែលត្រូវបានប្រើដើម្បីវាយឯកសារ សំបុត្រ និងរបាយការណ៍។

ក្រុមហ៊ុនសាជីវកម្ម ក្រុមហ៊ុនផ្សព្វផ្សាយ និងក្រុមហ៊ុនឯកកម្មសិទ្ធតែងមានគេហទំព័របង្ហោះលើអ៊ិនធើណិត។ ដូច្នេះ គ្រូបង្រៀនកុំព្យូទ័រអាចបំពេញការងារពាក់ព័ន្ធការប្រើភាសាដែលត្រូវការក្នុងការបង្កើតគេហទំព័រ និងបង្រៀនពីរបៀបអភិវឌ្ឍន៍គេហទំព័រ។

គ្រូបង្រៀន អាចបង្ហាត់បុគ្គលិកពីរបៀបប្រើកម្មវិធីរចនាទំព័រសៀវភៅ និងម៉ាស៊ីនព្រីនឯកសារ ដែលអាចបង្ហាញពីក្រាហ្វិចនិងសៀវភៅសកម្មភាពរបស់អង្គភាព។ គ្រូបង្រៀនកុំព្យូទ័រមួយចំនួនក៏អាចជួយបង្កើតបណ្តាញភ្ជាប់កុំព្យូទ័រទាំងអស់ដែលមានប្រើនៅក្នុងការិយាល័យ។



បន្ថែមលើនេះ គ្រូបង្រៀនកុំព្យូទ័រក៏អាចធ្វើការសម្រាប់ខ្លួនឯង និងធ្វើការដោយសេរី


តទៅទំព័របន្ទាប់

ឬអាចធ្វើការឲ្យសាលាបង្រៀនកុំព្យូទ័រ ឬក្រុមហ៊ុនដែលផ្តល់សេវាកម្មកុំព្យូទ័រក៏បាន។ ភាពជាគ្រូបង្រៀនគួរតែមានភាពអត់ធ្មត់ និងជាមនុស្សដែលរីករាយជាមួយអ្នកដទៃ និងមានសណ្តានចិត្តល្អ។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីរៀបចំខ្លួនចូលទៅកាន់អាជីពជាគ្រូបង្រៀនកុំព្យូទ័រ អ្នកគួរតែរៀនជំនាញពាណិជ្ជកម្ម វិទ្យាសាស្ត្រកុំព្យូទ័រ ភាសាអង់គ្លេស ប្រវត្តិសាស្ត្រ ជីវវិទ្យា គីមីវិទ្យា រូបវិទ្យា និងគណិតវិទ្យា។ ជំនាញវិទ្យាសាស្ត្រកុំព្យូទ័រអាចសិក្សាបាននៅតាមសកលវិទ្យាល័យ។ ក្រុមហ៊ុនផ្តល់សេវាកម្មកុំព្យូទ័រ និងសាលាបង្រៀនកុំព្យូទ័រក៏មានផ្តល់វគ្គសិក្សាកម្មវិធីកុំព្យូទ័រផងដែរ។ ទោះបីជា ការសិក្សានៅមហាវិទ្យាល័យសំខាន់ក៏ដោយ គេគួរមានបទពិសោធន៍ក្នុងការអនុវត្តការងារផ្ទាល់នៅតាមក្រុមហ៊ុន និងអាជីវកម្មផងដែរ។ អ្នកអាចទទួលបានបទពិសោធន៍នេះតាមរយៈការហាត់ប្រើកុំព្យូទ័រជាប្រចាំទាំងនៅផ្ទះ និងកន្លែងធ្វើការ។ បទពិសោធន៍ក៏អាចចេញមកពីការធ្វើការផ្នែកលក់នៅក្នុងហាងលក់កុំព្យូទ័រ ឬក្រុមហ៊ុនលក់កម្មវិធីកុំព្យូទ័រផងដែរ។ កម្រិតអប់រំសម្រាប់ជំនាញនេះគឺខុសៗគ្នាទៅតាមការបង្រៀនកុំព្យូទ័រ និងក្រុមហ៊ុនផ្តល់សេវាកម្មផ្នែកនេះ។ គ្រូបង្រៀននៅកម្រិតវិទ្យាល័យតម្រូវឲ្យមានបរិញ្ញាបត្រ។

### គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:
វិទ្យាសាស្ត្រកុំព្យូទ័រ
✦ កម្រិតអប់រំទាបបំផុត:
បរិញ្ញាបត្រ
✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

អ្នកជំនាញបណ្តាញកុំព្យូទ័រ
អ្នកបង្កើតកម្មវិធីកុំព្យូទ័រ
អ្នកជំនាញបង្កើតប្រព័ន្ធ
អ្នកជំនាញផ្គត់ផ្គង់បច្ចេកទេស

# គិលានុបដ្ឋាកផ្នែកសង្គ្រោះបន្ទាន់

( Emergency Nurses )

**សង្ខេបអំពីជំនាញ**

គិលានុបដ្ឋាកផ្នែកសង្គ្រោះបន្ទាន់ធ្វើការងារ:
✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន
✦ បំពេញកិច្ចការជាក្រុម

G

ជំនាញដែលត្រូវការច្រើន:
✦ ការដោះស្រាយបញ្ហា
✦ ការទទួលខុសត្រូវ
✦ ការគ្រប់គ្រងខ្លួនឯង

## តើគិលានុបដ្ឋាកផ្នែកសង្គ្រោះបន្ទាន់បំពេញកិច្ចការអ្វីខ្លះ?

គិលានុបដ្ឋាកផ្នែកសង្គ្រោះបន្ទាន់ក៏អាចហៅបានថាគិលានុបដ្ឋាកព្យាបាលរបួស ដែលមានជំនាញខ្ពស់ក្នុងការថែរក្សាអ្នកជម្ងឺដោយផ្ទាល់ទៅដល់អ្នកដែលត្រូវការព្យាបាលជម្ងឺ ឬរបួសជាបន្ទាន់។ ការទទួលខុសត្រូវដ៏សំខាន់របស់គិលានុបដ្ឋាកសង្គ្រោះបន្ទាន់ គឺការផ្តល់ថ្នាំសង្គ្រោះបន្ទាន់សម្រាប់អ្នកជម្ងឺប្រកបដោយវិជ្ជាជីវៈខ្ពស់។ ទោះបីជាការព្យាបាលបន្ទាន់គឺជាឯកទេសគិលានុបដ្ឋាកក៏ដោយ ប៉ុន្តែកិច្ចការត្រូវការយល់


តទៅទំព័របន្ទាប់

ដឹងនូវឯកទេសថែទាំ និងព្យាបាលផ្សេងទៀតក្នុងវិជ្ជាជីវនេះ។ គិលានុបដ្ឋាកសង្គ្រោះបន្ទាន់ ត្រូវមើលការខុសត្រូវចំពោះស្ត្រីមានផ្ទៃពោះ កូនង៉ែតទើបនឹងកើត អ្នកជម្ងឺមហារីក ជនរងគ្រោះ អ្នកជម្ងឺអេដស៍ អ្នកជម្ងឺភ្លេចការចងចាំ និងមនុស្សចាស់ជរា ។ល។ នៅពេលដែលអ្នកជម្ងឺចូលក្នុងអាគារសង្គ្រោះបន្ទាន់ គិលានុបដ្ឋាកត្រូវតែពិនិត្យមើលអ្នកជម្ងឺជាមុន និងកំណត់សភាពជម្ងឺ ឬគ្រោះថ្នាក់តាមរយៈការធ្វើរោគវិនិច្ឆ័យដំបូង និងការប៉ាន់ស្មាន សភាពជម្ងឺរបស់អ្នកជម្ងឺ។ ពួកគេនិយាយទៅកាន់អ្នកជម្ងឺនិងគ្រួសារអ្នកជម្ងឺ ធ្វើការកត់ត្រារោគសញ្ញាសំខាន់ៗនិងសង្កេតមើលរោគសញ្ញារបស់អ្នកជម្ងឺ ឬពិនិត្យមើលរបួស។

គិលានុបដ្ឋាកសង្គ្រោះបន្ទាន់ ត្រូវតែផ្តល់អាទិភាពទៅឲ្យអ្នកជម្ងឺនៅពេលត្រូវការអ្វីៗ ជាពិសេស ប្រសិនបើស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរដូចជា គ្រោះមហន្តរាយ ឬគ្រោះថ្នាក់ដែលមនុស្សជាច្រើនរងគ្រោះ។ ពួកគេត្រូវតែព្យាយាមធ្វើឲ្យអ្នកជម្ងឺនៅស្ងៀម ហើយរៀបចំបញ្ជូនអ្នកជម្ងឺចូលបន្ទប់ពិសោធន៍ជាបន្ទាន់ ឬធ្វើការវះកាត់។ នៅក្នុងករណីខ្លះទៀត គិលានុបដ្ឋាកត្រូវដឹងពីវិធីព្យាបាលបឋម ដោយការប្រើឧបករណ៍ព្យាបាលទំនើបដល់អ្នកជម្ងឺមុនពេលជួបជាមួយវេជ្ជបណ្ឌិត។ ជារឿយៗ គិលានុបដ្ឋាកសង្គ្រោះបន្ទាន់ត្រូវតែជួយអ្នកជម្ងឺឲ្យទទួលបាននូវការថែទាំដ៏ល្អបំផុត និងមានអធ្យាស្រ័យខ្ពស់ចំពោះសំណើរបស់អ្នកជម្ងឺពាក់ព័ន្ធការព្យាបាល។ គិលានុបដ្ឋាកត្រូវតែទំនាក់ទំនងជាមួយនឹងគ្រួសារអ្នកជម្ងឺអំឡុងពេលដែលមានបញ្ហាបន្ទាន់ ហើយជួយឲ្យពួកគេសម្រួលអារម្មណ៍ និងកុំមានការភ័យខ្លាច។ គិលានុបដ្ឋាកសង្គ្រោះបន្ទាន់ក៏ត្រូវដើរតួជាអ្នកអប់រំផងដែរដូចជា ការបង្ហាញអ្នកជម្ងឺពីរបៀបថែទាំដំបៅ របួស ឬការផ្សាំខ្លួននឹងការផ្លាស់ប្តូរលក្ខខណ្ឌរស់នៅរបស់ពួកគេប្រសិនបើមានការចាំបាច់។



## ការអប់រំ និងការបណ្តុះបណ្តាល

គិលានុបដ្ឋាកសង្គ្រោះបន្ទាន់ត្រូវមានអាជ្ញាបណ្ណដែលចុះបញ្ជីដោយក្រសួងឬស្ថាប័នពាក់ព័ន្ធ បន្ទាប់ពីបំពេញកម្មវិធីអប់រំនិងប្រលងជាប់។ គិលានុបដ្ឋាកត្រូវតែមានបទពិសោធន៍ក្នុងការថែទាំអ្នកជម្ងឺមុននឹងចូលបំពេញការងារនៅក្នុងវិស័យនេះ។ ដើម្បីបម្រើការក្នុងវិស័យនេះ គេគួរមានបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រសុខាភិបាល ការថែទាំជម្ងឺ និងមានបទពិសោធន៍ការងារផងដែរ។

### គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ជីវសាស្ត្រ និងគីមីវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកបច្ចេកទេសសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ

គិលានុបដ្ឋាកផ្នែកថ្នាំស្ពឹក

ជំនួយការគិលានុបដ្ឋាក



តទៅទំព័របន្ទាប់

គិលានុបដ្ឋាកផ្នែកធ្មេញ
ជំនួយការគ្រូពេទ្យ
គ្រូពេទ្យ

# អ្នកឆ្លើយឆ្លងព័ត៌មានពីបរទេស

( Foreign Correspondents )

**សង្ខេបអំពីជំនាញ**

**អ្នកឆ្លើយឆ្លងព័ត៌មានពីបរទេសធ្វើការងារ៖**

- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- បង្រៀន

G

**ជំនាញដែលត្រូវការប្រើ៖**

- ការគិតប្រកបដោយភាពច្នៃប្រឌិត
- ការធ្វើសេចក្ដីសម្រេចចិត្ត
- ការនិយាយ និងការស្ដាប់

## តើឆ្លើយឆ្លងព័ត៌មានពីបរទេសធ្វើកិច្ចការអ្វីខ្លះ?

អ្នកឆ្លើយឆ្លងព័ត៌មានពីបរទេសធ្វើសេចក្ដីរាយការណ៍អំពីព័ត៌មានសម្រាប់កាសែត បណ្ដាញវិទ្យុ ឬទូរទស្សន៍ ឬប្រព័ន្ធផ្ដល់ព័ត៌មានពីក្រៅប្រទេស។ អ្នកឆ្លើយឆ្លងព័ត៌មានពីបរទេសពេលខ្លះធ្វើការឲ្យភ្នាក់ងារសារព័ត៌មាននិងវិទ្យុមួយជាក់លាក់ ប៉ុន្តែ បច្ចុប្បន្ននេះប្រព័ន្ធផ្សព្វផ្សាយហាក់មានចំណាប់អារម្មណ៍ទៅលើព័ត៌មានក្នុងតំបន់និងអន្តរជាតិ ដូច្នេះបណ្ដាញសារព័ត៌មាន និងវិទ្យុល្បីៗត្រូវពឹងផ្អែកទៅលើសេចក្ដីរាយការណ៍ព័ត៌មានពីប្រព័ន្ធផ្ដល់ព័ត៌មានពីខាងក្រៅដោយមិនចាំបាច់បញ្ជូនមនុស្សទៅដល់កន្លែងកើតហេតុនោះទេ។ ព័ត៌មាននេះអាចគ្របដណ្ដប់លើមាតិកានយោបាយ សង្គ្រាម រដ្ឋប្រហារ ស្ថានភាពជនភៀសខ្លួន ព្រឹត្តិការណ៍វប្បធម៌ បញ្ហាសង្គម សុខភាព កីឡា វិបត្តិហិរញ្ញវត្ថុ ពាណិជ្ជកម្ម និងសាសនានៅក្នុងប្រទេសមួយឬច្រើន។ អ្នកឆ្លើយឆ្លងព័ត៌មានបានចំណាយពេលវេលាភាគច្រើនទៅលើការស្រាវជ្រាវរឿងរ៉ាវ រៀបចំការណាត់ជួបសម្ភាស រៀបចំការធ្វើដំណើរ និងការធ្វើបទសម្ភាសជាមួយមនុស្សសំខាន់ៗ ឬអ្នកដែលជាប់ពាក់ព័ន្ធនឹងហេតុការណ៍។ បន្ទាប់ពីការសម្ភាស ឬការថតយកហេតុការណ៍ អ្នកយកការណ៍ត្រូវសរសេររឿងរ៉ាវ និងបញ្ជូនព័ត៌មានទាំងនោះទៅទីស្នាក់ការកាសែត និងវិទ្យុរបស់ពួកគេ ឬផ្ញើទូរសារតាមរយៈអ៊ិនធើណិតនិងអ៊ីម៉េល។ អ្នកឆ្លើយឆ្លងព័ត៌មានពីបរទេសជារឿយៗថតរូប ថតវីដេអូ និងកែសម្រួលសម្លេងដោយខ្លួនឯង។

អ្នកឆ្លើយឆ្លងព័ត៌មានពីបរទេសតែងត្រូវបានទាក់ទាញឲ្យធ្វើដំណើរទៅកាន់តំបន់គ្រោះថ្នាក់ឬជម្លោះផ្សេងៗជាពិសេសសង្គ្រាម។ ពេលខ្លះពួកគេអាចជ្រើសយកការធ្វើដំណើរទៅកាន់សមរភូមិប្រយុទ្ធ ដើម្បីបានផ្ដិតយករូបភាពជាក់ស្ដែងនៃព្រឹត្តិការណ៍ដែលកំពុងកើតឡើង ឬក៏រង់ចាំទទួលព័ត៌មានពីទីតាំងមួយដែលមានសុវត្ថិភាព។ ពេលខ្លះ ពួកគេត្រូវទទួលនូវការហ្វឹកហាត់ប្រើកាំភ្លើងដោយផ្ទាល់មុនចេញទៅយកព័ត៌មាននៅឯសមរភូមិ។ ស្ថានភាពនៃការរស់នៅអំឡុងពេលយកព័ត៌មានអាចជួបប្រទះការលំបាកឬមិនមានផាសុខភាពនោះទេ ដូចជាខ្វះទឹកស្អាតប្រើប្រាស់។ ការងារបែបនេះក៏អាចបង្កើតនូវភាពឯកោផងដែរ ជាពិសេសពេលដែលត្រូវផ្លាស់ប្ដូរទៅតំបន់ផ្សេងទៀត ពីព្រោះបញ្ហាមិនចេះភាសា ទំនៀមទំលាប់នៃក្រុមមនុស្សផ្សេងគ្នានិងគ្រោះថ្នាក់ជាដើម។

ដើម្បីធ្វើជាអ្នកឆ្លើយឆ្លងព័ត៌មានពីបរទេស អ្នកត្រូវតែបង្កើតចម្ងល់អំពីអ្វីៗដែលនៅជុំវិញខ្លួន ឧទាហរណ៍ របៀបរស់នៅរបស់មនុស្សក្នុងវប្បធម៌ផ្សេងៗ វិធីសាស្ត្រក្នុងការសម្ភាស ការប្រឈមជាមួយប្រធានបទដែលមានភាពសើប

ការទំនាក់ទំនងជាមួយមនុស្សគ្រប់សណ្ឋាននិងការមានវិន័យចំពោះវិជ្ជាជីវៈ។

## ការអប់រំ និងការបណ្តុះបណ្តាល

មុខវិជ្ជាសំខាន់ៗសម្រាប់ត្រៀមខ្លួនចាប់យកអាជីពជាអ្នកសារព័ត៌មានមានដូចជា ភាសាអង់គ្លេស ការតែងនិពន្ធ សង្គមវិទ្យា វិទ្យាសាស្ត្រនយោបាយ សេដ្ឋកិច្ច ប្រវត្តិវិទ្យា និងភូមិវិទ្យា។ អ្នកឆ្លើយឆ្លងព័ត៌មានពីបរទេសទាមទារឲ្យមានបរិញ្ញាបត្រផ្នែកសារព័ត៌មាន។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ភាសាបរទេស ឬភាសាអង់គ្លេស

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកនិពន្ធសៀវភៅ

មន្ត្រី ឬបុគ្គលិកផ្នែកសេវាកម្មក្រៅប្រទេស

អ្នកសារព័ត៌មាន

អ្នកនិពន្ធទស្សនាវដ្តី




# ស្ថាបត្យកររទេសភាព

( Landscape Architecture )

**សង្ខេបអំពីជំនាញ**

**ស្ថាបត្យកររទេសភាពធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ បង្កើត និងបង្កើនប្រព័ន្ធដំណើរការ

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត

✦ គណិតវិទ្យា

✦ ការដោះស្រាយបញ្ហា

## តើស្ថាបត្យកររទេសភាពពេញកិច្ចការអ្វីខ្លះ?

ស្ថាបត្យកររទេសភាព ធ្វើគម្រោង និងរចនាផ្នែកខាងក្រៅរបស់ផ្ទះ មជ្ឈមណ្ឌលពាណិជ្ជកម្ម សួនច្បារ ឬឧទ្យាន តំបន់លំហែកាយ មហាវិថី និងមជ្ឈមណ្ឌលលក់ទំនិញ។ ពួកគេក៏អាចធ្វើការក្នុង គម្រោងខុសៗគ្នាជាច្រើនមានជាអាទិ៍ ការរចនាផ្លូវថ្នល់ គម្រោងសាងសង់ផ្ទះ អគារសិក្សា និងកន្លែងវាយកូនហ្គូល។ ពួកគេផ្តល់ក៏យោបល់អំពីវិធីសាស្ត្រដ៏ល្អបំផុតក្នុងការប្រើប្រាស់ដីធ្លី ព្រមទាំងការយកចិត្តទុកដាក់ចំពោះបរិស្ថាន។ ស្ថាបត្យកររទេសភាព ចាប់ផ្តើមគម្រោងមួយដោយការពិភាក្សាជាមួយនឹងអតិថិជន ពីគោលបំណង នៃគម្រោង រចនាសម្ព័ន្ធរបស់គម្រោង និងដើមទុន។ ស្ថាបត្យកររទេសភាពសិក្សាពីតំបន់ដែលត្រូវតុបតែងលំអ និងសង្កេតមើលកិនភាគសំខាន់ៗ ដូចជា ស្ថានភាពដី ប្រព័ន្ធទឹក សំណង់អាគារ ដើមឈើ និងរុក្ខជាតិ។ ស្ថាបត្យកររទេសភាពត្រូវពិភាក្សាជាមួយនឹងវិស្វករ មន្ត្រីក្រុង និងភ្នាក់ងារអចលន



តទៅទំព័របន្ទាប់

ទ្រព្យដែលពាក់ព័ន្ធនឹងគម្រោង។ បន្ទាប់ពីធ្វើការគូរវាសទីកន្លែងរួចរាល់ហើយ ស្ថាបត្យករទេសភាពនឹងស្វះស្វែងរកការយល់ព្រមលើគម្រោងពីអតិថិជនរបស់គេ។ នៅពេលដែលគម្រោងត្រូវបានយល់ព្រម ស្ថាបត្យករទេសភាពបង្កើតបញ្ជីសម្ភារៈដែលត្រូវប្រើប្រាស់ និងធ្វើគម្រោងពីរបៀបនៃការស្ថាបនាផ្លូវចូល ផ្លូវដើរ ស្ពាន ឬជណ្តើរ។ ស្ថាបត្យករទេសភាពមួយចំនួន ត្រូវនៅប្រចាំការ ដើម្បីគ្រប់គ្រងកិច្ចការរហូតដល់គម្រោងត្រូវបានបញ្ចប់ជាស្ថាពរ។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីក្លាយជាស្ថាបត្យករទេសភាព អ្នកគួរតែសិក្សាផ្នែកស្ថាបត្យកម្ម ជីវសាស្ត្រ គីមីវិទ្យា វិទ្យាសាស្ត្រផែនដី ភាសាអង់គ្លេស និងគណិតវិទ្យា។ ស្ថាបត្យករទេសភាពត្រូវមានបរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

កសិកម្ម និងវិទ្យាសាស្ត្រផែនដី

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

ស្ថាបត្យកម្ម

អ្នកធ្វើគម្រោងទីក្រុង

អ្នកបច្ចេកទេសផ្នែកទេសភាព

អ្នកច្នៃម៉ូតសម្ភារកីឡា

# គ្រូមធ្យមសិក្សាទុតិយភូមិ

(Secondary School Teachers)

**សង្ខេបអំពីជំនាញ**

**គ្រូមធ្យមសិក្សាទុតិយភូមិធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ បំពេញការងារប្រកបដោយភាពជាអ្នកដឹកនាំ

✦ បង្រៀន

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការទទួលខុសត្រូវ

✦ ការអាននិងសរសេរ

✦ ការនិយាយនិងការស្តាប់

## តើគ្រូមធ្យមសិក្សាទុតិយភូមិបំពេញកិច្ចការអ្វីខ្លះ?

គ្រូមធ្យមសិក្សាទុតិយភូមិបង្រៀនដល់សិស្សានុសិស្សនៅវិទ្យាល័យ។ ជាទូទៅពួកគាត់មានជំនាញលើមុខវិជ្ជាមួយច្បាស់លាស់ដូចជា ភាសាអង់គ្លេស គណិតវិទ្យា ជីវវិទ្យា ឬប្រវត្តិវិទ្យា ឬក៏អាចបង្រៀនមុខវិជ្ជាជាច្រើនទៀត។ គ្រូមធ្យមសិក្សាទុតិយភូមិខ្លះបង្រៀនលើមុខជំនាញផ្សេងៗ ដូចជាព័ត៌មានវិទ្យានិងកុំព្យូទ័រ ជំនួញ និងផ្នែកសិល្បៈជាដើម។ គ្រូក៏មានភារកិច្ចណែនាំ ឬផ្តល់ព័ត៌មានដល់សិស្សឲ្យដឹងអំពីការសិក្សានៅឧត្តមសិក្សា មុខរបរឬអាជីព និងមុខវិជ្ជាផ្សេងៗទៀតដូចជាផ្នែកសិល្បៈ សុខាភិបាល និងទំនាក់ទំនងផងដែរ។ បន្ថែមលើកិច្ចការបង្រៀននៅក្នុងថ្នាក់ គ្រូមធ្យមសិក្សាទុតិយភូមិត្រូវរៀបចំគម្រោងមេរៀនតាមកម្មវិធីសិក្សាដែល

បានកំណត់ដោយក្រសួងឬស្ថាប័នពាក់ព័ន្ធ។ ពួកគាត់ត្រូវរៀបចំវិញ្ញាសាប្រឡង តារាងព្រឹត្តិបត្រពិន្ទុ សៀវភៅតាមដានការសិក្សា ជួបជាមួយឪពុកម្តាយសិស្ស ព្រមទាំងគ្រប់គ្រងលើសកម្មភាពផ្សេងៗទៀត។ ជារឿយៗពួកគាត់តែងតែជួបផ្ទាល់ជាមួយសិស្សដើម្បីពិភាក្សាអំពីកិច្ចការផ្ទះ មេរៀន ឬបញ្ហាផ្ទាល់ខ្លួនៗ ក្នុងពេលបង្រៀនគ្រូអាចប្រើវិធីសាស្ត្រ សម្ភារ និងឧបករណ៍ផ្សេងៗជាមធ្យោបាយដូចជា ការបង្រៀនតាមបែបសូត្រមេរៀន ការចាក់បញ្ចាំងស្លាយរូបភាព ការអាន ការពិភាក្សា និងការដឹកនាំសិស្សឲ្យអនុវត្តជាដើម។ បន្ថែមលើនេះ គ្រូត្រូវមានទំនាក់ទំនងផ្ទាល់ជាមួយសិស្សតាមរយៈការចោទជាសំនួរ និងការឆ្លើយសំនួរដើម្បីបញ្ជាក់ថាសិស្សទាំងអស់ពិតជាយល់មេរៀនគ្រប់ៗគ្នា។ ដើម្បីបង្កើនបន្ថែមនូវចំណេះក្នុងថ្នាក់ គ្រូត្រូវដាក់កិច្ចការផ្ទះ ធ្វើការប្រឡង និងកិច្ចការស្រាវជ្រាវផ្សេងៗដែលអាចជួយឲ្យសិស្សអភិវឌ្ឍការយល់ដឹងកាន់តែច្បាស់អំពីមេរៀន។

មុខវិជ្ជានីមួយៗមានវិធីនិងលក្ខខណ្ឌក្នុងការបង្រៀនខុសៗគ្នា ឧទាហរណ៍ មុខវិជ្ជាវិទ្យាសាស្ត្រ គ្រូត្រូវត្រួតពិនិត្យការងារក្នុងមន្ទីរពិសោធន៍ដែលសិស្សអនុវត្តជាមួយអតិសុខុមទស្សន៍ និងសម្ភារផ្សេងៗទៀត។ ដោយឡែកចំពោះគ្រូបង្រៀនមុខវិជ្ជាគេហកិច្ច បង្រៀនសិស្សឲ្យចេះប្រើប្រាស់ឧបករណ៍ និងសម្ភារនៅក្នុងអគារ។ គ្រូសិល្បៈបង្រៀនសិស្សឲ្យចេះប្រើថ្នាំលាបពណ៌ ចម្លាក់ផ្សេងៗ ឬក៏សម្ភារសម្រាប់ប្រើក្នុងពេលជាងផ្នែកសិល្បៈ។

គ្រូមធ្យមសិក្សាទុតិយភូមិមួយចំនួនត្រូវបានបណ្តុះបណ្តាលជាពិសេស ដើម្បីអាចបង្ហាត់បង្រៀនសិស្សដែលមានពិការភាព។ គ្រូខ្លះទៀតបង្រៀនមុខវិជ្ជាពិសេសសម្រាប់សិស្សដែលមានកម្រិតខ្ពស់និងពិន្ទុខ្ពស់។ គ្រូមធ្យមសិក្សាទុតិយភូមិក៏មានទំនួលខុសត្រូវជាច្រើនទៀតនៅក្រៅថ្នាក់រៀនដូចជា ចូលរួមការប្រជុំរបស់សាលា និងចូលរួមវគ្គបណ្តុះបណ្តាលបន្ត។ គ្រូមធ្យមសិក្សាទុតិយភូមិមួយចំនួនទៀតអាចធ្វើជាអ្នកបង្ហាត់កីឡាខាងអត្តពលកម្ម ឬអ្នកបង្ហាត់នាដ្យសាស្ត្រ។

## ការអប់រំ និងការបណ្តុះបណ្តាល

គ្រូមធ្យមសិក្សាទុតិយភូមិត្រូវតែមានបរិញ្ញាបត្រ និងការ បណ្តុះបណ្តាលគរុកោសល្យដែលទទួលបានការបញ្ជាក់ពីក្រសួងឬស្ថាប័នជំនាញ។ បន្ថែមលើនេះគ្រូត្រូវតែសិក្សាលើមុខវិជ្ជាជាក់លាក់ណាមួយដែលខ្លួនចង់បង្រៀន ព្រមទាំងមុខវិជ្ជាមួយចំនួនទៀតពាក់ព័ន្ធបច្ចេកទេសនៃការបង្រៀន។ម្យ៉ាងទៀតគេត្រូវការចំណាយពេលជាច្រើនខែធ្វើកម្មសិក្សាក្រោមការត្រួតពិនិត្យរបស់គ្រូដែលមានបទពិសោធន៍។ ពេលចេញបំពេញការងារ គ្រូត្រូវចូលរួមសិក្ខាសាលាអប់រំដើម្បីទ្រទ្រង់ចំណេះដឹង និងបណ្តុះបណ្តាលចំណេះដឹងរបស់ពួកគាត់បន្ថែមទៀត។

## គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ភាសាបរទេស និងចិត្តវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

គ្រូមហាវិទ្យាល័យ

គ្រូបឋមសិក្សា

អ្នកប្រឹក្សាយោបល់ផ្នែកអាជីព និងគ្រូតន្ត្រី


តទៅទំព័របន្ទាប់

# ស្មៀនការិយាល័យ

( Office Clerks )

**សង្ខេបអំពីជំនាញ**

**ស្មៀនការិយាល័យធ្វើការងារ៖**

✦ គ្រប់គ្រងពេលវេលា
✦ បំពេញការងារជាក្រុម
✦ ជ្រើសរើសនិងប្រើប្រាស់ឧបករណ៍ឬបច្ចេកវិទ្យា

G

**ជំនាញដែលត្រូវការច្រើន៖**

✦ ការនិយាយ និងការស្តាប់
✦ ការអាននិងការសរសេរ
✦ ការគ្រប់គ្រងខ្លួនឯង

ទោះបីជា ស្មៀនការិយាល័យគឺជានិយោជិតដែលបំពេញការងារកម្រិតដំបូងនិងទាបជាងគេនៅក្នុងអង្គភាព ឬស្ថាប័នមួយក៏ដោយ ប៉ុន្តែពួកគេគឺជាបុគ្គលិកដែលត្រូវធានាថាដំណើរការរបស់ក្រុមហ៊ុនមានសភាពរលូន។ ការងារដែលបំពេញដោយស្មៀនការិយាល័យមានសភាពខុសៗគ្នាទៅតាមកម្រិតជំនាញ បទពិសោធន៍ និងប្រភេទនៃអង្គភាពឬស្ថាប័នដែលពួកគេកំពុងធ្វើការ។ កិច្ចការរបស់ពួកគេអាចត្រូវបានផ្លាស់ប្តូរជាប្រចាំថ្ងៃ ហើយពួកគេត្រូវតែមានសមត្ថភាពក្នុងការបំពេញកិច្ចការច្រើនមុខ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពឬតម្រូវការនៅក្នុងការិយាល័យ។

ស្មៀនការិយាល័យត្រូវតែមានចំណេះស្ទាត់ជំនាញក្នុងការប្រើប្រាស់កុំព្យូទ័រ និងការរៀបចំឯកសារ ហើយត្រូវតែមានសមត្ថភាពប្រើប្រាស់និងប្រតិបត្តិការសម្ភារបរិក្ខារនៅក្នុងការិយាល័យ ដូចជា កុំព្យូទ័រ ម៉ាស៊ីនគិតលេខ ម៉ាស៊ីនថតចម្លង ម៉ាស៊ីនបញ្ជូនសារ ម៉ាស៊ីនស្កេន និងទូរសព្ទជាដើម។ ពួកគេត្រូវតែមានជំនាញក្នុងការពិនិត្យកិច្ចការខ្លួនឯង និងកិច្ចការរបស់អ្នកដទៃផងដែរ។ បន្ថែមលើនេះត្រូវតែមានភាពប៉ិនប្រសប់ និងវិជ្ជាជីវៈក្នុងការឆ្លើយឆ្លងទូរសព្ទ ចែកចាយព័ត៌មាន ទទួលនិងបញ្ជូនសារ។ ស្មៀនការិយាល័យតែងមានភារកិច្ច និងកិច្ចការខុសគ្នាអាស្រ័យតាមប្រភេទនៃអង្គភាពឬស្ថាប័ន។ ឧទាហរណ៍ ស្មៀននៅក្នុងការិយាល័យច្បាប់មិនធ្វើការដូចស្មៀននៅក្នុងវិស័យសុខាភិបាលនោះទេ។ ភាគច្រើនស្មៀន មានទំនួលខុសត្រូវក្នុងការចែក និងផ្ញើសំបុត្រ ឆ្លើយឆ្លងទូរសព្ទ និងបញ្ជាទិញនូវទំនិញតាមតម្រូវការរបស់ការិយាល័យ។ នៅក្នុងការិយាល័យជំនាញឯកទេសផ្សេងៗដូចជាការិយាល័យច្បាប់ ស្មៀនមានទំនួលខុសត្រូវក្នុងការធ្វើតារាងការណាត់ជួប រក្សាទុកសំណុំរឿងរបស់អតិថិជន និងរៀបចំឯកសារ។ បទពិសោធន៍របស់ស្មៀនត្រូវបានកំណត់តាមរយៈកម្រិតនៃភារកិច្ចដែលបានបំពេញនិងភារកិច្ចដែលរំពឹងទុក។ ស្មៀនដែលមានជំនាញខ្ពស់អាចប្រើប្រាស់កុំព្យូទ័រដែលមានកម្មវិធីលំបាក ឬត្រួតពិនិត្យការងាររបស់ស្មៀនផ្សេងៗទៀត ខណៈពេលដែលអ្នកមិនសូវមានបទពិសោធន៍ បំពេញត្រឹមតែកិច្ចការងាយៗដូចជា ទទួលសំបុត្រចូល-ចេញ និងបែងចែកតាមផ្នែក ថតចម្លងឯកសារ រៀបចំឯកសារដាក់ក្នុងស្រោមសំបុត្រ និងរត់សំបុត្រឬឯកសារ។ ការមានជំនាញក្នុងការទំនាក់ទំនងបានល្អក្នុងការងារនិងជាមួយបុគ្គល ព្រមទាំងសមត្ថភាពក្នុងការវិភាគកិច្ចការនឹងជួយឲ្យស្មៀនទទួលបានតំណែងកាន់តែខ្ពស់។

## ការអប់រំ និងការបណ្តុះបណ្តាល

គួរខិតខំព្យាយាមរៀនមុខជំនាញទាក់ទងជំនួញឲ្យបានច្រើនតាមដែលអាចទៅរួចដើម្បីស្វែងយល់ពាក្យបច្ចេកទេសក្នុងការិយាល័យ និតិវិធី និងសម្ភារបរិក្ខា ដើម្បីកសាង និងដុះខាត់ជំនាញការិយាល័យរបស់អ្នក។ បន្ថែមលើនេះ ការរៀនមុខជំនាញគណិតវិទ្យាសម្រាប់ជំនួញ កុំព្យូទ័រ និងភាសាអង់គ្លេសនឹងជួយបង្កើនប្រសិទ្ធភាពក្នុងការងារ។ ចំណែកមុខ


តទៅទំព័របន្ទាប់

វិជ្ជាចិត្តវិទ្យានឹងជួយអ្នកឲ្យចេះពិនិត្យ និងស្វែងយល់បុគ្គលិកលក្ខណៈរបស់មនុស្ស និងការប្រាស្រ័យទាក់ទង។ និយោជកភាគច្រើនស្វែងរកស្មៀនដែលមានកម្រិតវប្បធម៌ទាបបំផុតត្រឹមមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។



## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

ភាសាបរទេស គណិតវិទ្យា និងចិត្តវិទ្យា

✦ កម្រិតអប់រំទាបបំផុត:

មធ្យមសិក្សាទុតិយភូមិ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

លេខាធិការផ្នែកច្បាប់

បុគ្គលិករដ្ឋបាលការិយាល័យ

អ្នកទទួលភ្ញៀវ

លេខាធិការ

# អ្នកបច្ចេកទេសខាងព្រៃឈើ

( Forestry Technicians )

**សង្ខេបអំពីជំនាញ**

**អ្នកបច្ចេកទេសខាងព្រៃឈើធ្វើការងារ៖**

✦ បង្កើត ឬបង្កើនប្រព័ន្ធ (ដំណើរការ)

✦ វាយតម្លៃនិងគ្រប់គ្រងព័ត៌មាន

✦ ជ្រើសរើសនិងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

G

**ជំនាញដែលត្រូវការប្រើ៖**

✦ គណិតវិទ្យា

✦ ការដោះស្រាយបញ្ហា

✦ ការនិយាយនិងការស្តាប់

## តើអ្នកបច្ចេកទេសខាងព្រៃឈើបំពេញកិច្ចការអ្វីខ្លះ?

អ្នកបច្ចេកទេសខាងព្រៃឈើបំពេញការងារជាផ្នែកមួយនៃក្រុមការងារគ្រប់គ្រងនិងអភិរក្សព្រៃឈើនៅតាមការិយាល័យ ឬដែនរដ្ឋបាលព្រៃឈើនានា។ ការងារភាគច្រើនពាក់ព័ន្ធនឹងការដាំដុះព្រៃឈើឡើងវិញ ការរក្សាធនធានចំណីសត្វក្នុងធម្មជាតិ ការរក្សាលំនឹងទឹកក្នុងធម្មជាតិ ការអភិរក្សសម្រាប់គោលបំណងសិក្សាអំពីវិទ្យាសាស្ត្រ និងសម្រាប់ការប្រើប្រាស់ក្នុងក្របខណ្ឌពិសេសអ្វីមួយ។ ការងារប្រចាំថ្ងៃរបស់អ្នកបច្ចេកទេសខាងព្រៃឈើរួមបញ្ចូលទាំងសកម្មភាពទូទៅក្នុងការគ្រប់គ្រង និងការទាញយកផលពីព្រៃឈើ។ អ្នកបច្ចេកទេសផ្នែកនេះទទួលបន្ទុកកិច្ចការដាំដើមឈើជំនួសឲ្យ

ព្រៃឈើដែលត្រូវបានកាប់ ប្រមូលផល បាត់បង់ដោយសារជម្ងឺ ឬដោយសារភ្លើងឆេះព្រៃ។ ពួកគេថែទាំនិងការពារព្រៃឈើធំទង់ៗដើម្បីទទួលបានការលូតលាស់ល្អបំផុត តាមរយៈការបាញ់ថ្នាំសម្លាប់សត្វល្អិតចង្រៃលើដើមឈើទាំងនោះនៅពេលចាំបាច់ និងការពារដើមឈើទាំងនោះពីភ្លើងឆេះឬការបំផ្លិចបំផ្លាញផ្សេងៗ។

ក្នុងពេលប្រមូលផល និងដាក់លក់ផលិតផលព្រៃឈើនៅលើទីផ្សារគេត្រូវការរៀបចំផែនការច្បាស់លាស់រួមទាំងការកសាងផ្លូវចូលសម្រាប់ម៉ាស៊ីនកាប់ឈើនិងរថយន្តដឹកជញ្ជូន។ បន្ទាប់ពីកាប់ឈើរួច អ្នកបច្ចេកទេសនឹងធ្វើការវាស់វែងឈើហ៊ុបទៅតាមខ្នាតផ្សេងៗដើម្បីកាត់ និងច្រៀកតាមសេចក្តីត្រូវការផ្សេងៗ។ ទីបំផុតឈើហ៊ុប និងឈើច្រៀកនឹងត្រូវបានលក់ទៅឲ្យរោងចក្រអារឈើ រោងចក្រក្តារបន្ទះ រោងចក្រធ្វើក្រដាស និងសិប្បកម្មផលិតគ្រឿងសង្ហារឹម។ បន្ទាប់ពីការប្រមូលផលរួចរាល់ អ្នកបច្ចេកទេសត្រូវធ្វើការកែប្រែស្ថានភាពដីដើម្បីត្រៀមសម្រាប់ការដាំដុះនាពេលក្រោយទៀត។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីក្លាយជាអ្នកបច្ចេកទេសខាងព្រៃឈើ គេត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និងបរិញ្ញាបត្រផ្នែករុក្ខាប្រមាញ់នៅឯមហាវិទ្យាល័យ ឬវិទ្យាស្ថានបច្ចេកទេសផ្នែកនេះ។ កម្មវិធីបច្ចេកទេសអំពីព្រៃឈើបូករួមទាំងមុខវិជ្ជា គណិតវិទ្យា រុក្ខសាស្ត្រ វិស្វករ និងបច្ចេកទេសអំពីព្រៃឈើដែលត្រូវសិក្សានៅក្នុងថ្នាក់ ព្រមទាំងអនុវត្តការងារនៅក្នុងមន្ទីរពិសោធន៍ និងនៅក្នុងព្រៃ។



### គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

វិទ្យាសាស្ត្រផែនដី និងគណិតវិទ្យា

✦ កម្រិតអប់រំទាបបំផុត:

បរិញ្ញាបត្រ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

អ្នកជីវវិទ្យា និង អ្នកអភិរក្សឧទ្យាន

## ក្រឡាបញ្ជី

(Court Reporters)

**សង្ខេបអំពីជំនាញ**

**ក្រឡាបញ្ជីធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ ជ្រើសរើសនិងប្រើប្រាស់បច្ចេកវិទ្យា

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការអាននិងការសរសេរ

✦ ការទទួលខុសត្រូវ

✦ ការនិយាយ និងការស្តាប់

ក្រឡាបញ្ជីត្រូវរក្សាទុកនូវព័ត៌មានទាំងអស់ដែលត្រូវបានជជែកដេញដោលនៅក្នុងអង្គសវនាការ និងការកាត់សេចក្តី។ ព័ត៌មានទាំងនេះហៅថាចម្លើយកសិណសាក្សី។ ក្រឡាបញ្ជីត្រូវប្រើនិមិត្តសញ្ញា ឬអក្សរបំប្រួញដើម្បីកត់ត្រាឲ្យបានឆាប់រហ័សនូវចម្លើយរបស់សាក្សី។ ជាទូទៅនៅក្នុងសាលកាត់ក្តីទាំងមេធាវី ចុងចោទ និងដើមចោទតែងនិយាយជាហូរហែរឥតដាច់នូវចម្លើយ ឬកសិណសាក្សី។ ដូច្នេះក្រឡាបញ្ជីត្រូវតែកត់ត្រាទុកនូវរាល់ពាក្យពេចន៍ដែលអ្នកទាំងនោះនិយាយចេញដើម្បីរក្សាទុកជាភស្តុតាង។ ដោយសារកំណត់ហេតុនោះនឹងត្រូវប្រើជាឯកសារផ្លូវការសម្រាប់ការកាត់ក្តី ដូច្នេះទើបក្រឡាបញ្ជីមិនអាចកត់រំលងមួយពាក្យនោះទេ។

ប្រសិនបើមានការរំលង ភ្លេចពាក្យ ឬក៏ឃ្លាអ្វីមួយ ក្រឡាបញ្ជីត្រូវប្រញាប់ប្រញាល់ស្នើសុំបង្អន់ ឬកាត់សម្តីរបស់អង្គជំនុំជម្រះដើម្បីឲ្យនិយាយឡើងវិញម្តងទៀត។ ជួនកាលចៅក្រមតម្រូវឲ្យក្រឡាបញ្ជីអានឮៗនូវសេចក្តី ឬចម្លើយកសិណសាក្សីដែលបានកត់ត្រារួចហើយ ដើម្បីបញ្ជាក់អំពីខ្លឹមសារ។

ដើម្បីបំពេញកិច្ចការនេះប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ក្រឡាបញ្ជីត្រូវមានជំនាញនិងវិធីសាស្ត្រកត់ត្រាឲ្យបានលឿន ប៉ុន្តែក្តោបបានខ្លឹមសារទាំងស្រុង ព្រមទាំងអាចរកនូវជំនួយពីឧបករណ៍បច្ចេកវិទ្យាទំនើបផ្សេងៗដូចជាកុំព្យូទ័រ និងប្រដាប់ថតសំឡេងជាដើមក្នុងការពន្លឿនកិច្ចការ។

ការងាររបស់ក្រឡាបញ្ជីមិនមែនបញ្ចប់ត្រឹមតែការកត់ត្រា និងរៀបចំឯកសារនៅក្នុងសាលជំនុំជម្រះ និងអង្គសវនាការប៉ុណ្ណោះទេ។ ប៉ុន្តែត្រូវមានតួនាទីពិនិត្យកែតម្រូវលើឯកសារព្រាងដែលបានកត់ត្រារួចជាថ្មីម្តងទៀតចៀសវាងមានកំហុស និងលើសលួសសេចក្តី។ បន្ទាប់ពីក្រឡាបញ្ជីបានពិនិត្យមើលអត្ថបទយ៉ាងយកចិត្តទុកដាក់រួចរាល់ហើយ អត្ថបទនោះត្រូវបានថតចម្លង និងចងក្រងយ៉ាងស្អាតដើម្បីផ្ញើទៅជូនមេធាវី និងចៅក្រម សម្រាប់ប្រើជាឯកសារភស្តុតាងនៅក្នុងពេលជំនុំជម្រះរឿងក្តី។

## ការអប់រំ និងការបណ្តុះបណ្តាល

ក្រឡាបញ្ជីយ៉ាងហោចណាស់ត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និងទទួលបានកម្មវិធីបណ្តុះបណ្តាលពិសេសផ្នែកធ្វើរបាយការណ៍។ កម្មវិធីបណ្តុះបណ្តាលត្រូវរួមបញ្ចូលរបៀបកត់ត្រានិងវាយអត្ថបទឲ្យបានលឿន ព្រមទាំងរៀនភាសាអង់គ្លេស ពាក្យបច្ចេកទេសផ្នែកច្បាប់ និងវិជ្ជាពេទ្យផងដែរ។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ភាសាបរទេស រដ្ឋបាល និងកុំព្យូទ័រ

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្ររង ឬបរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

លេខាធិការផ្នែកច្បាប់

លេខាធិការ

អ្នកជំនាញផ្នែកកត់ត្រាអក្សរបំព្រួញ



# អ្នកមេកានិកយន្តហោះ

( Aircraft Mechanics )

**សង្ខេបអំពីជំនាញ**

**អ្នកមេកានិកយន្តហោះធ្វើការងារ៖**

- ជួសជុលឧបករណ៍ ឬបច្ចេកវិទ្យា
- ជ្រើសរើសនិងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា
- គ្រប់គ្រងពេលវេលា

G

**ជំនាញដែលត្រូវការប្រើ៖**

- ការដោះស្រាយបញ្ហា
- ការទទួលខុសត្រូវ
- ការនិយាយនិងការស្តាប់

## តើអ្នកមេកានិកយន្តហោះបំពេញកិច្ចការអ្វីខ្លះ?

អ្នកមេកានិកយន្តហោះមានភារៈជួសជុល ត្រួតពិនិត្យ និងថែទាំយន្តហោះ និងម៉ាស៊ីនគ្រប់ប្រភេទ។ អ្នកមេកានិកយន្តហោះខ្លះធ្វើការជួសជុលតែគ្រឿងម៉ាស៊ីន ខ្លះទៀតមានឯកទេសផ្នែកតួយន្តហោះលើកលែងតែគ្រឿងម៉ាស៊ីន។ អ្នកមេកានិកយន្តហោះកែសម្រួលឧបករណ៍ ពិនិត្យពិច័យ និងជួសជុលប្រព័ន្ធខ្សែភ្លើង សម្អាតអេក្រង់ ដាក់ខ្លាញ់លើផ្នែកដែលមានចលនា និងត្រួតពិនិត្យស្បែកហ្វ្រាំង។ ជាងម៉ាស៊ីនដែលធ្វើការនៅតាមអាកាសយានដ្ឋានក្នុងចន្លោះពេលពីការហោះហើរមួយទៅការហោះហើរមួយទៀតត្រូវតែមានសមត្ថភាពធ្វើការលើគ្រប់ផ្នែកទាំងអស់របស់យន្តហោះ រួមបញ្ចូលទាំងការជួសជុលជាបន្ទាន់ និងការត្រួតពិនិត្យ និងការថែរក្សាជាប្រចាំ។ ឧទាហរណ៍ ពួកគេពិនិត្យប្រេង ពិនិត្យមើលផ្ទៃខាងក្រៅរបស់យន្តហោះ សំបកកង់យន្តហោះ វិទ្យុទាក់ទង រ៉ាដា និងបរិក្ខារភ្លើង។

ជាងម៉ាស៊ីនខ្លះទៀតថែទាំទៅលើយន្តហោះទៅតាមកាលវិភាគច្បាស់លាស់នៅក្នុងមជ្ឈមណ្ឌលជួសជុលយន្តហោះធំៗដែលមានជំនាញឯកទេសផ្នែកគ្រឿងម៉ាស៊ីន ឬតួយន្តហោះ។ ពួកគេពិនិត្យគ្រឿងម៉ាស៊ីន ថែរក្សា ជួសជុល ផ្លាស់ប្តូរផ្នែកដែលប្រើប្រាស់យូរ ឬផ្នែកដែលទទួលរងការបំផ្លាញ។

## ការអប់រំ និងការបណ្តុះបណ្តាល

អ្នក មេកានិកយន្តហោះត្រូវមានឯកទេសផ្នែក គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា មេកានិកបែបស្វ័យប្រវត្តិ និងអេឡិកត្រូនិកជាដើម ។

## គួរយល់ដឹង !

- **មុខវិជ្ជាសិក្សាក្នុងសាលា:**

វិទ្យាសាស្ត្រកុំព្យូទ័រ និងការបណ្តុះបណ្តាលបច្ចេកទេស

- **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ និងការបណ្តុះបណ្តាលបច្ចេកទេស

- **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

វិស្វករអវកាស

អ្នកមេកានិកយានយន្ត

អ្នកបច្ចេកទេសខាងឥន្ធនៈ


តទៅទំព័របន្ទាប់

## អ្នកនាំពាក្យ

( Press Secretaries )

**សង្ខេបអំពីជំនាញ**

**អ្នកនាំពាក្យធ្វើការងារ៖**

- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- បំពេញការងារក្នុងភាពជាអ្នកដឹកនាំ

G

**ជំនាញដែលត្រូវការច្រើន៖**

- ការគិតប្រកបដោយភាពច្នៃប្រឌិត
- ការអាននិងសរសេរ
- ការនិយាយនិងការស្តាប់

### តើអ្នកនាំពាក្យបំពេញកិច្ចការអ្វីខ្លះ?

អ្នកនាំពាក្យគឺជាតំណាងផ្នែកផ្សព្វផ្សាយ និងព័ត៌មាន ដែលបំពេញការងារជាជំនួយការដល់អ្នកនយោបាយ និងស្ថាប័នដើម្បីផ្សព្វផ្សាយពីព័ត៌មាន សេចក្តីសម្រេច និងការឃោសនាទៅដល់មហាជននិងអ្នកគាំទ្រ។ អ្នកនយោបាយ ឬមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋាភិបាលត្រូវការអ្នកនាំពាក្យដើម្បីឆ្លើយតបនឹងសំណួររបស់អ្នកសារព័ត៌មាន រៀបចំសុន្ទរកថា និងរៀបចំសន្និសីទសារព័ត៌មានជាដើម។ ពួកគេក៏អាចធ្វើការសម្រាប់ក្រុមហ៊ុន អង្គការក្រៅរដ្ឋាភិបាល និងអង្គការមុស្សធម៌ផងដែរ។

អ្នកនាំពាក្យត្រូវសរសេរព័ត៌មានសម្រាប់ធ្វើការផ្សព្វផ្សាយសាធារណៈ និងទស្សនៈគំនិតដែលបង្ហាញពីសេចក្តីប្រឹងប្រែងរបស់មន្ត្រីរបស់រដ្ឋាភិបាលក្នុងការអនុវត្តការងារ ឬគោលនយោបាយ។ បន្ថែមលើនេះ អ្នកនាំពាក្យក៏ត្រូវរៀបចំកាលវិភាគសម្រាប់ការធ្វើសន្និសីទសារព័ត៌មាន ព្រមទាំងរៀបចំចាត់ចែងកិច្ចសម្ភាសផ្សេងៗផងដែរ។

អ្នកនាំពាក្យគឺជាបុគ្គលដែលមានសមត្ថភាពខ្ពស់ និងចំណេះដឹងជ្រៅជ្រះដែលអាចពន្យល់ បញ្ចុះបញ្ចូល និងទាញអារម្មណ៍អ្នកស្តាប់ឲ្យគាំទ្រ ស្វែងយល់ និងយល់ស្របតាមគំនិតរបស់គេ។ វិធីនៃការផ្សព្វផ្សាយត្រូវធ្វើឡើងតាមរយៈប្រព័ន្ធឃោសនាមហាជន ដូចជាសារព័ត៌មាន វិទ្យុ ទូរទស្សន៍ ជាដើម។ ក្នុងខណៈពេលមានស្ថានភាពតានតឹងផ្នែកនយោបាយ បញ្ហានៅក្នុងរដ្ឋាភិបាល ការសម្រេចចិត្តដែលមានភាពចម្រូងចម្រាស់ និងបញ្ហានយោបាយការបរទេសជាដើម អ្នកនាំពាក្យត្រូវត្រៀមខ្លួនឆ្លើយតបនឹងសំណួររបស់អ្នកសារព័ត៌មាន និងសាធារណជនដោយចៀសវាងការយល់ច្រឡំ ព្រមទាំងផ្តល់ព័ត៌មានដោយត្រឹមត្រូវនិងយ៉ាងប្រុងប្រយ័ត្នបំផុត។

ដើម្បីអាចក្លាយជាអ្នកនាំពាក្យ អ្នកត្រូវតែមានជំនាញក្នុងការរៀបចំ និងមានសមត្ថភាពក្នុងការបំពេញ ឬដោះស្រាយកិច្ចការច្រើនជំពូកក្នុងពេលតែមួយ ដូចជាការសរសេរបានលឿនអំពីការឃោសនា ការផ្សព្វផ្សាយ ការរៀបគម្រោងថវិកា និងការគ្រប់គ្រងគណនេយ្យជាដើម។ ពួកគេត្រូវមានជំនាញក្នុងការដោះស្រាយបញ្ហា និងការស្រមៃគិតអំពីបញ្ហាដែលអាចកើតមានក្រោយពេលផ្សព្វផ្សាយព័ត៌មានអ្វីមួយចេញទៅខាងក្រៅ។

### ការអប់រំ និងការបណ្តុះបណ្តាល

ពេលរៀននៅវិទ្យាល័យ គេគួរផ្តោតលើមុខវិជ្ជាមួយចំនួន ដូចជា ភាសាអង់គ្លេស អក្សរសិល្ប៍ សុន្ទរកថា ដើម្បីអភិវឌ្ឍជំនាញក្នុងការទំនាក់ទំនង។ ម្យ៉ាងទៀត គួរសិក្សាមុខវិជ្ជាផ្នែករដ្ឋបាល ប្រវត្តិសាស្ត្រ និងសង្គមដើម្បីដឹងពីរចនាសម្ព័ន្ធរបស់រដ្ឋាភិបាល។ នៅមហាវិទ្យាល័យ គេគួរពិចារណាសិក្សាលើ

មុខជំនាញមួយចំនួនដូចជា: ផ្នែកសារព័ត៌មាន វិទ្យាសាស្ត្រនយោបាយ ទីផ្សារ សេដ្ឋកិច្ច ទំនាក់ទំនងអន្តរជាតិ និងរដ្ឋបាលសាធារណៈ។ អ្នកនាំពាក្យភាគច្រើនមានសញ្ញាបត្របរិញ្ញាបត្រ ខ្លះទៀតមានសញ្ញាប័ត្របរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បណ្ឌិត និងផ្នែកច្បាប់ផងដែរ




## គួរយល់ដឹង!

✦ មុខវិជ្ជាសិក្សាក្នុងសាលា:
រដ្ឋបាលសាធារណៈ និងសារព័ត៌មានវិទ្យា
✦ កម្រិតអប់រំទាបបំផុត:
បរិញ្ញាបត្រ
✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:
មន្ត្រីការទូត
បុគ្គលិកផ្នែកយុទ្ធនាការផ្សព្វផ្សាយ
អ្នកវិទ្យាសាស្ត្រនយោបាយ
អ្នកនិយាយបញ្ចុះបញ្ចូល
អ្នកឯកទេសខាងទំនាក់ទំនងសាធារណៈ

# បុគ្គលិកផ្នែកសេវាសង្គម

( Social Workers )

**សង្ខេបអំពីជំនាញ**

**បុគ្គលិកផ្នែកសេវាសង្គមធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ ជួយកិច្ចការដល់អតិថិជន ឬភ្ញៀវ
✦ បំពេញការងារជាក្រុម

G

**ជំនាញដែលត្រូវការប្រើ៖**

✦ សច្ចៈភាព និងភាពស្មោះត្រង់
✦ ភាពរួសរាយរាក់ទាក់
✦ ការនិយាយ និងការស្តាប់

បុគ្គលិកផ្នែកសេវាសង្គមជួយប្រជាពលរដ្ឋលើបញ្ហាផ្ទាល់ខ្លួន និងបញ្ហាក្នុងសហគមន៍ដែលបណ្តាលមកពីភាពក្រីក្រ កង្វះលំនៅដ្ឋាន ភាពអត់ការងារធ្វើ ជម្ងឺតម្កាត់ បញ្ហាក្នុងគ្រួសារ ឬពិការភាពផ្នែករាងកាយជាដើម។ បុគ្គលិកផ្នែកសេវាសង្គមភាគច្រើនធ្វើការដោយជួបផ្ទាល់ជាមួយបុគ្គល ឬគ្រួសារដែលមានបញ្ហា។ អ្នកខ្លះធ្វើការនៅក្នុងសាលារៀនដើម្បីជួយសិស្សដែលមានបញ្ហាផ្នែកអាកប្បកិរិយា។ ចំណែកនៅក្នុងមន្ទីរពេទ្យពួកគេជួយអ្នកជម្ងឺ និងគ្រួសារដើម្បីសម្របខ្លួនទៅនឹងបញ្ហាដែលបណ្តាលមកពីជម្ងឺ។ ក្រៅពីនេះ ពួកគេធ្វើការនៅក្នុងតុលាការ នាយកដ្ឋានប៉ូលីស និងពន្ធនាគារដើម្បីផ្តល់ការប្រឹក្សាដល់ទណ្ឌិត ព្រមទាំងជួយគាំពារដល់អ្នកប្រព្រឹត្តិបទល្មើសដែលជាក្មេង ឬក៏ជួយផ្តល់ដំបូន្មានដល់អ្នកទោសដែលជិតផុតកំណត់ពិរុទ្ធភាព ហើយត្រូវចាកចេញពីពន្ធនាគារទៅរស់នៅជាជីវភាពធម្មតាក្នុងសង្គម។ បុគ្គលិកផ្នែកសេវាសង្គមជាច្រើន ត្រូវបានជ្រើសរើសឲ្យបម្រើការងារដោយភ្នាក់ងារផ្នែកទទួលចិញ្ចឹមកុមារកំព្រា កម្មវិធីផ្នែកទប់ស្កាត់ថ្នាំញៀន និងទីភ្នាក់ងារដែលជួយគ្រួសារដើម្បីស្វែងរក

ដំណោះស្រាយចំពោះបញ្ហាថវិកា បញ្ហាផ្លូវចិត្ត ឬបញ្ហាសុខភាព។ ពួកគេធ្វើការក្នុងមជ្ឈមណ្ឌលគាំពារជនគ្មានទីលំនៅ ស្ត្រី ឬកុមារដែលត្រូវបានគេរំលោភបំពាន និងកន្លែងថែទាំជនចាស់ជរាជាដើម។

បុគ្គលិកផ្នែកសេវាសង្គមអាចធ្វើការជាក្រុម និងត្រូវបានជួលដោយមជ្ឈមណ្ឌលសហគមន៍ ការតាំងទីលំនៅ អង្គការយុវជន ស្ថាប័នសម្រាប់កុមារ ឬជនចាស់ជរា មន្ទីរពេទ្យ ពន្ធនាគារ។ ពួកគេផ្តល់សេវាផ្នែកស្តារលទ្ធភាពពលកម្ម និងយុវនីតិសម្បទាដល់ក្រុមមនុស្សដែលជួបប្រទះពិការភាព ឬបញ្ហាប្រឈមនានា។ លើសពីនេះបុគ្គលិកផ្នែកសេវាសង្គមដែលធ្វើការឲ្យអង្គការរបស់សហគមន៍តែងព្យាយាមវិភាគអំពីបញ្ហាក្នុងសហគមន៍ទាំងមូល និងស្វែងរកវិធីដោះស្រាយចំពោះបញ្ហាទាំងនេះ ដូចជា បទល្មើសរបស់យុវវ័យ អត្រាអត់ការងារធ្វើ និងអត្រាបទល្មើសឧក្រិដ្ឋ ជាដើមដែលតម្រូវឲ្យមានកិច្ចសហការណ៍ពីសហគមន៍ទាំងមូល ដើម្បីស្វែងរកដំណោះស្រាយ។

បុគ្គលិកផ្នែកសេវាសង្គមត្រូវតែមានភាពអត់ធ្មត់ យោគយល់ និងបារម្ភពីបញ្ហារបស់ប្រជាពលរដ្ឋ ហើយត្រូវមានឥរិយាបទប្រកបដោយការយកចិត្តទុកដាក់ ទោះបីជាបញ្ហាទាំងនោះបង្កឲ្យមានការ លំបាក ឬអាចមានកំហឹងក៏ដោយ។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីរៀបចំខ្លួនក្លាយជាបុគ្គលិកផ្នែកសេវាសង្គមក្នុងពេលអនាគត អ្នកគួរតែរៀនមុខវិជ្ជាខ្លះៗនៅក្នុងវិទ្យាល័យដើម្បីបង្កើនជំនាញទំនាក់ទំនង ដូចជា ភាសាអង់គ្លេស ហាត់ធ្វើសុន្ទរកថា និងការតែងនិពន្ធ។ បន្ថែមលើនេះ មុខវិជ្ជាប្រវត្តិ-សាស្ត្រ សិក្សាសង្គម និងសង្គមវិទ្យាមានសារសំខាន់ក្នុងការយល់ដឹងអំពីចិត្តសាស្ត្រឬអារម្មណ៍ និងបញ្ហាក្នុងសង្គម។ បុគ្គលិកផ្នែកសេវាសង្គមត្រូវតែមានបរិញ្ញាប័ត្រនៅក្នុងការងារសង្គម។




## គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

សុខភាពសាធារណៈ និងចិត្តវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកប្រឹក្សាយោបល់ផ្នែកជនញៀនថ្នាំ
អ្នកប្រឹក្សាយោបល់ផ្នែកស្តារលទ្ធភាពពលកម្ម
អ្នកប្រឹក្សាយោបល់ផ្នែកបញ្ហាសង្គម
អ្នកប្រឹក្សាយោបល់ផ្នែកជម្ងឺឆ្លង

# បុគ្គលិកក្រុមហ៊ុនទេសចរណ៍

( Travel Agents )

**សង្ខេបអំពីជំនាញ**

**បុគ្គលិកក្រុមហ៊ុនទេសចរណ៍ធ្វើការងារ៖**

- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- វាយតម្លៃនិងគ្រប់គ្រងព័ត៌មាន
- ជួយកិច្ចការដល់អតិថិជន ឬភ្ញៀវ

G

**ជំនាញដែលត្រូវការប្រើ៖**

- ការអាន និងការសរសេរ
- ភាពរួសរាយរាក់ទាក់
- ការនិយាយ និងការស្តាប់

## តើបុគ្គលិកក្រុមហ៊ុនទេសចរណ៍បំពេញកិច្ចការអ្វីខ្លះ?

បុគ្គលិកក្រុមហ៊ុនទេសចរណ៍ជួយរៀបចំគម្រោងដំណើរ វិស្សមកាលរបស់អ្នកដំណើរ និងការធ្វើដំណើរក្នុងមុខជំនួញ។ ពួកគេផ្តល់ព័ត៌មានអំពីការដឹកជញ្ជូន សណ្ឋាគារ ឬម៉ូតែល និងការដើរទស្សនាកំសាន្ត។ បុគ្គលិកក្រុមហ៊ុនទេសចរណ៍ រៀបចំកក់កន្លែងទុកមុន រៀបចំសំបុត្រ និងផ្តល់ដំបូន្មានដល់អ្នកដំណើរអំពីលិខិតឆ្លងដែន និងទិដ្ឋាការ។ បុគ្គលិកក្រុមហ៊ុនទេសចរណ៍បំពេញការងារមួយផ្នែកជាអ្នកលក់ និង មួយផ្នែក ជាអ្នកផ្តល់យោបល់អំពីការធ្វើដំណើរ និងមួយផ្នែកជាអ្នកកាន់បញ្ជី។ បុគ្គលិកប្រភេទនេះ ជាបឋមនិយាយពិភាក្សាជាមួយអតិថិជនរបស់គេអំពីកន្លែង និងពេលដែលពួកគេចង់ធ្វើដំណើរ ប្រាក់ដែលពួកគេអាចចំណាយ និងរយៈពេលដែលចង់ស្នាក់នៅ។ បន្ទាប់មកគេរៀបចំគម្រោងធ្វើដំណើរដែលត្រូវតាមតំរូវការរបស់អតិថិជន។

បុគ្គលិកនេះប្រើប្រភពព័ត៌មានជាច្រើនដើម្បីស្វែងយល់ពីកាលវិភាគហោះហើររបស់ជើងយន្តហោះ កប៉ាល់ ឬរថភ្លើង។ បន្ទាប់មកស្រាវជ្រាវអំពីតម្លៃធ្វើដំណើរដ៏សមរម្យបំផុត ហើយរៀបចំបន្ទប់សណ្ឋាគារឬកក់កន្លែងទុកមុនតាមរយៈបណ្តាញព័ត៌មានដែលមានផ្ទុកក្នុងប្រព័ន្ធកុំព្យូទ័រ ឬអ៊ីនធើរណិត។ ចំពោះអ្នកមិនធ្លាប់ធ្វើដំណើរ បុគ្គលិកក្រុមហ៊ុនទេសចរណ៍អាចផ្តល់ការណែនាំអំពីវត្ថុ ឬសម្ភារដែលគួរយកទៅជាមួយក្នុងដំណើរកំសាន្ត និងអ្វីដែលរំពឹងទុកនៅពេលដែលអ្នកដំណើរទៅដល់គោលដៅ។ ពួកគេពន្យល់អំពីស្ថានភាពអាកាសធាតុនិងសំលៀកបំពាក់តាមរដូវកាល ឬបរិយាកាស។ បន្ថែមលើនេះ ពួកគេអាចពន្យល់អំពីទំនៀមទំលាប់មួយចំនួនដែលអ្នកដំណើរគួរតែដឹងនៅក្នុងប្រទេសគោលដៅ ដូចជារបៀបប្រាស្រ័យទាក់ទង បដិសណ្ឋារកិច្ច និងរបៀបស្លៀកពាក់ជាដើម។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីក្លាយជាបុគ្គលិកក្រុមហ៊ុនទេសចរណ៍ អ្នកនឹងត្រូវមានចំណេះដឹងនិងបទពិសោធន៍ល្អដូចជា ជំនាញក្នុងការប្រាស្រ័យទាក់ទង រួសរាយរាក់ទាក់ សមត្ថភាពក្នុងការសរសេរ និងនិយាយបានច្បាស់លាស់។ អ្នកត្រូវការចំណេះដឹងភាសាបរទេសដើម្បីទំនាក់ទំនងជាមួយអ្នកធ្វើដំណើរជនជាតិបរទេស ឬក៏រៀបចំកម្មវិធី និងបំពេញកិច្ចការផ្សេងៗនៅប្រទេសខាងក្រៅ។ បន្ថែមលើនេះ អ្នកត្រូវតែដឹងអំពីទីតាំងភូមិសាស្ត្រពិភពលោក ព្រមទាំងតាមដានអំពីព័ត៌មានជុំវិញពិភពលោក ដើម្បីអាចឆ្លើយតបនឹងសំណួរអំពីព្រឹត្តិការណ៍ដែលកំពុងកើតមាន ឬដឹងពីតំបន់ និងទីតាំងនានាក្នុងពិភពលោកដែលគួរចៀសវាងធ្វើដំណើរទៅទីនោះ ដោយសារបញ្ហាទាស់ទែងក្នុងប្រទេសនោះ ឬគ្រោះថ្នាក់ផ្សេងៗទៀត។

ម្យ៉ាងទៀតការសិក្សាអំពីប្រវត្តិសាស្ត្រ និងមុខវិជ្ជាផ្នែកជំនួញដែលទាក់ទង ដូចជា វិទ្យាសាស្ត្រកុំព្យូទ័រ គណិតវិទ្យា ក៏មានសារសំខាន់ផងដែរ។

មុខវិជ្ជាផ្នែកទេសចរណ៍ និងបដិសណ្ឋារកិច្ចអាចស្វែងរកសិក្សាបាននៅតាមមហាវិទ្យាល័យ និងវិទ្យាស្ថានបណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់រដ្ឋ ឬឯកជន។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
ជំនួញ វិទ្យាសាស្ត្រកុំព្យូទ័រ និងភូមិសាស្ត្រ

✦ **កម្រិតអប់រំទាបបំផុត:**
មធ្យមសិក្សាទុតិយភូមិ ឬបរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**
អ្នកគ្រប់គ្រងសណ្ឋាគារ
បុគ្គលិកផ្នែកសេវាអតិថិជនក្នុងសណ្ឋាគារ
ភ្នាក់ងារលក់ និងកក់សំបុត្រ
មគ្គុទេសក៍ទេសចរណ៍

❶ តើក្រៅពីដំណើរកំសាន្តបែបធម្មជាតិ និងវប្បធម៌..! ខាងក្រុមហ៊ុនមានរៀបចំកម្មវិធីកំសាន្តអ្វីខ្លះទៀតទេ ចា៎!!

❷ អ៊ូ! ចា៎..! មានកម្មវិធីច្រើនណាស់លោកស្រី.. ដូចជា.. ការរត់ប្រណាំងបែបកីឡាម៉ារ៉ាតុន ដើម្បីសុខភាព និងមិត្តភាព...!!




## វិស្វកររ៉ែ

( Mining Engineers )

**សង្ខេបអំពីជំនាញ**

**វិស្វកររ៉ែធ្វើការងារ៖**

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ ជ្រើសរើសនិងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា
✦ បំពេញការងារជាក្រុម

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការធ្វើសេចក្តីសម្រេចចិត្ត
✦ គណិតវិទ្យា
✦ ការអាន និងការសរសេរ

វិស្វកររ៉ែធ្វើការស្រាវជ្រាវ និងរុករកកន្លែងដែលមានកំណករ៉ែធម្មជាតិនៅក្នុងស្រទាប់ផែនដី ហើយរិះគិតអំពីវិធីដើម្បីជីក ខួង ទាញយក ឬធ្វើអាជីវកម្មលើធនធានរ៉ែទាំងនោះ។ បាតុភូតធម្មជាតិ និងការវិវត្តរបស់ផែនដីតាំងពីរាប់លានឆ្នាំកន្លងមកបានបង្កើតនូវសារធាតុរ៉ែជាច្រើនប្រភេទនៅក្នុងធម្មជាតិ ដូចជា រ៉ែលោហៈធាតុ (ដែក ស្ពាន់ មាស សំណ) ឬរ៉ែមិនមែនលោហៈ (ថ្មកំបោរ ត្បូងថ្ម ប្រេងកាត)។ អំឡុងពេលសិក្សាអំពីសមាសធាតុរ៉ែប្រភេទផ្សេងៗ វិស្វកររ៉ែត្រូវត្រួតពិនិត្យលើគំរូរបស់រ៉ែមិនទាន់កែច្នៃ ដែលបានជីកយកមកពីតំបន់ណាមួយ ដើម្បីសិក្សាពីស្ថានភាព គុណភាព បរិមាណ និងលទ្ធភាព បន្ទាប់មកទើបសម្រេចចិត្តអំពីតម្លៃក្នុងការធ្វើអាជីវកម្មលើរ៉ែនោះ និងលទ្ធផលដែលទទួលបាន។ បន្ថែមលើនេះ វិស្វករត្រូវសិក្សាវាយតម្លៃអំពីវិធីសាស្ត្រក្នុងការទាញយករ៉ែ។ រ៉ែខ្លះត្រូវបានជីកយកពីសំបកផែនដី ឬពីក្នុងដី។ រ៉ែដែលស្ថិតនៅក្នុងដីវិស្វកររ៉ែត្រូវសិក្សាលើការបោះប្រហោងដើម្បីខួងយករ៉ែ និងរូងក្រោមដី ព្រមទាំងសម្រេច



តទៅទំព័របន្ទាប់

ចិត្តអំពីបរិមាណរ៉ែដែលត្រូវទាញយកមកលើសំបកផែនដី។ វិស្វកររ៉ែត្រូវគ្រប់គ្រងរាល់ប្រតិបត្តិការនៃការជីក ឬខួងរ៉ែតាំងពីដើមដល់ទទួលបានលទ្ធផល ហើយត្រូវមានទំនួលខុសត្រូវខ្ពស់លើសុវត្ថិភាពរបស់កម្មករអណ្តូងរ៉ែ និងអ្នកដែលធ្វើការនៅទីនោះ។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីក្លាយខ្លួនជាវិស្វកររ៉ែ គេត្រូវមានកម្រិតអប់រំខ្ពស់ក្នុងមុខជំនាញមួយចំនួនដូចជាគណិតវិទ្យា គីមីវិទ្យា រូបវិទ្យា ជាដើម។ បន្ថែមលើនេះ ចំណេះដឹងភាសាបរទេសក៏មានសារប្រយោជន៍ផងដែរពីព្រោះវិស្វករអាចចេញទៅធ្វើការនៅក្រៅស្រុក។ វិស្វកររ៉ែត្រូវមានកម្រិតសញ្ញាបត្រទាបបំផុតត្រឹមបរិញ្ញាបត្រផ្នែករ៉ែ ឬអាចបន្តការសិក្សារហូតដល់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតក៏បាន។

## គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

វិទ្យាសាស្ត្រផែនដី គណិតវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

វិស្វករគីមី

អ្នកភូគព្ភសាស្ត្រ

វិស្វករប្រេងកាត

# អ្នកអធិប្បាយកម្មវិធីតន្ត្រី

( Disk Jockeys )

**សង្ខេបអំពីជំនាញ**

**អ្នកអធិប្បាយកម្មវិធីតន្ត្រីធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ ជ្រើសរើសនិងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

✦ បំពេញការងារជាក្រុម

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការដោះស្រាយបញ្ហា

✦ ការទទួលខុសត្រូវ

✦ ការនិយាយនិងការស្តាប់

## តើអ្នកអធិប្បាយកម្មវិធីតន្ត្រីបំពេញកិច្ចការអ្វីខ្លះ?

អ្នកអធិប្បាយកម្មវិធីតន្ត្រី (DJ) បំពេញការងារជាអ្នកចាក់តន្ត្រីនៅក្នុងវិទ្យុ ឬក្នុងពេលជប់លៀង ការរាំរែក និងក្នុងឱកាសពិសេសផ្សេងៗ។ នៅក្នុងវិទ្យុពួកគេប្រកាសពីពេលវេលា ព្យាករណ៍អាកាសធាតុ និងព័ត៌មានសំខាន់ៗ។ ជូនកាល ពួកគេធ្វើការសម្ភាសភ្ញៀវកិត្តិយស និងផ្សព្វផ្សាយពីសេវាកម្មសាធារណៈ។ អ្នកអធិប្បាយកម្មវិធីតន្ត្រីភាគច្រើនមិនអានតាមអត្ថបទដែលបានសរសេរទុកជាមុនទេ ប៉ុន្តែបរិយាយឬផ្សាយដំណឹងតាមការនិយាយផ្ទាល់មាត់ភ្លាមៗតែម្តង។ ដូច្នេះគំនិត និងយោបល់របស់ពួកគេតែងនឹកឃើញឬកើតឡើងដោយពុំបានគ្រោងទុកជាមុន លើកលែងតែពេលអានអក្សរផ្សាយពាណិជ្ជកម្ម។ បន្ថែមលើនេះ ពួកគេចាក់បទចំរៀងជ្រើសរើស ជាហូរហែរ ហើយតែងបន្ថយសំឡេង

ចម្រៀង ឬតន្ត្រីនៅពេលចង់ប្រើប្រាស់ពេលនោះសម្រាប់ផ្សព្វផ្សាយព័ត៌មាន ឬពាណិជ្ជកម្ម ព័ត៌មានអំពីចរាចរ និងសេចក្តីរាយការណ៍អំពីអាកាសធាតុជាដើម។

អាស្រ័យដោយកម្មវិធីវិទ្យុភាគច្រើនជាកម្មវិធីផ្សាយបន្តផ្ទាល់ ដូច្នេះអាចមានរឿងជាច្រើនកើតមានឡើងនៅពេលកំពុងផ្សព្វផ្សាយ ដែលតម្រូវឲ្យអ្នកអធិប្បាយកម្មវិធី បញ្ចេញនូវប្រតិកម្មតាមបែបស្ងប់ស្ងាត់ អត់ធ្មត់ទៅនឹងសម្ពាធ ព្រមទាំងត្រូវដឹងពីរបៀបគ្រប់គ្រងស្ថានការណ៍ដែលមិនបានរំពឹងទុក។ បន្ថែមលើនេះ អ្នកអធិប្បាយកម្មវិធីតន្ត្រីត្រូវរក្សាជាប់ជានិច្ចនូវភាពរួសរាយរាក់ទាក់ ប្រកបដោយសម្តីសុភាពរាបសារ និងទេពកោសល្យខ្ពស់ក្នុងការធ្វើកម្មវិធីមានភាពរស់រវើកនិងអ្នកស្តាប់មានក្តីរីករាយក្នុងចិត្ត។ អ្នកអធិប្បាយកម្មវិធីតន្ត្រីមិនមានម៉ោងពេលទៀងទាត់នោះទេ ហើយច្រើនតែធ្វើការម្នាក់ឯងទោះនៅវេនយប់ ឬថ្ងៃ។

## ការអប់រំ និងការបណ្តុះបណ្តាល

មិនមានការអប់រំតាមកម្មវិធីផ្លូវការសម្រាប់អ្នកអធិប្បាយកម្មវិធីតន្ត្រីនោះទេ។ ទោះជាយ៉ាងណាក៏ដោយស្ថានីយ៍វិទ្យុធំៗច្រើនជ្រើសរើសអ្នកដែលមានការអប់រំពីមហាវិទ្យាល័យ។ បន្ថែមលើនេះ សាលាបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈខ្លះក៏មានកម្មវិធីបណ្តុះបណ្តាលសិស្សលើជំនាញនេះផងដែរ។ បើអ្នកមានចំណាប់អារម្មណ៍ចង់ក្លាយជាអ្នកអធិប្បាយកម្មវិធីតន្ត្រីហើយបន្តទៅមុខតំណែងផ្សព្វផ្សាយផ្សេងៗទៀត អ្នកគួរតែចូលរៀននៅសាលាបណ្តុះបណ្តាលផ្នែកព័ត៌មាន ការផ្សព្វផ្សាយ និងការអធិប្បាយ។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
ភាសាអង់គ្លេស ការនិយាយ ឬធ្វើសុន្ទរកថា
✦ **កម្រិតអប់រំទាបបំផុត:**
បរិញ្ញាបត្ររង ឬបរិញ្ញាបត្រ
✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**
សិល្បករ
វិស្វករផ្នែកការផ្សាយតាមរលកធាតុអាកាស
ពិធីករវិទ្យុ និងទូរទស្សន៍
អ្នកផលិតកម្មវិធីវិទ្យុ

## អ្នកបកប្រែភាសា

(Interpreters)

**សង្ខេបអំពីជំនាញ**

**អ្នកបកប្រែភាសាធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការដោះស្រាយបញ្ហា
✦ ការអាន និងសរសេរ
✦ ការនិយាយ និងការស្តាប់

## តើអ្នកបកប្រែភាសាបំពេញកិច្ចការអ្វីខ្លះ?

អ្នកបកប្រែ ត្រូវស្តាប់មនុស្សម្នាក់ដែលកំពុងនិយាយភាសាមួយ បន្ទាប់មកបកប្រែសម្តីដូចគ្នានោះទៅជាភាសាមួយផ្សេងទៀត ឧទាហរណ៍ អ្នកបកប្រែភាសាពីអង់គ្លេសមកជាភាសាខ្មែរ។ ការងារជាអ្នកបកប្រែអាចធ្វើនៅក្នុងស្ថាប័ន ឬក្រុមហ៊ុនដែលបុគ្គលិក និងអតិថិជនជាមនុស្សនិយាយភាសាផ្សេងពីគ្នា។ នៅអង្គការសហប្រជាជាតិ ដែលជាអង្គការដែលមានមនុស្សនិយាយភាសាខុសៗគ្នា ដើម្បីយល់ពីភាសាមួយទៅភាសាមួយទៀត នៅក្នុងកិច្ចប្រជុំធំៗតែងមានអ្នកបកប្រែភាសាច្រើនរូបត្រៀមចាំបំពេញកិច្ចការនេះ។ អ្នកបកប្រែខ្លះមាន ភារៈ បកប្រែសុន្ទរកថានៅក្នុងសន្និសីទអន្តរជាតិផ្សេងៗផងដែរ។ អ្នកបកប្រែខ្លះត្រូវតែបកប្រែនូវពាក្យសម្តីរបស់វាគ្មិនភ្លាមៗទៅតាមអ្វីដែលបានឮ ករណីនេះច្រើនហៅថាការបកប្រែប្រដេញ មានន័យថា បកប្រែប្រកៀកប្រកើយគ្នាជាមួយសម្តីដើម។ អ្នកបកប្រែប្រភេទនេះ ច្រើនធ្វើការនៅក្នុងបន្ទប់បិទជិត ឬបន្ទប់ដាច់ដោយឡែក ដោយស្តាប់សម្តីដើមរបស់វាគ្មិនតាមឧបករណ៍ស្តាប់សំឡេងនៅនឹងត្រចៀក បន្ទាប់មកនិយាយជាភាសាមួយទៀតតាមមីក្រូសម្រាប់ឲ្យអ្នកដទៃស្តាប់ឮ។ អ្នកបកប្រែត្រូវមានភាពវាងវៃ និងគិតបានយ៉ាងរហ័សរហួន តាមរយៈការផ្ចង់ស្មារតីស្តាប់ដើម្បីបកប្រែពាក្យសម្តីរបស់វាគ្មិនឲ្យបានត្រឹមត្រូវពិតប្រាកដ។

អ្នកបកប្រែ ក៏ច្រើនឃើញមានបំពេញការងារនៅក្នុងរដ្ឋាភិបាល និងស្ថានទូតបរទេសផងដែរ។ ក្រៅពីនេះមានធ្វើការក្នុងធនាគារ និងជំនួញដែលមានសាខានៅបរទេស ឬអាចត្រូវបានជួលឲ្យធ្វើជាអ្នកបកប្រែ និងនាំផ្លូវក្នុងការទេសចរណ៍ទៅបរទេស ដើម្បីសម្រួលដល់ការធ្វើដំណើរ ការប្រជុំ ការកុម្ម៉ង់ម្ហូបនៅភោជនីយដ្ឋាន និងកន្លែងផ្សេងទៀត។ អ្នកបកប្រែដើរតាមភ្ញៀវ ជាទូទៅមិនបកប្រែប្រដេញភ្លាមៗនោះទេ ពួកគេស្តាប់ភ្ញៀវនិយាយដល់ចប់មួយវគ្គទើបបកប្រែម្តង វិធីនេះច្រើនហៅថាការបកប្រែបណ្តាក់។ ចំណែក អ្នកបកប្រែខ្លះទៀតបកឯកសារ ដូចជាប្រលោមលោក របាយការណ៍ និងឯកសារច្បាប់ផ្សេងៗ។ អ្នកបកប្រែខ្លះ ធ្វើការឲ្យរដ្ឋាភិបាល និងស្ថាប័នបោះពុម្ព ការិយាល័យច្បាប់ កាសែត និងអង្គការអន្តរជាតិ។




## ការអប់រំ និងការបណ្តុះបណ្តាល

អ្នកបកប្រែត្រូវតែចេះភាសាពីរយ៉ាងតិចឲ្យបានច្បាស់លាស់។ បន្ថែមលើនេះ ពួកគេក៏ត្រូវមានចំណេះដឹងអំពីភូមិសាស្ត្រ វប្បធម៌ និងប្រវត្តិសាស្ត្រនៃប្រទេសដែលត្រូវបកប្រែភាសាទាំងនោះ។ ប្រសិនគេមានបំណងក្លាយជាអ្នកបកប្រែភាសា គួរចាប់ផ្តើមសង្វាតរៀនសូត្រមុខវិជ្ជាភាសាបរទេសតាំងពីនៅវិទ្យាល័យ ដូចជាភាសាអង់គ្លេស និងភាសាបារាំងជាដើម។

ចំណែកមុខវិជ្ជាសំខាន់បន្ថែមទៀតមានដូចជា ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ វិទ្យាសាស្ត្រនយោបាយ និងការប្រើកុំព្យូទ័រក៏

 តទៅទំព័របន្ទាប់

## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

ភាសាបរទេស: អង់គ្លេស បារាំង ជប៉ុន ចិន កូរ៉េ...

✦ កម្រិតអប់រំទាបបំផុត:

បរិញ្ញាបត្រ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

អ្នកប្រឹក្សាយោបល់ផ្នែកវប្បធម៌

មន្ត្រីផ្នែកផ្តល់សេវាអន្តរជាតិ

អ្នកភាសាវិទ្យា

អ្នករាយការណ៍ព័ត៌មាន

អ្នកបកប្រែភាសាដោយកាយវិការ

# អ្នកឯកទេសខាងទំនាក់ទំនងផ្សព្វផ្សាយ

(Media Relation Specialists)

**សង្ខេបអំពីជំនាញ**

**អ្នកឯកទេសខាងទំនាក់ទំនងផ្សព្វផ្សាយធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ ជួយកិច្ចការដល់អតិថិជន ឬភ្ញៀវ

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត

✦ ការអាន និងការសរសេរ

✦ ការនិយាយ និងការស្តាប់

## តើអ្នកឯកទេសខាងទំនាក់ទំនងផ្សព្វផ្សាយបំពេញកិច្ចការអ្វីខ្លះ?

អ្នកឯកទេសខាងទំនាក់ទំនងផ្សព្វផ្សាយត្រូវរចនារូបភាពដែលមានខ្លឹមសារក្នុងប្រព័ន្ធផ្សព្វផ្សាយសម្រាប់ក្រុមហ៊ុន អង្គការ ឬក៏ឯកជនដែលមានតម្រូវការតាមផ្នែកឬវិស័យ។ ពួកគេមានជំនាញពាក់ព័ន្ធប្រព័ន្ធផ្សព្វផ្សាយច្រើនប្រភេទ ដូចជាទូរទស្សន៍ វិទ្យុ និងសារព័ត៌មាន។ ពួកគេបំពេញការងារជាអ្នកតំណាងរវាងបុគ្គល ក្រុមហ៊ុន និងប្រព័ន្ធផ្សព្វផ្សាយរួមមានកាសែត ទស្សនាវដ្តី និងអ្នកត្រួតពិនិត្យកែសំរួលព័ត៌មានផ្សាយតាមវិទ្យុ ឬទូរទស្សន៍ និងជាអ្នករាយការណ៍។ អ្នកឯកទេសខាងទំនាក់ទំនងផ្សព្វផ្សាយគ្រប់គ្រងប្រព័ន្ធទំនាក់ទំនងនេះតាមរយៈការសរសេរ និងផ្ញើអត្ថបទប្រកាសព័ត៌មាន និងការផ្សព្វផ្សាយផ្សេងទៀតទៅកាន់ប្រព័ន្ធផ្សព្វផ្សាយ។

អ្នកឯកទេសខាងទំនាក់ទំនងផ្សព្វផ្សាយរៀបចំរូបភាព និងអត្ថបទនិពន្ធសម្រាប់ផ្សព្វផ្សាយដោយគំនិតច្នៃប្រឌិត និងបែបសិល្បៈទាក់ទាញអារម្មណ៍មហាជន។ អ្នកឯកទេសផ្នែកនេះត្រូវមានទំនាក់ទំនង ព្រមទាំងធ្វើការជិតស្និទ្ធជាមួយអ្នកយកព័ត៌មាន និងអ្នកត្រួតពិនិត្យការផ្សព្វផ្សាយ។ គួរកត់សម្គាល់ថា សារព័ត៌មាន និងសារអេឡិកត្រូនិកត្រូវបានផ្សព្វផ្សាយក្នុងចំនួនដ៏ច្រើនជារៀងរាល់ថ្ងៃ។ ករណីនេះ អ្នកឯកទេសខាងទំនាក់ទំនងផ្សព្វផ្សាយត្រូវដឹងពីពេលវេលាឱកាស និងដើមរឿងព័ត៌មានដែលមានតំលៃ ដើម្បីចាក់ផ្សាយប្រកប ដោយខ្លឹមសារសង្ខេប ងាយយល់ និងមានភាពរស់រវើក។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីទទួលបានជោគជ័យក្នុងអាជីពនេះ គេគួរផ្តោតអារម្មណ៍លើការសរសេរ និងការនិយាយជាសាធារណៈ។ ពេលសិក្សានៅវិទ្យាល័យ អ្នកត្រូវរៀនមុខវិជ្ជាភាសាបរទេស



តទៅទំព័របន្ទាប់

(ឧទា. អង់គ្លេស) សារព័ត៌មាន និងរបៀបថ្លៃងសុន្ទរកថា។ បន្ថែមលើនេះ មុខវិជ្ជាវិទ្យាសាស្ត្រកុំព្យូទ័រ ជំនួញ ប្រវត្តិសាស្ត្រ និងសង្គមវិជ្ជា ក៏មានសារសំខាន់ណាស់ដែរសម្រាប់សម្រួចចំណេះដឹងទៅចាប់យកអាជីពនេះ។

នៅឧត្តមសិក្សា អ្នកត្រូវមានបរិញ្ញាបត្រផ្នែកទំនាក់ទំនង សារព័ត៌មាន ឬទំនាក់ទំនងសាធារណៈ។ អ្នកខ្លះអាចបន្តការសិក្សាដល់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ផងក៏មានដើម្បីទទួលបានឱកាសកាន់តែទូលាយក្នុងការស្វែងរកការងារធ្វើ។

## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ជំនួញ និងសារព័ត៌មាន

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្ដីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកគ្រប់គ្រងការផ្សាយពាណិជ្ជកម្ម

បុគ្គលិកផ្នែកផ្សព្វផ្សាយការលក់

អ្នកឯកទេសខាងទំនាក់ទំនងសាធារណៈ

អ្នករាយការណ៍ព័ត៌មាន និងអ្នកនិពន្ធ

# អ្នករចនាកម្មវិធីក្រាហ្វិកកុំព្យូទ័រ

(Graphic Programmers)

សង្ខេបអំពីជំនាញ

អ្នករចនាកម្មវិធីក្រាហ្វិកកុំព្យូទ័រធ្វើការងារៈ

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ វាយតម្លៃនិងគ្រប់គ្រងព័ត៌មាន

✦ ជួយកិច្ចការដល់អតិថិជន ឬភ្ញៀវ

G

ជំនាញដែលត្រូវការច្រើនៈ

✦ ការអាន និងការសរសេរ

✦ ភាពរួសរាយរាក់ទាក់

✦ ការនិយាយ និងការស្ដាប់

## តើអ្នករចនាកម្មវិធីក្រាហ្វិកកុំព្យូទ័របំពេញកិច្ចការអ្វីខ្លះ?

អ្នករចនាកម្មវិធីក្រាហ្វិកកុំព្យូទ័របង្កើតកម្មវិធីដែលអាចឲ្យកុំព្យូទ័រមានដំណើរការ និងធ្វើកិច្ចការបានច្រើនមុខតាមការបញ្ជា ឧទាហរណ៍ កម្មវិធីរចនារូបភាព ការរៀបចំសៀវភៅទស្សនាវដ្ដី កម្មវិធីទូរទស្សន៍ ការផ្សព្វផ្សាយ និងគេហទំព័រ ជាដើម។ អ្នករចនាកម្មវិធីក្រាហ្វីកសរសេរកម្មវិធីផ្នែកទន់របស់កុំព្យូទ័រដែលអនុញ្ញាតឲ្យកុំព្យូទ័របង្កើតកម្មវិធីរចនា និងបង្ហាញ

❶ និយាយអ៊ីចឹង..! ខ្ញុំទើបតែដឹងថាថ្មីៗនេះឯងបានសរសេរកម្មវិធីកុំព្យូទ័រ ដែលអាចប្រកាសអាសន្នអំពី អគ្គិ



រូបភាព។ ដើម្បីសរសេរកម្មវិធីមួយ អ្នកឯកទេសផ្នែកនេះត្រូវចេះភាសាកុំព្យូទ័រ ឬកូដនៅក្នុងប្រព័ន្ធ។តាមរយៈការប្រើភាសា ឬកូដនេះអាចឲ្យអ្នកបច្ចេកទេសរចនាសមាសធាតុជាច្រើនដូចជា អក្សរ ពណ៌ ពន្លឺ ស្រមោល និងរូបជីវចល។ បច្ចេកទេសបែបនេះក៏ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ផងដែរក្នុងកិច្ចការស្រាវជ្រាវជាច្រើន ដូចជាផ្នែកវេជ្ជសាស្ត្រ ផែនទី ភូមិសាស្ត្រ ភាពយន្ត និងវិទ្យាសាស្ត្រ ឬបច្ចេកវិទ្យាជាច្រើនទៀត។ អ្នករចនាកម្មវិធីក្រាហ្វិកត្រូវពិនិត្យលើកិច្ចការ និងគោលបំណងដែលរូបភាព ឬក្រាហ្វិកនឹងត្រូវបង្ហាញ ឧទាហរណ៍ ការរចនារូបគំនូរក្រាហ្វិកសម្រាប់បង្ហាញពីរាងកាយ និងសរីរៈរបស់មនុស្សសម្រាប់បង្រៀននិស្សិតផ្នែកវេជ្ជសាស្ត្រ ត្រូវរំលេចនូវរូបភាពលម្អិតរបស់រាងកាយទាំងឆ្អឹង សាច់ សរសៃ ស្បែក និងប្រព័ន្ធដំណើរការនៃសរីរៈរបស់មនុស្ស។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីក្លាយជាអ្នកបច្ចេកទេសផ្នែករចនាកម្មវិធីក្រាហ្វិក អ្នកត្រូវសិក្សាជំនាញវិទ្យាសាស្ត្រកុំព្យូទ័រកម្រិតឧត្តមសិក្សា។ ប៉ុន្តែអ្នកគួរចាប់អារម្មណ៍រៀនជំនាញ ឬមុខវិជ្ជាខ្លះៗតាំងពីនៅវិទ្យាល័យ ដូចជាកុំព្យូទ័រ ភាសាបរទេស គណិតវិទ្យា វិទ្យាសាស្ត្រ។ បន្ថែមលើនេះ សិល្បៈផ្នែកគំនូរ និងការរចនាក៏អាចជួយបង្កើនសមត្ថភាពក្នុងការរៀបចំផ្គុំរូបភាព សមាមាត្រ ចក្ខុទស្សន៍ និងផ្នែកផ្សេងៗទៀតនៃសិល្បៈ។ ចំណែកនៅឧត្តមសិក្សា អ្នកគួរផ្តោតលើមុខវិជ្ជាកុំព្យូទ័រទូទៅ រួមទាំងមុខវិជ្ជាក្រាហ្វិកផងដែរ។

## គួរយល់ដឹង!

✦ មុខវិជ្ជាសិក្សាក្នុងសាលា៖

សិល្បៈ និងវិទ្យាសាស្ត្រកុំព្យូទ័រ

✦ កម្រិតអប់រំទាបបំផុត៖

បរិញ្ញាបត្រ

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា៖

អ្នកបច្ចេកទេសខាងរចនារូបភាព

អ្នករចនាគេហទំព័រអ៊ីនធើណេត

អ្នកបង្កើតកម្មវិធីផ្នែកទន់របស់កុំព្យូទ័រ

## អ្នកគ្រប់គ្រងសណ្ឋាគារ និងម៉ូតែល

( Hotel and Motel Managers )

**សង្ខេបអំពីជំនាញ**

**អ្នកគ្រប់គ្រងសណ្ឋាគារ និងម៉ូតែលធ្វើការងារ៖**

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

✦ គ្រប់គ្រងបុគ្គលិក ឬមនុស្ស

✦ បំពេញការងារជាក្រុម

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការដោះស្រាយបញ្ហា

✦ ការទទួលខុសត្រូវ

✦ ការនិយាយ និងការស្តាប់

## តើអ្នកគ្រប់គ្រងសណ្ឋាគារបំពេញកិច្ចការអ្វីខ្លះ?

អ្នកគ្រប់គ្រងសណ្ឋាគារ និងម៉ូតែលផ្តល់សេវាកម្មផ្នែកបន្ទប់ អាហារ ការកំសាន្ត និងសេវាកម្មផ្សេងៗទៀតដល់អ្នកដំណើរ ឬភ្ញៀវ។ ពួកគេគ្រប់គ្រងរាល់សកម្មភាពនៅក្នុងសណ្ឋាគារ និងម៉ូតែល រួមទាំងគ្រប់គ្រងបុគ្គលិក និងការផ្តល់សេវាកម្មជូនភ្ញៀវ។ បុគ្គលិកសណ្ឋាគារគ្រប់ផ្នែកទាំងអស់មានទំនួលខុសត្រូវក្នុងការបម្រើសេវា និងការមើលការថែរក្សាដល់ភ្ញៀវទាំងអស់ ឲ្យទទួលបានការស្នាក់ប្រកបដោយផាសុខភាព សុវត្ថិភាព និងសប្បាយរីករាយ ដើម្បីបញ្ជាក់ពីភាពជោគជ័យក្នុងការផ្តល់សេវកម្ម។

នៅក្នុងសណ្ឋាគារខ្នាតតូច អ្នកគ្រប់គ្រងអាចជាម្ចាស់ផ្ទាល់ក៏មាន ហើយទទួលខុសត្រូវទាំងស្រុងទៅលើមុខជំនួញ។ ទំនួលខុសត្រូវរបស់អ្នកគ្រប់គ្រងរួមមាន គ្រប់គ្រងកន្លែងទទួលភ្ញៀវ ធ្វើគាវកិច្ច រៀបចំចាត់ចែងបន្ទប់ ត្រួតពិនិត្យបុគ្គលិក និងផ្តល់នូវគ្រប់សេវាទាំងអស់។ អាស្រ័យដោយកិច្ចការមមាញឹក អ្នកគ្រប់គ្រងសណ្ឋាគារអាចស្នាក់នៅ និងហូបចុកក្នុងសណ្ឋាគារផ្នែកបន្ទប់បុគ្គលិកដើម្បីឆ្លើយតបកិច្ចការឲ្យបានទាន់ពេលវេលា។ ចំណែក សណ្ឋាគារខ្នាតធំ តែងមានម្ចាស់ដាច់ដោយឡែក និងធ្វើប្រត្តិបត្តការជាដៃគូជាមួយម្ចាស់ហ៊ុនជាច្រើន។ ហេតុនេះ ពួកគេបែងចែកកាតព្វកិច្ច នៅក្នុងដំណើរការសណ្ឋាគារ ដោយមានអ្នកគ្រប់គ្រងតាមផ្នែកផ្សេងៗ។

អ្នកគ្រប់គ្រងកន្លែងតុទទួលភ្ញៀវ ធ្វើការស្វាគមន៍ដល់ភ្ញៀវកក់បន្ទប់ និងផ្តល់ការបម្រើតាមការស្នើសុំរបស់អតិថិជន ឬការតវ៉ាបន្ទោសផ្សេងៗ។ អ្នកគ្រប់គ្រងផ្នែកអាហារមានភារៈពិនិត្យមើលគម្រោងរៀបចំម្ហូប ការទិញឥវ៉ាន់ ការបំរើម្ហូបអាហារ និងភេសជ្ជៈនៅក្នុងភោជនីយដ្ឋាន។ ចំណែកអ្នកគ្រប់គ្រងផ្នែកបន្ទប់វិញទទួលខុសត្រូវក្នុងការត្រួតពិនិត្យអ្នករៀបចំបន្ទប់ និងបំរើសេវាបោកគក់។ អ្នកគ្រប់គ្រងផ្សេងៗទៀតអាចទទួលខុសត្រូវចំពោះទីកន្លែងកំសាន្ត ដូចជាអាងហែលទឹក ឬសាលប្រជុំ ជាដើម។




## ការអប់រំ និងការបណ្តុះបណ្តាល

ត្រូវ រៀនមុខវិជ្ជាជំនួញ គណិតវិទ្យា ភាសាអង់គ្លេស និងការថ្លៃងសុន្ទរកថានៅវិទ្យាល័យ។ បន្ថែមលើនេះ ត្រូវមានចំណេះផ្នែកភាសាបរទេសផ្សេងៗដូចជា អង់គ្លេស បារាំង ចិន កូរ៉េ និងជប៉ុន ជាដើម។

ជាទូទៅ ការកាន់មុខតំណែងខុសៗគ្នាក្នុងសណ្ឋាគារតម្រូវឲ្យមានការបណ្តុះបណ្តាល និងត្រៀមលក្ខណ:ចូលបម្រើការងារខុសៗគ្នា។ ចំណេះដឹង ឬវិជ្ជាជីវ:កាន់តែមានតម្រូវការខ្លាំងកាលណាមុខតំណែងកាន់តែស្មុគស្មាញ និងសំខាន់។ ក្រៅពីនេះ បទពិសោធន៍ការងារផ្នែកសណ្ឋាគារនិងបដិសណ្ឋារកិច្ចនៅកន្លែងផ្សេងៗក៏មានតម្លៃបំផុតសម្រាប់ឱកាសការងារនេះ។

## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

ជំនួញ និងគណិតវិទ្យា

✦ កម្រិតអប់រំទាបបំផុត:

បរិញ្ញាបត្រ ឬបរិញ្ញាបត្ររង

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

ស្មៀន

អ្នកចម្អិនអាហារ

អ្នកបម្រើអាហារ

ភ្នាក់ងារទេសចរណ៍

## មេធាវីកម្មសិទ្ធិបញ្ញា

( Intellectual Property Lawyers )

**សង្ខេបអំពីជំនាញ**

**មេធាវីកម្មសិទ្ធិបញ្ញាធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត

✦ ការអាន និងការសរសេរ

✦ ការនិយាយនិងការស្តាប់

## តើមេធាវីកម្មសិទ្ធិបញ្ញាបំពេញកិច្ចការអ្វីខ្លះ?

មេធាវីខាងកម្មសិទ្ធិបញ្ញាជួយការពារគំនិត និងទ្រព្យសម្បត្តិដែលពាក់ព័ន្ធកម្មសិទ្ធិឯកជននៃការច្នៃបង្កើត របកគំហើញថ្មីរបស់បុគ្គល ឬក្រុមណាមួយ ដែលច្បាប់កំណត់ថាជាកម្មសិទ្ធិបញ្ញា។ មេធាវីផ្នែកនេះយកចិត្តទុកដាក់ការពារកម្មសិទ្ធិដែលអតិថិជនរបស់គេបាននិពន្ធ ឬផលិតដូចជា តន្ត្រី កម្មវិធីកុំព្យូទ័រតាមរយៈការការពារសិទ្ធិផ្តាច់មុខ ឬការពារស្លាកសញ្ញាពាណិជ្ជកម្ម ដែលបង្ហាញពីសមត្ថភាព ការព្យាយាម ជំនាញនិងការបង្កើតរបស់អតិថិជនដែលដាក់ពាក្យបណ្តឹង។ បន្ថែមលើនេះ មេធាវីខាងកម្មសិទ្ធិបញ្ញាធ្វើការជាមួយក្រុមហ៊ុនដើម្បីលាក់ការណ៍ជំនួញរបស់ក្រុមហ៊ុន។

ពួកគេជួយការពារគំនិត និងការបង្កើតថ្មីរបស់បុគ្គល ឬក្រុមហ៊ុន ដូចជាគេហទំព័រអ៊ីនធើណិត និងរបកគំហើញវិទ្យាសាស្ត្រផ្សេងទៀត។ កិច្ចការសំខាន់ម្យ៉ាងទៀតរបស់មេធាវី គឺផ្តល់ការប្រឹក្សាយោបល់ដល់អតិថិជន ក្នុងការពន្យល់ឲ្យយល់អំពីកម្មសិទ្ធិបញ្ញា លទ្ធភាពបានទទួលបានសិទ្ធិផ្តាច់មុខឬបណ្ណប៉ាតង់ ស្លាកសញ្ញាពាណិជ្ជកម្ម ឬរក្សាសិទ្ធិការលួចចម្លងផលិតផល និងរបកគំហើញ។ ជាពិសេសគឺផ្តល់យោបល់ដល់អតិថិជនពីវិធីដ៏ល្អបំផុតដើម្បីការពារទ្រព្យសម្បត្តិរបស់ពួកគេ។ មេធាវីខាងកម្មសិទ្ធិបញ្ញាក៏រៀបចំឯកសារ ឬសេចក្តីព្រាងច្បាប់ផ្សេងៗដែរ ដូចជាឯកសារក្នុងការទទួលបានសិទ្ធិផ្តាច់មុខ និងការព្រមព្រៀងផ្តល់អាជ្ញាប័ណ្ណបន្ទាប់មកពួកគេធ្វើអាជ្ញាប័ណ្ណ និងឯកសារចាំបាច់ផ្សេងៗទៀតដើម្បីទទួលបានសិទ្ធិផ្តាច់មុខ និងដាក់ស្លាកសញ្ញាពាណិជ្ជកម្ម។

មេធាវីខាងកម្មសិទ្ធិបញ្ញា ក៏ជាអ្នកតំណាងឲ្យអតិថិជនរបស់គេចំពោះមុខស្ថាប័នផ្នែករដ្ឋបាល និងតុលាការផងដែរ។


តទៅទំព័របន្ទាប់

ពួកគេ តស៊ូមតិជំនួសអតិថិជនរបស់គេចំពោះការការពារក្តី និងការពារសិទ្ធិ។ ករណី អតិថិជនរបស់គេត្រូវបានចោទប្រកាន់ពីបទបំពានទៅលើកម្មសិទ្ធិបញ្ញារបស់អ្នកដទៃ មេធាវីក៏មានតួនាទីក្នុងការការពារអតិថិជនរបស់ពួកគេពីការចោទប្រកាន់នោះផងដែរ។

មេធាវីខាងកម្មសិទ្ធិបញ្ញាអាចជួយអតិថិជនរបស់ពួកគេឲ្យជ្រើសរើសឈ្មោះសម្រាប់ក្រុមហ៊ុននៅក្នុងប្រព័ន្ធអ៊ីនធើរណិត ឬស្លាកសញ្ញាពាណិជ្ជកម្ម។ ជួនកាល ពួកគេត្រូវបានស្នើសុំឲ្យទៅពិនិត្យមើលឯកសារចម្លងសម្រាប់ការផ្សព្វផ្សាយពាណិជ្ជកម្ម ការចេញសេចក្តីប្រកាសព័ត៌មាន និងឯកសារផ្លូវការណ៍ផ្សេងទៀតដើម្បីធានាថាគ្មានបញ្ហាប៉ះពាល់ចំពោះច្បាប់នៃកម្មសិទ្ធិបញ្ញា។ មេធាវីខាងកម្មសិទ្ធិបញ្ញាធ្វើការជាមួយអតិថិជនផ្សេងៗគ្នាជាច្រើន ចាប់ពីអ្នកវិនិយោគទុនម្នាក់ៗ រហូតដល់អ្នកគ្រប់គ្រងកម្រិតខ្ពស់ៗនៃសាជីវកម្មធំៗ។ មេធាវីខាងកម្មសិទ្ធិបញ្ញាដែលធ្វើការឲ្យក្រុមហ៊ុន ឬសាជីវកម្ម ជាទូទៅបំពេញកិច្ចការពីផ្ទះ ក្នុងការពិនិត្យលើសេចក្តីសម្រេចនានាដែលអាចប៉ះពាក់ដល់ការប្រើប្រាស់កម្មសិទ្ធិបញ្ញានៅក្នុងក្រុមហ៊ុន។

❶សូមទោស.. លោកចៅក្រម.. ខ្ញុំបាទសូមជំទាស់ទៅនឹងការបកស្រាយនេះ..!!




មេធាវីខាងកម្មសិទ្ធិបញ្ញានៅសាកលវិទ្យាល័យមានភារៈជួយអ្នកវិទ្យាសាស្ត្រ និងអ្នកស្រាវជ្រាវដោយធ្វើអត្តសញ្ញាណកម្មផលិតផល និងច្នៃបង្កើតនានាដែលមានសក្តានុពលនៅលើទីផ្សារ។

## ការអប់រំ និងការបណ្តុះបណ្តាល

ចំណេះដឹងផ្នែកវិទ្យាសាស្ត្រ ការអប់រំ ឬអក្សរសាស្ត្រ គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់អាជីពនេះ។ បន្ថែមលើនេះ មុខវិជ្ជាផ្នែកគណនេយ្យ ជំនួញ វិទ្យាសាស្ត្រកុំព្យូទ័រ ភាសាអង់គ្លេស រដ្ឋបាល វិទ្យាសាស្ត្រធម្មជាតិ និងការសរសេរ។ អាជីពនេះ តម្រូវឲ្យមានការអប់រំទាបបំផុតត្រឹមបរិញ្ញាប័ត្រច្បាប់ វិស្វកម្ម រូបវិទ្យា ឬវិទ្យាសាស្ត្រជាដើម។

## គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ភាសាបរទេស រដ្ឋបាល ការថ្លែងសុន្ទរកថា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

ចៅក្រម

មេធាវី និង

អ្នកប្រឹក្សាផ្នែកច្បាប់

# អ្នកឯកទេសផ្នែកទំនាក់ទំនងសាធារណៈ

( Public Relations Specialists )

**សង្ខេបអំពីជំនាញ**

**អ្នកឯកទេសផ្នែកទំនាក់ទំនងសាធារណៈធ្វើការងារ៖**

- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

G

**ជំនាញដែលត្រូវការប្រើ៖**

- ការគិតប្រកបដោយភាពច្នៃប្រឌិត
- ការអាន និងការសរសេរ
- ការនិយាយ និងការស្តាប់

## អ្នកឯកទេសទំនាក់ទំនងសាធារណៈបំពេញកិច្ចការអ្វី?

នៅពេលក្រុមហ៊ុន, អង្គភាព ឬស្ថាប័នចង់ធ្វើបទបង្ហាញផ្សព្វផ្សាយទៅកាន់សាធារណៈជន គេត្រូវការអ្នកឯកទេសផ្នែកទំនាក់ទំនងសាធារណៈ ឬក្រុមហ៊ុនផ្នែកទំនាក់ទំនង សាធារណៈ។ អ្នកឯកទេសផ្នែកទំនាក់ទំនងសាធារណៈ រួមបញ្ចូលទាំងនាយកគ្រប់គ្រងប្រត្តិបត្តិការ, អ្នកនិពន្ធ, សិល្ប-ករ និងអ្នកស្រាវជ្រាវ ផងដែរ។ អ្នកជំនាញទាំងនេះធ្វើការជាមួយគ្នា ដើម្បីផ្តល់ព័ត៌មានទៅដល់សាធារណៈជនអំពីគោលដៅរបស់ស្ថាប័ន,ភាពជោគជ័យរបស់ក្រុមហ៊ុន និងអំពីគម្រោងទៅថ្ងៃអនាគតរបស់ក្រុមហ៊ុន។ អ្នកឯកទេសផ្នែកនេះត្រូវចំណាយពេលយ៉ាងច្រើនក្នុងការតែងនិពន្ធ, រៀបចំរបាយការណ៍ព័ត៌មាន, ផ្សព្វផ្សាយបណ្ណព័ត៌មាន, ថ្លែងសុន្ទរកថា, រៀបចំកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ និងអត្ថបទសម្រាប់ភាពយន្ត។ ការតែងនិពន្ធ និងការបោះពុម្ពនេះមានគោលដៅតែមួយគឺផ្តល់ព័ត៌មានជាវិជ្ជមានទៅដល់សាធារណៈជនអំពីបុគ្គល ឬក្រុមហ៊ុន។

ការទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ គឺជាកិច្ចការសំខាន់មួយទៀតរបស់អ្នកឯកទេសទំនាក់ទំនងសាធារណៈ។ ពួកគេប្រើវិទ្យុ, ទូរទស្សន៍, សារព័ត៌មាន និងទស្សនាវដ្តីជាមធ្យោបាយផ្សព្វផ្សាយតាមរយៈ ព្រឹត្តិការណ៍ពិសេសៗផងដែរ ដូចជា ពិធីជប់លៀង, ការប្រជុំ, ពិព័រណ៍, និងសន្ទរកដើម្បីបង្កើតបរិយាកាសល្អ និងទាក់ទាញការចាប់អារម្មណ៍ប្រកបដោយទិដ្ឋភាពវិជ្ជាមាន។

ក្រុមហ៊ុនខ្លះមានផ្នែកទំនាក់ទំនងសាធារណៈផ្ទាល់របស់ពួកគេ ហើយមានបុគ្គលិកសម្រាប់បំពេញកិច្ចការនេះទៀត ផង។ ចំណែកក្រុមហ៊ុនផ្សេងទៀតជួលសេវាកម្មផ្នែកទំនាក់ទំនងសាធារណៈពីខាងក្រៅមករៀបចំកម្មវិធីផ្សព្វផ្សាយ។ ក្នុងករណីទាំងពីរនេះ អ្នកឯកទេសផ្នែកទំនាក់ទំនងសា-ធារណៈធ្វើការយ៉ាងជិតស្និទ្ធជាមួយផ្នែកគ្រប់គ្រងរបស់ស្ថា-ប័នរកវិធីផ្សព្វផ្សាយ ឬអភិវឌ្ឍរូបភាពវិជ្ជមានរបស់ក្រុមហ៊ុន។




តទៅទំព័របន្ទាប់

## ការអប់រំ និងការបណ្តុះបណ្តាល

អ្នកឯកទេសខាងទំនាក់ទំនងសាធារណៈ ភាគច្រើនមានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ។ មុខវិជ្ជាសម្រាប់ជំនាញនេះមានដូចជា ភាសាអង់គ្លេស, សុន្ទរកថា, មនុស្សសាស្ត្រ និងភាសាវិទ្យា។ បន្ថែមលើនេះ ការសរសេរ ឬតែងនិពន្ធគឺជាផ្នែកមួយដ៏សំខាន់នៃទំនាក់ទំនងសាធារណៈ។

ដើម្បីក្លាយជាអ្នកឯកទេសផ្នែកនេះ គេគួរសិក្សាឯកទេសផ្នែកទំនាក់ទំនងសាធារណៈ, ភាសាអង់គ្លេស ឬសារព័ត៌មាន។ ក្រុមហ៊ុន ឬអង្គភាពខ្លះមានកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកឯកទេសខាងទំនាក់ទំនងសាធារណៈ ឬហាត់ការងារយ៉ាងជិតស្និទ្ធក្រោមការគ្រប់គ្រងរបស់អ្នកជំនាញដែលមានបទពិសោធន៍ច្រើន។

## គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលាៈ**
ភាសាអង់គ្លេស, សារព័ត៌មាន

✦ **កម្រិតអប់រំទាបបំផុតៈ**
បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នាៈ**
អ្នកឃោសនាអង្គាសមូលនិធិ
អ្នកស្រាវជ្រាវផ្នែកទីផ្សារ
អ្នកឯកទេសខាងប្រព័ន្ធឃោសនា
អ្នកនាំពាក្យ និង
អ្នកនិពន្ធ

# បុគ្គលិកផ្នែកកម្មវិធីកំសាន្ត

(Recreation Workers)

**សង្ខេបអំពីជំនាញ**

**បុគ្គលិកផ្នែកកម្មវិធីកំសាន្តធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន
✦ បង្រៀន ឬបង្ហាត់

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
✦ ការទំនាក់ទំនង
✦ ការនិយាយនិងការស្តាប់

## តើបុគ្គលិកផ្នែកកម្មវិធីកំសាន្តបំពេញកិច្ចការអ្វីខ្លះ?

បុគ្គលិកផ្នែកកម្មវិធីកំសាន្តជួយមនុស្សទូទៅ ដើម្បីបង្កើតពេលវេលាសម្រាក់លំហែល ដោយការ រៀបចំគម្រោង និងសកម្មភាពកំសាន្តពេលទំនេរ។ ពួកគេតែងតែធ្វើការជាមួយភ្នាក់ងារស្ម័គ្រចិត្ត,មជ្ឈមណ្ឌលសហគមន៍, ទីកន្លែងកំសាន្ត, ពន្ធនាគារ និងមន្ទីរពេទ្យ។ កិច្ចការដែលត្រូវបំពេញរួមមានៈ រៀបចំកម្មវិធីសិល្បៈ, ការសម្តែងល្ខោន, ការប្រគុំតន្ត្រី, ការរាំរែក, ការហែលទឹក, ការបោះជំរុំ និងការសិក្សាអំពីបរិដ្ឋាន ជាដើម។ កម្មវិធីកំសាន្តនេះអាចរៀបចំជាពិសេសសម្រាប់សកម្មភាពមនុស្សចាស់ជរា, ជនពិការ, កុមារ និងមនុស្សពេញវ័យ


តទៅទំព័របន្ទាប់

## ការអប់រំ និងការបណ្តុះបណ្តាល

សញ្ញាប័ត្រកម្រិតមធ្យមសិក្សាទុតិយភូមិមានតម្លៃគ្រប់គ្រាន់សម្រាប់បំពេញកិច្ចការនេះ។ ប្រសិនជាបុគ្គលិកបំពេញការងារសង្គម ត្រូវការសញ្ញាប័ត្រកម្រិតឧត្តមសិក្សា។ មុខវិជ្ជាសម្រាប់ជំនាញនេះមានដូចជា ការគ្រប់គ្រងសួនសាធារណៈ, ការគ្រប់គ្រងសកម្មភាពកំសាន្ត, ការថែទាំសុខភាព ។ល។ បន្ថែមលើនេះ បុគ្គលិកខ្លះត្រូវការការបណ្តុះបណ្តាលពិសេសផ្នែកសិល្បៈ, តន្ត្រី, ល្ខោន ឬកីឡា។



## គួរយល់ដឹង !

✦ មុខវិជ្ជាសិក្សាក្នុងសាលា:

ការអប់រំផ្នែកកាយសម្ព័ន្ធ, ល្ខោន និងរបាំ

✦ កម្រិតអប់រំទាបបំផុត:

មធ្យមសិក្សាទុតិយភូមិ ឬខ្ពស់ជាង

✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:

បុគ្គលិកនៅរមណីយដ្ឋាន

បុគ្គលិកផ្នែកនាំភ្ញៀវ (មគ្គុទេសក៍ទេសចរ)

អ្នកបង្ហាត់របាំ ឬល្ខោន

# ម្ចាស់អាជីវកម្មលក់រាយ

( Retail Business Owners )

**សង្ខេបអំពីជំនាញ**

**ម្ចាស់អាជីវកម្មលក់រាយធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ បំពេញការងារប្រកបដោយភាពជាអ្នកដឹកនាំ

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

**G**

**ជំនាញដែលត្រូវការប្រើ៖**

✦ ការធ្វើសេចក្តីសម្រេចចិត្ត

✦ គណិតវិទ្យា ឬលេខនព្វន្ត

✦ ការនិយាយនិងការស្តាប់

## តើម្ចាស់អាជីវកម្មលក់រាយបំពេញកិច្ចការអ្វីខ្លះ?

ម្ចាស់អាជីវកម្មលក់រាយទទួលខុសត្រូវលើដំណើរការជំនួញដោយគិតចាប់ពីការផ្តើមគម្រោង, ការបញ្ជាទិញ និងការគ្រប់គ្រងដំណើរការអាជីវកម្មប្រចាំថ្ងៃ។ មុខទំនិញអាចមានច្រើនប្រភេទរាប់តាំងពីផ្លែឈើ, សម្ភារប្រើប្រាស់, រហូតដល់រថយន្ត។ ការងារក្នុងអាជីវកម្មនេះមានចែកជាច្រើនប្រភេទ ដូចជា ផ្នែកលក់ និងទិញចូល, ផ្នែកគ្រប់គ្រងហាង, ផ្នែកផ្សព្វផ្សាយនិងទីផ្សារ, ផ្នែកគណនេយ្យ, និងផ្នែកគ្រប់គ្រងបុគ្គលិក។

ម្ចាស់អាជីវកម្មលក់រាយត្រូវតែដឹងអំពីប្រភេទការងារទាំងអស់នេះ ដើម្បីធ្វើសេចក្តីសម្រេចចិត្តលើមុខជំនួញ។ កិច្ចការរបស់ម្ចាស់អាជីវកម្មអាស្រ័យលើទំហំនៃហាង និងចំនួននៃបុគ្គលិក។ នៅក្នុងហាងដែលមានបុគ្គលិកច្រើនជាងដប់


តទៅទំព័របន្ទាប់

នាក់ ប្រត្តិបត្តិការការងារប្រចាំថ្ងៃ, ការផ្សព្វផ្សាយ និង សកម្មភាពរបស់បុគ្គលិកគឺត្រូវបានត្រួតពិនិត្យដោយអ្នក គ្រប់គ្រង ខណៈពេលដែលម្ចាស់ហាងរៀបចំគម្រោងសម្រាប់ ដំណើរការរួមៗ ចំណែកនៅក្នុងហាងតូច ម្ចាស់ហាងអាច គ្រប់គ្រងទៅលើកិច្ចការស្ទើរទាំងអស់ ដូចជា ការរៀបចំឥវ៉ាន់, បោសសំអាត, រាក់ទាក់អតិថិជន, ផ្ទៀងផ្ទាត់សៀវភៅ គណនេយ្យ ព្រមទាំងផ្សព្វផ្សាយតាមវិធីផ្សេងៗ។

ទោះបីជាអាជីវកម្មធំ ឬតូច ម្ចាស់ហាងត្រូវតែតាម ដានទូវព័ត៌មានទំនិញ, ស្ថានភាពសេដ្ឋកិច្ច និងការវិវត្តនៃប ច្ចេកវិទ្យាដែលអាចប៉ះពាល់ដល់មុខជំនួញ។ ហេតុនេះម្ចាស់ អាជីវកម្មត្រូវយល់ដឹងពីផលិតផល, ពិនិត្យបញ្ជីឥវ៉ាន់, កំណត់តម្លៃ និងស្រាវជ្រាវពីវិធីដែលអាចជួយឲ្យដំណើរការ អាជីវកម្មកាន់តែល្អប្រសើរ។

## ការអប់រំ និងការបណ្តុះបណ្តាល

មិនមានការអប់រំ ឬបទពិសោធន៍ជាក់លាក់សម្រាប់មុខ តំណែងនេះទេ។ ប៉ុន្តែ មុខវិជ្ជាគណិតវិទ្យា, ការគ្រប់គ្រង ជំនួញ, គណនេយ្យ, ការសរសេរ និងវិទ្យាសាស្ត្រកុំព្យូទ័រគឺ មានប្រយោជន៍សម្រាប់សម្រួលដល់ដំណើរការជំនួញ។

ប្រសិនបើ អ្នកមានបំណងចង់ធ្វើជំនួញផ្ទាល់ខ្លួននៅថ្ងៃ ណាមួយ អ្នកគួរតែសិក្សាឯកទេសផ្នែកគ្រប់គ្រងជំនួញឬ ពាណិជ្ជកម្ម, ការទំនាក់ទំនងមុខជំនួញ, ទីផ្សារ, ច្បាប់ជំនួញ, និងគណនេយ្យ។ អ្នកអាចបន្តសិក្សាកម្រិតបរិញ្ញាបត្រជាន់ ខ្ពស់ផ្នែកគ្រប់គ្រងជំនួញ (MBA) ក៏បាន។ លើសពីនេះក៏មាន វគ្គបណ្តុះបណ្តាលផ្នែកជំនួញរយៈពេលខ្លី និងវែងផងដែរ។

## គួរយល់ដឹង!

✦ មុខវិជ្ជាសិក្សាក្នុងសាលាៈ
ជំនួញ និងគណិតវិទ្យា
✦ កម្រិតអប់រំទាបបំផុតៈ
មធ្យសិក្សាទុតិយភូមិ
✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នាៈ
អ្នកទិញ
អ្នកគិតបញ្ជី
អ្នករៀបចំតាំងបង្ហាញឥវ៉ាន់
អ្នកគ្រប់គ្រងហាងឥវ៉ាន់

## អ្នកនិពន្ធខ្សែភាពយន្ត

( Screenwriters )

**សង្ខេបអំពីជំនាញ**

**អ្នកនិពន្ធខ្សែភាពយន្តធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
✦ ការអាន និងការសរសេរ
✦ ការនិយាយនិងការស្តាប់

## តើអ្នកនិពន្ធខ្សែភាពយន្តបំពេញកិច្ចការអ្វីខ្លះ?

អ្នកនិពន្ធខ្សែភាពយន្តសរសេរអត្ថបទសម្រាប់ផលិតជាខ្សែភាពយន្ត ឬក៏ទូរទស្សន៍។ ខ្លឹមសារអាចជាគំនិតផ្ទាល់របស់គេ ឬជាសាច់រឿងដែលកំណត់ឡើងដោយអ្នកផលិត ឬនាយកគ្រប់គ្រង។ អ្នកនិពន្ធតែងតែលើកយករឿងបែបប្រជាប្រិយ ឬប្រលោមលោកមកច្នៃបង្កើតឲ្យទៅជាសាច់រឿងសម្រាប់សម្តែងជាភាពយន្តប្រកបដោយភាពរស់រវើក។ អ្នកនិពន្ធ ក៏សរសេរសម្រាប់ផ្សាយក្នុងកម្មវិធីទូរទស្សន៍ផងដែរ ដូចជារឿងកំប្លែង, ល្ខោន, ឯកសារ, ការបង្ហាញផ្សេងៗ និងការកំសាន្តពិសេស។

អ្នកនិពន្ធខ្សែភាពយន្ត មិនត្រឹមតែជាអ្នកមានទេពកោស-ល្យច្នៃប្រឌិតនោះទេ ប៉ុន្តែថែមទាំងមានជំនាញខ្ពស់ក្នុងការស្រាវជ្រាវផងដែរ។ ឧទាហរណ៍ រឿងប្រវត្តិសាស្ត្រ, ឯកសារ និងកម្មវិធីទាក់ទងជាមួយវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រជាដើម។ អ្នកនិពន្ធត្រូវតែមានការស្រមើស្រមៃបែបច្នៃប្រឌិត និងសមត្ថភាពក្នុងការនិទានប្រាប់អំពីសាច់រឿងទាំងមូល។

ដំបូង អ្នកនិពន្ធខ្សែភាពយន្តចាប់ផ្តើមសេចក្តីព្រាងផ្ទៃរឿងត្រួសៗ នៅពេលដែលនាយកគ្រប់គ្រង ឬអ្នកផលិតយល់ស្របលើសាច់រឿង បន្ទាប់មកអ្នកនិពន្ធត្រូវសរសេរបំពេញសាច់រឿងឲ្យចប់សព្វគ្រប់សម្រាប់ការផលិត។ អ្នកនិពន្ធខ្សែភាពយន្តខ្លះធ្វើការម្នាក់ឯង ខ្លះទៀតធ្វើការជាក្រុមជាមួយអ្នកនិពន្ធផ្សេងទៀត។ ពួកគេភាគច្រើនមានជំនាញឯកទេសពិតប្រាកដមួយៗដូចជារឿងល្ខោន, កំប្លែង, ឯកសារ, រូបភាព, និងទូរទស្សន៍។



## ការអប់រំ និងការបណ្តុះបណ្តាល

នៅក្នុងវិទ្យាល័យ អ្នកគួរតែអភិវឌ្ឍជំនាញសរសេរអត្ថបទ, ភាសាបរទេស, ភាពយន្ត, សុន្ទរកថា និងសារព័ត៌មាន។ បន្ថែមលើនេះ ការសិក្សាអំពីសង្គម និងអក្សរសាស្ត្រក៏មានប្រយោជន៍ផងដែរក្នុងការបង្កើតនាដ្យកថា។

វិធីដ៏ល្អបំផុតដើម្បីរៀបចំអាជីពជាអ្នកនិពន្ធខ្សែភាពយន្តគឺការសរសេរ និងអានរាល់ថ្ងៃ។ កម្មវិធីអប់រំផ្នែកខ្សែភាពយន្តតែងតែមានវគ្គសិក្សាជំនាញតែងនិពន្ធសម្រាប់ខ្សែភាពយន្ត។ អ្នកគួរតែចាប់ផ្តើមប្រឡូកក្នុងវិស័យល្ខោន និងភាពយន្តដើម្បីដឹងអំពីចំណុចសំខាន់ៗទាំងអស់ក្នុងការសម្តែងឲ្យមានភាពរស់រវើកដូចជា តួអង្គ, ទីកើតហេតុ, និងខ្លឹមសាររឿង ហើយធ្វើការផ្សារភ្ជាប់ទៅនឹងជំនាញតែងនិពន្ធ។



### គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ភាសាអង់គ្លេស, សិល្បៈល្ខោន និងរបាំ

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

សិល្បករ

អ្នកថតខ្សែភាពយន្ត

ផាងហ្វាងផលិតកម្មភាពយន្ត និងទូរទស្សន៍

អ្នកនិពន្ធ

## អ្នករចនាគ្រឿងសង្ហារឹម

( Furniture Designers )

**សង្ខេបអំពីជំនាញ**

**អ្នករចនាគ្រឿងសង្ហារឹមធ្វើការងារៈ**

- ប្រាស្រ័យទាក់ទងផ្នែកគំនិត
- វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ជ្រើសរើស និងប្រើប្រាស់សម្ភារ ឬបច្ចេកវិទ្យា

G

**ជំនាញដែលត្រូវការប្រើៈ**

- ការគិតប្រកបដោយភាពច្នៃប្រឌិត
- គណិតវិទ្យា
- ការដោះស្រាយបញ្ហា

## តើអ្នករចនាគ្រឿងសង្ហារឹមបំពេញកិច្ចការអ្វីខ្លះ?

អ្នករចនាគ្រឿងសង្ហារឹមបង្កើតគំនិតដើម្បីច្នៃផលិតកៅអី, តុ, ធ្នើរ, គ្រែ និងទូដាក់ឥវ៉ាន់។ កិច្ចការបែបនេះអាចធ្វើនៅក្នុងក្រុមហ៊ុន ឬសិប្បកម្មផលិតគ្រឿងសង្ហារឹម ឬក៏ ក្រុមហ៊ុនធំៗដែលធ្វើកិច្ចសន្យាជាមួយអ្នកផលិតគ្រឿងសង្ហារឹម។

អ្នករចនាគ្រឿងសង្ហារឹមតែងប្រើជំនាញ និងចំណេះផ្សេងៗក្នុងការងារ ដូចជាប្រវត្តិសាស្ត្រ, សិល្បៈ, គណិតវិទ្យា, ការរចនាខាងក្នុងអគារ ឬបន្ទប់ និងការងារជាងឈើ។ ជាទូទៅការបង្កើតគំនិតអាចសំដៅលើការរចនាគ្រឿងសង្ហារឹមតែមួយប្រភេទ ឬការរចនាលម្អគ្រឿងសង្ហារឹមជាឈុតក៏មាន។ ពួកគេចាប់ផ្តើមកិច្ចការតាមរយៈការគូសប្លង់ក្រាគិច ឬគូរគំនូរព្រាងអំពីរូបរាងរបស់គ្រឿងសង្ហារឹម បន្ទាប់មកបង្កើតម៉ូដែលតូចមួយពីឈើ ឬស្នោដើម្បីងាយពិនិត្យមើលឃើញពីគ្រប់ជ្រុងៗ។ ពេលបង្កើត និងកែច្នៃម៉ូដែលរួចរាល់ហើយ គេត្រូវបង្កើតគំរូពិតដែលស្របទៅនឹងទំហំ ឬខ្នាតរបស់វត្ថុនោះ ដោយប្រើប្រាស់សម្ភារពិតប្រាកដ។ បន្ទាប់ពីឯកភាពលើគំរូនេះហើយ គេនឹងបញ្ជូនទៅកាន់សិប្បកម្មឬរោងចក្រដើម្បីផលិតទៅតាមទំហំ និងខ្នាតឲ្យបានចំនួនច្រើនសម្រាប់លក់ក្នុងទីផ្សារ។

អ្នករចនាគ្រឿងសង្ហារឹមច្រើនតែប្រើកម្មវិធីគូររូបដែលមាននៅក្នុងប្រព័ន្ធកុំព្យូទ័រដើម្បីបង្ហាញពីគំនិត។ អ្នករចនាត្រូវពិចារណាអំពីមុខងារប្រើប្រាស់តាមប្រភេទឈើ, រូបរាង, ម៉ូត, និងទីកន្លែងដែលត្រូវដាក់តាំង។ គ្រឿងសង្ហារឹមអាចផលិតឡើងវិញ ចម្លងគំរូប្រហាក់ប្រហែលទៅនឹងគ្រឿងសង្ហារឹមចាស់ ឬក៏ជាការរៀបចំតុបតែងថ្មីទាំងស្រុង។

អ្នករចនាគិតអំពីវត្ថុធាតុដើមដែលអាចយកមកប្រើប្រាស់បានដូចជាប្លាស្ទិក, ឈើ, លោហៈ, ស័ង្កសី, ស្បែកសត្វ, ក្រណាត់ ឬផ្តៅ។ ពួកគេក៏ត្រូវគិតពីតំលៃរបស់វត្ថុធាតុដើម, ផលិតកម្ម, ដំណើរការផលិត និងពេលវេលាផលិត។

អ្នករៀបចំតុបតែងគ្រឿងសង្ហារឹមទទួលការបញ្ជាផលិតរបស់អតិថិជន ឬចៅហ្វាយមកច្នៃជាម៉ូដែលសម្រាប់បង្ហាញ។ បន្ទាប់មកពន្យល់ពីវត្ថុធាតុដើម, រូបរាង, ពុម្ពគំរូ, និងគំរូលម្អិត។ ការផលិតគ្រឿងសង្ហារឹមជាត្រូវការជំនាញផ្សេងៗដូចជា វិស្វករ, ជាងឈើ, ជាងផ្ដុំ, អ្នកតុបតែងផលិតផលសម្រេច, គណនេយ្យករ, អ្នកលក់, អ្នកទីផ្សារ និងអ្នកដឹកជញ្ជូនទំនិញ។

## ការអប់រំ និងការបណ្តុះបណ្តាល

មុខវិជ្ជាផ្នែកសិល្បៈ និងផ្នែកលក់ទំនិញគឺជាមូលដ្ឋានគ្រឹះសម្រាប់ការបណ្តុះបណ្តាល ដើម្បីក្លាយជាអ្នករៀបចំតុបតែងគ្រឿងសង្ហារឹម។ អ្នកត្រូវរៀនមុខវិជ្ជាគូរប្លង់, ចម្លាក់, ធ្វើម៉ូដែលគ្រឿងឈើ និងលោហៈធាតុ។ បន្ថែមលើនេះ មុខវិជ្ជា

គណិតវិទ្យា, ពិជគណិត និងធរណីមាត្រ ក៏មានសារៈសំខាន់ខ្លាំងណាស់ដែរក្នុងកិច្ចការជាងឈើ។ ជំនាញនេះអាចសិក្សាបានពីសាលាបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈឬសិក្សាដោយហាត់ធ្វើការផ្ទាល់ពីសិប្បកម្មផលិតគ្រឿងសង្ហារឹមក៏បាន។



## គួរយល់ដឹង !

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
សិល្បៈ, គណិតវិទ្យា, បច្ចេកទេស និងការលក់ដូរ
✦ **កម្រិតអប់រំទាបបំផុត:**
អប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈ
✦ **ព័ត៌មានគួរអានបន្ថែមស្ដីពីអ្នកមានជំនាញស្រដៀងគ្នា:**
សិល្បករ
ជាងឈើ
អ្នករចនាគំរូក្នុងកុំព្យូទ័រ

# វិស្វករផ្នែកវេចខ្ចប់ឥវ៉ាន់

( Packaging Engineers )

**សង្ខេបអំពីជំនាញ**

**វិស្វករផ្នែកវេចខ្ចប់ធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ បង្កើន និងបង្កើនប្រព័ន្ធដំណើរការ
✦ ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ ឬបច្ចេកវិទ្យា

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត
✦ ការដោះស្រាយបញ្ហា
✦ ការនិយាយ និងការស្ដាប់

## តើវិស្វករផ្នែកវេចខ្ចប់បំពេញកិច្ចការអ្វី?

វត្ថុប្រើប្រាស់ទាំងអស់ត្រូវបានគេវេចខ្ចប់តាមប្រភេទនីមួយៗ រាប់ចាប់ពីរបស់ធំៗ ដល់របស់តូចៗដើម្បីផ្ញើឬដឹកជញ្ជូនទៅអតិថិជន។ កញ្ចប់នីមួយៗត្រូវបានបង្កើត និងកែច្នៃដោយវិស្វករខាងផ្នែកវេចខ្ចប់។ សូមពិនិត្យលើការវេចខ្ចប់ផលិតផលផ្លែប៉ោម។ អ្នកកែច្នៃធ្វើប្រអប់ឈើដើម្បីដាក់ផ្លែប៉ោមពីចំការរហូតដល់រោងចក្រកែច្នៃ បន្ទាប់មកកែច្នៃប្រអប់ក្រដាសដាក់ទឹកផ្លែប៉ោមដែលបានកែច្នៃរួចចូលទៅផ្សារទំនើប។ បន្ថែមលើនេះពួកគេកែច្នៃប្រអប់ទឹកផ្លែឈើដែលមានបំពាក់ដោយបំពង់បឺតសម្រាប់ដាក់លក់ក្នុងផ្សារផងដែរ។ កិច្ចការដំបូងដែលវិស្វករខាងផ្នែកវេចខ្ចប់ត្រូវធ្វើនៅពេលកែច្នៃប្រអប់សម្រាប់ផ្ទុកសម្ភារ គឺការសិក្សាអំពីប្រភេទទំនិញនិងគិនភាគមុខទំនិញ ឬផលិតផលដែលត្រូវផ្ទុកក្នុងនោះ ដូចជាវត្ថុរាវ ឬរឹង, ស្រាល ឬធ្ងន់, ផុយស្រួយ ឬមាំ, ងាយខូច ឬនៅបានយូរ។ បន្ទាប់មកពួកគេគូរគម្រោងប្លង់សម្រាប់វេចខ្ចប់និងជ្រើសរើសវត្ថុធាតុដើមល្អជាងគេដើម្បីបង្កើតជាផលិតផលសម្រេច។ វិស្វករចង់បង្កើត ប្រអប់សម្រាប់ផ្ទុកដែលអាចការពារទំនិញផ្ទុកនៅក្នុងនោះ, មានភាពទាក់ទាញចំពោះអ្នកទិញ, តម្លៃសមរម្យសម្រាប់ការផលិត, ប្រើវត្ថុធាតុដើមដែលអាចកែច្នៃឡើងវិញបាន និងមិនប៉ះពាល់ដល់បរិស្ថាន។

នៅពេលដែលឧបករណ៍សម្រាប់វេចខ្ចប់ត្រូវបានសម្រេចលើលក្ខណៈសម្បត្តិទាំងអស់រួចហើយ វិស្វករខាង



តទៅទំព័របន្ទាប់

ផ្នែកវេចខ្ចប់ត្រូវធ្វើការផលិតសាកល្បង ព្រមទាំងសហការជាមួយវិស្វករ និងអ្នកជំនាញបច្ចេកទេសខាងផ្នែកវេចខ្ចប់ដទៃទៀតដើម្បីអភិវឌ្ឍ និងបង្កើតម៉ាស៊ីនដែលអាចច្រក និងវេចខ្ចប់វត្ថុដោយផ្ទាល់ទៅក្នុងប្រអប់ឬប្រដាប់ផ្ទុក។

## ការអប់រំ និងការបណ្ដុះបណ្ដាល

វិស្វករខាងផ្នែកវេចខ្ចប់ត្រូវមានសញ្ញាប័ត្រកម្រិតបរិញ្ញាប័-ត្រពីសាលាវិស្វកម្ម ឬសាលាបណ្ដុះបណ្ដាលបច្ចេកទេសផ្នែកវេចខ្ចប់។ វិស្វករខាងផ្នែកវេចខ្ចប់ត្រូវបន្តសិក្សា និងដកស្រង់បទពិសោធន៍ថ្មីៗពីការផ្លាស់ប្ដូររបស់បច្ចេកវិទ្យា និងបច្ចេក- ទេសវេចខ្ចប់តាមរយៈការចូលរួមក្នុងសិក្ខាសាលា ឬការប្រជុំចែករំលែកបទពិសោធ។




## គួរយល់ដឹង!

✦ មុខវិជ្ជាសិក្សាក្នុងសាលាៈ

គណិតវិទ្យា និងរូបវិទ្យា

✦ កម្រិតអប់រំទាបបំផុតៈ

បរិញ្ញាប័ត្រ

✦ ព័ត៌មានគួរអានបន្ថែមស្ដីពីអ្នកមានជំនាញស្រដៀងគ្នាៈ

អ្នករចនាក្នុងកុំព្យូទ័រ

អ្នករចនាផ្នែកឧស្សាហកម្ម

វិស្វករឧស្សាហកម្ម

អ្នកបច្ចេកទេសខាងម៉ាស៊ីនវេចខ្ចប់

## អ្នករៃអង្គាសមូលនិធិ

( Fund-Raisers )

**សង្ខេបអំពីជំនាញ**

**អ្នករៃអង្គាសមូលនិធិធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត

✦ បំពេញកិច្ចការក្នុងភាពជាអ្នកដឹកនាំ

✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

G

**ជំនាញដែលត្រូវការប្រើ៖**

✦ ការគិតប្រកបដោយភាពច្នៃប្រឌិត

✦ គណិតវិទ្យា

✦ ការនិយាយ និងការស្ដាប់

## តើអ្នករៃអង្គាសមូលនិធិបំពេញកិច្ចការអ្វីខ្លះ?

អ្នករៃអង្គាសមូលនិធិធ្វើគម្រោង និងរៀបចំកម្មវិធីដើម្បីរៃអង្គាសថវិកាសម្រាប់បុព្វហេតុមនុស្សធម៌ និងការជួយសង្គ្រោះ ដែលចែកចេញជាប្រភេទផ្សេងៗដូចជា បុគ្គលិកនៃមជ្ឈមណ្ឌលសុខភាព, ស្ថាប័នវប្បធម៌, ភ្នាក់ងារផ្តល់សេវាសង្គម, ក្រុមសហគមន៍ ឬអង្គការមិនរកប្រាក់ចំណូលផ្សេងទៀត។ ពួកគេធ្វើគម្រោងសកម្មភាពរៃអង្គាសសម្រាប់ស្ថាប័ន ឧទាហរណ៍ អ្នករៃអង្គាសមូលនិធិធ្វើការក្នុងមហាវិទ្យាល័យអាចទាក់ទងជាមួយសាជីវកម្ម ឬក្រុមហ៊ុនធំៗដើម្បីប្រមូលវិភាគទានកសាងសមិទ្ធផលនានាសម្រាប់សិស្ស និស្សិត។ អ្នករៃអង្គាសមូលនិធិសម្រាប់អង្គការសប្បុរសធម៌ និងអង្គការមិនរកចំណូលអាចរៀបចំការរៃអង្គាសជាច្រើនក្នុងពេលជាមួយគ្នាដើម្បីគម្រោងជាច្រើន ឧទាហរណ៍ ការរៀបចំព្រឹត្តិការណ៍សប្បុរសធម៌ប្រចាំឆ្នាំ រួមមាន ការរត់ប្រណាំងម៉ារ៉ាតុន, ការផ្សព្វផ្សាយតាមទស្សនាវដ្តី និងទូរទស្សន៍ និងការអំពាវនាវសុំជំនួយពីអ្នកផ្តល់វិភាគទានធំៗ។ អង្គការមិនរកប្រាក់ចំណូលនីមួយៗមានគោលដៅច្បាស់លាស់ និងតម្រូវការហិរញ្ញវត្ថុជាក់លាក់ ដូច្នេះហើយអ្នករៃអង្គាសមូលនិធិត្រូវតែខិតខំកៀគររកប្រាក់ឲ្យគ្រប់តាមសេចក្តីត្រូវការសម្រាប់ផ្គត់ផ្គង់ដល់អ្នកដែលត្រូវការជំនួយ។

អ្នករៃអង្គាសមូលនិធិខ្លះទៀតធ្វើការសម្រាប់ក្រុមហ៊ុនដែលរៀបចំព្រឹត្តិការណ៍រៃអង្គាសសម្រាប់អង្គការដែលមានបំណងចង់ប្រមូលជំនួយ។ ក្រុមហ៊ុនបែបនេះអាចមានជំនាញឯកទេសនៅក្នុងការធ្វើបទបង្ហាញក្នុងកម្មវិធីទូរទស្សន៍, ពិធីតាំងពិព័រណ៍, ការប្រគុំតន្ត្រី, និងពីធីជប់លៀង។ មួយភាគនៃថវិកាដែលរៃអង្គាសត្រូវបញ្ជូនទៅអង្គការសប្បុរស់ធម៌ និងទៅក្រុមហ៊ុនរៃអង្គាសមួយផ្នែក។ កិច្ចការបែបនេះគឺអាស្រ័យទៅតាមព្រឹត្តិការណ៍នីមួយៗ ប៉ុន្តែអ្នករៃអង្គាសមូលនិធិមានទំនួលខុសត្រូវក្នុងការធ្វើគម្រោង, រៀបចំកញ្ចប់ថវិកា, រៀបចំការបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្ត, រៀបចំផ្សព្វផ្សាយតាមសារព័ត៌មាន, ស្រាវជ្រាវ និងការទំនាក់ទំនងជាមួយអ្នកផ្តល់វិភាគទានធំៗ ដូចជា សាជីវកម្ម, មូលនិធិសប្បុរសធម៌ និងអ្នកដែលមានទ្រព្យច្រើន។ ក្រៅពីនេះនៅមានកិច្ចការផ្សេងទៀតដូចជា ផ្សព្វផ្សាយពាណិជ្ជកម្ម និងផលិតរូបភាពផ្សព្វផ្សាយតាមទូរទស្សន៍។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីក្លាយជាអ្នកជំនាញផ្នែករៃអង្គាសមូលនិធិ អ្នកត្រូវមានការអប់រំផ្នែកភាសាអង់គ្លេស, ការតែងអត្ថបទដែលមានភាពច្នៃប្រឌិត, សុន្ទរកថា, គណិតវិទ្យា, ជំនួញ, ប្រវត្តិសាស្រ្ត, គណនេយ្យ, និងការបណ្តុះបណ្តាលជំនាញកុំព្យូទ័រ។ មុខវិជ្ជាចិត្តសាស្រ្ត, ទំនាក់ទំនងសាធារណៈ, សង្គមវិទ្យា, សារព័ត៌មាន, និងការងារសង្គម ក៏មានសារៈសំខាន់ផងដែរ។

## គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**

ជំនួញ, និងគណិតវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**

បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**

អ្នកសម្របសម្រួលផ្នែកហរិញ្ញប្បទាន

អ្នកស្រាវជ្រាវផ្នែកទីផ្សារ

អ្នកឯកទេសផ្នែកទំនាក់ទំនងបណ្តាញផ្សព្វផ្សាយ

អ្នកឯកទេសផ្នែកទំនាក់ទំនងសាធារណៈ


តទៅទំព័របន្ទាប់

# បុគ្គលិកផ្នែកទទួលភ្ញៀវក្នុងសណ្ឋាគារ

(Hotel Desk Clerks)

**សង្ខេបអំពីជំនាញ**

**បុគ្គលិកផ្នែកទទួលភ្ញៀវក្នុងសណ្ឋាគារធ្វើការងារ៖**

- វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
- ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន
- បំពេញការងារជាក្រុម

G

**ជំនាញដែលត្រូវការប្រើ៖**

- ការអាន និងការសរសេរ
- ការទទួលខុសត្រូវ
- ការនិយាយ និងការស្តាប់

## បុគ្គលិកទទួលភ្ញៀវក្នុងសណ្ឋាគារបំពេញកិច្ចការអ្វីខ្លះ?

បុគ្គលិកផ្នែកទទួលភ្ញៀវក្នុងសណ្ឋាគារ ធ្វើការនៅកន្លែងទទួលភ្ញៀវខាងមុខ និងមានទំនួលខុសត្រូវក្នុងការបំរើសេវាកម្មផ្សេងៗដល់ភ្ញៀវ ដូចជា ការចុះឈ្មោះ, ការរៀបចំចាត់ចែងបន្ទប់និងការផ្តល់ព័ត៌មានផ្សេងៗ។ បុគ្គលិកផ្នែកទទួលភ្ញៀវក្នុងសណ្ឋាគារជាអ្នកដែលបង្កើតចំណាប់អារម្មណ៍ដំបូងបង្អស់របស់ភ្ញៀវចំពោះសណ្ឋាគារ។ កាតព្វកិច្ចរបស់បុគ្គលិកផ្នែកនេះគឺដំណើរការកក់កន្លែងទុកមុន, ការចុះបញ្ជីឈ្មោះភ្ញៀវ, ទំនាក់ទំនងភ្ញៀវ និងចាត់ចែងការចាកចេញរបស់ភ្ញៀវ។

បុគ្គលិកផ្នែកកក់បន្ទប់គ្រប់គ្រងទៅលើការកក់កន្លែងរបស់ភ្ញៀវ ភាគច្រើនតាមរយៈទូរស័ព្ទ។ ពួកគេត្រូវពិនិត្យមើលកាលបរិច្ឆេទ, អត្រាតម្លៃ, កត់ត្រាប្រាក់កក់, បញ្ជាក់អំពីការកក់បន្ទប់ និងប្រាប់អំពីសេវាផ្សេងៗទៅដល់ភ្ញៀវ។ នៅពេលដែលមានបញ្ហាជាមួយការកក់បន្ទប់ ជំនួយការខាងផ្នែកកក់បន្ទប់ត្រូវតែធ្វើកំណត់ត្រារបស់សណ្ឋាគារសារជាថ្មី, ផ្លាស់ប្តូរ ឬក៏លុបចោលនូវការកក់កន្លែង។ ជំនួយការខាងផ្នែកកក់បន្ទប់ក៏ត្រូវតែពិចារណាទៅលើតម្រូវការពិសេសរបស់ភ្ញៀវក្នុងខណៈពេលនៃការស្នាក់នៅក្នុងសណ្ឋាគារ និងរៀបចំផ្គត់ផ្គង់ឲ្យត្រូវទៅតាមផ្នែក និងកន្លែងនោះ។ ដើម្បីចុះបញ្ជីឈ្មោះភ្ញៀវ បុគ្គលិកផ្នែកទទួលភ្ញៀវក្នុងសណ្ឋាគារទទួលបាន និងផ្ទៀងផ្ទាត់ព័ត៌មានចាំបាច់មួយចំនួន ដូចជា ឈ្មោះ, អាស័យដ្ឋាន និងរយៈពេលស្នាក់នៅរបស់ភ្ញៀវ។ នៅពេលកក់បន្ទប់ ភ្ញៀវត្រូវការប្រើបណ្ណឥណទានរបស់ធនាគារ (credit card) ដើម្បីធានាចំពោះចំណាយក្នុងពេលស្នាក់នៅ។

បុគ្គលិកផ្នែកទទួលភ្ញៀវក្នុងសណ្ឋាគារតែងបំពេញតួនាទីជាអ្នកទំនាក់ទំនងរវាងសណ្ឋាគារ និងភ្ញៀវ។ ក្រៅពីនេះក៏អាចជួយក្នុងការចាត់ចែងសេវាបោកគក់, រំឭកការភ្ញាក់ពីដំណេករបស់ភ្ញៀវតាមតាមទូរស័ព្ទ និងបញ្ជូនសំបុត្រ ឬទូរសារទៅដល់បន្ទប់។ ពួកគេក៏ផ្តល់ព័ត៌មានទូទៅអំពីតំបន់ជុំវិញសណ្ឋាគារ និងសហគមន៍ក្បែរៗនោះ។ កិច្ចការសំខាន់បំផុតគឺការដោះស្រាយភ្លាមៗនូវរាល់បញ្ហាដើម្បីឆ្លើយតបនឹងសំណូមពរ និងការត្អូញត្អែររបស់ភ្ញៀវ។

អ្នកធ្វើការនៅការិយាល័យជួរមុខទទួលខុសត្រូវលើការធ្វើបច្ចុប្បន្នកម្មប្រព័ន្ធព័ត៌មានរបស់សណ្ឋាគារ។ ជួនកាលបុគ្គលិកប្រភេទនេះ ត្រូវមើកការខុសត្រូវការទូរសព្ទហៅចេញ និងចូល, បញ្ជីគណនេយ្យ, រក្សាទុកប្រាក់សម្រាប់ចំណាយបន្ទាន់, បញ្ចូលសាច់ប្រាក់ដាក់នៅក្នុងធនាគាប្រចាំថ្ងៃ និងការកកត់ត្រាកូនសោរបន្ទប់។ បន្ថែមពីនេះ ពួកគេត្រូវថែរក្សា និងជូតសម្អាតតុទទួលភ្ញៀវឲ្យស្អាតជានិច្ចដើម្បីបង្ហាញពីការទាក់ទាញចំពោះអតិថិជន និងអ្នកចូលមកស្នាក់នៅ។

## ការអប់រំ និងការបណ្តុះបណ្តាល

បុគ្គលិកផ្នែកទទួលភ្ញៀវក្នុងសណ្ឋាគារត្រូវការជំនាញផ្នែកទំនាក់ទំនង, ជំនួញ, ទីផ្សារ, កុំព្យូទ័រ និងគណិតវិទ្យា។ ទោះបីមិនតម្រូវលើការអប់រំខ្ពស់ ប៉ុន្តែគួរសិក្សាកម្រិតបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈផ្នែកបដិសណ្ឋារកិច្ច និងការគ្រប់គ្រងសណ្ឋាគារ។ ម្យ៉ាងទៀត ការហាត់ការដោយផ្ទាល់គឺជាវិធីដ៏ល្អ ដើម្បីស្វែងរកបទពិសោធន៍។

### គួរយល់ដឹង!

✦ មុខវិជ្ជាសិក្សាក្នុងសាលា:
ជំនួញ និងការធ្វើសុន្ទរកថា
✦ កម្រិតអប់រំទាបបំផុត:
មធ្យមសិក្សាទុតិយភូមិ
✦ ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:
អ្នកជញ្ជូនឥវ៉ាន់ក្នុងសណ្ឋាគារ
អ្នកក្រឡុកស្រា
អ្នកគ្រប់គ្រងសណ្ឋាគារ និងផ្ទះភ្ញៀវ
ភ្នាក់ងារធ្វើដំណើរកំសាន្ត

## អ្នកធ្វើគម្រោងហិរញ្ញវត្ថុ

(Financial Planners)

សង្ខេបអំពីជំនាញ
អ្នកធ្វើគម្រោងហិរញ្ញវត្ថុធ្វើការងារ៖
✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន
✦ ជួយកិច្ចការដល់ភ្ញៀវ ឬអតិថិជន

G
ជំនាញដែលត្រូវការប្រើ៖
✦ គណិតវិទ្យា
✦ ការអាន និងការសរសេរ
✦ ការនិយាយនិងការស្តាប់

## តើអ្នកធ្វើគម្រោងហិរញ្ញវត្ថុបំពេញកិច្ចការអ្វីខ្លះ?

អ្នកធ្វើគម្រោងហិរញ្ញវត្ថុផ្តល់ប្រឹក្សាឲ្យអតិថិជនរបស់គេលើវិស័យជាច្រើនពាក់ព័ន្ធហិរញ្ញវត្ថុ។ ពួកគេមិនធ្វើការតែម្នាក់ឯងនោះទេ ប៉ុន្តែត្រូវការកិច្ចសហការជាមួយអ្នកឯកទេស និងសហការីជាច្រើនទៀត ដូចជា ជួបពិភាក្សាជាមួយទីប្រឹក្សាផ្សេងទៀតរបស់អតិថិជន រួមមាន មេធាវី, គណនេយ្យករ, និងអ្នកវិនិយោគទុនផ្នែកធនាគារ។ បន្ទាប់ពីជួបប្រជុំជាមួយអតិថិជន និងអ្នកប្រឹក្សាទាំងនោះរួចមក អ្នកធ្វើគម្រោងហិរញ្ញវត្ថុវិភាគទិន្នន័យដែលពួកគេទទួលបាន និងរៀបចំរបាយការណ៍លម្អិតអំពីគោលដៅហិរញ្ញវត្ថុរបស់អតិថិជន, ចំណូលសព្វថ្ងៃ, ការវិនិយោគទុន, ហានិភ័យ, ចំណាយ, ការបង់ពន្ធ, ការធានារ៉ាប់រង, កម្មវិធីចូលនិវត្តន៍, គម្រោងអចលនទ្រព្យ និងព័ត៌មានសំខាន់ៗផ្សេងទៀត។

គម្រោងហិរញ្ញវត្ថុគឺជាឯកសារផ្តល់យោបល់ និងយុទ្ធសាស្ត្រសម្រាប់អតិថិជនដើម្បីសម្រេចអនុវត្តឬមិនអនុវត្ត ហើយអ្នកធ្វើគម្រោងហិរញ្ញវត្ថុត្រូវតែត្រៀមខ្លួនក្នុងការឆ្លើយតបទៅនឹងសំណួរទាំងឡាយពាក់ព័ន្ធគម្រោងដែលពួកគេបានបង្កើត។ អ្នកធ្វើគម្រោងហិរញ្ញវត្ថុត្រួតពិនិត្យ និងពិនិត្យសាឡើងវិញគម្រោងទៅតាមកាលកំណត់ជាក់លាក់ ហើយធ្វើការកែសម្រួលនៅពេលដែលចាំបាច់ ដើម្បីធានាថាគម្រោងនីមួយៗនៅតែមានសារសំខាន់តាមតម្រូវការរបស់អតិថិជន។

អ្នកធ្វើគម្រោងហិរញ្ញវត្ថុត្រូវចំណាយពេលយ៉ាងច្រើនក្នុងការរៀបចំផែនការវិនិយោគ, ផែនការចូលនិវត្តន៍, ផែនការបង់ពន្ធ, ផែនការអចលនទ្រព្យនិងការគ្រប់គ្រងហានិភ័យដែលវិស័យនីមួយៗតម្រូវឲ្យមានចំណេះដឹងផ្នែកហិរញ្ញវត្ថុផ្សេងៗពីគ្នា។

អ្នកធ្វើគម្រោងត្រូវមានចំណេះច្បាស់អំពីការគ្រប់គ្រងធនធាន, ផលចំណេញរបស់និយោជក, ការធ្វើគម្រោងអចលនទ្រព្យ, ធានារ៉ាប់រង, វិនិយោគទុន និងការចូលនិវត្តន៍។ អ្នកធ្វើគម្រោងហិរញ្ញវត្ថុត្រូវតែមានជំនាញផ្នែកលក់ ដើម្បីជាមូលដ្ឋានក្នុងការទំនាក់ទំនងជាមួយអតិថិជនរបស់គេ។ ជំនាញអន្តរបុគ្គលក៏មានសារៈសំខាន់ក្នុងការបង្កើតទំនាក់ទំនងជាមួយគម្រោងរបស់អតិថិជនប្រកបដោយភាពរឹងមាំ។

អ្នកធ្វើគម្រោងហិរញ្ញវត្ថុបង្កើតបណ្តាញអតិថិជនតាមរយៈទូរសព្ទ, ផ្តល់សិក្ខាសាលាអំពីគម្រោងហិរញ្ញវត្ថុទៅដល់មនុស្សទូទៅ ឬអង្គការ ស្ថាប័ន ព្រមទាំងទាក់ទងជាមួយបណ្តាញទំនាក់ទំនងសង្គម និងបណ្តាញជំនាញវិជ្ជាជីវៈ។ ម្យ៉ាងទៀត ការនិយាយលើកសរសើរពីសំណាក់អតិថិជនដែលពេញចិត្តចំពោះសេវាកម្មដែលធ្លាប់ប្រើប្រាស់កន្លងមកក៏ជួយលើកតម្លៃកិច្ចការជំនួញរបស់អ្នកធ្វើគម្រោងផងដែរ។




## ការអប់រំ និងការបណ្តុះបណ្តាល

អ្នកធ្វើគម្រោងហិរញ្ញវត្ថុគួរតែមានកម្រិតអប់រំថ្នាក់បរិញ្ញាប័ត្រផ្នែកជំនួញ ឬវិទ្យាសាស្ត្រ។ បន្ថែមលើនេះគួរមានជំនាញខាងគ្រប់គ្រងជំនួញ និងហិរញ្ញវត្ថុ, គណនេយ្យ, សេដ្ឋកិច្ច, ទីផ្សារ, និងការប្រឹក្សាយោបល់។

## គួរយល់ដឹង!

✦ **មុខវិជ្ជាសិក្សាក្នុងសាលា:**
ជំនួញ និងគណិតវិទ្យា

✦ **កម្រិតអប់រំទាបបំផុត:**
បរិញ្ញាបត្រ

✦ **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា:**
គណនេយ្យករ
អ្នកគ្រប់គ្រងជំនួញ
អ្នកវិភាគហិរញ្ញវត្ថុ
អ្នករៀបចំតារាងពន្ធ

## គិលានុបដ្ឋាកផ្នែកជម្ងឺផ្លូវចិត្ត

(Psychiatric Nurse)

**សង្ខេបអំពីជំនាញ**

**គិលានុបដ្ឋាកផ្នែកជម្ងឺផ្លូវចិត្តធ្វើការងារ៖**

✦ ប្រាស្រ័យទាក់ទងផ្នែកគំនិត
✦ ជួយកិច្ចការដល់អតិថិជន និងភ្ញៀវ
✦ បំពេញការងារជាក្រុម

G

**ជំនាញដែលត្រូវការច្រើន៖**

- ការគិតប្រកបដោយភាពច្នៃប្រឌិត
- ការដោះស្រាយបញ្ហា
- ការនិយាយ និងការស្តាប់

## តើគិលានុបដ្ឋាកផ្នែកជម្ងឺផ្លូវចិត្តបំពេញកិច្ចការអ្វីខ្លះ?

គិលានុបដ្ឋាកផ្នែកជម្ងឺផ្លូវចិត្តផ្តោតលើកិច្ចការថែទាំសុខភាពផ្លូវចិត្ត រួមបញ្ចូលទាំងការការពារជម្ងឺផ្លូវចិត្តនិងការថែទាំសុខភាពផ្លូវចិត្តឲ្យបានល្អ ព្រមទាំងធ្វើរោគវិនិច្ឆ័យនិងការព្យាបាលជម្ងឺវិបត្តិផ្លូវចិត្ត ឬភាពច្របូកច្របល់ក្នុងចិត្ត។ គិលានុបដ្ឋាកផ្នែកនេះយកចិត្តទុកដាក់ទៅលើអ្នកជម្ងឺដែលជាកុមារ, មនុស្សវ័យជំទង់, មនុស្សពេញវ័យ និងអ្នកជម្ងឺជាមនុស្សចាស់ដែលជាប់ទាក់ទងជាពិសេសទៅនឹងវិបត្តិផ្លូវចិត្ត និងបញ្ហាស្មុគស្មាញនៅក្នុងអារម្មណ៍។

គិលានុបដ្ឋាកផ្នែកជម្ងឺផ្លូវចិត្តអាចចែកចេញជាពីរកម្រិតគឺកម្រិតមូលដ្ឋាន និងកម្រិតខ្ពស់។ កម្រិតមូលដ្ឋានគឺសំដៅដល់គិលានុបដ្ឋាយិកាដែលបំពេញការងារជាបឋមក្នុងការថែទាំអ្នកជម្ងឺផ្នែកផ្លូវចិត្ត ឬវិកលចរិត។ ចំណែកគិលានុបដ្ឋាកផ្នែកជម្ងឺផ្លូវចិត្តកម្រិតខ្ពស់ជាអ្នកឯកទេសដែលមានជំនាញច្បាស់លាស់។

គិលានុបដ្ឋាកផ្នែកនេះខ្លះបំពេញតួនាទីជាអ្នកគ្រប់គ្រង ឬផ្តល់យោបល់ ការងារផ្នែករដ្ឋបាល ព្រមទាំងអាចផ្តល់សេវាព្យាបាលជម្ងឺផ្លូវចិត្ត និងចេញ វេជ្ជបញ្ជាប្រើប្រាស់ថ្នាំផងដែរ។ គិលានុបដ្ឋាកផ្នែកជម្ងឺផ្លូវចិត្តកម្រិតខ្ពស់អាចមានជំនាញឯក-ទេសនៅក្នុងផ្នែកមួយចំនួន ឧទាហរណ៍ការថែរក្សាសុខភាពផ្លូវចិត្តរបស់កុមារ និងមនុស្សវ័យជំទង់។ បន្ថែមទៅលើកិច្ចការថែទាំអ្នកជម្ងឺផ្ទាល់ គិលានុបដ្ឋាកផ្នែកជម្ងឺផ្លូវចិត្តក៏ប្រើប្រាស់ជំនាញរបស់គេធ្វើការបណ្តុះបណ្តាលអ្នករស់នៅក្នុងសហគមន៍អំពីសុខភាពផ្លូវចិត្តផងដែរ។

## ការអប់រំ និងការបណ្តុះបណ្តាល

ដើម្បីរៀបចំខ្លួនសម្រាប់អាជីពនេះអ្នកគួរតែចាប់ផ្តើមរៀនមុខវិជ្ជាគណិតវិទ្យា, វិទ្យាសាស្ត្រ, ជីវវិទ្យា, គីមីវិទ្យា និងរូបវិទ្យានៅវិទ្យាល័យ។ បន្ថែមលើនេះ មុខវិជ្ជាទាក់ទងនឹងសុខភាពក៏មានសារសំខាន់ផងដែរ។ ចំណែក ភាសាអង់គ្លេស និងការនិយាយ ឬសុន្ទរកថាមានសារសំខាន់ក្នុងការទំនាក់ទំនងល្អជាមួយអ្នកជម្ងឺ។ បន្ទាប់ពីវិទ្យាល័យគេអាចបន្តការសិក្សាដើម្បីទទួលបានឯកទេសគិលានុបដ្ឋាកផ្នែកជម្ងឺផ្លូវចិត្តដែលមានច្រើនកម្រិតដូចជាកម្រិតបឋម, កម្រិតមធ្យម និងកម្រិតបរិញ្ញាបត្រ។

## គួរយល់ដឹង!

- **មុខវិជ្ជាសិក្សាក្នុងសាលា៖**
  ជីវវិទ្យា និងគីមីវិទ្យា
- **កម្រិតអប់រំទាបបំផុត៖**
  ការបណ្តុះបណ្តាលផ្នែកវេជ្ជសាស្ត្រ
- **ព័ត៌មានគួរអានបន្ថែមស្តីពីអ្នកមានជំនាញស្រដៀងគ្នា៖**
  គិលានុបដ្ឋាកកម្រិតខ្ពស់
  អ្នកចិត្តវិទ្យា
  គិលានុបដ្ឋាក
  អ្នកឯកទេសផ្នែកជម្ងឺផ្លូវចិត្ត



ព័ត៌មានជ្រើសរើសបុគ្គលិក

# ព័ត៌មានជ្រើសរើសបុគ្គលិក

VACANCY ANNOUNCEMENT

លោកអ្នកដែលមានបំណងដាក់ពាក្យសុំការងារ និងចង់ដឹងព័ត៌មានអំពីឱកាសការងារជាច្រើនប្រភេទផ្សេងទៀតអាចទំនាក់ទំនងមកកាន់ «**មជ្ឈមណ្ឌលការងារ**» ណាមួយរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ឬអាចស្វែងរក និងទាញយកព័ត៌មានទាំងអស់នេះ

**ដើម្បីទទួលបានសេវាការងារដោយ «ឥតគិតថ្លៃ» សូមទំនាក់ទំនង ឬធ្វើដំណើរមកកាន់៖**

**មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ**
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទួលស្វាយ ខណ្ឌទួលគោក
រាជធានីភ្នំពេញ
☎ ០២៣ ៦៣៣ ៦០០២
០៧៧ ២៣២ ៣៧៨
០១៦ ៧៨៦ ៦៥៥
✉ jc_pp@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តបាត់ដំបង**
វិទ្យាស្ថានពហុបច្ចេកទេសខេត្តបាត់ដំបង
ផ្លូវលេខ ១ ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ
ក្រុងបាត់ដំបង
☎ ០៥៣ ៧៣៣ ១១១
០១៦ ៩២៦ ៦៥៥
✉ jc_battambang@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តសៀមរាប**
មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប
សង្កាត់ស្លក្រាម ក្រុងសៀមរាប
☎ ០៦៣ ២១០ ២៧៧
០១៦ ៥៣៦ ៦៥៥
✉ jc_siemreap@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តកំពត**
វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពត
ភូមិ ១ ឧសភា សង្កាត់កំពង់កណ្តាល
ក្រុងកំពត
☎ ០៣៣ ២១០ ២៧៧
០១៦ ៥០៦ ៦៥៥
✉ jc_kampot@nea.gov.kh

**មជ្ឈមណ្ឌលការងារខេត្តស្វាយរៀង**
មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្វាយរៀង
ភូមិមេភ្លើង សង្កាត់ស្វាយរៀង
ក្រុងស្វាយរៀង
☎ ០៤៤ ៧១៥ ២៧៧
០១៦ ៦៤៦ ៦៥៥
✉ jc_svayrieng@nea.gov.kh

ឥឡូវនេះ អតិថិជនរបស់ Hello អាចធ្វើការហៅចូលដោយ «ឥតគិតថ្លៃ» មកកាន់មជ្ឈមណ្ឌលការងារណាមួយក៏បាន ដើម្បីសាកសួរព័ត៌មានបន្ថែម!

 តទៅទំព័របន្ទាប់ 

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## National Center for Tuberculosis and Leprosy Control

**Closing Date:** 31 July 2014
**Location:** Phnom Penh
**Job Title:**
1. Chief of Monitoring and Evaluation (M&E)

**Requirement**
- Medical Doctor, preferably Master of Public Health or equivalent
- At least 5 years experience in monitoring and evaluation within the health sector
- Fluency in English and excellent computer skills (MS Word, Excel, Access, Statistical software

**Please contact:**
# 1, St. 278/95, Sangkat Boeung Keng Kang 2, Khan Chamkar Morn, Phnom Penh.
☎ 016 660 688
kantharath_bou@cenat.gov.kh

## Ministry of Water Resources and Meteorology

**Closing Date:** 19 August 2014
**Location:** Phnom Penh
**Job Title:**
1. Financial and Accounting Specialist

**Requirement**
- A Bachelor's Degree in accounting or business administrative
- At least 5 years of experience in the of accounting and maintenance or accounts
- Fluency in oral and written both languages Khmer and English

**Please contact:**
Ministry of Water Resources and Meteorology, Monivong Blvd, Sangkat Psar Demthkov, Khan Chamkar Morn, Phnom Penh.
☎ 012 977 772/023 221 970
cbchhoeurn@hotmail.com

## ELT Elementary and Secondary School

**ថ្ងៃផុតកំណត់:** ២១-សីហា-២០១៤
**ទីកន្លែងធ្វើការ:** ភ្នំពេញ
**មុខតំណែង:**
១. English Teachers ( Adults & Kids )/Assistance Teachers
២. Information Technology
៣. ផ្នែកសន្តិសុខ
៤. អ្នកបើកបរ
៥. ផ្នែកសំអាត
៦. ផ្នែកជួសជុល និងតំឡើងម៉ាស៊ីនត្រជាក់
៧. ចុងភៅ និងជំនួយការ

**លក្ខខណ្ឌជ្រើសរើស:**
- មានការសិក្សាថ្នាក់បរិញ្ញាបត្រឡើងទៅ
- មានបទពិសោធន៍ការងារយ៉ាងតិច២ឆ្នាំ
- មានចំណេះដឹងផ្នែកភាសាច្បាស់លាស់

**សូមទំនាក់ទំនងតាមរយៈ:**
អាគារលេខ ៥-១៥ ផ្លូវលេខ ១៣៦ សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។
☎ ០១២ ៩០០ ២១១/០៨៩ ៩១៣ ១៣១
elt.camiu1994@gmailc.com

## ក្រុមហ៊ុនស៊ីខក្វសាស

**ថ្ងៃផុតកំណត់:** ២១-សីហា-២០១៤
**ទីកន្លែងធ្វើការ:** ភ្នំពេញ
**មុខតំណែង:**
១. ផ្នែកទីផ្សារ ( ១០នាក់ )
២. ផ្នែកគណនេយ្យ ភេទស្រី ( ១នាក់ )

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

☑ **លក្ខខណ្ឌជ្រើសរើស:**

- មានអាយុចាប់ពី២៥-៣០ឆ្នាំឡើងទៅ
- មានបទពិសោធន៍ការងារ៣ឆ្នាំឡើងទៅ
- មានកម្រិតសិក្សាបរិញ្ញាបត្រឡើងទៅ

✉ **សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ ២២១J ផ្លូវលេខ ៥៩៨ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

☎ ០២៣ ៦៨៩១ ៣០០/០៦៦ ៥៥៥ ១១១

✉ zingko100@gmail.com

## ហាងចំប៉ីស្ប៉ា និងសាឡន

🕒 **ថ្ងៃផុតកំណត់:** ២១-សីហា-២០១៤

**ទីកន្លែងធ្វើការ:** ភ្នំពេញ

⊙ **មុខតំណែង:**

១. ផ្នែកគិតលុយ ភេទស្រី (ច្រើននាក់)

២. ផ្នែកបុគ្គលិកម៉ាស្សា ភេទស្រី (ច្រើននាក់)

៣. ផ្នែកអ្នកលើកម្ហូបរត់តុ (ច្រើននាក់)

៤. ផ្នែកកូនកាំបិត (ច្រើននាក់)

៥. ផ្នែកអនាម័យ ភេទស្រី (ច្រើននាក់)

☑ **លក្ខខណ្ឌជ្រើសរើស:**

- មានអាយុចាប់ពី១៨ឆ្នាំឡើងទៅ
- មានអាកប្បកិរិយាល្អ រួសរាយរាក់ទាក់ មានភាពស្មោះត្រង់
- មានបទពិសោធន៍ការងារ

✉ **សូមទំនាក់ទំនងតាមរយៈ:**

អាគារលេខ ៧ ផ្លូវលេខ ៣៣៤ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

☎ ០៧០ ៧១០ ១០១/០១៧ ៨២៩ ៨១១

✉ keopisey@gmail.com

## Cambo Victoriaimpex Co., Ltd

🕒 **ថ្ងៃផុតកំណត់:** ២១-សីហា-២០១៤

**ទីកន្លែងធ្វើការ:** ភ្នំពេញ

⊙ **មុខតំណែង:**

១. ផ្នែកលក់ (១០នាក់)

២. ផ្នែក Information Technology

☑ **លក្ខខណ្ឌជ្រើសរើស:**

- មានការសិក្សាថ្នាក់បរិញ្ញាបត្រឡើងទៅ
- មានបទពិសោធន៍ការងារយ៉ាងតិច១ឆ្នាំ
- មានចំណេះដឹងផ្នែកភាសាអង់គ្លេស

✉ **សូមទំនាក់ទំនងតាមរយៈ:**

អាគារលេខ ៥០៧ ផ្លូវលេខ ១៩៧៤ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

☎ ០៧៧ ៤៨៤ ៥៦៥

✉ dany.chan9@gmail.com

## សែនសុខ លក់គ្រឿងសំណង់

🕒 **ថ្ងៃផុតកំណត់:** ២១-សីហា-២០១៤

**ទីកន្លែងធ្វើការ:** ភ្នំពេញ

⊙ **មុខតំណែង:**

១. ផ្នែកលក់

☑ **លក្ខខណ្ឌជ្រើសរើស:**

- មានបទពិសោធន៍លក់គ្រឿងសំណង់យ៉ាងតិច២ឆ្នាំ
- មានយានជំនិះផ្ទាល់ខ្លួន
- មានការសិក្សាមធ្យមសិក្សាទុតិយភូមិ

✉ **សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ ៥០ ផ្លូវលេខ ២៧១ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

☎ ០១២ ៨៦៨ ៩៧០/០១០ ៥៨២ ៩៥០

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់ «មជ្ឈមណ្ឌលការងារ» ណាមួយរបស់ ទ.ជ.ម.ក ឬតាមរយៈគេហទំព័រ www.nea.gov.kh/jobshop

## ក្រុមហ៊ុនទូរទស្សន៍ខ្សែកាបរាជធានីភ្នំពេញ

**ថ្ងៃផុតកំណត់:** ០៩-សីហា-២០១៤

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ផ្នែកទីផ្សារ (៨នាក់)
២. ផ្នែកបើកបរឡាន (៣នាក់)
៣. ផ្នែកជាងជួសជុលខ្សែកាប ភេទប្រុស (៤នាក់)
៤. ផ្នែកជំនួយការិយាល័យ ភេទប្រុស (២នាក់)
៥. ផ្នែកកាន់ស្តុក (២នាក់)
៦. ផ្នែកបេឡាធិការ ភេទស្រី (២នាក់)
៧. ផ្នែកប្រមូលប្រាក់ ភេទប្រុស (៤នាក់)
៨. ផ្នែកជាងភ្លើង ភេទប្រុស (២នាក់)
៩. ផ្នែកកាត់តវីដេអូ ភេទប្រុស(១នាក់)
១០. ផ្នែករៀបចំកម្មវិធីសម្រាប់ចាក់ផ្សាយ (២នាក់)

**លក្ខខណ្ឌជ្រើសរើស:**

- មានបទពិសោធន៍ការងារយ៉ាងតិច១ឆ្នាំ
- មានចំណេះដឹងភាសាអង់គ្លេស និងភាសាចិន
- មានចំណេះដឹងក្នុងការប្រើប្រាស់កុំព្យូទ័រ

**សូមទំនាក់ទំនងតាមរយៈ:**

អាគារលេខ ៣AB ផ្លូវមុន្នីរ៉េត សង្កាត់វាល់វង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

០៩០ ៨៨០ ០២៨/០១០ ៩១៣ ២៨៩

job@ppctv.com.kh

## ក្រុមហ៊ុន ហេង ស្រេងហុង

**ថ្ងៃផុតកំណត់:** ២១-សីហា-២០១៤

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ផ្នែកលក់ និងទីផ្សារ (១០នាក់)
២. ផ្នែកទីផ្សារតាមបណ្តាខេត្ត ភេទប្រុស (៣នាក់)
៣. អ្នករត់ឯកសារគយ ភេទស្រី (៣នាក់)
៤. ជំនួយការរដ្ឋបាល

**លក្ខខណ្ឌជ្រើសរើស:**

- ត្រូវបញ្ចប់ថ្នាក់បរិញ្ញាបត្រ
- មានបទពិសោធន៍ក្នុងការងារយ៉ាងតិច២ឆ្នាំឡើងទៅ
- មានភាពស្មោះត្រង់យកចិត្តទុកដាក់ការងារ និងមានភាពអត់ធ្មត់ក្នុងការងារ

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ ៧៥ ផ្លូវលេខ ២៧១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

០២៣ ៤២៤ ៤១១/០៩៧ ៦៩៧ ២៩២៩

hr@hengsrenghong.com

## Latte Mei (Cambodia) Co., Ltd

**ថ្ងៃផុតកំណត់:** ២១-សីហា-២០១៤

**ទីកន្លែងធ្វើការ:** ភ្នំពេញ

**មុខតំណែង:**

១. ប្រធានគ្រប់គ្រងទូទៅ
២. ប្រធានផ្នែកគណនេយ្យ
៣. ប្រធានផ្នែកទីផ្សារ
៤. ផ្នែករចនារូបភាព
៥. ផ្នែកដឹកជញ្ជូន
៦. អ្នកក្រុឡុកស្រា

**លក្ខខណ្ឌជ្រើសរើស:**

- មានបទពិសោធន៍ការងារចាប់ពី៣ឆ្នាំឡើងទៅ
- មានចំណេះដឹងភាសាចិន និងភាសាអង់គ្លេស
- មានប័ណ្ណបើកបរត្រឹមត្រូវ

**សូមទំនាក់ទំនងតាមរយៈ:**

ផ្ទះលេខ ៧៣១B ផ្លូវកម្ពុជាក្រោម សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

០៧០ ៣៧៧ ៧៧៥



# កំសាន្ត និងប្រាជ្ញា

កំសាន្ត និងប្រាជ្ញា

ទំព័រកំសាន្ត និងប្រាជ្ញាត្រូវបានបង្កើតឡើងក្នុងបំណងផ្តល់នូវការកំសាន្តតាមបែបល្បងប្រាជ្ញា ដើម្បីទទួលបាននូវការរីករាយ និងបង្កើនចំណេះដូនមិត្តអ្នកអានទាំងអស់។ ព្រឹត្តិបត្រការងារសង្ឃឹមថា ទំព័រនេះអាចជួយផ្តល់ជាប្រយោជន៍ផ្នែកសតិប្រាជ្ញានិងការត្រិះរិះពិចារណា ជាពិសេស ចំពោះមិត្តអ្នកអានណា ដែលមិនធ្លាប់សាកល្បងដោះស្រាយនូវចំណោទបែបនេះពីមុនមក។

ទំព័រកំសាន្ត និងប្រាជ្ញានេះមានល្បែងផ្សេងៗដូចជាការស្វែងរកពាក្យជាភាសាអង់គ្លេស ល្បែងផ្គុំឈើគូស ការស្វែងរក ល្បែងស្វែងរកច្រកចេញ និងការធ្វើចំណោទជាលេខនព្វន្តជាដើម។ អាស្រ័យហេតុនេះសូមប្រិយមិត្តអ្នកអានទាំងអស់សាកល្បងដោះស្រាយ និងរីករាយជាមួយល្បែងល្បងប្រាជ្ញាដូចខាងក្រោម៖

## ល្បែងស្វែងរកពាក្យ

ចូរបំពេញនូវពាក្យក្នុងប្រអប់ខាងក្រោមដោយប្រើប្រាស់និយមន័យ ឬពាក្យដែលមានន័យដែលគេបានផ្តល់ឱ្យខាងក្រោម៖




### Across

5. 12 oçlock at night
6. Not awake
7. A swinging or sliding cover over the place where someone usually enters a room
9. Ceremony in which a man and a woman are married.
10. Someone who does not use good judgment is _______.

### Down

1. Someone who has good judgment and makes good decisions is ______.
2. Devices used to produce light
3. A feast or meal held in recognition of some person or occasion
4. To observe or look at something
8. A liquid that is often used to make fuel.

## ល្បែងផ្គុំឈើគូស

ខាងក្រោមនេះមានរូបឈើគូសដែលផ្គុំគ្នាជារាងការេចំនួនពីរ ដូចនេះសូមលោកអ្នករំកិលឈើគូសចំនួនបួនដើម ដើម្បីបង្កើតបានជារាងការេចំនួនបី។ ខាងក្រោមនេះជាឧទាហរណ៍សម្រាប់លោកអ្នកៈ





១. រំកិលឈើគូសចំនួន៨ ដើម្បីឱ្យបានចតុកោណស្មើចំនួន ៣



២. រំកិលឈើគូសចំនួន១៦ ដើម្បីឱ្យបានការេចំនួន ៣



៣. រំកិលឈើគូសចំនួន៨ ដើម្បីឱ្យបានការេចំនួន៦



៤. រំកិលឈើគូសចំនួន១២ ដើម្បីបានឆកោណចំនួន៥



៥. រំកិលឈើគូសចំនួន១០ ដើម្បីឱ្យបានឆកោណចំនួន៣



៥. រំកិលឈើគូសចំនួន៦ ដើម្បីឱ្យបានត្រីកោណចំនួន៥



៦. រំកិលឈើគូសចំនួន១២ ដើម្បីឱ្យបានឆកោណកោណចំនួន៥



៧. រំកិលឈើគូសចំនួន៤ ដើម្បីឱ្យបានចតុកោណស្មើចំនួន៧



៨. រំកិលឈើគូសចំនួន១២ ដើម្បីឱ្យបានឆកោណចំនួន៣ និង ចតុកោណស្មើចំនួន៣



## ល្បែងស្វែងរកច្រកចេញ នឹងច្រកចូល

ចូរប្រើប្រាស់នូវរូបភាពខាងក្រោមដើម្បីជួយគាត់ឱ្យបានទៅដល់កន្លែងជិះស្គីលើភ្នំទឹកកក



## ល្បែងសូដូគុ

ចូរបំពេញនូវការេនីមួយៗ ដែលធ្វើឱ្យជួរដេក និងជួរឈរ ព្រមទាំងប្រអប់ទាំង៣x៣ មានលេខរៀងគ្នាពី១ ដល់ ៩។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 4 | 3 | | 9 | 8 | | 7 | 2 | 5 |
| 1 | | 9 | 7 | 5 | 4 | | 8 | 3 |
| 5 | 7 | | 3 | | 2 | 9 | 4 | 1 |
| 6 | | 5 | 4 | 9 | | 2 | 3 | 7 |
| | 9 | | | 3 | 6 | 8 | | 4 |
| 8 | | 3 | 2 | 1 | | 5 | 9 | 6 |
| 9 | 6 | 2 | | 4 | 5 | | 7 | 8 |
| | 5 | 4 | 8 | 7 | | 1 | 6 | |
| 7 | | 1 | 6 | 2 | 3 | | 5 | |

## ល្បែងស្វែងរកចំណុចខុសគ្នា

ចូរស្វែងរកចំណុចខុសគ្នាអោយបាន៩ចំណុច រវាងរូបភាពនៅខាងឆ្វេង នឹងរូបភាពខាងស្តាំ ខាងក្រោម៖





## រឿងកំប្លែងខ្លី



## ចម្លើយកំសាន្ត និងប្រាជ្ញា (ក្នុងការផ្សាយលេខ ០២៧)







| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 6 | 5 | 4 | 8 | 7 | 1 | 9 | 3 | 2 |
| 9 | 8 | 3 | 2 | 5 | 4 | 1 | 7 | 6 |
| 1 | 7 | 2 | 9 | 3 | 6 | 5 | 8 | 4 |
| 2 | 6 | 5 | 7 | 1 | 3 | 8 | 4 | 9 |
| 3 | 1 | 8 | 4 | 9 | 5 | 6 | 2 | 7 |
| 7 | 4 | 9 | 6 | 2 | 8 | 3 | 5 | 1 |
| 5 | 3 | 6 | 1 | 4 | 2 | 7 | 9 | 8 |
| 4 | 9 | 1 | 3 | 8 | 7 | 2 | 6 | 5 |
| 8 | 2 | 7 | 5 | 6 | 9 | 4 | 1 | 3 |






# ទីភ្នាក់ងារជាតិមុខរបរ និងការងារ
## មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ

## វគ្គបណ្ដុះបណ្ដាលស្ដីពី "របៀបសរសេរប្រវត្តិរូបសង្ខេប លិខិតអម និងការត្រៀមខ្លួនសម្ភាសន៍ការងារ"

តាមរយៈសិក្ខាសាលានេះអ្នកនឹងទទួលបាននូវៈ

1. ចំណេះដឹង និងវិធីសាស្ត្រនៃការស្វែងរកការងារធ្វើ
2. បែបបទក្នុងការរៀបចំប្រវត្តិរូបសង្ខេប និងលិខិតអម
3. ការរៀបចំឥរិយាបថសម្រាប់ត្រៀមខ្លួនមុនសម្ភាសន៍ការងារ
4. ទទួលបានការប្រឹក្សាយោបល់អំពីឱកាសការងារ
5. ព័ត៌មានទីផ្សារការងារ

ចូលរួមដោយ
**ឥតគិតថ្លៃ!**

កាលបរិច្ឆេទៈ រៀងរាល់ថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍
វេលាម៉ោង ០៩:០០ - ១១:០០ ព្រឹក
ចូលរួមដោយសេរី (សម្រាប់២៥នាក់)

ព័ត៌មានបន្ថែមសូមទំនាក់ទំនងៈ
មជ្ឈមណ្ឌលការងាររាជធានីភ្នំពេញ អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ (ស្ថិតក្នុងបរិវេណក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ)
ទូរស័ព្ទលេខៈ ០២៣ ៦៣៣ ៦០០២ អ៊ីម៉ែលៈ jc_pp@nea.gov.kh ឬគេហទំព័រៈ www.nea.gov.kh

# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
Ministry of Labour and Vocational Training
## វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា
National Polytechnic Institute of Cambodia

អាហារូបករណ៍ពិសេស

និទ្ទេស A : ទទួលបានអាហារូបករណ៍ ១០០%
និទ្ទេស B : ទទួលបានអាហារូបករណ៍ ៥០%
និទ្ទេស C : ទទួលបានអាហារូបករណ៍ ៣០%
ចំពោះសិស្សនារីទទួលបានការបញ្ចុះតម្លៃ ៣០%
និស្សិតលេខ ១ ទទួលបានអាហារូបករណ៍ប្រចាំឆ្នាំ ១០០%
និស្សិតលេខ ២ ទទួលបានអាហារូបករណ៍ប្រចាំឆ្នាំ ៣០%




ភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ
(023) 96 15 193 / 010 970 351 / 012 381 246 / 011 769 003
www.npic.edu.kh,Email : npicinfo@gmail.com

## មានបណ្តុះបណ្តាលលើជំនាញ
- វិទ្យាសាស្ត្រកុំព្យូទ័រ
- ភាសាកូរ៉េ
- សំណង់ស៊ីវិល
- អក្សរសាស្ត្រអង់គ្លេស
- អេឡិចត្រូនិក
- វិជ្ជាជីវៈគណនេយ្យ
- មេកានិក
- គ្រប់គ្រងបច្ចេកវិទ្យា
- អគ្គិសនី
- ទេសចរណ៍ និងបដិសណ្ឋារកិច្ច

## ម៉ោងសិក្សា
- ថ្ងៃចន្ទ ដល់ សុក្រ
  ០៨.០០-១២.០០ និង ១៣.០០-១៦.០០
- ថ្នាក់បន្តវិស្វករ ឬបរិញ្ញាបត្របច្ចេកវិទ្យា
  ថ្ងៃសៅរ៍-អាទិត្យ ០៨.០០-១២.០០ និង ១៣.០០-១៧.០០
- មហាវិទ្យាល័យវិទ្យាសាស្ត្រកុំព្យូទ័រ និងមហាវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច
  វេនព្រឹក ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ ០៨.០០-១២.៣០
  វេនរសៀល ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ ១៣.០០-១៧.៣០

- មានបំពាក់ប្រព័ន្ធ អ៊ិនធើណេត និង កWI គ្របដណ្តប់ក្នុងបរិវេណរបស់វិទ្យាស្ថានសម្រាប់និស្សិតសិក្សាស្រាវជ្រាវ
- មានអ្នកជំនាញការជាតិ និងអន្តរជាតិនៅគ្រប់មហាវិទ្យាល័យ
- សាស្ត្រាចារ្យខ្មែរមានសញ្ញាបត្រ អនុបណ្ឌិត, បណ្ឌិត និងបទពិសោធន៍យូរឆ្នាំ
- កល់កម្មវិធីសិក្សាស្របតាមតម្រូវការទីផ្សារស្តង់ដាជាតិ និងអន្តរជាតិ
- បន្ទប់ទ្រឹស្តី និងអនុវត្តន៍មានឧបករណ៍សម្ភារៈប្រើប្រាស់តាមបច្ចេកវិទ្យាទំនើប

## បវេសនកាលថ្មីចូលរៀននៅ ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៤ ចាប់ផ្តើមទទួលពាក្យពី ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ នេះតទៅ


## NPIC បានចុះអនុស្សរណៈយោគយល់ជាមួយ សាកលវិទ្យាល័យ ១០បន្ថែមទៀតរបស់ប្រទេសចិន

កាលពីថ្ងៃទី ១២ ឧសភា ឆ្នាំ ២០១៤ វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាបានចុះអនុស្សរណៈយោគយល់គ្នាជាមួយសាកលវិទ្យាល័យ និងវិទ្យាស្ថានរបស់ប្រទេសចិនសរុបចំនួន ១០ដែលក្នុងនោះមានការពិភាក្សាពីការផ្លាស់ប្តូរបច្ចេកទេស និងមុខវិជ្ជាសិក្សាទៅតាមផ្នែកនីមួយៗដើម្បីត្រៀមក្នុងការបញ្ជូន និងផ្លាស់ប្តូរនិស្សិតតាមកម្មវិធី (Exchange Program) ឬតាមកម្មវិធីអាហារូបករណ៍ផ្សេងៗទៀតដើម្បីផ្តល់ឱកាសដល់និស្សិត NPIC មានលទ្ធភាពបានទៅបន្តការសិក្សានៅប្រទេសចិន ។
គួររំលឹកផងដែរថាបច្ចុប្បន្នវិទ្យាស្ថាន NPIC មានដៃគូសហប្រតិបត្តិការទាំងក្នុង និងក្រៅប្រទេសចំនួន ៨១ ក្នុងនេះយើងមានដៃគូសហប្រតិបត្តិការក្នុងប្រទេសចិនចំនួន ១៦ ផងដែរ ។






## NPIC បានធ្វើពិធីបោះជំរុំ និងសម្ពោធបុស្សក ដំកល់ព្រះបដិមា ព្រះបាទជ័យវរ្ម័នទី ៧

នៅក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា កាលពីថ្ងៃទី ២៨ ដល់ ២៩ ខែឧសភា ឆ្នាំ ២០១៤ បានប្រារព្ធពិធីបោះជំរុំដែលមាន មន្ត្រី សាស្ត្រាចារ្យខ្មែរ បរទេស និងនិស្សិតដែលមកពីសាកលវិទ្យាល័យ វិទ្យាស្ថានផ្សេងៗចូលរួមសរុបប្រមាណ ២ពាន់នាក់ ។ ពិធីនេះមានរយៈពេល ២យប់ ៣ថ្ងៃ ដោយមានការចូលរួមបើកជំរុំជាអធិបតីភាពឯកឧត្តមបណ្ឌិត ពេជ សោភ័ន រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ។

ការតំកល់ព្រះបដិមាព្រះបាទជ័យវរ្ម័នទី ៧ ក្នុងវិទ្យាស្ថាននេះ ដើម្បីរំលឹកដល់គុណព្រះអង្គដែលបានកសាងទឹកដីកម្ពុជាឲ្យរីកចំរើនរុងរឿងក្នុងរជ្ជកាលដឹកនាំរបស់អង្គ និងដើម្បីទុកជាទីសក្ការៈបូជារបស់មន្ត្រី សាស្ត្រាចារ្យ-បុគ្គលិក សិស្ស និស្សិតនៅក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសទាំងមូល ។

គោលបំណងសំខាន់បំផុតដែលវិទ្យាស្ថាន NPIC បានបង្កើតកម្មវិធីបោះជំរុំនេះឡើងគឺ ដើម្បីឲ្យនិស្សិតមានសមត្ថភាពទទួលខុសត្រូវលើការងារដោយខ្លួនឯង និងចេះសហការធ្វើការងារជាក្រុមដើម្បីផ្លាស់ប្តូរចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក ។





## ទស្សនកិច្ចសិក្សារបស់សិស្សវិទ្យាល័យនៅ ក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា





សិស្សានុសិស្សថ្នាក់ទី ១២របស់វិទ្យាល័យចំនួន ១៨ ដែលឋិតនៅក្នុង និងជុំវិញរាជធានីភ្នំពេញត្រូវបានអនុញ្ញាតឲ្យមកធ្វើទស្សនកិច្ចសិក្សាក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាចាប់ពីខែ ឧសភា ដល់ខែ មិថុនា ឆ្នាំ ២០១៤ ។ គោលបំណងសំខាន់ក្នុងដំណើរទស្សនកិច្ចសិក្សានេះគឺ វិទ្យាស្ថានចង់បង្ហាញ និងពន្យល់ប្អូនៗសិស្សានុសិស្សឲ្យយល់ដឹងពីសារៈសំខាន់ក្នុងការសិក្សាមុខជំនាញបច្ចេកទេសដែលជាតម្រូវការចាំបាច់សម្រាប់ការចូលរួមអភិវឌ្ឍន៍សង្គមកម្ពុជាក្នុងពេលបច្ចុប្បន្ន ។


សូមមេត្តារង់ចាំទស្សនា
ទ.ជ.ម.ក
NEA
NATIONAL EMPLOYMENT AGENCY
នាទី
ទីផ្សារការងារ និង មុខរបរ
www.nea.gov.kh
នៅលើកញ្ចក់ទូរទស្សន៍
អង្គារ 22h
ពុធ 17h
សុក្រ 10h:45mn
សុក្រ 10h
សៅរ៍ 11h
សៅរ៍ 11h
សៅរ៍ 12h
សៅរ៍ 14h
សៅរ៍/អាទិត្យ 13h
អាទិត្យ 10h/17h
TV3
CNC
ឬលើគេហទំព័រ
www.nea.gov.kh

## ដៃគូសហការសំខាន់ៗ



បើកទូលាយសម្រាប់សាធារណជនទូទៅ

# ពិព័រណ៍ ការងារ ថ្នាក់ជាតិ 2014

# National Career Fair 4th 2014

រៀបចំដោយ: សហការរៀបចំដោយ: ឧបត្ថម្ភដោយ:

# 21-22 តុលា Oct. 2014

**មជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ**

**អគារ D E F**

- ជ្រើសរើសបុគ្គលិកនៅនឹងកន្លែង
- ផ្សព្វផ្សាយឈ្មោះក្រុមហ៊ុន និងផលិតផលដើម្បីទាក់ទាញអ្នកស្វែងរកការងារដែលមានសមត្ថភាពខ្ពស់
- ទទួលបានព័ត៌មានដែលទាក់ទងនឹងឱកាសការងារ និងការណែនាំអំពីអាជីពទៅថ្ងៃអនាគត
- ទទួលបានការណែនាំល្អៗអំពីក្រុមការជំនាញក្នុងវិស័យឧស្សាហកម្មដែលកំពុងរីកដុះដាល
- ផ្សព្វផ្សាយអំពីព័ត៌មាន ឬកម្មវិធីសិក្សារបស់លោកអ្នក

## www.nea.gov.kh

អ្នកស្វែងរកការងារធ្វើសូមកុំភ្លេចយក CVs ភ្ជាប់មកជាមួយផង!

ចូលរួមដោយ:

សម្រាប់ព័ត៌មានបន្ថែម និងការកក់បញ្ជរ:

**012 718 198 | 088 6666 007 | sale@nea.gov.kh**